**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Science Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ជំនួយទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌ

## (ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌)

## Mutual on Legal Assistance in Criminal Matters

## (ASEAN – Ministry of Justice)

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ៖ លោក **ឈន់ ម៉េងហេង**

លោក **ទី ខឡូនៈពុទ្ធិរ៉ា**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **ពៅ សារឿន**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៨ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Science Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ជំនួយទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌ
# ( ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌ )
# Mutual on Legal Assistance in Criminal Matters (ASEAN – Ministry of Justice)

ស្រាវជ្រាវចាប់ពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ លោក **ឈន់ ម៉េងហេង**
លោក **ទី ខឌ្ឍនៈពុទ្ធិរ៉ា**

ណែនាំដោយ
សាស្ត្រាចារ្យជំនួយ **ពៅ សារឿន**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី២៨ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៩
ឆ្នាំសរសេរសារណា ២០២៣

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឈន់ ម៉េងហេង** និងខ្ញុំបាទឈ្មោះ **ទី ទេវ្ឋានៈពុទ្ធិរ៉ា** ជានិស្សិតឆ្នាំទី៤ នៃថ្នាក់បរិញ្ញាបត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជំនាញនីតិសាស្រ្ត ជំនាន់ទី២៨ (អាហារូបករណ៍) នៃក្រុម L4B03 ក្នុងឆ្នាំសិក្សា ២០២២-២០២៣។

**សូមគោរពថ្លែងអំណរគុណ និងសូមសម្តែងនូវការគោរពយ៉ាងខ្ពង់ខ្ពស់**
**និងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅជូនចំពោះ**

**លោកអ្នកមានគុណទាំងពីរ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សាអប់រំទូន្មានប្រៀនប្រដៅ ព្រមទាំងបានលះបង់នូវកម្លាំងកាយចិត្ត ទ្រព្យសម្បត្តិ និងធនធានដើម្បីទំនុកបម្រុងការសិក្សារបស់កូនៗតាំងពីវ័យកុមារភាពរហូតដល់ពេលសព្វថ្ងៃនេះ និងតែងតែលើកទឹកចិត្ត ផ្តល់ជាដំបូន្មានល្អៗមកដល់ក្រុមខ្ញុំបាទ ទាំងការរស់នៅប្រចាំថ្ងៃក៏ដូចជាការសិក្សាផងដែរ ហើយថែមទាំងបានបណ្តុះនូវគោលគំនិត ក្រុមខ្ញុំបាទក្នុងការរស់នៅក្នុងសង្គមប្រកបដោយ សីលធម៌ល្អ ចេះគោរពចាស់ទុំ ចេះជួយយកអាសារអ្នកដទៃ ប្រព្រឹត្តអំពើល្អ មានភាពស្មោះត្រង់ និងត្រូវធ្វើខ្លួនឱ្យក្លាយទៅជាពលរដ្ឋល្អដើម្បីតបស្នងដល់សង្គមជាតិ និងគ្រួសារ។ ទាំងអស់នេះ គឺជាគុណូបការៈ ដ៏អនេកប្បការ និងវិសេសវិសាលខ្ពង់ខ្ពស់បំផុតដែលមិនអាចរកអ្វីមកប្រៀបផ្ទឹម និងកាត់ថ្លៃបាន។ បន្ថែមលើសពីនេះទៅទៀត ក្រុមខ្ញុំបាទសូមថ្លែងអំណរគុណជាពិសេសទៅដល់សមាជិកក្នុងក្រុមគ្រួសារ ជានិច្ចជាកាលដែលតែងតែជួយជ្រោមជ្រែង លើកទឹកចិត្ត ទូន្មានប្រៀនប្រដៅ និងដាស់តឿនជារៀងរាល់ពេលវេលា ឱ្យខិតខំប្រឹងប្រែងសិក្សារៀនសូត្ររហូតទទួលបាននូវសមិទ្ធផលដ៏ល្អត្រចះត្រចង់ និងជាទីគាប់ប្រសើរនាពេលនេះ។

សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ដែលសម្តេចទាំងពីរបានផ្តល់អាហារូបករណ៍សម្រាប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្រ្ត ដល់រូបខ្ញុំបាទទាំងពីរនាក់ ដោយឥតគិតថ្លៃចំនួន ៤ឆ្នាំ តាមរយៈ **ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត** ជាប្រធានសមាគមសិស្ស-និស្សិតអាហារូបករណ៍ ដើម្បីខ្ញុំបាទទាំងពីរនាក់មានឱកាសទទួលបាននូវចំណេះដឹង ការសិក្សារៀនសូត្រ ដោយទទួលបាននូវពុទ្ធិដ៏មានតម្លៃ និងប្រកបដោយគុណភាព ហើយដើម្បីយកពុទ្ធិ ដែលទទួលបានទាំងអស់នោះយកទៅបម្រើប្រទេសជាតិនាពេលអនាគត ក្រោមម្លប់នៃសុខសន្តិភាព និងការអភិវឌ្ឍ។ ជាថ្មីម្តងទៀត ខ្ញុំបាទទាំងពីរនាក់ សូមគោរពជូនពរ និងសូមបួងសួងដល់គុណព្រះរតនត្រ័យកែវទាំងបី និងវត្ថុស័ក្តសិទ្ធក្នុងលោក តាមបីបាច់ថែរក្សា និងប្រសិទ្ធពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរ ជូនចំពោះ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំង

បុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រលាញ់ សូមទទួលបាននូវសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន បញ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំប្រទេសកម្ពុជាឱ្យកាន់តែមានការរីកចម្រើនរុងរឿងទៅមុខលើគ្រប់វិស័យ ជាភិយ្យោភាព ក្រោមម្លប់នៃសុខសន្តិភាព និងការអភិវឌ្ឍ។

សូមអរគុណសន្តិភាព អរគុណនយោបាយ ឈ្នះ-ឈ្នះ ដឹងគុណស្ថាបនិកមគ្គុទ្ទេសក៏ឯក និងប្រតិបត្តិករនយោបាយ ឈ្នះ-ឈ្នះ ដែលបាននាំមកនូវសន្តិភាព និងការឯកភាពជាតិពេញលេញ និងឯកភាពទឹកដីទាំងស្រុង។

សូមគោរពថ្លែងអំណរគុណចំពោះ **ក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា** ដែលបានផ្តល់ឱកាសឱ្យក្រុមខ្ញុំបាទបានចុះកម្មសិក្សាដើម្បីហ្វឹកហាត់ការងារ និងស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងប្រធានបទសារណានេះ នៅនាយកដ្ឋានជំនាញ ចំណុះអគ្គនាយកដ្ឋាន នៃក្រសួងយុត្តិធម៌។ ឆ្លៀតក្នុងឱកាសនេះ ក្រុមខ្ញុំបាទក៏សូមថ្លែងអំណរគុណទៅដល់រៀមច្បងគ្រប់ៗគ្នា ដែលជាមន្ត្រីរាជការកំពុងមប្រើការងារនៅក្នុងក្រសួងយុត្តិធម៌នេះផ្ទាល់តែម្តង ដែលរៀមច្បងគ្រប់ៗគ្នាបានចំណាយពេលណែនាំ បង្ហាត់បង្ហាញ និងលើកទឹកចិត្តដល់ក្រុមខ្ញុំបាទទាំងពីរនាក់ ដើម្បីធ្វើការចងក្រងសារណាបញ្ចប់ការសិក្សាមួយនេះឡើងប្រកបដោយគុណភាព និងប្រសិទ្ធភាព។

សូមគោរពថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត លុយ ចណ្ណា** ជាសាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច **លោក-លោកស្រី ជាសាកលវិទ្យាធិការរង ព្រឹទ្ធបុរស គណៈគ្រប់គ្រង ព្រមទាំងលោកគ្រូ-អ្នកគ្រូ សាស្ត្រាចារ្យ បុគ្គលិកគ្រប់ផ្នែកទាំងអស់** ដែលបានខិតខំប្រឹងប្រែងក្នុងការដឹកនាំ គ្រប់គ្រង បង្ហាត់បង្ហាញ អប់រំណែនាំ ស្វែងរកវិធីសាស្ត្រថ្មីៗក្នុងការបង្រៀនទាំងផ្នែកទ្រឹស្តី និងការអនុវត្តផ្ទាល់ទៅដល់សិស្ស-និស្សិត ដើម្បីទទួលបានពុទ្ធិ និងជាពិសេសបានផ្តល់ដំបូន្មានល្អៗជាច្រើនសម្រាប់ការរស់នៅសង្គមដល់ក្រុមខ្ញុំបាទ ក្នុងគោលដៅដើម្បីធ្វើឱ្យការអភិវឌ្ឍន៍ផ្នែកធនធានមនុស្សរបស់ប្រទេសកម្ពុជាមានភាពល្អប្រសើរគួរជាទីមោទនៈ នាពេលអនាគត។

សូមគោរពថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យជំនួយ ពៅ សារឿន** ជាសាកលវិទ្យាធិការរង និងជាសាស្ត្រាចារ្យណែនាំក្រុមខ្ញុំបាទទាំងពីរនាក់ក្នុងការសរសេរសារណា បញ្ចប់ឆ្នាំសិក្សា ២០២២-២០២៣ ដែលលោកបានខិតខំចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងកាយចិត្ត ក្នុងការដឹកនាំតម្រង់ទិស និងចង្អុលបង្ហាញ ព្រមទាំងបានជួយជ្រោមជ្រែងក្នុងការស្វែងរកឯកសារនានា ចែករំលែកនូវបទពិសោធន៍ ផ្តល់ជាមតិយោបល់ល្អៗ និងលោកបានចូលរួមចំណែកក្នុងការកែលម្អនូវរាល់ចំណុចខ្វះខាតផ្សេងៗ ក៏ដូចជាចំណុចខុសឆ្គងទៅលើខ្លឹមសារ និងផ្នែកអក្ខរាវិរុទ្ធ ដើម្បីធ្វើឱ្យការចងក្រង និងរៀបរៀងសារណាបញ្ចប់ឆ្នាំសិក្សារបស់ក្រុមខ្ញុំបាទទាំងពីរនាក់ ចេញជារូបរាងប្រកបទៅដោយគុណភាព និងភាពជោគជ័យ។

ជាទីបញ្ចប់ ក្រុមខ្ញុំបាទសូមគោរពជូនពរទៅដល់លោកអ្នកមានគុណទាំងអស់ និងមិត្តនិស្សិតគ្រប់រូប សូមទទួលបាននូវសុខភាពល្អ ប្រាជ្ញាឈ្លាសវៃ និងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## អារម្ភកថា

ជាបឋម ខ្ញុំបាទ **ឈន់ ម៉េងហេង** និងខ្ញុំបាទ **ទី វឌ្ឍនៈពុទ្ធិរ៉ា** សូមសម្តែងនូវសេចក្តីគោរព និងសូមស្វាគមន៍ជូនចំពោះ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ នាងកញ្ញា សិស្ស-និស្សិត និងមិត្តអ្នកអានទាំងអស់ ជាទីគោរព និងទីជាមេត្រី។ បន្ទាប់ពីក្រុមខ្ញុំបាទទាំងពីរនាក់ បានឆ្លងកាត់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ អស់រយៈពេល ៤ឆ្នាំ ចាប់ពីឆ្នាំសិក្សា ២០១៩ រហូតដល់ឆ្នាំ២០២៣ នៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្រុមខ្ញុំបាទពិតជាមានមោទនភាព និងកិត្តិយសយ៉ាងក្រៃលែងដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ** ក្នុងការចូលរួមរៀបចំចងក្រងនូវសារណាបញ្ចប់ការសិក្សាមួយនេះឡើង ក្រោមប្រធានបទ «**ជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌**» ក្នុងគោលបំណងដើម្បីអភិវឌ្ឍន៍នូវចំណេះដឹង និងឱ្យកាន់តែមានភាពច្បាស់លាស់និងស៊ីជម្រៅបន្ថែមទៀត។

ប្រធានបទខាងលើនេះ បានកើតចេញពីការចូលបម្រើការងាររបស់ខ្ញុំបាទ **ឈន់ ម៉េងហេង** ដែលបានបម្រើការងារជាមន្ត្រីហាត់ការនៅក្នុងក្រសួងយុត្តិធម៌ ដែលជាអ្នកទទួលបន្ទុកលើកិច្ចការងារនេះផ្ទាល់ និងខ្ញុំបាទ **ទី វឌ្ឍនៈពុទ្ធិរ៉ា** បានចុះទៅស្រាវជ្រាវឯកសារពាក់ព័ន្ធនឹងប្រធានបទសារណានេះនៅក្រសួងយុត្តិធម៌តាមរយៈការស្នើសុំពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយមួយផ្នែកទៀតគឺជាការចង់ដឹងឱ្យកាន់តែច្បាស់លាស់បន្ថែមទៀត ទើបក្រុមខ្ញុំបាទបានធ្វើការសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយនេះឡើង «**ជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌**» មកធ្វើការបកស្រាយ ដើម្បីស្វែងយល់អំពីគោលការណ៍ វិសាលភាព នីតិវិធី និងសារៈសំខាន់របស់ប្រធានបទនេះ ក្នុងគោលបំណងចងក្រងទុកជាឯកសារសម្រាប់មិត្តអ្នកអាន និងសម្រាប់សិស្សនិស្សិតជំនាន់ក្រោយ។ ការសិក្សាស្រាវជ្រាវចំពោះប្រធានបទមួយនេះធ្វើឡើងដោយផ្អែកទៅលើច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា មានដូចជា ៖ ច្បាប់ សន្ធិសញ្ញា និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងកម្រងឯកសារស្នាដៃ សៀវភៅ បទឧទ្ទេសរបស់សាស្ត្រាចារ្យ និងអ្នកជំនាញក្នុងវិស័យច្បាប់ផងដែរ។

ខ្ញុំបាទសង្ឃឹមជឿជាក់យ៉ាងមុតមាំថា សារណាបញ្ចប់ការសិក្សានេះ នៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយនោះទេ ទោះបីជាមានការពិនិត្យជាច្រើនលើកច្រើនសារយ៉ាងណាក៏ដោយ ក៏ក្រុមខ្ញុំបាទនៅមានជំនឿថា មិត្តនិស្សិត និងអ្នកអានទាំងអស់ ពិតជាមានយោគយល់ និងមានការអធ្យាស្រ័យ នូវរាល់កំហុសខុសឆ្គងនានា ទៅលើការប្រើប្រាស់ពាក្យពេចន៍ អត្ថន័យ និងអក្ខរាវិរុទ្ធមួយចំនួនដែលកើតមានឡើងដោយអចេតនានៅលើសារណាបញ្ចប់ការសិក្សាមួយនេះ។ ក្រុមខ្ញុំបាទសូមទទួលយកនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនា កែលំអ ដោយក្តីសោមនស្សរីករាយ ដើម្បីទុកជាបទពិសោធន៍ សម្រាប់យកទៅធ្វើការស្រាវជ្រាវនាពេលក្រោយៗបន្តទៀត ឱ្យកាន់តែមានភាពច្បាស់លាស់ត្រឹមត្រូវ និងកាន់តែមានភាពសុក្រឹតបន្ថែមមួយកម្រិតទៀត។

ជាចុងក្រោយ ក្រុមខ្ញុំបាទសូមថ្លែងអំណរគុណដល់មិត្តអ្នកអាន និងសូមឱ្យមិត្តនិស្សិតទាំងអស់ទទួលបានជោគជ័យនៅក្នុងការសិក្សា មានសុខភាពល្អ ប្រាជ្ញាឈ្លាសវៃ និងសូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

ទំព័រ

**បញ្ជីអក្សរកាត់**......iii

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ......១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ......២

៣. គោលបំណងនៃការស្រាវជ្រាវ......៣

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ......៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ......៤

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ......៤

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ......៥

## ជំពូកទី១

## សញ្ញាណទូទៅនៃជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

១. ប្រវត្តិអង្គភាពដែលទទួលបន្ទុកលើសំណុំរឿង MLA នៃក្រសួងយុត្តិធម៌......៧

១.១. ប្រវត្តិនៃការកកើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍......៧

១.២.ដំណើរការចូលជាសមាជិកអាស៊ានរបស់កម្ពុជា......៩

១.៣. ប្រវត្តិនៃក្រសួងយុត្តិធម៌ (១៩៨០-២០២២)......១៥

១.៤. ប្រវត្តិនៃអង្គភាពទទួលបន្ទុកកិច្ចការអាស៊ាន នៃក្រសួងយុត្តិធម៌......១៦

២. សញ្ញាណទូទៅនៃសំណុំរឿងជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ......២១

២.១. គោលបំណង វិសាលភាព និយមន័យ......២១

២.២. កិច្ចប្រជុំពាក់ព័ន្ធនឹងសំណុំរឿង MLA......២៥

២.៣. អាជ្ញាធរកណ្តាល......២៩

២.៤. អាជ្ញាធរអនុវត្តសំណើ......៣២

## ជំពូកទី២
## ភាគីដែលស្នើសុំជំនួយ


១. សំណើសុំជំនួយដោយរដ្ឋបរទេស ........ ៣៣

១.១. វិធានទូទៅ ........ ៣៣

១.២. វិធានជាក់លាក់ ........ ៤៤

២. សំណើសុំជំនួយដោយព្រះរាជាណាចក្រកម្ពុជា ........ ៥៨

២.១. វិធានទូទៅ ........ ៥៨

២.២. វិធានជាក់លាក់ ........ ៥៨

៣. ការចំណាយ ........ ៦០


## ជំពូកទី៣
## បែបបទរដ្ឋបាលនៃការធ្វើសំណើជំនួយទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌


១. សំណើចូល ........ ៦២

១.១. កំណត់បង្ហាញ ........ ៦២

១.២. លិខិតផ្ញើចេញទៅកាន់អាជ្ញាធរអនុវត្តសំណើ ........ ៦៥

១.៣. លិខិតឆ្លើយតបទៅកាន់រដ្ឋធ្វើសំណើ ........ ៦៧

២. សំណើចេញ ........ ៦៨

២.១. កំណត់បង្ហាញ ........ ៦៩

២.២. លិខិតផ្ញើទៅកាន់អាជ្ញាធរកណ្ដាលនៃរដ្ឋទទួលសំណើ ........ ៦៩

២.៣. ទម្រង់លិខិតសំណើសុំជំនួយផ្នែកច្បាប់ (MLA) ទៅរដ្ឋទទួលសំណើ ........ ៧២

២.៤. លិខិតឆ្លើយតបទៅកាន់អាជ្ញាធរធ្វើសំណើ ........ ៧៨

**សេចក្ដីសន្និដ្ឋាន** ........ ៨០

**អនុសាសន៍** ........ ៨៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| -ក្រ.កបទសអ | ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ |
| -ក្រ.យ | ក្រសួងយុត្តិធម៌ |
| -សំណើ | ឬសរសេរម្យ៉ាងទៀតថា សំណើសុំជំនួយផ្នែកច្បាប់ គឺសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ហៅកាត់ជាភាសាអង់គ្លេសថា MLA |
| -សំណើចេញ | សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដែលព្រះរាជាណាចក្រកម្ពុជាស្នើសុំប្រទេសជាសមាជិកអាស៊ាន |
| -សំណើចូល | សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដែលប្រទេសជាសមាជិកអាស៊ានស្នើសុំមកព្រះរាជាណាចក្រកម្ពុជា |
| -អាស៊ាន | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| -AHRD | ASEAN Human Rights Declaration |
| -AMM | ASEAN Foreign Ministerial Meetings |
| -AMAG-MLAT | ASEAN Ministers/Attorneys-General Meeting of the Central Authorities on Mutual Legal Assistance in Criminal Matters |
| -ARMAC | ASEAN Regional Mine Action Center |
| -ASEAN | Association of South-East Asian Nations |
| -ASEANAPOL | ASEAN Chiefs of National Police |
| -DOC | Declaration on the Conduct of the Parties in the South China Sea |
| -GDP | Gross Domestic Product |
| -INTERPOL | The International Criminal Police Organization |
| -MLA | Mutual on Legal Assistance in Criminal Matters |
| -MLAT | Treaty on Mutual Legal Assistance in Criminal Matters |
| -RCEP | Regional Comprehensive Economic Partnership |
| -SEAJust | South East Asia Justice Network |
| -SOM-MLAT | Senior Official’s Meeting of the Central Authorities on Mutual Legal Assistance in Criminal Matters |
| -TAC | The Treaty of Amity and Cooperation in Southeast Asia |
| -UNODC | United Nations Office on Drugs and Crime |

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅថ្ងៃអង្គារ ៣កើត ខែស្រាពណ៍ ឆ្នាំមមែ នព្វស័ក ពុទ្ធសករាជ ២៥១១ ត្រូវនឹងថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ាន ត្រូវបានបង្កើតឡើង នាទីក្រុងបាងកក ព្រះរាជាណាចក្រថៃ ហើយនៅថ្ងៃសុក្រ ១រោច ខែពិសាខ ឆ្នាំថោះ ឯកស័ក ពុទ្ធសករាជ ២៥៤៣ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ព្រះរាជាណាចក្រកម្ពុជាបានក្លាយខ្លួនទៅជាសមាជិកទី១០ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថាអាស៊ានមួយនេះ។

បន្ទាប់ពី ព្រះរាជាណាចក្រកម្ពុជាបានបោះជំហានចូលទៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍នេះហើយ កម្ពុជាមានការកើនឡើងនូវកិច្ចសហប្រតិបត្តិការរវាងប្រទេសជាច្រើនជុំវិញពិភពលោក ជាពិសេសជាមួយប្រទេសដែលជាសមាជិកអាស៊ានផ្ទាល់តែម្តង ហើយនៅក្នុងនោះវិស័យព្រហ្មទណ្ឌ គឺជាវិស័យដ៏ធំមួយក្នុងចំណោមវិស័យធំៗជាច្រើនផ្សេងទៀត ដែលតម្រូវឱ្យមានការធ្វើកិច្ចសហប្រតិបត្តិការផ្នែកច្បាប់រវាងរដ្ឋនិងរដ្ឋ ដែលជាសមាជិកនៃសមាគមបន៍ប្រជាជាតិអាស៊ីអាគ្នេយ៍មួយនេះ។ រហូតមកដល់ពាក់កណ្តាលឆ្នាំ២០២០ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានសព្វព្រះរាជហឫទ័យឡាយព្រះហស្ថលេខាប្រកាសឱ្យប្រើប្រាស់ច្បាប់មួយជាការប្រញាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ តាមរយៈ**ព្រះរាជក្រមលេខ នស/រកម/០៦២០/០២០** ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី៤។ ច្បាប់នេះមានសារៈសំខាន់សម្រាប់ព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រើប្រាស់ក្នុងការធ្វើកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសដែលជាសមាជិកអាស៊ានទាំង១០ (ក្នុងពេលបច្ចុប្បន្ន) និង១១ (នាពេលអនាគតបូកបញ្ចូលសមាជិកបន្ថែមគឺប្រទេស Timor-Leste) ទាក់ទងនឹងដំណើរការនីតិវិធីនានាពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងការបង្កក ការចាប់យក និងការរឹបអូសទ្រព្យក្នុងគោលបំណងដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសជាសមាជិកអាស៊ានទាំងអស់។ ហើយបណ្តាប្រទេសក្នុងក្របខណ្ឌអាស៊ានទាំងអស់ក៏អាចធ្វើសំណើមកកាន់ព្រះរាជាណាចក្រកម្ពុជា ដើម្បីស្នើសុំកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌផងដែរ។

ហេតុដូច្នេះហើយ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ពីកិច្ចសហប្រតិបត្តិការក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជាជាមួយប្រទេសជាសមាជិកអាស៊ាននេះហើយ ទើបក្រុមខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយស្តីពី "ជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាននៃក្រសួងយុត្តិធម៌" មកធ្វើការសិក្សាស្រាវជ្រាវ ដោយផ្តោតសំខាន់ទៅលើទម្រង់ និងបែបបទនៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ របស់អង្គភាពក្រោមចំណុះក្រសួងយុត្តិធម៌ ដែលទទួលបន្ទុកកិច្ចការងារ និងកិច្ចសហប្រតិបត្តិការជាមួយនឹងអាស៊ាន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

យើងដឹងហើយថា វិស័យព្រហ្មទណ្ឌស្តែងឡើងពីការប្រព្រឹត្តបទល្មើសនានា ដែលជាវិស័យមួយធ្វើឱ្យមានការប៉ះពាល់ ឬជះផលអាក្រក់ទៅលើសណ្តាប់ធ្នាប់សាធារណជាខ្លាំង។ ហើយបណ្តាប្រទេសដែលជាសមាជិកអាស៊ានបាននិងកំពុងខិតខំបង្កើតឱ្យមានកិច្ចសហប្រតិបត្តិការ ក្នុងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះឡើង ដើម្បីការពារសណ្តាប់ធ្នាប់សាធារណរបស់រដ្ឋដែលជាសមាជិកអាស៊ាននេះដែរ។ ដើម្បីយល់ដឹងឱ្យកាន់តែច្បាស់អំពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាននេះ យើងគួរគប្បីតែសិក្សាស្វែងយល់ដឹងអំពី៖

- តើនរណាជាអាជ្ញាធរកណ្តាល និងជាអាជ្ញាធរអនុវត្តសំណើ នៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជាយើងនេះ?
- តើនៅក្នុងក្របខណ្ឌក្រសួងយុត្តិធម៌ អង្គភាពណាដែលទទួលបន្ទុកធ្វើកិច្ចការងារជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាននេះ?
- ដោយស្ថិតនៅក្នុងវិស័យព្រហ្មទណ្ឌដូចគ្នា តើសំណុំរឿងជំនួយផ្នែកច្បាប់នេះ ខុសគ្នាពីសំណុំរឿងបត្យាប័ន និងផ្ទេរទណ្ឌិត ដូចម្តេចខ្លះ?
- តើការធ្វើជំនួយផ្នែកច្បាប់នេះ បង្កើនកិច្ចសហប្រតិបត្តិការអន្តរជាតិយ៉ាងដូចម្តេចខ្លះជាមួយរដ្ឋសមាជិកអាស៊ាន?
- តើសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ានមាននីតិវិធីបែបណាខ្លះ?
- តើបែបបទរដ្ឋបាលក្នុងការរៀបចំសំណើចេញ ដើម្បីស្នើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌទៅរដ្ឋដែលជាសមាជិកអាស៊ាន ត្រូវរៀបចំយ៉ាងដូចម្តេច?
- តើបែបបទរដ្ឋបាលក្នុងការរៀបចំសំណើចូល អំពីជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌពីរដ្ឋដែលជាសមាជិកអាស៊ាន ត្រូវរៀបចំយ៉ាងដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់ៗនៃការស្រាវជ្រាវទាក់ទងទៅនឹង ជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌ គឺផ្តោតសំខាន់ទៅលើចំណុចមួយចំនួនដូចជា៖

- សិក្សាទៅលើការកកើតក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌
- សិក្សាទៅលើសមត្ថកិច្ចរបស់អាជ្ញាធរកណ្តាល និងអាជ្ញាធរអនុវត្តសំណើ ក្នុងការធ្វើជំនួយទៅវិញទៅមក ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
- សិក្សាអំពីសន្ធិសញ្ញា ច្បាប់ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹងការធ្វើ ជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
- សិក្សាអំពីទម្រង់នៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
- សិក្សាអំពីនីតិវិធីនៃការរៀបចំធ្វើសំណើចេញ និងសំណើចូល នៃជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យ ព្រហ្មទណ្ឌ របស់អង្គភាពទទួលបន្ទុកអាស៊ាន ចំណុះក្រោមក្រសួងយុត្តិធម៌
- ការធ្វើសេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

### ៤.១. ទំហំ

ក្របខណ្ឌអាស៊ាន គឺជាក្របខណ្ឌមួយដែលមានវិសាលភាពទាក់ទងទៅនឹងវិស័យនានាទាំងអស់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ដែលពាក់ព័ន្ធទៅនឹងប្រទេសជាសមាជិកទាំង១០ បូករួមទាំងកម្ពុជាផងដែរ។ អាស្រ័យ ហេតុនេះ ទើបក្រុមខ្ញុំបាទមិនអាចធ្វើការសិក្សាស្រាវជ្រាវលម្អិត និងស៊ីជម្រៅទៅលើវិស័យនានានៃក្របខណ្ឌ ទាំងអស់នោះបានទេ គឺក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវនេះ ក្រុមខ្ញុំបាទផ្តោតសំខាន់តែទៅលើប្រធានបទ ជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រ កម្ពុជាតែប៉ុណ្ណោះ។

### ៤.២. ដែនកំណត់

ដោយផ្អែកទៅលើប្រធានបទដែលបានកំណត់រួច ការសិក្សាស្រាវជ្រាវនេះ គឺស្រាវជ្រាវដោយផ្តោតការ យកចិត្តទុកដាក់ និងស៊ីជម្រៅទៅលើចំណុចមួយចំនួនដូចខាងក្រោម៖

- សមត្ថកិច្ចនៃអាជ្ញាធរកណ្តាល និងអង្គភាពដែលទទួលបន្ទុកក្នុងការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌
- ទម្រង់ និងនីតិវិធីនៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

- នីតិវិធីបែបបទរដ្ឋបាលរបស់ក្រសួងយុត្តិធម៌ក្នុងការរៀបចំសំណើចេញអំពីជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌទៅរដ្ឋដែលជាសមាជិកអាស៊ាន
- នីតិវិធីបែបបទរដ្ឋបាលរបស់ក្រសួងយុត្តិធម៌ក្នុងការរៀបចំសំណើចូលអំពីជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីរដ្ឋដែលជាសមាជិកអាស៊ាន។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌ ផ្តល់សារៈសំខាន់មួយចំនួនដូចជា៖

- ទទួលបានចំណេះដឹងថ្មីៗទាក់ទងទៅនឹងការស្រាវជ្រាវ និងយល់ដឹងកាន់តែលម្អិតទាក់ទងនឹងប្រធានបទ
- យល់ដឹងពីស្ថានភាពមួយផ្នែកក្នុងវិស័យព្រហ្មទណ្ឌនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ឬអាស៊ាន
- យល់ដឹងពីជ្រុងមួយនៃវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌
- យល់ដឹងពីរចនាសម្ព័ន្ធ តួនាទី របស់ក្រសួងយុត្តិធម៌ដែលជាអាជ្ញាធរកណ្តាលនៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់នៃវិស័យព្រហ្មទណ្ឌ
- យល់ដឹងពីច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា
- យល់ដឹងពីទម្រង់ និងនីតិវិធីនៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌
- យល់ដឹងពីរបៀបរបបនីតិវិធីរដ្ឋបាលនៃការរៀបចំធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌
- យល់ដឹងអំពីកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយនឹងប្រទេសសមាជិកអាស៊ាន
- ពង្រឹង និងពង្រីកចំណេះដឹងបន្ថែមទាក់ទងនឹងជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
- ផ្តល់ឯកសារទុកសម្រាប់សិស្សនិស្សិត អ្នកសិក្សា និងអ្នកស្រាវជ្រាវ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៦.១. វិធីសាស្ត្រមូលទិន្នន័យ

នៅក្នុងការស្រាវជ្រាវនេះ ក្រុមខ្ញុំបាទបានប្រមូលព័ត៌មាន និងទិន្នន័យមកសំអាងពីទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។ ដើម្បីឱ្យដំណើរការនៃការស្រាវជ្រាវនេះប្រកបដោយភាពជោគជ័យយើងទាមទារនូវតម្រូវការទិន្នន័យជាច្រើន ដែលទទួលបានពីប្រភពចម្បងពីរដែលសម្រួលក្នុងការប្រមូលទិន្នន័យ និងវិភាគឱ្យគ្រប់គ្រាន់ គឺទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំ។

**ក. ទិន្នន័យចម្បង**

ទិន្នន័យចម្បង ជាទិន្នន័យដែលទទួលបានតាមរយៈមធ្យោបាយមួយចំនួនដូចខាងក្រោម ៖

- បទពិសោធន៍ការងារក្នុងការធ្វើសំណុំរឿងជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នៅក្នុងអង្គភាពទទួលបន្ទុកកិច្ចការអាស៊ាន នៃក្រសួងយុត្តិធម៌
- សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន
- ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

**ខ. ទិន្នន័យបន្ទាប់បន្សំ**

ទិន្នន័យបន្ទាប់បន្សំ ជាទិន្នន័យដែលទទួលបានតាមរយៈមធ្យោបាយមួយចំនួនដូចខាងក្រោម ៖

- ធម្មនុញ្ញអាស៊ាន ឆ្នាំ២០២០ ចេញផ្សាយដោយលេខាធិការដ្ឋានអាស៊ាន ប្រចាំនៅទីក្រុងហ្សាកាតា នៃសាធារណរដ្ឋឥណ្ឌូនេស៊ី។
- សេចក្តីណែនាំ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីកំណត់ទម្រង់នៃការអនុវត្តសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។
- សៀវភៅអង្គការអន្តរជាតិ និពន្ធដោយលោកសាស្ត្រចារ្យ ពៅ សារឿន ឆ្នាំ២០១០។
- សៀវភៅអាស៊ាន និងសមាហរណកម្ម និពន្ធដោយលោក បណ្ឌិត ឈុន ណារ៉េត ឆ្នាំ២០១០។
- សៀវភៅសិក្សាអំពីអាស៊ាន រៀបរៀងដោយ ក្រុមអ្នកសរសេរហាតប៊ុក របស់គ្រឹះស្ថានស្រាវជ្រាវ និងបោះពុម្ពផ្សាយហាតប៊ុក ឆ្នាំ២០២២។

## ៦.២. វិធីសាស្ត្រវិភាគទិន្នន័យ

ចំពោះវិធីសាស្ត្រវិភាគទិន្នន័យ ដែលប្រើប្រាស់ក្នុងការវិភាគសារណា ដែលទាក់ទងទៅនឹងជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌នេះ គឺត្រូវបានកំណត់ និងអនុវត្តន៍នូវវិធីសាស្ត្រតាមបែបគុណភាព និងមិនធ្វើតាមបែបបរិមាណនោះទេ។ សម្រាប់ការវិភាគទិន្នន័យ គឺក្រុមខ្ញុំបាទយកទិន្នន័យចម្បង និងទិន្នន័យបន្ទាប់បន្សំដែលប្រមូលបានមកវិភាគ ដើម្បីឈានទៅដល់ការទាញចេញជាសេចក្តីសន្និដ្ឋាន និងការផ្តល់អានុសាសន៍។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ ត្រូវបានបែងចែកចេញជាពីរជំពូកដូចខាងក្រោម ៖

**ជំពូកទី១ ៖** សញ្ញាណទូទៅនៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ៖ រៀបរាប់អំពីប្រវត្តិនៃការកកើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ប្រវត្តិនៃអង្គភាពទទួលបន្ទុកកិច្ចការអាស៊ានក្រោមចំណុះក្រសួងយុត្តិធម៌ អំណាច និងសមត្ថកិច្ចរបស់អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា និយមន័យពាក្យសំខាន់ៗ និងកិច្ចប្រជុំនានាពាក់ព័ន្ធនឹងសំណុំរឿងជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

**ជំពូកទី ២ ៖** រដ្ឋធ្វើសំណើ ៖ រៀបរាប់អំពីសន្ធិសញ្ញា ឬច្បាប់ ដែលគ្រប់គ្រងទៅលើ ទម្រង់ និងនីតិវិធីនៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងភាគី ព្រះរាជាណាចក្រកម្ពុជាជាមួយរដ្ឋបរទេស ការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងរដ្ឋបរទេស ជាមួយព្រះរាជាណាចក្រកម្ពុជា។

**ជំពូកទី៣ ៖** នីតិវិធីនៃបែបបទរដ្ឋបាលក្នុងការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌ ៖ រៀបរាប់លម្អិតអំពីនីតិវិធីបែបបទរដ្ឋបាលនៃការរៀបចំសំណើស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌចេញទៅរដ្ឋដែលជាសមាជិកអាស៊ាន ដើម្បីផ្តល់ជំនួយផ្នែកច្បាប់មកវិញ និងរដ្ឋដែលជាសមាជិកអាស៊ានស្នើសុំជំនួយផ្នែកច្បាប់មកព្រះរាជាណាចក្រកម្ពុជាវិញ។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៖** ការស្វែងរកចំណុចវិជ្ជមាន និងអវិជ្ជមាន ដែលកើតមានឡើង និងការវិភាគស្វែងរកដំណោះស្រាយដ៏សមរម្យ ដើម្បីចូលរួមកាត់បន្ថយនូវកង្វះខាតដែលបានកើតឡើង។

# ជំពូកទី១
# សញ្ញាណទូទៅនៃជំនួយទៅវិញទៅមក
# ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

# ជំពូកទី១
# សញ្ញាណទូទៅនៃជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

## ១. ប្រវត្តិអង្គភាពដែលទទួលបន្ទុកលើសំណុំរឿង MLA នៃក្រសួងយុត្តិធម៌

### ១.១. ប្រវត្តិនៃការកកើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍

សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ឬហៅកាត់ថា អាស៊ាន (The Association of Southeast Asian Nations – ASEAN) ត្រូវបង្កើតឡើងនៅ **ថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧** នាក្រុងទេពមហានគរ (បាងកក) នៃព្រះរាជាណាចក្រថៃ ដោយមានប្រទេសចំនួន «៥» ចូលរួមក្នុងនោះរួមមានដូចជា ម៉ាឡេស៊ី សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី និងព្រះរាជាណាចក្រថៃ បានចុះហត្ថលេខាលើឯកសារមួយ ដែលតាមរយៈឯកសារនោះហើយទើប សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ត្រូវបានបង្កើតឡើង។[1] ការចុះហត្ថលេខានៅពេលនោះមានការចូលរួមពីលោក **អាដាំ ម៉ាលីក** (**Adam Malik**) រដ្ឋមន្ត្រីការបរទេសឥណ្ឌូនេស៊ី លោក **ណាស៊ីសូ រូកា រ៉ាម៉ូស** (**Narciso Rueca Ramos**) រដ្ឋមន្ត្រីការបរទេសហ្វីលីពីន លោក **ទុន អាប់ឌុល រ៉ាហ្សាក់** (**Tun Abdul Razak**) រដ្ឋមន្ត្រីការបរទេសម៉ាឡេស៊ី លោក **ស៊ីនណាថាំប៊ី រ៉ាចារ៉ាត់ណាំ** (**Sinnathamby Rajaratnam**) រដ្ឋមន្ត្រីការបរទេសសិង្ហបុរី និងលោក **ថាណាត់ ខូម៉ាន់** (**Thanat Khoman**) រដ្ឋមន្ត្រីការបរទេសថៃ អ្នកទាំងនោះត្រូវបានគេហៅថាជា បិតាស្ថាបនិក (**Founding Fathers**) នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ហៅកាត់ថា អាស៊ាន ដែលទទួលបានជោគជ័យរហូតមកទល់ពេលបច្ចុប្បន្ននេះ។[2] ហើយឯកសារដែលគេចុះហត្ថលេខាមានកម្រាស់ចំនួន៥ទំព័រនោះ ត្រូវបានគេស្គាល់ថាជាសេចក្តីថ្លែងការណ៍អាស៊ាន (ASEAN Declaration) ឬត្រូវបានគេហៅម្យ៉ាងទៀតថា សេចក្តីថ្លែងការណ៍ក្រុងបាងកក (Bangkok Declaration)។ នៅក្នុងសេចក្តីថ្លែងការណ៍អាស៊ានដ៏ខ្លីតែខ្លឹមនោះ ត្រូវបានបែងចែកទៅជា ៥ មាត្រា ដែលមាត្រា១ ប្រកាសអំពីការបង្កើតសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ មាត្រា២ បង្ហាញអំពីគោលដៅ និងវត្ថុបំណងរបស់សមាគម មាត្រា៣ បង្ហាញអំពីការបង្កើតយន្តការអនុវត្តដើម្បីឆ្លើយតបនឹងគោលដៅ និងវត្ថុបំណងរបស់សមាគម មាត្រា៤ បង្ហាញអំពីការទទួលស្វាគមន៍ចំពោះសមាជិកភាពដែលស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងមាត្រា៥ បង្ហាញអំពីការរួបរួមសហប្រតិបត្តិការ និងមិត្តភាពរវាងប្រទេសនៅក្នុងតំបន់។ ប្រទេសស្ថាបនិកទាំងនោះ លើកលែងប្រទេសថៃ សុទ្ធសឹងតែជាដែនដីដែលទើបទទួលបានអធិបតេយ្យភាពថ្មីថ្មោងពីនឹមអាណានិគមក្នុងសម័យនោះ។ គួបផ្សំនឹងការចាប់ផ្តើមនៃសង្គ្រាមត្រជាក់ផង ទើបជំរុញឱ្យ

[1] THE ASEAN DECLARATION (BANGKOK DECLARATION), BANGKOK, 8 AUGUST 1967, Article 1។
[2] ពៅ សារឿន, អង្គការអន្តរជាតិ (ភ្នំពេញ, ២០១០), ៤៧។

ប្រទេសទាំងប្រាំប្រកៀកស្មាគ្នាបង្កើតសមាគមនេះឡើង ដោយមានគោលដៅរួម គឺជំរុញឱ្យមានសន្តិភាព ស្ថិរភាព កំណើនសេដ្ឋកិច្ច រួមទាំងការអភិវឌ្ឍសង្គម និងវប្បធម៌ ក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល។ ក្រោយពីសង្គ្រាមត្រជាក់ អាស៊ានបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងកិច្ចសហប្រតិបត្តិការពង្រឹងវិស័យសេដ្ឋកិច្ច នយោបាយ សង្គមកិច្ច និងសន្តិសុខនៅក្នុងតំបន់អាស៊ីអាគ្នេយ៍និយាយជារួម និងតំបន់អាស៊ីប៉ាស៊ីហ្វិចនិយាយដោយឡែក។ សមាគមនេះបានបង្រួបបង្រួមប្រទេសទាំង១០ នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ដូចក្តីសុបិនរបស់ស្ថាបនិកនៃសមាគមនេះ។ ចាប់ពីឆ្នាំ១៩៨៤ មក បណ្តាប្រទេសចំនួន ៥ ផ្សេងទៀតក្នុងតំបន់នេះរួមមាន ប្រទេសប្រ៊ុយណេដារូសាឡាម សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា និងព្រះរាជាណាចក្រកម្ពុជា ដែលជាកូនពៅ បានក្លាយទៅជាសមាជិកនៃសមាគមមួយនេះជាបន្តបន្ទាប់។ ដោយឡែកសម្រាប់ប្រទេសកម្ពុជា ត្រូវបានចូលជាសមាជិកពេញសិទ្ធិ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ **នាថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩** នៅទីក្រុងហាណូយ ប្រទេសវៀតណាម។ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ឬហៅកាត់ថា អាស៊ាន (ASEAN) គឺជាអង្គការថ្នាក់តំបន់មួយ រួមមានប្រទេសនៅអាស៊ីអាគ្នេយ៍ទាំងដប់ ជាសមាជិកត្រូវបានបង្កើតឡើងដើម្បីជួយជំរុញកិច្ចសហប្រតិបត្តិការអន្តររដ្ឋាភិបាល និងជួយសម្រួលការធ្វើសមាហរណកម្មក្នុងចំណោមសមាជិកទាំងអស់។ តាមរយៈសេចក្តីថ្លែងការណ៍របស់ប្រមុខដឹកនាំអាស៊ាន នាឱកាសកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ នៅរាជធានីភ្នំពេញក្នុងឆ្នាំ២០២២ នាពេលដ៏ខ្លីខាងមុខនេះសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត (Timor Leste) និងក្លាយខ្លួនជាសមាជិកអាស៊ានទី១១[3] បន្ទាប់ពីប្រទេសកម្ពុជា ដោយបច្ចុប្បន្នប្រទេសទីម័រខាងកើត ត្រូវបានអាស៊ានផ្តល់ឋានៈជាប្រទេសសង្កេតការណ៍ និងអនុញ្ញាតឱ្យប្រទេសនេះចូលរួមក្នុងកិច្ចប្រជុំអាស៊ានទាំងអស់ រួមបញ្ចូលទាំងសម័យប្រជុំពេញអង្គនៃកិច្ចប្រជុំកំពូលអាស៊ាន។

គោលបំណងសំខាន់ៗនៃអង្គការនេះ គឺការជំរុញនូវកំណើនសេដ្ឋកិច្ច វឌ្ឍនភាពសង្គម និងការអភិវឌ្ឍវប្បធម៌នៅក្នុងតំបន់ ជំរុញកិច្ចសហប្រតិបត្តិការដើម្បីឱ្យមានភាពប្រសើរឡើង ខាងវិស័យកសិកម្ម និងឧស្សាហកម្ម ដើម្បីលើកកម្ពស់ជីវភាពប្រជាជន និងសម្រាប់សមាជិកទាំងអស់ រួមជាមួយការការពារស្ថិរភាព លើកកម្ពស់សន្តិភាពនៅក្នុងតំបន់ ការផ្តល់យន្តការមួយសម្រាប់ប្រទេសជាសមាជិកដើម្បីដោះស្រាយទំនាស់ដោយសន្តិវិធី ជំរុញឱ្យមានភាពសកម្មនៅក្នុងការសហការគ្នា និងការជួយទំនុកបម្រុងគ្នាទៅវិញទៅមកដើម្បីផលប្រយោជន៍រួមនៅក្នុងវិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ បច្ចេកទេស វិទ្យាសាស្ត្រ រដ្ឋបាល និងផ្តល់ជំនួយដល់គ្នាទៅវិញទៅមកដែលមានដូចជា ជំនួយផ្នែកបណ្តុះបណ្តាល និងការស្រាវជ្រាវក្នុងវិស័យអប់រំ វិជ្ជាជីវៈ បច្ចេកទេស

[3] សេចក្តីថ្លែងការណ៍របស់ប្រមុខដឹកនាំអាស៊ាន ស្តីពីសំណើសុំចូលជាសមាជិកអាស៊ានរបស់ទីម័រឡេស្តេ នាកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា, ១១ ខែវិច្ឆិកា ឆ្នាំ២០២២, ចំណុច១។

និងរដ្ឋបាល។ អាស៊ានគ្រប់ដណ្តប់លើផ្ទៃដី ៤.៤ លានគីឡូម៉ែត្រការ៉េ ស្មើនឹង៣% នៃផ្ទៃដីផែនដីសរុប។ អាស៊ានគ្របដណ្តប់ទៅលើដែនទឹកធំជាងដែនគោកចំនួន៣ដង។ អាស៊ានមានប្រជាជនសរុបប្រមាណ ៦២៥ លាននាក់ ស្មើនឹង៨% នៃប្រជាជនលើពិភពលោក។ នៅឆ្នាំ២០១៥ GDP ជាមធ្យមនៃអាស៊ាន គឺបានកើនឡើងជាង២.៨លានលានដុល្លារអាមេរិក។ ប្រសិនបើអាស៊ានជាប្រទេសមួយ នោះនឹងក្លាយជាប្រទេសជាប់ចំណាត់ថ្នាក់ជាប្រទេសមហាអំណាចសេដ្ឋកិច្ចទី៦ នៅក្នុងពិភពលោក បន្ទាប់ពី**សហរដ្ឋអាមេរិក ចិន ជប៉ុន អាល្លឺម៉ង់ និងអង់គ្លេស**។ អាស៊ានមានទីស្នាក់ការកណ្តាល នៅរដ្ឋធានីហ្សាកាតា នៃប្រទេសឥណ្ឌូនេស៊ី។ ភាសាសម្រាប់ប្រើប្រាស់ជាផ្លូវការក្នុងអាស៊ាន គឺ«ភាសាអង់គ្លេស» ហើយបាវចនារបស់អាស៊ាន គឺ «ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ» ឬ «One Vision, One Identity, One Community»។

## ១.២.ដំណើរការចូលជាសមាជិកអាស៊ានរបស់កម្ពុជា

### ១.២.១. ការទទួលបានឋានៈដំបូងក្នុងនាមជាភ្ញៀវពិសេសរបស់អាស៊ាន (១៩៩៣-១៩៩៥)

ក្រោយពីមានការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី១ នៃរដ្ឋសភា នាថ្ងៃទី២៣-២៨ ខែឧសភា ឆ្នាំ១៩៩៣ រួចមក រាជរដ្ឋាភិបាលចម្រុះមួយបានត្រូវបង្កើតឡើង។ គោលនយោបាយថ្មីស្រឡាងសម្រាប់រាជរដ្ឋាភិបាល ត្រូវបានអនុម័តដោយសភាជាតិ ពេលនោះហើយប្រជាជនខ្មែរគ្រប់រូបក៏ទទួលបាននូវរបបថ្មីមួយ ដែលមានជីវិតរហូតមកដល់ទល់សព្វថ្ងៃនេះគឺ **របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ** ឬរាជានិយមអាស្រ័យច្បាប់ ដោយអនុវត្តប្រព័ន្ធនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស។ គោលនយោបាយក្រៅប្រទេសរបស់រាជរដ្ឋាភិបាលថ្មីនេះ គឺប្រទេសកម្ពុជាចង់ឱ្យមានទំនាក់ទំនង ជាប្រក្រតីឡើងវិញជាមួយបណ្តាប្រទេសជាច្រើននៅក្នុងសកលលោក ជាពិសេសជាមួយប្រទេសមហាអំណាច និងជាមួយបណ្តាប្រទេសនានា ដែលស្ថិតនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍។ ជាក់ស្តែងព្រះរាជាណាចក្រកម្ពុជា បានចាប់ផ្តើមធ្វើដំណើរបោះជំហានចូលទៅក្នុងតំបន់អាស៊ានជាលើកដំបូង ដែលនៅពេលនោះអាស៊ានក៏បានអញ្ជើញប្រទេសកម្ពុជាឱ្យចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន (AMM-ASEAN Foreign Ministerial Meetings) លើកទី២៦ នៅប្រទេសសឹង្ហបុរីក្នុងឋានៈជាភ្ញៀវ។ នៅក្នុងឱកាសនោះហើយ ដែលអាស៊ានបានចាប់ផ្តើមឈោងដៃរបស់ពួកគេមកចាប់ដៃកម្ពុជាវិញផងដែរ។[4] នាខែកក្កដា ឆ្នាំ១៩៩៤ កម្ពុជាត្រូវបានអាស៊ានអញ្ជើញឱ្យចូលរួមម្តងទៀត នៅឯកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី២៧ នៅទីក្រុងបាងកក ប្រទេសថៃ ក្នុងឋានៈជាភ្ញៀវពិសេស។ ឆ្លៀតក្នុងឱកាសនោះ ប្រទេសកម្ពុជាបានសំដែងនូវគោលបំណងរបស់ខ្លួនឱ្យដឹងថា ខ្លួនមានបំណងចង់ក្លាយជាអ្នកសង្កេតការណ៍របស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា (អាស៊ាន) មួយនេះ។

[4] បណ្ឌិត ឈុន ណារ៉េត, អាស៊ាន និងសមាហរណកម្ម (ភ្នំពេញ, ២០១០), ៩១។

នៅដើមខែធ្នូ ឆ្នាំ១៩៩៤ អគ្គលេខាធិការអាស៊ាន គឺ**លោក ដាតូ អាហ្សីតស៊ីង (Dato Ajit Singh)** អមដំណើរដោយគណៈប្រតិភូ បានអញ្ជើញមកទស្សនកិច្ចជាផ្លូវការនៅកម្ពុជា ដើម្បីជួយឱ្យកម្ពុជាអាចនឹងបំពេញបែបបទ និងយល់អំពីយន្តការដ៏ចាំបាច់សំរាប់ចូលរួមជាអ្នកសង្កេតការណ៍របស់សមាគមអាស៊ាន។

**១.២.២.ការទទួលបានឋានៈក្នុងនាមជាអ្នកសង្កេតការណ៍** (**១៩៩៥- ១៩៩៦**)

បន្ទាប់ពីបានទទួលឋានៈជាភ្ញៀវពិសេសរបស់អាស៊ានរួចហើយ រាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័នដែលពាក់ព័ន្ធដទៃទៀត បានរួមគ្នាបន្តធ្វើការងារនេះយ៉ាងសកម្ម ធ្វើយ៉ាងណាឱ្យកម្ពុជាបានចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ាន។ ជាក់ស្តែង ៣ខែ ក្រោយពីកិច្ចប្រជុំថ្នាក់រដ្ឋមន្រ្តីការបរទេសលើកទី២៧ របស់អាស៊ាន នៅទីក្រុងបាងកក ព្រះរាជាណាចក្រកម្ពុជាបានដាក់សំណើជាផ្លូវការ ដើម្បីទទួលឋានៈជាអ្នកអង្កេតការណ៍របស់អាស៊ាន នៅខែតុលា ឆ្នាំ១៩៩៤។ លើសពីនេះទៅទៀត នៅខែធ្នូ ឆ្នាំ១៩៩៤ សម្តេចសហនាយករដ្ឋមន្រ្តីទាំងពីរ **សម្តេចនរោត្តម រណឫទ្ធិ និង សម្តេច ហ៊ុន សែន** បានបង្ហាញនូវការគាំទ្រក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យព្រះរាជាណាចក្រកម្ពុជាក្លាយខ្លួនជាសមាជិកពេញសិទ្ធិរបស់អាស៊ាន។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៥ លោករដ្ឋមន្រ្តីការបរទេសកម្ពុជា បានចុះកិច្ចព្រមព្រៀងទៅលើសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (The Treaty of Amity and Cooperation in Southeast Asia ហៅកាត់ថា TAC)។ កិច្ចព្រមព្រៀងកម្ពុជាជាមួយសន្ធិសញ្ញានេះ គឺជាជំហានដំបូងដែលអាចឱ្យកម្ពុជាក្លាយទៅជា អ្នកសង្កេតការណ៍ក្នុងសមាគមនេះ។ ប៉ុន្មានសប្តាហ៍កន្លងមក រដ្ឋសភាជាតិបានពិភាក្សាអនុម័តជាឯកច្ឆ័ន្ទទៅលើសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (TAC) ដែលជាសេចក្តីសម្រេចចុងក្រោយរបស់កម្ពុជាក្នុងការចូលជាសមាជិកសមាគមអាស៊ាន។ នៅឯកិច្ចប្រជុំថ្នាក់រដ្ឋមន្រ្តីការបរទេសអាស៊ានលើកទី២៨ នៅប្រទេសប្រ៊ុយណេ (ASEAN Ministerial Meeting : AMM) កម្ពុជាត្រូវបានទទួលស្វាគមន៍ដោយអាស៊ានក្នុងឋានៈជាអ្នកសង្កេតការណ៍ពេញសិទ្ធិរបស់អាស៊ាន។[5]

**១.២.៣. ការទទួលបានឋានៈជាសមាជិកពេញសិទ្ធិអាស៊ានរបស់កម្ពុជា** (**១៩៩៩**)

ក្រោយពីបានធ្វើការពិគ្រោះយោបល់អស់រយៈពេល ៧ឆ្នាំ ពីឆ្នាំ១៩៩១ រហូតដល់ឆ្នាំ១៩៩៧ ព្រះរាជាណាចក្រកម្ពុជា ក៏ដូចអាស៊ានបានឈានដល់ការសំរេចបានជោគជ័យនូវគោលការណ៍របស់ខ្លួនដូចដែលបានចែងក្នុងសេចក្តីប្រកាសទីក្រុងបាងកក ឆ្នាំ១៩៦៧។ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ ជាថ្ងៃប្រវត្តិសាស្រ្តថ្មីមួយទៀតសំរាប់ប្រទេសកម្ពុជា និងប្រជាជាតិអាស៊ីអាគ្នេយ៍ ជាង ១០ប្រទេស ដែលរួមមានប្រជាជនប្រមាណជាង ៥០០លាននាក់ បានចូលរួមអបអរសាទរ ក្នុងឱកាសដែលសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍បានសម្រេចបញ្ចូលព្រះរាជាណាចក្រកម្ពុជា ចូលជាសមាជិកពេញសិទ្ធិទី១០ របស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។

[5] បណ្ឌិត ឈុន ណាវ៉េត, អាស៊ាន និងសមាហរណកម្ម (ភ្នំពេញ, ២០១០), ៩៣។

នៅពេលនោះ យើងឃើញមានការសំដែងនូវការអបអរសាទរពីសំណាក់មេដឹកនាំនៃបណ្តាប្រទេសជាសមាជិកអាស៊ានជាច្រើន បានថ្លែងកោតសរសើរ និងលើកទឹកចិត្តឱ្យកម្ពុជាចូលរួមយ៉ាងសកម្ម និងពេញសិទ្ធិនូវរាល់វេទិកានៃកិច្ចប្រជុំអាស៊ាននានា ហើយសម្រាប់កម្ពុជាក៏បានប្តេជ្ញាចិត្តថានឹងចូលរួមចំណែកឱ្យអស់ពីលទ្ធភាពក្នុងការជួយជ្រោមជ្រែងឱ្យតំបន់អាស៊ីអាគ្នេយ៍មួយនេះ ក្លាយទៅជាតំបន់សុខសន្តិភាព ស្ថិរភាព និងភាពសម្បូររុងរឿងទៅថ្ងៃអនាគត។ ការរៀបចំចុះហត្ថលេខាជាផ្លូវការនៃការបញ្ចូលព្រះរាជាណាចក្រកម្ពុជាត្រូវបានប្រព្រឹត្តិទៅ នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩ នាទីក្រុងហាណូយ (Hanoi) សាធារណរដ្ឋសង្គមនិយមវៀតណាម (The Socialist Republic of Vietnam)។

ក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងនូវសុន្ទរកថាចំពោះភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិថាអ្វីដែលធ្វើឱ្យកម្ពុជាចាប់ចិត្តចំពោះអាស៊ាន គឺដោយសារអាស៊ានមានចំណុចខ្លាំង ៤ យ៉ាងដែលសំខាន់ គឺ៖

១. អាស៊ានបានបង្កើតនូវបរិយាកាសតំបន់មួយប្រកបទៅដោយសន្តិសុខ សន្តិភាព និងស្ថិរភាព ដែលអនុញ្ញាតឱ្យតំបន់នេះមានការរីកចម្រើន។

២. អាស៊ានជាតំបន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិ។

៣. អាស៊ានជាតំបន់ដែលត្រូវបានទទួលស្គាល់ថា មានការរីកលូតលាស់ខាងផ្នែកសេដ្ឋកិច្ចខ្លាំងខ្លា។

៤. អាស៊ានជាវេទិកាការទូត និងជាច្រកផ្លូវអន្តរជាតិដ៏សំខាន់។[6]

ដូច្នេះសំរាប់ប្រទេសកម្ពុជា ការចូលជាសមាជិកពេញសិទ្ធិរបស់អាស៊ាន គឺជាសក្ខីភាពតំណាងឱ្យការធ្វើសមារណកម្មទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ ព្រឹត្តិការណ៍ដ៏មានសំខាន់មួយនេះនឹងកំណត់ពីអនាគតនៃការអភិវឌ្ឍប្រទេសកម្ពុជាទៅថ្ងៃអនាគត។ ដូច្នេះកម្ពុជា ត្រូវតែមានកាតព្វកិច្ចចូលរួមក្នុងគ្រប់សកម្មភាពរបស់អាស៊ានយ៉ាងពេញលេញដូចសមាជិកអាស៊ានចាស់ដែរ ហើយកម្ពុជានឹងទទួលបាននូវអត្ថប្រយោជន៍ ដោយឈរលើគោលការណ៍ស្មើភាពក្នុងឋានៈជាសមាជិកអាស៊ានដូចគ្នា។ ក្រោយពេលកម្ពុជាចូលជាសមាជិកពេញលេញហើយនោះ កម្ពុជានឹងទទួលបានអត្ថប្រយោជន៍ជាច្រើនដូចជា ចំណេញខាងទស្សនៈនយោបាយ និងការអភិវឌ្ឍសេដ្ឋកិច្ចពីសមាជិកភាពនេះ។

**១.២.៤.គុណសម្បត្តិ**

ក្រោយពេលចូលអាស៊ាន ប្រទេសកម្ពុជាមានលទ្ធភាពច្រើនក្នុងការបង្កលក្ខណៈងាយស្រួលរកមធ្យោបាយទំនាក់ទំនងពាណិជ្ជកម្មលើការនាំចេញ និងនាំចូល ពីព្រោះអាស៊ានមានទីផ្សារធំទូលលាយ ហើយនៅជិតដែល

[6] បណ្ឌិត ឈុន ណាវ៉េត, អាស៊ាន និងសមាហរណកម្ម (ភ្នំពេញ, ២០១០), ៩៦។

ងាយស្រួលក្នុងការដឹកជញ្ជូនទំនិញ។ លើសពីនេះ កម្ពុជាអាចទាក់ទាញវិនិយោគទុនបរទេស និងកសាងសេដ្ឋកិច្ចឡើងវិញបានក្នុងរយៈពេលដ៏ឆាប់រហ័ស។

ក្រោយពេលចូលជាសមាជិកអាស៊ាន កម្ពុជានឹងទទួលបាន ៖

- កម្ពុជាលែងមានការព្រួយបារម្ភចំពោះរឿងគំរាមគំហែងផ្នែកសន្តិសុខ និងលែងនៅឯកោទៀត។
- កម្ពុជាមានសន្តិភាព និងសេរីភាពក្នុងតំបន់ ព្រមទាំងអាចដោះស្រាយបញ្ហារួបរួមជាមួយអាស៊ានជាអាទិភាពបញ្ហាព្រំដែន និងបញ្ហានយោបាយប្រចាំតំបន់ដោយសន្តិវិធី។
- មានការផ្លាស់ប្តូរគ្នាផ្នែកចំណេះដឹងលើផ្នែកសង្គមកិច្ច វប្បធម៌ ព្រមទាំងប្រពៃណីទំនៀមទម្លាប់រវាងសមាជិកអាស៊ានទាំង ១០។
- ការផ្លាស់ប្តូរគ្នាទៅវិញមកផ្នែកធនធានមនុស្ស វិទ្យាសាស្ត្រ និងបច្ចេកទេសថ្មីបន្ថែមទៀត។
- ការផ្លាស់ប្តូរគ្នាទៅវិញទៅមករវាងប្រព័ន្ធសិក្សាធិការ។
- កម្ពុជាបានលេចមុខមាត់នៅលើឆាកអន្តរជាតិ និងមានមុខមាត់ស្មើនឹងប្រទេសក្នុងសមាគមអាស៊ាន និងមានសិទ្ធិធ្វើសហប្រតិបត្តិការរួមគ្នាដោយសមភាព។
- កម្ពុជាទទួលបានផលចំណេញយ៉ាងច្រើនខាងផ្នែកកិច្ចការនយោបាយការបរទេស និងកិច្ចការសេដ្ឋកិច្ច។
- កម្ពុជាបានទទួលផលប្រយោជន៍ពីការអភិវឌ្ឍខាងវិស័យផ្សេងៗទៀតដូចជា កសិកម្ម និងទេសចរណ៍។
- អាស៊ានបានជួយឱ្យកម្ពុជាដើរតួនាទីយ៉ាងសំខាន់ខាងនយោបាយក្នុងតំបន់ និងនៅ លើឆាកអន្តរជាតិ។
- កម្ពុជាទទួលបានកិច្ចសហប្រតិបត្តិការផ្នែកច្បាប់ជាមួយបណ្តាប្រទេសជាសមាជិកអាស៊ានពេញសិទ្ធិ។
- កម្ពុជាទទួលបានការពង្រឹងកិច្ចសហប្រតិបត្តិការតាមរយៈវិស័យការទូត និងផ្នែកការបរទេសជាមួយប្រទេសជាសមាជិកអាស៊ានទាំង១០។

### ១.២.៥.សមាជិកភាពរបស់កម្ពុជាក្នុងអាស៊ាន

កម្ពុជាគឺជាប្រទេសចុងក្រោយគេ ដែលបានក្លាយជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៩។ នេះគឺជាមោទនភាពរបស់កម្ពុជាដែលបានចូលជាផ្នែកមួយនៃសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន។ ចាប់តាំងពីពេលនោះមក អាស៊ានតែងតែជាផ្នែកយ៉ាងសំខាន់មួយនៃគោលនយោបាយការបរទេសរបស់កម្ពុជា។ ដូច្នេះហើយទើបកម្ពុជា តែងតែជាអ្នកចូលរួមគាំទ្រ និងផ្តល់ការស្ថាបនាយ៉ាងសកម្ម ក្នុងដំណើរការកសាងសហគមន៍អាស៊ាន ដើម្បីពង្រីក និងធ្វើឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច នយោបាយ សន្តិសុខ និងសង្គម-វប្បធម៌ ដើម្បីធានាថាអាស៊ានជាសហគមន៍មួយដែលពោរពេញទៅដោយឱកាស ជាសហគមន៍ដែលយកច្បាប់ជាគោល ជាសហគមន៍ដែលមានសមាហរណកម្មពេញលេញ និងជាសហគមន៍ដែលផ្តោតលើប្រជាជន និងដើម្បីប្រជាជន

ដោយគ្មាននរណាម្នាក់ត្រូវបានទុកចោលឡើយ។ ក្នុងរយៈពេលជាង២០ឆ្នាំកន្លងមកនេះ កម្ពុជាបានទទួលផលប្រយោជន៍យ៉ាងច្រើនពីអាស៊ានតាមរយៈផលចំណេញខាងសេដ្ឋកិច្ចពាណិជ្ជកម្ម សន្តិសុខ នយោបាយ ការធ្វើទំនាក់ទំនងអន្តរជាតិ វប្បធម៌ ទេសចរណ៍ និងតាមរយៈការបោះទុនវិនិយោគនៅក្នុងប្រទេសកម្ពុជា នៃបណ្តាប្រទេសដែលស្ថិតនៅក្នុងតំបន់អាស៊ានជាអាទិ៍។ ទាំងអស់នេះ គឺជាផលប្រយោជន៍នៃការចូលជាសមាជិកអាស៊ានរបស់កម្ពុជា ដែលបានធ្វើឱ្យកំណើនសេដ្ឋកិច្ចរបស់កម្ពុជាមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ និងជាពិសេសបានធ្វើឱ្យពិភពលោក ក៏ដូចជាប្រទេសនៅក្នុងតំបន់ទទួលស្គាល់អំពីតួនាទីរបស់កម្ពុជា នៅក្នុងការធ្វើសមាហរណកម្មជាមួយប្រជាជាតិរស់នៅក្នុងតំបន់អាស៊ានទាំងមូលដែលមានសមាជិក ១០ប្រទេស ហើយបានធ្វើការផ្លាស់ប្តូរគ្នានូវបទពិសោធន៍ក្នុងការដឹកនាំ កសាងសេដ្ឋកិច្ច នយោបាយ វប្បធម៌ ទេសចរណ៍។

**គោលបំណងរបស់កម្ពុជាក្នុងការចូលជាសមាជិកអាស៊ាន៖**

- ពង្រីកឱកាសជាអតិបរមា ដើម្បីកសាងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការទាំងក្នុងតំបន់ និងនៅក្រៅតំបន់ ឆ្ពោះទៅរកសន្តិភាព ស្ថិរភាព សន្តិសុខ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា
- ពង្រឹងសមាហរណកម្មក្នុងតំបន់ និងអន្តរជាតិ និងពង្រឹងភាពជាសមាជិកនៃសហគមន៍អន្តរជាតិមួយដែលមានការទទួលខុសត្រូវ
- លើកកម្ពស់ និងពង្រីកការរួមចំណែករបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងតំបន់ និងសកលលោក ព្រមទាំងចូលរួមក្នុងការស្ថាបនាពិភពលោកមួយដែលប្រកបទៅដោយសុខដុមរមនា សន្តិភាព និងវិបុលភាពសម្រាប់ទាំងអស់គ្នា
- លើកកម្ពស់តម្លៃសន្តិភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ តាមរយៈការអនុវត្តប្រកបដោយជោគជ័យនៃនយោបាយឈ្នះ-ឈ្នះរបស់កម្ពុជា និងការចូលរួមយ៉ាងសកម្មជាមួយអង្គការសហប្រជាជាតិ ក្នុងការថែរក្សាសន្តិភាព
- គាំទ្រដល់ដំណើរការនៃការអភិវឌ្ឍដ៏រឹងមាំនៃសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ដើម្បីពន្លឿនសមាហរណកម្មតំបន់ និងកិច្ចខិតខំប្រឹងប្រែងកសាងសហគមន៍អាស៊ាន។

**១.២.៦.តាពជាប្រធានអាស៊ានរបស់កម្ពុជា**

កម្ពុជាបានក្លាយជាប្រធានប្តូរវេនអាស៊ានជាលើកទី៣ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២ បន្ទាប់ពីបានធ្លាប់ធ្វើជាប្រធានប្តូរវេននៃសមាគមនេះចំនួន ២ លើករួចមកហើយ គឺលើកទី១ កាលពីឆ្នាំ២០០២ និងលើកទី២ នាឆ្នាំ២០១២។ ក្នុងអំឡុងពេលធ្វើជាប្រធានអាស៊ានលើកទី១ កម្ពុជាបានសម្រេចបាននូវឯកសារជាប្រវត្តិសាស្ត្រ

របស់អាស៊ាន គឺ«សេចក្តីថ្លែងការណ៍ប្រតិបត្តិរបស់បណ្តាភាគីនៃជម្លោះនៅសមុទ្រចិនខាងត្បូង (Declaration on the Conduct of the Parties in the South China Sea-DOC)» ត្រូវបានចុះហត្ថលេខាដោយរដ្ឋមន្ត្រីការបរទេសរបស់បណ្តាប្រទេសជាសមាជិកអាស៊ាន និងចិន ដែលមានទាំងទិដ្ឋភាពនយោបាយ និងច្បាប់សម្រាប់ការដោះស្រាយបញ្ហានៅសមុទ្រចិនខាងត្បូងដោយសន្តិវិធី។ សម្រាប់ឆ្នាំ២០១២ នៃការធ្វើជាប្រធានអាស៊ានជាលើកទី២ កម្ពុជាបានសម្រេចនូវសមិទ្ធផលជាច្រើនរួមមាន៖

១-សេចក្តីថ្លែងការរួមស្តីពីអាស៊ានគ្មានគ្រឿងញៀន។

២-សេចក្តីថ្លែងការណ៍ស្តីពីសិទ្ធិមនុស្សអាស៊ាន (ASEAN Human Rights Declaration – AHRD)។

៣-ការបង្កើតមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ASEAN Regional Mine Action Center – ARMAC)។

៤-ការចាប់ផ្តើមចរចាស្តីពី «ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (Regional Comprehensive Economic Partnership – RCEP)» ដែលរួមមានប្រទេសអាស៊ានទាំង១០ បូក អូស្ត្រាលី ចិន ឥណ្ឌា ជប៉ុន កូរ៉េខាងត្បូង និងណូវែលហ្សេឡង់។

៥-កិច្ចសន្ទនាជា សកលរបស់អាស៊ាន។

នាពេលកន្លងទៅថ្មីនេះ នាកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ ដែលប្រព្រឹត្តទៅនៅរាជធានីភ្នំពេញ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះជាលើកទី ៣ នេះ ចាប់ពីថ្ងៃទី ៨-១៣ វិច្ឆិកា ឆ្នាំ២០២២ កម្ពុជាបានសម្រេចនូវលទ្ធផល និងសមិទ្ធផលជាច្រើនក្នុងការកសាងសហគមន៍អាស៊ាន ប្រកបដោយសុខសន្តិភាព ទំនើបកម្ម ភាពធន់ និងបរិយាប័ន្ន ក្នុងនោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងនាមជាប្រធានអាស៊ានឆ្នាំ២០២២ បានប្រកាសឱ្យដឹងថា ឯកសារសមិទ្ធផល និងសេចក្តីប្រកាសចំនួន ៧០ ត្រូវបានអនុម័តនិងកត់សម្គាល់ក្នុងកិច្ចប្រជុំកំពូលអាស៊ាន និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ។ លើសពីនេះកម្ពុជាក៏បានចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាក្នុងតំបន់ និងបញ្ហាសកលលោក រួមមានដូចជាបញ្ហាវិបត្តិនៅមីយ៉ាន់ម៉ា បញ្ហាសង្គ្រាមនៅអ៊ុយក្រែន ការកើនឡើងកម្តៅនៅឧបទ្វីបកូរ៉េ និងច្រកសមុទ្រតៃវ៉ាន់ជាអាទិ៍។ កម្ពុជាមានគោលដៅជំរុញសន្ទុះនៃកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសហគមន៍អាស៊ាន និងពង្រីកទំនាក់ទំនងជាមួយដៃគូខាងក្រៅបន្ថែមទៀត ដើម្បីរក្សាសន្តិភាព ស្ថិរភាព និងវិបុលភាពនៅក្នុង និងក្រៅតំបន់។

ការធ្វើជាប្រធានអាស៊ានរបស់កម្ពុជា គឺជាការបន្តធ្វើកិច្ចការងារដែលនៅសេសសល់ពីប្រធានមុនៗ និងសកម្មភាពនានាដែលកំពុងត្រូវបានអនុវត្ត ដើម្បីពង្រឹងការអនុវត្តផែនការសហគមន៍អាស៊ានឆ្នាំ២០២៥ និងការអភិវឌ្ឍចក្ខុវិស័យសហគមន៍អាស៊ាន ក្រោយឆ្នាំ២០២៥ ដើម្បីបង្រួបបង្រួម និងពង្រឹងការកសាងសហគមន៍អាស៊ាន និងសាមគ្គីភាពអាស៊ាន ក៏ដូចជាភាពពាក់ព័ន្ធ និងកិត្យានុភាពរបស់ខ្លួននៅលើឆាកអន្តរជាតិ។

ក្នុងបរិបទនេះ កម្ពុជាបានជ្រើសរើសយកមូលបទ **«អាស៊ានរួមគ្នាធ្វើ ដោះស្រាយបញ្ហាប្រឈមទាំងអស់គ្នា»** សម្រាប់ឆ្នាំ២០២២ ដើម្បីឆ្លុះបញ្ចាំងពីសារៈសំខាន់នៃស្មារតីអាស៊ានក្នុងនាមជាគ្រួសារតែមួយដែលមានសមាជិកចំនួន១០ ដោយឈរលើស្មារតីរឹងមាំនៃ «ភាពទាំងអស់គ្នា» ដើម្បីដោះស្រាយបញ្ហាប្រឈមរួមគ្នា និងសម្រេចនូវគោលដៅរួមគ្នា។

### ១.៣. ប្រវត្តិនៃក្រសួងយុត្តិធម៌ (១៩៨០-២០២២)

នៅពេលដែលប្រទេសកម្ពុជាត្រូវបានរំដោះពីរបបប្រល័យពូជសាសន៍ ប៉ុល ពត (កម្ពុជាប្រជាធិបតេយ្យ) នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ដែលនៅពេលនោះមាន លោក **ហេង សំរិន** ជាប្រធានក្រុមប្រឹក្សារដ្ឋ បានបង្កើតឡើងសាជាថ្មីឡើងវិញនូវបណ្តាក្រសួងស្ថាប័នមួយចំនួន ដើម្បីជាសេនាធិការឱ្យរដ្ឋាភិបាលក្នុងការដឹកនាំប្រទេស។ នៅក្នុងនោះផងដែរ ក្រសួងយុត្តិធម៌ ត្រូវបានបង្កើតឡើងនៅក្នុងខែមិថុនា ឆ្នាំ១៩៨០[7] ដែលនៅពេលនោះក្រសួងត្រូវបានដឹកនាំដោយ សមមិត្ត **អ៊ុក ប៊ុនឈឿន** ជារដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌។

ក្រោយពេលមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស នៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមទទួលនូវសុខសន្តិភាពជាបណ្តើរៗ និងក្រោយពេលមានការបោះឆ្នោតថ្នាក់ជាតិឆ្នាំ១៩៩៣។ របបរាជានិយម «ព្រះរាជាណាចក្រកម្ពុជាទី២» បានចាប់បដិសន្ធិឡើងវិញ តាមរយៈរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ នៅពេលនោះបណ្តាក្រសួងស្ថាប័ននានា ត្រូវបានបង្កើត និងរៀបចំឡើងវិញតាមរយៈព្រះរាជក្រមដែលឡាយព្រះហស្តលេខា ដោយព្រះមហាក្សត្រ។ ជាក់ស្តែងរាជរដ្ឋាភិបាល ក្នុងនីតិកាលទី១ នៃរដ្ឋសភាតាមរយៈសម្តេចសហនាយករដ្ឋមន្ត្រីទាំងពីរបានក្រាបបង្គំទូលថ្វាយ ព្រះប្រមុខរដ្ឋ[8] ដើម្បីស្នើសុំ ព្រះអង្គឡាយព្រះហស្តលេខាលើព្រះរាជក្រមមួយជាការប្រញាប់ ស្តីពីការបង្កើតក្រសួងយុត្តិធម៌។ តាមរយៈព្រះរាជក្រមលេខ **នស/រកម/០១៩៦/0៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦** ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១ ក្រសួងយុត្តិធម៌ នាសម័យព្រះរាជាណាចក្រកម្ពុជាទី២ (របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ) ត្រូវបានបង្កើតសារជាថ្មីឡើងវិញ។ ជាមួយគ្នានោះដែរ ច្បាប់នេះបានប្រគល់អំណាច និងសមត្ថកិច្ចជូនក្រសួងយុត្តិធម៌ដើម្បីដឹកនាំ និងគ្រប់គ្រងវិស័យយុត្តិធម៌ នៅក្នុងដែននីនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។

ឥស្សរជនជាន់ខ្ពស់កាន់តំណែងជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្រោយពេលប្រទេសកម្ពុជាត្រូវបានរំដោះ នាថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រហូតដល់បច្ចុប្បន្ន មានដូចជា៖

- **ឯកឧត្តម អ៊ុក ប៊ុនឈឿន** ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩៣

[7] ពុយគា, រដ្ឋាភិបាលកម្ពុជា ពីឆ្នាំ១៩៤៥ ដល់ឆ្នាំ២០១០ (ភ្នំពេញ ៖ រាហ៍, ២០១០), ទំព័រ១៣០។

[8] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៣ ខែកញ្ញា ឆ្នាំ១៩៩៣, មាត្រា៧ វាក្យខណ្ឌទី២។

- **ឯកឧត្តម ចែម ស្គួន** ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ១៩៩៨[9]
- **ឯកឧត្តម អ៊ុក វិធន់** ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ ២០០១[10]
- **ឯកឧត្តម នាវ ស៊ីថុង** ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីឆ្នាំ២០០១ ដល់ឆ្នាំ ២០០៤[11]
- **ឯកឧត្តម អង្គ វង្សវឌ្ឍានា** ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ ២០២០[12]
- **ឯកឧត្តម កើត រិទ្ធ** ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចាប់ពីឆ្នាំ២០២០ ដល់ បច្ចុប្បន្ន។[13]

## ១.៤. ប្រវត្តិនៃអង្គភាពទទួលបន្ទុកកិច្ចការអាស៊ាន នៃក្រសួងយុត្តិធម៌

### ១.៤.១. នាយកដ្ឋានកិច្ចការអន្តរជាតិ

ចាប់តាំងពីបានបង្កើតក្រសួងយុត្តិធម៌នៅឆ្នាំ១៩៩៦ មក គេត្រូវរង់ចាំរហូតដល់ឆ្នាំ២០០០ ទើបរាជរដ្ឋាភិបាលអាណត្តិទី២ (១៩៩៨-២០០៣) បានចេញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ដំបូងគេ ដែលក្នុងនោះក្រសួងយុត្តិធម៌ត្រូវបានរៀបចំរចនាសម្ព័ន្ធឱ្យមានត្រឹមតែ ខុទ្ទកាល័យ១ អគ្គាធិការដ្ឋាន១ និងនាយកដ្ឋានក្រោមចំណុះចំនួន៦ ប៉ុណ្ណោះ។[14]

នៅក្នុងនាយកដ្ឋានចំនួន៦នោះ មាននាយកដ្ឋានមួយ គឺនាយកដ្ឋានកិច្ចការអន្តរជាតិ ដែលជានាយកដ្ឋានមានតួនាទី និងភារកិច្ចធ្វើជាសេនាធិការឱ្យក្រសួងយុត្តិធម៌លើកិច្ចការងារអន្តរជាតិមួយចំនួនដូចជាៈ

- សម្របសម្រួលកិច្ចការបរទេសទាំងឡាយ ដែលពាក់ព័ន្ធជាមួយនឹងវិស័យយុត្តិធម៌

---

[9] ក្រឹត្យគ្មានលេខស្តីពីការតែងតាំងរដ្ឋាភិបាលបណ្តោះអាសន្ននៃកម្ពុជា ឆ្នាំ១៩៩៣, ២ ខែកក្កដា ឆ្នាំ១៩៩៣, មាត្រា ២, ចំណុច១៧ ក្រសួងយុត្តិធម៌។ ព្រះរាជក្រឹត្យគ្មានលេខស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី១ ឆ្នាំ១៩៩៣-១៩៩៨, ១ ខែវិច្ឆិកា ឆ្នាំ១៩៩៣, មាត្រា ១, ចំណុច ៨ ក្រសួងយុត្តិធម៌។

[10] ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី២ ឆ្នាំ១៩៩៨-២០០៣, លេខ នស/រកត/១១៩៨/៧២, ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨, មាត្រា ២, ចំណុច២២ ក្រសួងយុត្តិធម៌។

[11] ព្រះរាជក្រឹត្យស្តីពីការតែងតាំង និងកែសម្រួលសមាជិករាជរដ្ឋាភិបាល, លេខ នស/រកត/០៨០១/២៨៧, ២៧ ខែសីហា ឆ្នាំ២០០១, មាត្រា ១, ចំណុ៣, ដោយតែងតាំង ឯកឧត្តម នាវ ស៊ីថុង ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួសឯកឧត្តម អ៊ុក វិធុន។

[12] -ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី៣ ឆ្នាំ២០០៣-២០០៨, លេខ នស/រកត/០៧០៤/១២៤, ១៥ ខែកក្កដា ឆ្នាំ២០០៤, មាត្រា ១, ក្រសួង និងស្ថាប័ន ចំណុច១៧ ក្រសួងយុត្តិធម៌។

-ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី៤ ឆ្នាំ២០០៨-២០១៣, លេខ នស/រកត/០៩០៨/១០៥៥, ២៥ ខែកញ្ញា ឆ្នាំ២០០៨, មាត្រា ១, ក្រសួង និងរដ្ឋលេខាធិការ ចំណុច១៧ ក្រសួងយុត្តិធម៌។

-ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី៥ ឆ្នាំ២០១៣-២០១៨, លេខ នស/រកត/០៩១៣/៩០៣, ២៤ ខែកញ្ញា ឆ្នាំ២០១៣, មាត្រា ១, ក្រសួង និងរដ្ឋលេខាធិការ ចំណុច១៧ ក្រសួងយុត្តិធម៌។

-ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី៦ ឆ្នាំ២០១៨-២០២៣, លេខ នស/រកត/០៩១៨/៩២៥, ៦ ខែកញ្ញា ឆ្នាំ២០១៨, មាត្រា ១, រដ្ឋមន្ត្រី ចំណុច១៨ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

[13] ព្រះរាជក្រឹត្យស្តីពីការតែងតាំង និងកែសម្រួលសមាជិករាជរដ្ឋាភិបាល, លេខ នស/រកត/០៣២០/៤២១, ៣០ ខែមីនា ឆ្នាំ២០២០, មាត្រា ១ កែសម្រួល និងតែងតាំងសមាសភាពរដ្ឋមន្ត្រី, ចំណុច ២ ដោយតែងតាំង ឯកឧត្តម កើត រិទ្ធ ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួសឯកឧត្តម អង្គ វង្សវឌ្ឍានា ដែលត្រូវតែងតាំងជាទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)។

[14] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ១៩ អនក្រ.បក, ៧ ខែមេសា ឆ្នាំ២០០០, មាត្រា៤។

- សិក្សាស្រាវជ្រាវច្បាប់អន្តរជាតិពាក់ព័ន្ធវិស័យយុត្តិធម៌
- ធ្វើទំនាក់ទំនងជាមួយបណ្តាប្រទេសនានាលើវិស័យុត្តិធម៌
- ធ្វើទំនាក់ទំនងជាមួយអន្តរជាតិ ក្រសួង និងស្ថាប័ននានាលើវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀន និងលើវិស័យលាងលុយកខ្វក់
- រៀបចំស្ថិតិ និងរបាយការណ៍បូកសរុបកិច្ចការអន្តរជាតិ
- រៀបចំកម្មវិធីសហប្រតិបត្តិការ អនុស្សរណៈ នៃកិច្ចព្រមព្រៀងវិស័យយុត្តិធម៌ជាមួយប្រទេសនានា និងអង្គការអន្តរជាតិលើវិស័យយុត្តិធម៌ និងរៀបចំពិធីការសម្រាប់ថ្នាក់ដឹកនាំក្រសួងជួបជាមួយភ្ញៀវបរទេស
- ទទួលភារកិច្ចផ្សេងៗដែលថ្នាក់ដឹកនាំប្រគល់ជូន។[15]

នាយកដ្ឋានកិច្ចការអន្តរជាតិនេះ មានភារកិច្ចចម្បងដោយឡែកមួយទៀត គឺទទួលបន្ទុកកិច្ចការអាស៊ានលើវិស័យយុត្តិធម៌ តាមរយៈការធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដែលជាសមាជិកអាស៊ានទាំង១០។

**១.៤.២. នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ**

នៅក្នុងឆ្នាំ២០០៧ តាមរយៈរាជរដ្ឋាភិបាលអាណត្តិទី៣ (២០០៣-២០០៨) បានសម្រេចចេញនូវអនុក្រឹត្យស្តីពីរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ជាលើកទី២ ហើយតាមរយៈអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៧ នេះ ក្រសួងយុត្តិធម៌ត្រូវបានដំឡើងរចនាសម្ព័ន្ធឱ្យមានខុទ្ទកាល័យ១ នាយកដ្ឋានសវនកម្មផ្ទៃក្នុង១ និងអគ្គនាយកដ្ឋានចំនួន៤[16] ដែលក្នុងនោះអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ មានតួនាទីជាសេនាធិការឱ្យក្រសួងយុត្តិធម៌ លើការងារសម្របសម្រួលទំនាក់ទំនងអន្តរជាតិ។ ដោយសារតែអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌មានតួនាទីក្នុងការសម្របសម្រួលកិច្ចការទំនាក់ទំនង ទើបតម្រូវឱ្យអគ្គនាយកដ្ឋាននេះមាន នាយកដ្ឋានទំនាក់ទំនងអន្តរជាតិជាចំណុះ ដើម្បីបំពេញភារកិច្ចក្នុងការធ្វើទំនាក់ទំនងអន្តរជាតិនេះ។

តាមរយៈមាត្រា ១៨ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៧ នេះ តម្រូវឱ្យនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ មានតួនាទី ភារកិច្ច ទទួលបន្ទុកដូចជា៖

- សម្របសម្រួលកិច្ចការបរទេសទាំងឡាយ ដែលពាក់ព័ន្ធជាមួយនឹងក្រសួងយុត្តិធម៌
- សម្របសម្រួលជំនួយអន្តរជាតិលើវិស័យយុត្តិធម៌
- ធ្វើទំនាក់ទំនងជាមួយអន្តរជាតិ ក្រសួង ឬស្ថាប័ននានាលើវិស័យភេរវកម្ម ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ការប្រឆាំងនឹងការសំអាតប្រាក់ ការជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន

[15] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ១៩ អនក្រ.បក, ៧ ខែមេសា ឆ្នាំ២០០០, មាត្រា១២។

[16] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ៤៧ អនក្រ.បក, ១៤ ខែឧសភា ឆ្នាំ២០០៧, មាត្រា៤។

- រៀបចំកម្មវិធីសហប្រតិបត្តិការ អនុស្សរណៈ និងកិច្ចព្រមព្រៀងលើវិស័យយុត្តិធម៌ ជាមួយប្រទេសនានា និងអង្គការអន្តរជាតិ
- សម្របសម្រួល និងរៀបចំបេសកកម្មក្រៅប្រទេស របស់ថ្នាក់ដឹកនាំ និងគណៈប្រតិភូរបស់ក្រសួង
- រៀបចំស្ថិតិ និងធ្វើរបាយការណ៍បូកសរុបកិច្ចការអន្តរជាតិ
- ធ្វើរបាយការណ៍សកម្មភាពប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងឆ្នាំ ជូនថ្នាក់ដឹកនាំ
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរដ្ឋមន្ត្រីប្រគល់ជូន។

ដោយមើលឃើញថា នាយកដ្ឋានកិច្ចការអន្តរជាតិ (អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០) មានការផ្លាស់ប្តូរឈ្មោះមកជា នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ (អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៧) ក៏ដោយ ក៏ក្រសួងយុត្តិធម៌តម្រូវឱ្យនាយកដ្ឋាននេះនៅតែទទួលបន្ទុកកិច្ចការអាស៊ានលើវិស័យយុត្តិធម៌ តាមរយៈការធ្វើកិច្ចសហប្រតិបត្តិការ ការផ្តល់ជាព័ត៌មាន ការផ្តល់ឯកសារ ជំនួយបច្ចេកទេស និងការផ្លាស់ប្តូរទស្សនៈគ្នាទៅវិញទៅមកទាក់ទងនឹងវិស័យយុត្តិធម៌ ជាមួយបណ្តាប្រទេសនៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន នេះដដែរ។

**១.៤.៣. នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍**

ចាប់តាំងពីការបង្កើតក្រសួងយុត្តិធម៌ក្នុងឆ្នាំ១៩៩៦ មក នាយកដ្ឋានដែលទទួលបន្ទុកកិច្ចការទំនាក់ទំនងអន្តរជាតិនៃក្រសួងយុត្តិធម៌នេះបានផ្លាស់ប្តូរឈ្មោះ និងកែសម្រួលតួនាទី ភារកិច្ច ចំនួន ៣ លើករួចមកហើយ ដូចតទៅ៖

តាមរយៈអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ដែលជាអនុក្រឹត្យដំបូងគេដែលក្រសួងយុត្តិធម៌បង្កើតឱ្យមានអង្គភាពក្រោមចំណុះដែលទទួលភារកិច្ចទំនាក់ទំនងអន្តរជាតិ នោះគឺនាយកដ្ឋានកិច្ចការអន្តរជាតិ ហើយក្រៅពីកិច្ចការអន្តរជាតិ នាយកដ្ឋាននេះក៏ទទួលបន្ទុកកិច្ចការអាស៊ានផងដែរ។

តាមរយៈអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ក្រសួងយុត្តិធម៌ចាប់ផ្តើមបង្កើតឱ្យមានអគ្គនាយកដ្ឋាន ហើយក្នុងអគ្គនាយកដ្ឋាននោះក៏នៅមាននាយកដ្ឋានជាច្រើនក្រោមចំណុះផងដែរ។ តាមរយៈអនុក្រឹត្យនេះ អគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ជាសេនាធិការដែលមានបន្ទុកក្នុងកិច្ចការទំនាក់ទំនងអន្តរជាតិនេះ ហើយអគ្គនាយកដ្ឋាននេះក៏នៅមាននាយកដ្ឋានក្រោមចំណុះមួយដែលមានភារកិច្ចផ្ទាល់ក្នុងរឿងទំនាក់ទំនងអន្តរជាតិនេះ នោះគឺនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ។ ទោះអនុក្រឹត្យថ្មីឆ្នាំ២០០៧ បានផ្លាស់ប្តូរឈ្មោះនាយកដ្ឋាននេះ ពីនាយកដ្ឋានកិច្ចការអន្តរជាតិ ទៅនាយកដ្ឋានទំនាក់ទំនងអន្តរជាតិក៏ដោយ ក៏នាយកដ្ឋាននេះនៅតែជាអ្នកទទួលបន្ទុកកិច្ចការអាស៊ានដដែរ។

តាមរយៈអនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ក្រសួងយុត្តិធម៌ចាប់ផ្តើមផ្លាស់ប្តូរមុខមាត់ថ្មីដោយមាន ខុទ្ទកាល័យ១ នាយកដ្ឋានសវនកម្មផ្ទៃក្នុង១ និងអគ្គនាយកដ្ឋានចំនួន៦[17] (ការបង្កើតអគ្គនាយកដ្ឋានថែមចំនួន២ទៀត បើធៀបទៅនឹងអនុក្រឹត្យឆ្នាំ២០០៧)។ មិនតែប៉ុណ្ណោះក្រសួងយុត្តិធម៌ក៏បានផ្លាស់ប្តូរឈ្មោះ អគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌ ទៅជាអគ្គនាយកដ្ឋានអភិវឌ្ឍន៍វិស័យយុត្តិធម៌តែម្តង ហើយអគ្គនាយកដ្ឋាននេះមាននាយកដ្ឋានចំនួនប្រាំមួយ[18] នៅក្រោមចំណុះរបស់ខ្លួន ដែលក្នុងនោះនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ មានមុខងារ ភារកិច្ចក្នុងកិច្ចការទំនាក់ទំនងអន្តរជាតិ និងជាមួយដៃគូអភិវឌ្ឍន៍លើវិស័យយុត្តិធម៌។

នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូរអភិវឌ្ឍន៍ មានតួនាទី និងត្រូវទទួលបន្ទុកលើការងារដែលមានដូចជា៖

- សម្របសម្រួលកិច្ចការបរទេសដែលពាក់ព័ន្ធនឹងក្រសួងយុត្តិធម៌
- ធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ លើវិស័យយុត្តិធម៌
- ធ្វើទំនាក់ទំនងជាមួយបណ្តាប្រទេសនានាលើវិស័យយុត្តិធម៌
- សម្របសម្រួល ស្វែងរក និងគ្រប់គ្រងជំនួយជាតិ និងអន្តរជាតិ ដើម្បីអភិវឌ្ឍន៍វិស័យយុត្តិធម៌
- សិក្សាប្រមូលផ្តុំតម្រូវការចាំបាច់ និងធ្វើផែនការអភិវឌ្ឍន៍វិស័យយុត្តិធម៌ ដើម្បីស្នើសុំជំនួយជាតិ និងអន្តរជាតិ
- រៀបចំកម្មវិធីសហប្រតិបត្តិការ អនុស្សរណៈ និងកិច្ចព្រមព្រៀងលើវិស័យយុត្តិធម៌ជាមួយប្រទេសនានា និងអង្គការអន្តរជាតិ
- សហការ សម្របសម្រួល ការបកប្រែភាសាលើសំណើសុំសេវាកម្មឯកសារពាក់ព័ន្ធ និងជំនួយផ្នែកច្បាប់ និងសេចក្តីព្រាងសន្ធិសញ្ញាអន្តរជាតិ
- សម្របសម្រួល និងរៀបចំបេសកកម្មក្រៅប្រទេស របស់ថ្នាក់ដឹកនាំ និងគណៈប្រតិភូរបស់ក្រសួង
- ទទួល និងផ្តល់ការបញ្ជាក់នីត្យានុកូលភាពលើឯកសារភាសាបរទេសថតចម្លង
- រៀបចំស្ថិតិ និងធ្វើរបាយការណ៍បូកសរុបកិច្ចការអន្តរជាតិ
- ធ្វើរបាយការណ៍សកម្មភាពការងារ ប្រចាំខែ ត្រីមាស ឆមាស ០៩ខែ និងប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ
- បំពេញភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីប្រគល់ឱ្យ។[19]

[17] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ២៤០ អនក្រ.បក, ១៩ ខែសីហា ឆ្នាំ២០១៤, មាត្រា៦។

[18] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ២៤០ អនក្រ.បក, ១៩ ខែសីហា ឆ្នាំ២០១៤ មាត្រា៣៣។

[19] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ២៤០ អនក្រ.បក, ១៩ ខែសីហា ឆ្នាំ២០១៤, មាត្រា៣៤។

ទោះបីជាប្រែមុខមាត់ថ្មីពីនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ (អនុក្រឹត្យឆ្នាំ២០០៧) ទៅនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ (អនុក្រឹត្យឆ្នាំ២០១៤) ក៏ដោយ ក៏នាយកដ្ឋាននេះនៅតែមានភារកិច្ចក្នុងការងារសម្របសម្រួលកិច្ចការអាស៊ានដដែរ ហើយមិនតែប៉ុណ្ណោះនាយកដ្ឋាននេះក៏បានបង្កើតឱ្យមាននូវការិយាល័យមួយមានឈ្មោះថា ការិយាល័យកិច្ចការអាស៊ានផងដែរ។

នៅពេលនោះកិច្ចការងារជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក៏ឈានជើងចូលមកក្រសួងយុត្តិធម៌ជាបណ្តើរហើយ[20] តែចំពោះកិច្ចការងារជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសជាសមាជិកអាស៊ាននោះ គឺមិនមែនជាភារកិច្ចរបស់ការិយាល័យកិច្ចការអាស៊ាននៃនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នោះទេ គឺក្រសួងយុត្តិធម៌បានផ្តល់អំណាចឱ្យនាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងបត្យាប័ន នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ជាអង្គភាពទទួលបន្ទុកផ្ទាល់លើរឿងនេះ។

**១.៤.៤. នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន**

តាមរយៈអនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ ដោយតាមរយៈអនុក្រឹត្យនេះក្រសួងយុត្តិធម៌បានប្រែមុខមាត់ ក៏ដូចជារចនាសម្ព័ន្ធរបស់ខ្លួនសារជាថ្មីម្តងទៀត គឺមានខុទ្ទកាល័យរដ្ឋមន្ត្រីចំនួន១ អគ្គនាយកដ្ឋានចំនួន៧ នាយកដ្ឋានសវនកម្មផ្ទៃក្នុងចំនួន១ និងអង្គភាពព័ត៌មានចំនួន១។[21] តាមរយៈអនុក្រឹត្យថ្មីនេះផងដែរ អគ្គនាយកដ្ឋានអភិវឌ្ឍន៍វិស័យយុត្តិធម៌ក៏បានប្តូរឈ្មោះទៅជា អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ ហើយបានបំបែកនាយកដ្ឋានដែលទទួលបន្ទុកក្នុងកិច្ចការងារទំនាក់ទំនងអន្តរជាតិ និងអាស៊ានជាពីរ ដាច់ដោយឡែកពីគ្នា គឺនាយកដ្ឋានដែលទទួលបន្ទុកការងារទំនាក់ទំនងអន្តរជាតិ បានផ្តល់អំណាចឱ្យទៅលើ នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការផ្នែកច្បាប់[22] ហើយនាយកដ្ឋានដែលទទួលបន្ទុកខាងការងារអាស៊ាន បានផ្តល់អំណាចឱ្យទៅលើនាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន។[23]

តាមរយៈព្រះរាជក្រមលេខ នស/រកម/០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌នេះ ក្រសួងយុត្តិធម៌បានលុប

[20] ទោះបីជាព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាននេះ តាមរយៈព្រះរាជក្រមលេខ នស/រកម/០១១០/០០១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០ ហើយក៏ដោយ។

[21] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ១៣០ អនក្រ.បក, ១ ខែកក្កដា ឆ្នាំ២០២២, មាត្រា៣៤។

[22] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ២៤០ អនក្រ.បក, ១៩ ខែសីហា ឆ្នាំ២០១៤, មាត្រា៣៧។

[23] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ២៤០ អនក្រ.បក, ១៩ ខែសីហា ឆ្នាំ២០១៤, មាត្រា៣៨។

ចោលនូវនាយកដ្ឋានជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ និងបត្យាប័ន នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនេះចោល ហើយបានផ្ទេរអំណាច និងភារកិច្ចក្នុងកិច្ចការងារជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសជាសមាជិកអាស៊ាន ទៅនាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន[24] ហើយចំពោះកិច្ចការងារជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាមួយប្រទេសក្រៅតំបន់អាស៊ាន គឺជាសមត្ថកិច្ចរបស់នាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការផ្នែកច្បាប់[25] នៃអគ្គនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ ជាអ្នករ៉ាប់រងដោយផ្ទាល់។

## ២. សញ្ញាណទូទៅនៃសំណុំរឿងជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

### ២.១. គោលបំណង វិសាលភាព និយមន័យ

#### ២.១.១. គោលបំណង

គោលបំណងនៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ គឺជាការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជានិងរដ្ឋបរទេស ទាក់ទងនឹងដំណើរការនីតិវិធីនានាពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងការបង្កក ការចាប់យក និងការរឹបអូសទ្រព្យ ក្នុងគោលបំណងដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការអន្តរជាតិ[26] ជាអាទិ៍។

#### ២.១.២. វិសាលភាព

យោងតាមសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន ឆ្នាំ២០០៤ បណ្តាភាគីនៅក្នុងទ្រង់ទ្រាយដ៏ធំបំផុតដែលអាចធ្វើបាន ត្រូវផ្តល់នូវវិធាននៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដូចជា ការស៊ើបអង្កេត ការចោទប្រកាន់ និងដំណើរការរឿងក្តី។ សន្ធិសញ្ញានេះ អនុវត្តចំពោះតែការផ្តល់ជំនួយទៅវិញទៅមក នៅក្នុងចំណោមបណ្តាភាគីតែប៉ុណ្ណោះ។ បទប្បញ្ញត្តិនៃសន្ធិសញ្ញានេះ មិនបង្កើតសិទ្ធិណាមួយដល់បុគ្គលឯកជន ដើម្បីទទួលបាន រារាំង ឬទាត់ចោល នូវភស្តុតាង ឬដើម្បីបង្អាក់ដល់ការអនុវត្តសំណើសុំជំនួយឡើយ។[27]

---

[24] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននានា នៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌, លេខ ១២៧ កយ.ប្រក/២២, ២៩ ខែសីហា ឆ្នាំ២០២២, ប្រការ៥, ចំណុច៣ ការិយាល័យសហប្រតិបត្តិការផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

[25] ប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននានា នៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌, លេខ ១២៧ កយ.ប្រក/២២, ២៩ ខែសីហា ឆ្នាំ២០២២, ប្រការ៤ ចំណុច២ ការិយាល័យជំនួយទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ។

[26] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១។

[27] សន្ធិសញ្ញា ស្តីពីជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, គ្មានលេខ, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១ ចំណុចទី១ និង៣។

បើយោងតាមច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២០ ការធ្វើសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ មានវិសាលភាពអនុវត្តចំពោះ៖

- ការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដែលត្រូវផ្តល់ដល់រដ្ឋធ្វើសំណើទាំងអស់ ទោះបីរដ្ឋធ្វើសំណើនោះមិនមានកិច្ចព្រមព្រៀងជាមួយនឹងព្រះរាជាណាចក្រកម្ពុជាក៏ដោយ
- ការស្វែងរកការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីរដ្ឋទទួលសំណើទាំងអស់ ទោះបីរដ្ឋទទួលសំណើនោះមិនមានកិច្ចព្រមព្រៀងជាមួយនឹងព្រះរាជាណាចក្រកម្ពុជាក៏ដោយ។

វិសាលភាពនេះមិនមានការអនុវត្តចំពោះ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដែលធ្វើឡើងស្របតាមសន្ធិសញ្ញាទ្វេភាគីឬពហុភាគី ឬអនុសញ្ញា ដែលទទួលបានសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជា។

នីតិវិធីផ្ទៃក្នុងសម្រាប់អនុវត្តសំណើជួយគ្នាទៅវិញទៅមកដែលមានចែងក្នុងច្បាប់នេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ករណីទាំងអស់នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដោយរួមបញ្ចូលទាំងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដែលធ្វើឡើងស្របតាមសន្ធិសញ្ញាទ្វេភាគី ឬពហុភាគី ឬអនុសញ្ញាដែលបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជាផង លើកលែងតែមានបញ្ញត្តិផ្ទុយដែលមានចែងជាក់លាក់ក្នុងសន្ធិសញ្ញា ឬអនុសញ្ញានោះ ឬច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។

វិសាលភាពនេះក៏មិនរារាំងដល់ការធ្វើសំណើ ឬទទួលសំណើទាក់ទងនឹងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ឬកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជាជាមួយរដ្ឋបរទេសណាមួយតាមរយៈមធ្យោបាយស្របច្បាប់ផ្សេងទៀតឡើយ។[28]

### ២.១.៣. និយមន័យ

និយមន័យនៅទីនេះ គឺសំដៅទៅលើន័យរបស់ពាក្យដែលត្រូវយកមកប្រើក្នុងការធ្វើសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលមានដូចជា៖

១. **ការជួយផ្នែកច្បាប់** ៖

❖ នៅក្នុងសន្ធិសញ្ញា[29] ជំនួយទៅវិញទៅមក ដែលត្រូវផ្តល់រួមមាន ៖

- ការទទួលយកភស្តុតាង ឬ កំណត់ហេតុយកចម្លើយដោយស្ម័គ្រចិត្តពីជនណាមួយ
- ការរៀបចំឱ្យជនណាមួយ ផ្តល់ភស្តុតាង ឬជួយនៅក្នុងវិស័យព្រហ្មទណ្ឌ
- ការចាត់ចែងសេវាឯកសារតុលាការ

[28] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២។

[29] សន្ធិសញ្ញា ស្តីពីជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, គ្មានលេខ, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១ ចំណុចទី២។

- ការអនុវត្តការឆែកឆេរ និងការរឹបអូស
- ការពិនិត្យលើវត្ថុ និងទីកន្លែង
- ការផ្ដល់ឯកសារ របាយការណ៍ ច្បាប់ដើម ឬច្បាប់ចម្លងដែលមានបញ្ជាក់ថាត្រឹមត្រូវ និងវត្ថុតាងពាក់ព័ន្ធ
- ការកំណត់អត្តសញ្ញាណ ឬតាមដានទ្រព្យសម្បត្តិទទួលបានមកពីការប្រព្រឹត្តបទល្មើស និងមធ្យោបាយនៃបទល្មើស
- ការរឹតត្បិតលើ ការលក់ដូរទ្រព្យសម្បត្តិ ឬការបង្កកផ្អឹបទុកទ្រព្យសម្បត្តិ ដែលទទួលបានមកពីការប្រព្រឹត្តបទល្មើស ដែលអាចត្រូវយកមកវិញ រឹបអូស ឬដកហូត
- ការយកមកវិញ ការរឹបអូស ឬការដកហូតទ្រព្យសម្បត្តិដែលទទួលបានមកពី ការប្រព្រឹត្តបទល្មើស
- កំណត់ទីតាំង និងកំណត់អត្តសញ្ញាណសាក្សី និងជនសង្ស័យ និង
- ការផ្ដល់ជំនួយបែបនេះផ្សេងដទៃទៀត បើមានការព្រមព្រៀងគ្នា និងស្របទៅនឹងវត្ថុបំណងរបស់សន្ធិសញ្ញានេះ និងច្បាប់របស់ភាគីទទួលសំណើ។

❖ នៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា[30] ការជួយផ្នែកច្បាប់ សំដៅដល់ការជួយគ្នាក្នុងវិស័យព្រហ្មទណ្ឌដែលរួមមានជាអាទិ៍៖

- ការប្រមូលភស្តុតាង ឬការស្ដាប់ចម្លើយសាក្សី
- ការឆែកឆេរ និងការចាប់យក
- ការផ្ដល់ភស្តុតាងនៅចំពោះមុខតុលាការ
- ការផ្ដល់ព័ត៌មានដែលគ្រប់គ្រងដោយព្រះរាជាណាចក្រកម្ពុជា
- ការចាត់ចែងសេវាកម្មឯកសារតុលាការ
- ការផ្ទេរបុគ្គលជាប់ឃុំដើម្បីផ្ដល់ភស្តុតាង
- ការកំណត់ទីតាំងរបស់បុគ្គលណាមួយ
- ការចាត់វិធានការលើសំណើទាក់ទងនឹងការបង្កក ការចាប់យក ឬការរឹបអូសទ្រព្យសម្បត្តិ និង
- ការរឹបអូសសម្ភារៈភស្តុតាងពីស្ថាប័នហិរញ្ញវត្ថុ។

២. **ការស៊ើបអង្កេត** សំដៅដល់ការស្រាវជ្រាវ ការស៊ើបអង្កេត និងការស៊ើបសួរក្នុងរឿងព្រហ្មទណ្ឌ។

៣. **ផលនៃបទល្មើស** សំដៅដល់ទ្រព្យណាដែលបាន ឬទទួលដោយផ្ទាល់ ឬដោយប្រយោល តាមរយៈការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។

[30] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣ ចំណុចទី១។

៤. **ទ្រព្យសម្បត្តិ** សំដៅដល់៖

- ទ្រព្យសម្បត្តិគ្រប់ប្រភេទរួមមានជាអាទិ៍ ចលនទ្រព្យ ឬអចលនទ្រព្យ ទ្រព្យរូបិយ ឬទ្រព្យអរូបិយ និងឯកសារ ឬ ឧបករណ៍គតិយុត្តដែលជាភស្តុតាងនៃកម្មសិទ្ធិ ឬអត្ថប្រយោជន៍លើទ្រព្យទាំងនេះ
- ទ្រព្យដែលរួមបញ្ចូលឧបករណ៍និងផលដែលបានមកពីការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងបទល្មើសធ្ងន់ធ្ងរផ្សេងៗ និង
- ទ្រព្យដែលរួមបញ្ចូលទ្រព្យជំនួសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានតម្លៃស្មើនឹងទ្រព្យដែលជាកម្មវត្ថុនៃការបង្កក ការឃាត់ទុក និងការរឹបអូស។

៥. **នីតិវិធីផ្ទៃក្នុង** សំដៅដល់នីតិវិធីសម្រាប់អនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាចំពោះសំណើជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

៦. **រដ្ឋទទួលសំណើ** សំដៅដល់រដ្ឋបរទេសដែលទទួលបានសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីព្រះរាជាណាចក្រកម្ពុជា។

៧. **រដ្ឋផ្ញើសំណើ** សំដៅដល់រដ្ឋបរទេសដែលស្វែងរកការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីព្រះរាជាណាចក្រកម្ពុជា។

៨. **វិស័យព្រហ្មទណ្ឌ** សំដៅដល់៖

- បទល្មើសព្រហ្មទណ្ឌ ឬ
- ការកំណត់អំពីផលនៃបទល្មើស ឬឧបករណ៍មធ្យោបាយប្រព្រឹត្តបទល្មើស ឬទ្រព្យភេរវករ ឬ
- សេចក្តីសម្រេចរឹបអូសដែលអាចអនុវត្តបាន ឬ
- ការបង្កក ឬការចាប់យកផលនៃបទល្មើស ឬឧបករណ៍មធ្យោបាយប្រព្រឹត្តបទល្មើស ឬទ្រព្យភេរវករ។

៩. **ឧបករណ៍មធ្យោបាយប្រព្រឹត្តបទល្មើស** សំដៅដល់ទ្រព្យដែលត្រូវបានប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬការប៉ុនប៉ងយកទៅប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស។[31]

១០. **ការសម្អាតប្រាក់** សំដៅដល់៖

- ការបំប្លែងឬការផ្ទេរទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើស ក្នុងគោលបំណងបិទបាំង ឬក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឱ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន។

[31] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣។

- ការបិទបាំង ឬការក្លែងសភាវៈពិត ប្រភព ទីតាំង សិទ្ធិចាត់ចែង ចលនា ឬកម្មសិទ្ធិ ឬសិទ្ធលើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនោះបានមកពីបទល្មើស។
- ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិទាំងនេះបានមកពីបទល្មើស។
- ការចូលរួម ការប៉ុនប៉ងប្រព្រឹត្ត ដោយជួយនិងជំរុញឱ្យប្រព្រឹត្តសកម្មភាពណាមួយដែលបានកំណត់ស្របតាមកថាខណ្ឌទី១ នៃមាត្រា៣ នៃច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២០។

១១. **ហិរញ្ញប្បទានភេរវកម្ម** សំដៅដល់ការផ្តល់ឬការប្រមូលដោយចេតនានូវទ្រព្យសម្បត្តិ មូលនិធិ ឬសេវាផ្សេងៗក្នុងបំណងប្រើប្រាស់ ឬដោយដឹងថាទ្រព្យសម្បត្តិ មូលនិធិ ឬសេវានេះនឹងត្រូវបាន ឬអាចប្រើប្រាស់ទាំងមូល ឬមួយផ្នែកសម្រាប់គាំទ្រវាល់សកម្មភាពជាអាទិ៍ ការធ្វើដំណើរ ការបណ្តុះបណ្តាល ការរៀបចំ ការចូលរួម ឬការប្រព្រឹត្តអំពើភេរវកម្ម របស់ភេរវករ ឬអង្គការចាត់តាំងរបស់ភេរវកម្ម។

១២. **ការបង្កកទ្រព្យសម្បត្តិ** សំដៅដល់ការទប់ស្កាត់ការលក់ ការផ្តត់ផ្គង់ ភតិសន្យា ការផ្ទេរ ការបំប្លែង ការធ្វើមត៌កឬអនុប្បទាន ការចល័ត ឬការប្រើប្រាស់ទ្រព្យ។

## ២.២. កិច្ចប្រជុំពាក់ព័ន្ធនឹងសំណុំរឿង MLA

### ២.២.១. កិច្ចប្រជុំពាក់ព័ន្ធនឹង ASEAN - MLAT

ដំបូងឡើយនៅក្នុងឆ្នាំ២០០៤ រដ្ឋាភិបាលនៃបណ្តាប្រទេស ប្រ៊ុយណេដារ៉ូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម មានបំណងដើម្បីកែលំអប្រសិទ្ធភាពរបស់អាជ្ញាធរអនុវត្តច្បាប់នៃបណ្តារដ្ឋភាគី ក្នុងការទប់ស្កាត់ការស៊ើបអង្កេត និងការចោទប្រកាន់បទល្មើស តាមរយៈកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលជាហេតុធ្វើឱ្យបណ្តារដ្ឋភាគីទាំងនេះបានព្រមព្រៀងគ្នាលើទម្រង់ និងខ្លឹមសារ ដើម្បីបង្កើតសន្ធិសញ្ញាមួយ ដែលគេឱ្យឈ្មោះថា សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

បន្ទាប់ពីរដ្ឋសមាជិកអាស៊ានបានបើកកិច្ចប្រជុំពិនិត្យ និងអនុម័តលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៅឆ្នាំ២០០៤ មក រដ្ឋសមាជិកអាស៊ានទាំងអស់បានព្រមព្រៀងគ្នាសម្រេចបើកកិច្ចប្រជុំពាក់ព័ន្ធនឹង សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ (MLAT) ដើម្បីបូកសរុបការងារ និងលទ្ធផលនៃសំណុំរឿង MLA ក៏ដូចជាដាក់ចេញនូវយុទ្ធសាស្ត្រថ្មីដើម្បីដោះស្រាយវិបត្តិ ឬបញ្ហានានា ដែលបណ្តាលឱ្យរាំងស្ទះទៅដល់ដំណើរការនៃការអនុវត្តនៃសំណុំរឿង MLA នេះ។

បន្ទាប់ពីបង្កើតសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នេះរួចមក តាមរយៈមាត្រា ៤ នៃសន្ធិសញ្ញានេះតម្រូវឱ្យបង្កើតអាជ្ញាធរកណ្តាលមួយដើម្បីសម្របសម្រួលក្នុងសំណុំរឿង MLA មួយនេះ។ ជាមួយគ្នានេះដែរ ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាមួយនេះ កាលពីឆ្នាំ២០១០ ហើយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏បានចាត់តាំង «ក្រសួងយុត្តិធម៌» ដើម្បីធ្វើជាស្ថាប័នអាជ្ញាធរ កណ្តាលដើម្បីសម្របសម្រួលកិច្ចការងារ MLA មួយនេះ កាលពីឆ្នាំ២០១១ រហូតដល់ឆ្នាំ២០១៧ ទើបក្រសួងយុត្តិធម៌បានសម្រេចផ្លាស់ប្តូរសមាសភាព ហើយបន្ថែមតួនាទី និងភារកិច្ច ទៅលើអាជ្ញាធរកណ្តាលមួយនេះថែមទៀត។ គោលបំណងនៃការតែងតាំងអាជ្ញាធរកណ្តាលនេះ ក្រៅពីសម្របសម្រួលក្នុងការងារ MLA គឺដើម្បីឱ្យចូលរួមកិច្ចប្រជុំ MLAT ក្នុងតំបន់អាស៊ានផងដែរ។ កិច្ចប្រជុំ MLAT នេះមានចំនួន ២ គឺកិច្ចប្រជុំរដ្ឋមន្ត្រីអាជ្ញាធរកណ្តាលអាស៊ានស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ (AMAG-MLAT) និងកិច្ចប្រជុំឧត្តមមន្ត្រីអាជ្ញាធរកណ្តាលស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ (SOM-MLAT) ដើម្បីជួយសម្រួលដល់កិច្ចប្រជុំ AMAG-MLAT។

កាលពីឆ្នាំ២០១៨ នៅក្នុងជំនួបនៃកិច្ចប្រជុំ SOM-MLAT លើកទី៨ (8th SOM-MLAT) នៅទីក្រុងហាណូយ (Ha Noi) នៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានសម្រេចប្តូរឈ្មោះកិច្ចប្រជុំ AG's MLAT ពី «**កិច្ចប្រជុំរដ្ឋមន្ត្រីយុត្តិធម៌ និងរដ្ឋមន្ត្រីច្បាប់ ស្តីពីសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ** (Attorneys-General/Ministers of Justice and Minister of Law on Treaty on Mutual Legal Assistance in Criminal Matters-AG's MLAT)» ទៅជា «**កិច្ចប្រជុំរដ្ឋមន្ត្រីនៃអាជ្ញាធរកណ្តាលអាស៊ានស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ** (ASEAN Ministers/Attorneys General Meeting of the Central Authorities on Mutual Legal Assistance in Criminal Matters-AMAG-MLAT)[32]» និងប្តូរឈ្មោះកិច្ចប្រជុំ SOM-MLAT ពី «**កិច្ចប្រជុំឧត្តមមន្ត្រីនៃសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ** (The Senior Official Meeting on the Treaty on Mutual Legal Assistance in Criminal Matters)» ទៅជា «**កិច្ចប្រជុំឧត្តមមន្ត្រីនៃអាជ្ញាធរកណ្តាលស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ** (The Senior Officials' of the Central Authorities Meeting on Mutual Legal Assistance in Criminal Matters)»។[33] ហើយជាមួយគ្នានេះដែរ នៅក្នុងកិច្ចប្រជុំ SOM-MLAT លើកទី៨ នេះ បានសម្រេចឱ្យមានការកិច្ចប្រជុំ SOM-MLAT នេះ រៀងរាល់ពីរឆ្នាំមួយដង។[34]

---

[32] ធម្មនុញ្ញអាស៊ាន, ខែវិច្ឆិកា ឆ្នាំ២០២០, ចំណុច ៥ ឧបសម្ព័ន្ធទី១។

[33] ធម្មនុញ្ញអាស៊ាន, ខែវិច្ឆិកា ឆ្នាំ២០២០, ចំណុច ៥ ឧបសម្ព័ន្ធទី១។

[34] របាយការណ៍កិច្ចប្រជុំ SOM-MLAT លើកទី៩ នៅទីក្រុងយូយ៉ាកាតា នៃសាធារណរដ្ឋឥណ្ឌូនេស៊ី, ២៣ មេសា ២០១៩។

ហើយនៅឆ្នាំ២០១៩ នៅក្នុងកិច្ចប្រជុំ SOM-MLAT លើកទី៩ (9th SOM-MLAT) នៅទីក្រុងយូយ៉ាកាតា (Yogyakarta) នៃសាធារណរដ្ឋឥណ្ឌូនេស៊ី បានសម្រេចដាក់បញ្ចូលកិច្ចប្រជុំ AMAG-MLAT និង SOM-MLAT នេះ ទៅក្នុងឧបសម្ព័ន្ធទី១ នៃធម្មនុញ្ញអាស៊ាន។[35]

**២.២.២. បណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍** SEAJust-Network

នាពេលថ្មីៗនេះ ប្រទេសនៅក្នុងអាស៊ានក៏រួមគ្នាបានបង្កើតឱ្យមានបណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍ (SEAJust-Network) មួយឡើង ដើម្បីសម្របសម្រួលបន្ថែមទៀតទៅលើការធ្វើ MLA មួយនេះ ដែល SEAJust នេះ ជាបណ្តាញថ្មីមួយដែលអាចទាក់ទងគ្នាបានយ៉ាងឆាប់រហ័សជាងផ្លូវទូត ព្រោះថាយើងអាចបញ្ជូនសំណើសុំ MLA នេះ ទៅរដ្ឋទទួលសំណើបានមុនពេលដែលលិខិតផ្លូវការបានទៅដល់រដ្ឋទទួលសំណើនោះ ហើយយើងក៏អាចទាក់ទងគ្នាដើម្បីពិភាក្សា ផ្លាស់ប្តូរយោបល់ ឬដោះស្រាយបញ្ហារួមគ្នាជាមួយនឹងរដ្ឋធ្វើសំណើ និងរដ្ឋទទួលសំណើ ដើម្បីសម្រួលដល់ការធ្វើ MLA នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ឱ្យមានភាពប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។

បណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍ ត្រូវបានបង្កើតឡើងក្នុងខែមីនា ឆ្នាំ២០២០។ បណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍ ហៅកាត់ជាភាសាអង់គ្លេសថា (SEAJust) គឺជាបណ្តាញកិច្ចសហប្រតិបត្តិការផ្នែកតុលាការដែលគាំទ្រដោយ UNODC (United Nations Office on Drugs and Crime) ដែលបម្រើជាវេទិកាក្រៅផ្លូវការដែលសម្របសម្រួលទំនាក់ទំនងផ្ទាល់ និងការទំនាក់ទំនងរវាងអាជ្ញាធរកណ្តាលសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងរឿងព្រហ្មទណ្ឌ។ សមាជិកភាពនៃបណ្តាញនេះត្រូវបានសម្ពោធជាដំបូងដោយបានចាប់ផ្តើមជាមួយនឹងប្រទេសចំនួន ៨ មកពីក្នុងតំបន់ ហើយបច្ចុប្បន្ននេះត្រូវបានពង្រីករហូតទៅដល់ ១៤ ប្រទេសនៅទូទាំងតំបន់ និងលើសពីនេះទៅទៀត។ បច្ចុប្បន្ននេះសមាជិកនៃបណ្តាញនេះត្រូវបានតំណាងដោយការទំនាក់ទំនងគ្នាដែលត្រូវបានតែងតាំងដោយជាតិមកពីប្រទេសដូចជា៖ អូស្ត្រាលី ប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ម៉ាឡេស៊ី ម៉ាល់ឌីវ សហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋកូរ៉េ រូម៉ានី សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ ទីម័រខាងកើត និងសាធារណរដ្ឋសង្គមនិយមវៀតណាម។

ចាប់តាំងពីការបង្កើតឡើងមក បណ្តាញនេះបានរៀបចំការប្រជុំបានជាច្រើនលើករួចមកហើយ ទោះបីជាក្នុងទម្រង់ជានិម្មិតក៏ដោយ ក្នុងគោលបំណងដើម្បីពិភាក្សាអំពីបញ្ហាជាច្រើន រួមមានទាំងបញ្ហាសមាជិកភាព និងបញ្ហាសំខាន់ៗជាច្រើនទៀតដែលទាក់ទងទៅនឹងផលប្រយោជន៍រួមរបស់សមាជិក។

[35] របៀបវារៈទី៥ នៃកិច្ចប្រជុំ SOM-MLAT លើកទី៩ នៅសណ្ឋាគារ Royal Ambarrukmo ក្នុងទីក្រុងយូយ៉ាកាតា នៃសាធារណរដ្ឋឥណ្ឌូនេស៊ី កាលពីថ្ងៃ២៣ ខែមេសា ឆ្នាំ២០១៩។

ជាមួយនឹងការធូរស្រាលនៃការរាតត្បាតនៃជម្ងឺកូវីដ-១៩ នៅក្នុងឆ្នាំ២០២៣ នេះ តាមរយៈការគាំទ្រពីក្រសួងយុត្តិធម៌នៃសាធារណរដ្ឋកូរ៉េ ដែលបានបង្ហាញការគាំទ្រជាបន្តបន្ទាប់ និងប្តេជ្ញាចិត្តចំពោះបណ្តាញ SEAJust។ បណ្តាញនេះបានរៀបចំកិច្ចប្រជុំពេញអង្គលើកដំបូងរបស់ខ្លួនចាប់ពីថ្ងៃទី២៦-២៨ ខែមេសា នៅទីក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ។

កិច្ចប្រជុំនេះមានគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរតំបន់ក្នុងបញ្ហាឧក្រិដ្ឋកម្ម និងចែករំលែកនូវជំនាញ និងការអនុវត្តដ៏ល្អក្នុងចំណោមអ្នកអនុវត្តជំនួយផ្នែកច្បាប់ទៅវិញទៅមក ដើម្បីទប់ស្កាត់ និងប្រឆាំងអំពើពុករលួយ និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ និងអាចជួយសម្រួលដល់ការសន្ទនារវាងសមាជិកនៃបណ្តាញ និងដៃគូនៅខាងក្រៅអាស៊ីអាគ្នេយ៍។

ក្នុងនាមជាកិច្ចប្រជុំពេញអង្គលើកដំបូង ចាប់តាំងពីការបង្កើតបណ្តាញនេះមក កិច្ចប្រជុំនេះនឹងត្រូវបានចូលរួមដោយអ្នកដែលមានឋានៈខ្ពង់ខ្ពស់ ដើម្បីផ្តល់ឱកាសឱ្យពួកគេចែករំលែកការយល់ដឹង និងទស្សនៈរបស់ពួកគេ ក៏ដូចជាបន្តការប្តេជ្ញាចិត្ត និងឆន្ទៈដ៏មុតមាំរបស់ពួកគេក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន។

កិច្ចប្រជុំរយៈពេលបីថ្ងៃនេះ នឹងដោះស្រាយយ៉ាងស៊ីជម្រៅអំពីបញ្ហាប្រឈមសំខាន់ៗដែលអាជ្ញាធរកណ្តាលប្រឈមមុខសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងបញ្ហាព្រហ្មទណ្ឌ ដែលនឹងនាំទៅដល់ការបង្ហាញពីមធ្យោបាយដែលអាចធ្វើទៅបានដើម្បីកែលម្អកិច្ចសហប្រតិបត្តិការក្នុងចំណោមសមាជិក និងអភិវឌ្ឍន៍បណ្តាញ SEAJust បន្ថែមទៀត។[36]

គោលបំណងនៃបណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍ គឺដើម្បី ៖

- កំណត់អត្តសញ្ញាណចំណុចទំនាក់ទំនង ដើម្បីធ្វើជាអន្តរការីសកម្មរវាងបណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍ (SEAJust) និងបណ្តាញក្នុងតំបន់ផ្សេងទៀត។
- ជួយសម្រួលដល់ការងាររបស់អាជ្ញាធរកណ្តាល និងសមត្ថកិច្ច និងព្រះរាជអាជ្ញានៅខាងក្នុង និងក្រៅតំបន់អាស៊ីអាគ្នេយ៍។
- ជួយសម្របសម្រួលការប្រាស្រ័យទាក់ទងនៅកម្រិតក្រៅផ្លូវការក្នុងការគាំទ្របណ្តាញផ្លូវការ និងយន្តការក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងបញ្ហាព្រហ្មទណ្ឌ ជាពិសេសនៅក្នុងសំណុំរឿង MLA។ យន្តការនៃបណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍ (SEAJust) មិនបានជំនួសតួនាទីរបស់បណ្តាញ និងយន្តការផ្លូវការដែលមានស្រាប់នោះទេ។

[36] របៀបវារៈនៃកិច្ចប្រជុំពេញអង្គរបស់បណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍-SEAJust, ២៦-២៨ ខែមេសា ឆ្នាំ២០២៣, កិច្ចប្រជុំធ្វើនៅទីក្រុងសេអ៊ូ (Seoul) នៃសាធារណរដ្ឋកូរ៉េ។

- ជំរុញការកសាងសមត្ថភាពរបស់អាជ្ញាធរកណ្តាល និងអ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌពាក់ព័ន្ធលើកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងបញ្ហាព្រហ្មទណ្ឌ និងការដោះស្រាយប្រភេទផ្សេងៗនៃឧក្រិដ្ឋកម្មឆ្លងដែនដែលមានការរៀបចំ និងលក្ខណៈធ្ងន់ធ្ងរតាមរយៈការបណ្តុះបណ្តាល និងការផ្លាស់ប្តូរវិជ្ជាជីវៈ។
- គាំទ្រ និងលើកកម្ពស់ការពង្រឹងក្របខណ្ឌច្បាប់អន្តរជាតិ ថ្នាក់តំបន់ និងថ្នាក់ជាតិ និងការអនុវត្តលើសំណុំរឿង MLA។
- គាំទ្រដល់ការអភិវឌ្ឍន៍ និងការផ្សព្វផ្សាយនៃឧបករណ៍ដែលពាក់ព័ន្ធ។
- គាំទ្រដល់កិច្ចសហប្រតិបត្តិលើការប្រតិបត្តិការរវាងប្រទេសពីរឬច្រើន និង
- ផ្នែកផ្សេងទៀតនៃកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងបញ្ហាព្រហ្មទណ្ឌ ដូចដែលអាចត្រូវបានយល់ព្រមដោយសមាជិករបស់ខ្លួន។[37]

## ២.៣. អាជ្ញាធរកណ្តាល

### ២.៣.១. ស្ថាប័នទទួលបន្ទុកជាអាជ្ញាធរកណ្តាល

នៅក្នុងសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន បានចែងនៅក្នុងមាត្រា ៤ ថា ៖ "ភាគីនីមួយៗ ត្រូវតែងតាំងអាជ្ញាធរកណ្តាលមួយ ដើម្បីរៀបចំនិងទទួលសំណើ អនុលោមតាមសន្ធិសញ្ញានេះ។ ការតែងតាំងអាជ្ញាធរកណ្តាល ត្រូវធ្វើឡើងនៅពេលតម្កល់លិខិតតុបករណ៍ នៃការផ្តល់សច្ចាប័ន ទទួលយកអនុម័ត ឬចូលជាសមាជិកនៃសន្ធិសញ្ញានេះ។ ភាគីនីមួយៗត្រូវជូនដំណឹងទៅភាគីផ្សេងៗទៀតឱ្យបានរួសរាន់ អំពីការផ្លាស់ប្តូរនៅក្នុងការតែងតាំងអាជ្ញាធរកណ្តាលរបស់ខ្លួន។ អាជ្ញាធរកណ្តាលត្រូវទំនាក់ទំនងគ្នាដោយផ្ទាល់ ប៉ុន្តែភាគីអាចទំនាក់ទំនងគ្នាតាមបណ្តាញការទូតប្រសិនបើភាគីជ្រើសរើសដូចនេះ"។[38]

បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នទៅលើសន្ធិសញ្ញាខាងលើនេះនៅឆ្នាំ២០១០ រួចហើយនៅដើមឆ្នាំ២០១១ ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា បានចេញសេចក្តីសម្រេចស្តីពីការបង្កើតអាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌[39] ដែលបានបង្កើតឱ្យមានអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើការសម្របសម្រួលក្នុងសំណុំរឿង MLA នេះ ប៉ុន្តែសេចក្តីសម្រេចនេះត្រូវបាននិរាករណ៍ទៅវិញនៅឆ្នាំ២០១៧ ដោយសារតែក្រសួងយុត្តិធម៌បានចេញប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌[40] ថ្មីមួយទៀតដើម្បីបន្ថែមសមាភាព និងមុខងារ តួនាទី ភារកិច្ច របស់អាជ្ញាធរកណ្តាលដែល

[37] Terms of Reference របស់បណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍-SEAJust, ១៣ ខែមេសា ឆ្នាំ២០២០។

[38] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា៤។

[39] សេចក្តីសម្រេច ស្តីពីការបង្កើតអាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌, លេខ ០១ កយ.សសរ/១១, ១១ ខែមករា ឆ្នាំ២០១១។

[40] ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌, លេខ ១០០ កយ.ប្រក/១៧, ១២ ខែមេសា ឆ្នាំ២០១៧, មាត្រា ៥។

សម្របសម្រួលក្នុងសំណុំរឿង MLA នេះ។ អាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌ថ្មីនេះ មានលេខាធិការដ្ឋានមួយដើម្បីជួយសម្របសម្រួល និងអនុវត្តការងារ ដែលបានផ្តល់សមត្ថកិច្ចទៅឱ្យ អគ្គនាយកដ្ឋានអភិវឌ្ឍន៍វិស័យយុត្តិធម៌ (បច្ចុប្បន្នជា អគ្គនាយកដ្ឋានកិច្ចការច្បាប់ និងអភិវឌ្ឍន៍វិស័យុត្តិធម៌) ធ្វើជាលេខាធិការដ្ឋាននៃអាជ្ញាធរកណ្តាលមួយនេះ។[41]

អាស្រ័យហេតុនេះហើយទើប ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តកាលពីឆ្នាំ២០២០ នៅតែផ្តល់អំណាចឱ្យក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ធ្វើជាអាជ្ញាធរកណ្តាលក្នុងរឿងជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះដដែរ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចាត់តាំងមន្ត្រីជាតំណាងរបស់អាជ្ញាធរកណ្តាលក្នុងទំនាក់ទំនងការងារជាមួយរដ្ឋបរទេស អាជ្ញាធរអនុវត្តសំណើ និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។[42]

**២.៣.២. សមត្ថកិច្ចរបស់អាជ្ញាធរកណ្តាល**

នៅក្នុងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌ អាជ្ញាធរកណ្តាលមានបេសកកម្ម តួនាទី និងភារកិច្ចដូចតទៅ ៖

- ទទួលពិនិត្យ និងសម្របសម្រួលលើសំណើ នៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
- បញ្ជូនសំណើទៅភ្នាក់ងារពាក់ព័ន្ធ និងបញ្ជូនសំណើត្រឡប់ទៅភាគីម្ចាស់សំណើវិញ
- រៀបចំបញ្ចូលព័ត៌មាន និងតាមដានរាល់សំណើដែលបានទទួល និងបញ្ជូន ដើម្បីធានាឱ្យមានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងឱ្យបានឆាប់រហ័ស
- ដើរតួជាអង្គភាពបង្គោល ដើម្បីសម្របសម្រួលរាល់បញ្ហាទាក់ទងនឹងជំនួយផ្នែកច្បាប់
- ធ្វើការទំនាក់ទំនងដោយផ្ទាល់ ឬតាមរយៈផ្លូវទូតជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីសម្របសម្រួលលើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់
- រៀបចំទិន្នន័យនៃសំណើសុំជំនួយផ្នែកច្បាប់ និងចងក្រងឯកសារច្បាប់ដោយបញ្ជូនតៅក្នុងប្រព័ន្ធមូលដ្ឋានទិន្នន័យដោយបង្ហោះនៅលើគេហទំព័ររបស់ក្រសួងយុត្តិធម៌
- រក្សាការសម្ងាត់ចំពោះសំណើសុំជំនួយផ្នែកច្បាប់ ខ្លឹមសារ និងឯកសារគាំទ្រសំណើ ហេតុការណ៍នៃការផ្តល់ជំនួយ និងចំណាត់ការណាមួយដែលអនុវត្តទៅតាមសំណើ

[41] ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌, លេខ ១០០ កយ.ប្រក/១៧, ១២ ខែមេសា ឆ្នាំ២០១៧, មាត្រា ៤។

[42] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៤។

- ធានានូវព័ត៌មាន និងភស្តុតាងត្រូវបានការពារមិនឱ្យបាត់បង់ និងការទទួលបានការប្រើប្រាស់ការកែប្រែ ការបង្ហាញដោយគ្មានការអនុញ្ញាត ឬការប្រើប្រាស់មិនត្រឹមត្រូវផ្សេងៗ
- រៀបចំផែនការសកម្មភាព នៃការអភិវឌ្ឍលើការងារសម្របសម្រួល ការចំណាយ ដំណើរទស្សនកិច្ច សិក្សា ចូលរួមសិក្ខាសាលា និងកិច្ចប្រជុំ ទាំងក្នុង និងក្រៅប្រទេស
- ធ្វើការទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីស្វែងរកជំនួយក្នុងការបណ្តុះបណ្តាលធនធានមនុស្ស
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីសម្របសម្រួល លើការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់។[43]

ចំណែកឯនៅក្នុងច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាវិញ អាជ្ញាធរកណ្តាលមានសមត្ថកិច្ច ជាអាទិ៍ដូចខាងក្រោម៖

១. ទទួលសំណើពីរដ្ឋធ្វើសំណើ និងបញ្ជូនសំណើនោះទៅអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា។

២. ទទួលសំណើដែលបានស្នើសុំដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា និងបញ្ជូនសំណើនោះទៅកាន់រដ្ឋទទួលសំណើ។

៣. វាយតម្លៃ និងកំណត់អំពីលក្ខខណ្ឌនៃសំណើរបស់រដ្ឋធ្វើសំណើ ដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៤. វាយតម្លៃ និងកំណត់អំពីលក្ខខណ្ឌនៃការបញ្ជូនសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ នៃព្រះរាជាណាចក្រកម្ពុជាទៅរដ្ឋទទួលសំណើដោយអនុលោមតមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

៥. តាមដាននិងពន្លឿនការអនុវត្តរបស់អាជ្ញាធរអនុវត្តសំណើ ក្នុងការផ្តល់ការជួយផ្នែកច្បាប់ទៅកាន់រដ្ឋធ្វើសំណើ។

៦. តាមដាន និងទាក់ទងជាមួយអាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើដើម្បីពន្លឿនការអនុវត្តសំណើរបស់ព្រះរាជាណាចក្រកម្ពុជា។

៧. សម្របសម្រួលជាមួយអាជ្ញាធរអនុវត្តសំណើទាំងអស់ ដើម្បីជំរុញប្រសិទ្ធភាពក្នុងការអនុវត្តសំណើដោយអនុលោមតាមច្បាប់នេះនិងបទប្បញ្ញត្តិពាក់ព័ន្ធដទៃផ្សេងទៀត។

៨. ក្នុងករណីចាំបាច់អាចចេញសេចក្តីណែនាំ ឬវិធានការនានាដើម្បីធានាប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់នេះ។[44]

[43] ប្រកាស ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌, លេខ ១០០ កយ.ប្រក/១៧, ១២ ខែមេសា ឆ្នាំ២០១៧, មាត្រា ៣។

[44] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៥។

## ២.៤. អាជ្ញាធរអនុវត្តសំណើ

អាជ្ញាធរអនុវត្តសំណើចំពោះសំណើសុំជំនួយដែលមានកំណត់នៅក្នុង ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមក នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២០នេះ គឺជាសាលាដំបូងរាជធានី/ខេត្ត និងអយ្យការអមសាលាដំបូង រាជធានី/ខេត្ត អាស្រ័យតាមករណីនៃសំណើសុំជំនួយនីមួយៗ និងតាមការកំណត់របស់អាជ្ញាធរកណ្តាល។ ក្នុងករណីសាលាដំបូងរាជធានី/ខេត្ត បានទទួលសំណើពីអាជ្ញាធរកណ្តាល ប្រធានសាលាដំបូងត្រូវបានប្រគល់ សមត្ថកិច្ចតាមច្បាប់ខាងលើនេះ ដើម្បីអនុវត្តសំណើនោះដោយប្រើប្រាស់សិទ្ធិអំណាចទាំងអស់ដែលត្រូវបាន ប្រគល់ឱ្យទៅចៅក្រម ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីអយ្យការអមសាលាដំបូងរាជធានី/ខេត្ត បានទទួលសំណើពីអាជ្ញាធរកណ្តាល ព្រះរាជអាជ្ញានៃ អយ្យការអមសាលាដំបូងរាជធានី/ខេត្ត ត្រូវបានប្រគល់សមត្ថកិច្ចតាមច្បាប់នេះ ដើម្បីអនុវត្តសំណើនោះដោយ ប្រើប្រាស់សិទ្ធិអំណាចទាំងអស់ដែលត្រូវបានប្រគល់ឱ្យទៅព្រះរាជអាជ្ញា ដោយយោងតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ផ្សេងទៀតនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុវត្តសំណើនោះ។ ដោយឡែក អាជ្ញាធរអនុវត្តសំណើ ចំពោះសំណើសុំជំនួយទាក់ទងនឹងការផ្តល់ឯកសារ និងព័ត៌មានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋ ដូចមានចែងនៅក្នុងអនុផ្នែកទី៣ (ជំនួយទាក់ទងនឹងការផ្តល់ឯកសារនិងព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រង របស់ស្ថាប័នរដ្ឋ) ផ្នែកទី២ (វិធានដោយឡែកទាក់ទងនឹងទម្រង់ជាក់លាក់នៃជំនួយ) ជំពូកទី៣ (សំណើសុំជំនួយ ដោយរដ្ឋផ្ញើសំណើ) នៃច្បាប់ខាងលើនេះ គឺជាស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដែលភាគច្រើន គឺក្រសួង មហាផ្ទៃ (ចំពោះរឿងដែលពាក់ព័ន្ធនឹងការស្នើសុំបញ្ជាក់ប្រវត្តិរូប អត្តសញ្ញាណ ឬសញ្ជាតិ) និងក្រសួងយុត្តិធម៌ នេះផ្ទាល់តែម្តង (ចំពោះរឿងដែលពាក់ព័ន្ធនឹងការស្នើសុំបញ្ជាក់ប្រវត្តិនៃការផ្តន្ទាទោស)។[45]

[45] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៦។

# ជំពូកទី២
# ភាគីដែលស្នើសុំជំនួយ

# ជំពូកទី២
# ភាគីដែលស្នើសុំជំនួយ

## ១. សំណើសុំជំនួយដោយរដ្ឋបរទេស (រដ្ឋធ្វើសំណើ)

សំណើសុំជំនួយដោយរដ្ឋបរទេស ឬហៅថារដ្ឋធ្វើសំណើ គឺជាការធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ រវាងប្រទេសជាសមាជិកអាស៊ានជាមួយនឹងព្រះរាជាណាចក្រកម្ពុជា ដើម្បីបង្កើតការពង្រឹងទំនាក់ទំនងការបរទេស វិស័យការទូត ក៏ដូចជាវិស័យព្រហ្មទណ្ឌ នៅក្នុងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍។

### ១.១. វិធានទូទៅ (នីតិវិធីទូទៅ)

ការបញ្ជូនសំណើមកព្រះរាជាណាចក្រកម្ពុជា គឺរដ្ឋធ្វើសំណើត្រូវបញ្ជូនសំណើមកអាជ្ញាធរកណ្តាលដោយផ្ទាល់ ឬតាមបណ្តាញការទូត។[46] មានន័យថាអាជ្ញាធរកណ្តាលនៃរដ្ឋធ្វើសំណើត្រូវបញ្ជូនសំណើនោះមកកាន់អាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើដោយផ្ទាល់ដោយមិនចាំបាច់ឆ្លងកាត់ស្ថានទូតនោះទេ ឬរដ្ឋធ្វើសំណើអាចបញ្ជូនសំណើមកកាន់អាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើតាមរយៈស្ថានទូតក៏បានដែរ។

#### ១.១.១. ខ្លឹមសារ និងទម្រង់នៃសំណើមកព្រះរាជាណាចក្រកម្ពុជា

បើតាមការព្រមព្រៀងគ្នារវាងរដ្ឋសមាជិកអាស៊ាន នៅក្នុងសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន ឆ្នាំ២០០៤ ចំពោះទម្រង់ និងខ្លឹមសារនៃសំណើសុំជំនួយផ្នែកច្បាប់ដែលរដ្ឋសមាជិកធ្វើការស្នើសុំគ្នាទៅវិញទៅមកនោះ ត្រូវអនុលោមដូចខាងក្រោមនេះ ៖

- ចំពោះទម្រង់ ៖
  - រាល់សំណើសុំជំនួយ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬប្រសិនបើធ្វើទៅបានតាមរយៈមធ្យោបាយណាមួយ ដែលអាចបង្កើតជាកំណត់ហេតុជាលាយលក្ខណ៍អក្សរក្រោមលក្ខខណ្ឌអនុញ្ញាតឱ្យភាគីទទួលសំណើធ្វើកំណត់ហេតុជាយថាភូត។ នៅក្នុងស្ថានភាពបន្ទាន់ និងបើច្បាប់របស់ភាគីទទួលសំណើអនុញ្ញាតឱ្យនោះ សំណើអាចធ្វើឡើងដោយផ្ទាល់មាត់បាន ប៉ុន្តែនៅក្នុងករណីបែបនេះ រាល់សំណើត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរក្នុងរយៈពេលប្រាំថ្ងៃ។
  - អាជ្ញាធរកណ្តាលត្រូវចាត់ចែងក្នុងការបញ្ជូនសំណើ ឬការទំនាក់ទំនងពាក់ព័ន្ធ។ នៅក្នុងស្ថានភាពបន្ទាន់ និងបើច្បាប់របស់ភាគីទទួលសំណើអនុញ្ញាតឱ្យ រាល់សំណើ និងការទំនាក់ទំនងពាក់ព័ន្ធអាចត្រូវបានបញ្ជូនតាមរយៈអង្គការនគរបាលព្រហ្មទណ្ឌអន្តរជាតិ (INTERPOL) ឬអង្គការនគរបាលអាស៊ីអាគ្នេយ៍ (ASEANAPOL)។[47]

---

[46] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៧។

[47] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា៥។

❖ ចំពោះខ្លឹមសារ ៖

– សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ត្រូវមានព័ត៌មានដូចខាងក្រោម ៖

- ឈ្មោះការិយាល័យភាគីដាក់សំណើ និងអាជ្ញាធរមានសមត្ថកិច្ចស៊ើបអង្កេត ឬដំណើរការរឿងក្តីព្រហ្មទណ្ឌ ដែលទាក់ទងទៅនឹងសំណើនោះ។
- គោលបំណងរបស់សំណើ និងប្រភេទជំនួយស្នើសុំ។
- ការអធិប្បាយពីប្រភេទរឿងក្តីព្រហ្មទណ្ឌ និងស្ថានភាពបច្ចុប្បន្នរបស់វា និងរបាយការណ៍បង្ហាញពីសេចក្តីសង្ខេបនៃអង្គហេតុ និងអង្គច្បាប់ពាក់ព័ន្ធ។
- ការអធិប្បាយពីបទល្មើសទាក់ទងនឹងសំណើ រួមទាំងទោសបញ្ញត្តិជាអតិបរមា។
- ការអធិប្បាយពីអង្គហេតុ សំដៅដល់ការបង្កើតបានជាបទល្មើស និងរបាយការណ៍ ឬអត្ថបទច្បាប់ពាក់ព័ន្ធ។
- ការអធិប្បាយពីអំពើប្រព្រឹត្ត ឬការប៉ុនប៉ង ឬបញ្ជានៃបណ្តឹងបរិហារ ឬការស្វែងរកដែលបញ្ជាក់ថាពិតប្រាកដ។
- ការអធិប្បាយពីភស្តុតាង ព័ត៌មាន ឬជំនួយផ្សេងៗដែលត្រូវស្នើសុំ។
- មូលហេតុ និងសេចក្តីលំអិតនៃនីតិវិធី ឬសេចក្តីតម្រូវពិសេសណាមួយ ដែលភាគីដាក់សំណើប្រាថ្នាចង់ឱ្យអនុវត្តតាម។
- ការបញ្ជាក់ច្បាស់លាស់ពីពេលវេលាកំណត់ ដែលចង់ឱ្យការអនុវត្តតាមសំណើធ្វើឡើងនៅក្នុងរយៈពេលកំណត់នេះ និង
- សេចក្តីតម្រូវពិសេសណាមួយ ទាក់ទងការរក្សាភាពសម្ងាត់ និងមូលហេតុនៃការរក្សាភាពសម្ងាត់។

– អាស្រ័យលើវិសាលភាពនៃភាពចាំបាច់ រាល់សំណើសុំជំនួយអាចមានព័ត៌មានដូចខាងក្រោម ៖

- អត្តសញ្ញាណ សញ្ជាតិ និងទីតាំងរបស់ជនណា ឬបណ្តាបុគ្គលណាដែលជាកម្មវត្ថុនៃការស៊ើបអង្កេត ឬដំណើរការរឿងក្តីព្រហ្មទណ្ឌ។
- អត្តសញ្ញាណ និងទីតាំងរបស់ជនដែលត្រូវស្វែងរកភស្តុតាងពីជននោះ។
- អត្តសញ្ញាណ និងទីតាំងរបស់ជនដែលត្រូវស្វែងរកការទំនាក់ទំនងរបស់ជននោះទៅនឹងដំណើររឿងក្តីព្រហ្មទណ្ឌ និងរបៀបតម្រូវឱ្យជននោះផ្តល់សេវា។
- ព័ត៌មានស្តីពីអត្តសញ្ញាណ និងទីតាំងរបស់ជនដែលត្រូវស្វែងរក។
- ការអធិប្បាយអំពីរបៀបយក ឬធ្វើកំណត់ហេតុពីការផ្តល់ចំលើយ និងសក្ខីភាព។

- បញ្ជីសំណួរដែលត្រូវសួរបំភ្លឺសាក្សី។
- ការអធិប្បាយអំពីឯកសារ កំណត់ហេតុ ឬវត្ថុតាងដែលត្រូវបង្កើត ព្រមទាំងការអធិប្បាយពីជនសមស្របដែលត្រូវសួរបំភ្លឺ ដើម្បីបង្កើតឯកសារ និងវត្ថុតាងទាំងអស់នេះ។
- របាយការណ៍បញ្ជាក់ថា តើមានតម្រូវការឱ្យធ្វើសម្បថ ឬអះអាងទៅលើភស្តុតាង ឬទៅលើការផ្តល់ចំលើយដែរឬទេ។
- ការអធិប្បាយអំពីទ្រព្យសម្បត្តិ ទ្រព្យសកម្ម ឬវត្ថុដែលទាក់ទងនឹងសំណើ រួមទាំងអត្តសញ្ញាណ និងទីតាំងរបស់វា និង
- ដីកាបង្គាប់តុលាការទាក់ទងនឹងសំណើសុំជំនួយ និងរបាយការណ៍ទាក់ទងនឹងអង្គហេតុចុងក្រោយនៃដីកាបង្គាប់នោះ។

– បណ្តាសំណើ ឯកសារគាំទ្រ និងការប្រាស្រ័យទាក់ទងផ្សេងៗដែលបានធ្វើឡើងដោយអនុលោមទៅតាមសន្ធិសញ្ញានេះ ត្រូវធ្វើជាភាសាអង់គ្លេស និងប្រសិនបើចាំបាច់ត្រូវអមមកជាមួយនូវការបកប្រែជាភាសារបស់ប្រទេសទទួលសំណើ ឬភាសាផ្សេងទៀតដែលភាគីទទួលសំណើអាចទទួលយកបាន។

– ប្រសិនបើភាគីទទួលសំណើពិចារណាឃើញថា ព័ត៌មាននៅក្នុងសំណើមិនទាន់គ្រប់គ្រាន់ ដើម្បីឱ្យសំណើអាចអនុវត្តតាមបាន នោះភាគីទទួលសំណើអាចស្នើសុំព័ត៌មានបន្ថែម។ ភាគីដាក់សំណើត្រូវផ្តល់ព័ត៌មានបន្ថែមបែបនេះ ដែលភាគីទទួលសំណើពិចារណាឃើញថា មានការចាំបាច់ដើម្បីអនុវត្តបំពេញតាមសំណើ។[48]

បើយោងទៅលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជាវិញ ចំពោះទម្រង់ និងខ្លឹមសារនៃសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលរដ្ឋសមាជិកអាស៊ានបញ្ជូនមកព្រះរាជាណាចក្រកម្ពុជា ត្រូវរួមបញ្ចូលនូវព័ត៌មានមួយចំនួនដូចខាងក្រោម៖

– ឈ្មោះអាជ្ញាធរដែលធ្វើការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ ការជំនុំជម្រះ ឬការអនុវត្តនីតិវិធីព្រហ្មទណ្ឌដែលទាក់ទងទៅនឹងសំណើ ដូចជាព័ត៌មានលម្អិតរបស់បុគ្គលដែលមានសមត្ថកិច្ចឆ្លើយតបទៅនឹងសំណួរនានាដែលពាក់ព័ន្ធនឹងសំណើ

– ការពណ៌នាអំពីសញ្ញាណនៃរឿងក្តីព្រហ្មទណ្ឌ រួមបញ្ចូលទាំងសេចក្តីសង្ខេបអង្គហេតុឈ្មោះនៃបទល្មើស និងទោសដែលត្រូវអនុវត្ត ព្រមទាំងភ្ជាប់មកជាមួយនូវអត្ថបទច្បាប់ដែលពាក់ព័ន្ធ និង

48 សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា៦។

- ការពណ៌នាអំពីគោលបំណងនៃការស្នើសុំជំនួយ និងប្រភេទនៃជំនួយដែលត្រូវស្វែងរក។ អាជ្ញាធរកណ្តាលអាចស្នើសុំឱ្យរដ្ឋធ្វើសំណើផ្តល់ព័ត៌មាន និងឯកសារពាក់ព័ន្ធបន្ថែមទៀតបាន ប្រសិនបើយល់ឃើញថាព័ត៌មាននិងឯកសារក្នុងសំណើមិនទាន់គ្រប់គ្រាន់។[49]

សំណើដែលមានព័ត៌មានមិនគ្រប់គ្រាន់ មិនធ្វើឱ្យប៉ះពាល់ដល់លក្ខខណ្ឌសុពលភាពនៃសំណើ ឬរាំងដល់ការអនុវត្តសំណើជាស្វ័យប្រវត្តិឡើយ។ សំណើនិងឯកសារដែលពាក់ព័ន្ធនឹងសំណើ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ជាភាសាខ្មែរ និងជាភាសាអង់គ្លេស។

**១.១.២. គោលការណ៍បដិការ និងការបដិសេធសំណើ**

**១.១.២.១. គោលការណ៍បដិការ**

ការផ្តល់ជំនួយដោយផ្អែកលើគោលការណ៍បដិការ គឺការជួយផ្នែកច្បាប់អាចត្រូវបានផ្តល់ឱ្យក្រោមលក្ខខណ្ឌដែលរដ្ឋធ្វើសំណើប្តេជ្ញាចិត្តថានឹងផ្តល់ការជួយផ្នែកច្បាប់ដល់ព្រះរាជាណាចក្រកម្ពុជាវិញ នៅក្នុងរបៀបប្រហាក់ប្រហែលគ្នានៅពេលមានសំណើពីព្រះរាជាណាចក្រកម្ពុជា។ តាមន័យសាមញ្ញធម្មតាគោលការបដិការ គឺបើអ្នកជួយខ្ញុំ ខ្ញុំនឹងជួយអ្នកវិញ អ្នកជួយខ្ញុំរបៀបណា ខ្ញុំនឹងជួយអ្នករបៀបនោះវិញ។ ដូចនេះ ក្នុងសំណុំរឿងជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ មិនថាជាមួយរដ្ឋបរទេសដែលនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (រដ្ឋសមាជិកនៃអាស៊ាន) ឬរដ្ឋបរទេសដែលមិននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ក៏ដោយ បើមិនមានសន្ធិសញ្ញាទ្វេភាគី ត្រីភាគី ចតុភាគី ឬសន្ធិសញ្ញាក្នុងតំបន់រួមក៏ដោយ ក៏អាចធ្វើសំណើសុំជំនួយផ្នែកច្បាប់នៃវិស័យព្រហ្មទណ្ឌបានដែរ ដោយយោងតាមគោលការណ៍បដិការមួយនេះ។[50]

**១.១.២.២. ការបដិសេធសំណើ**

នៅក្នុងសន្ធិសញ្ញារបស់អាស៊ាន រដ្ឋភាគីទាំងអស់បានយល់ស្របទៅលើការកម្រិតលើជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់រដ្ឋធ្វើសំណើ ដែលអនុញ្ញាតឱ្យភាគីទទួលសំណើត្រូវបដិសេធការសុំជំនួយនោះប្រសិនបើខ្លួនយល់ឃើញថា៖

- សំណើនោះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ឬការផ្តន្ទាទោសជនណាម្នាក់ពីបទល្មើសដែលមានលក្ខណៈនយោបាយ ឬដោយមានសំអាងលើហេតុផលនៃកាលៈទេសៈក្នុងការចោទប្រកាន់ថាជននោះកំពុងបានប្រព្រឹត្ត ឬបានប្រព្រឹត្តរួចហើយនូវបទល្មើសណាមួយដែលមានលក្ខណៈនយោបាយ។
- សំណើនោះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ឬការផ្តន្ទាទោសជនណាម្នាក់ទាក់ទងដល់អំពើប្រព្រឹត្តបទល្មើស ឬការប៉ុនប៉ងណាមួយដែលគួរចាត់ទុកថាជាបទល្មើសយោធា ប្រសិនបើ

[49] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៨។
[50] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៩។

វាបានកើតឡើងនៅក្នុងភាគីទទួលសំណើ យោងតាមច្បាប់របស់ភាគីទទួលសំណើ អំពើប្រព្រឹត្ត ឬការប៉ុនប៉ងនោះមិនមែនជាបទល្មើសផងដែរ ស្ថិតនៅក្រោមច្បាប់ព្រហ្មទណ្ឌធម្មតារបស់ភាគីទទួលសំណើ។

- មានហេតុផលដ៏ធ្ងន់ដែលគួរឱ្យជឿបានថា សំណើត្រូវបានធ្វើឡើងសម្រាប់គោលបំណងស៊ើបអង្កេត ចោទប្រកាន់ ផ្តន្ទាទោស ឬបើមិនដូច្នោះទេ បង្កឱ្យមានភាពលំអៀងចំពោះជនណាមួយដោយសារតែជាតិសាសន៍ សាសនា ភេទ ដើមកំណើត ជនជាតិ សញ្ជាតិ ឬទស្សនៈនយោបាយរបស់ជននោះ។[51]
- សំណើនោះទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ការផ្តន្ទាទោស លើជនណាមួយពីបទល្មើសនៅក្នុងករណីដែលជននោះ ៖
    - ត្រូវបានកាត់ឱ្យជាប់ទោស សម្រេចឱ្យរួចខ្លួន ឬលើកលែងទោសដោយតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀត នៅក្នុងភាគីដាក់សំណើ ឬភាគីទទួលសំណើ។
    - បានទទួលការផ្តន្ទាទោសដែលចែងដោយច្បាប់របស់ភាគីដាក់សំណើ ឬភាគីទទួលសំណើទាក់ទងនឹងបទល្មើសនោះ ឬបទល្មើសផ្សេងទៀត ដែលផ្សំឡើងដោយអំពើ ឬការប៉ុនប៉ងដូចបទល្មើសដែលបានលើកឡើងពីដំបូង។
- សំណើទាក់ទងនឹងការស៊ើបអង្កេត ការចោទប្រកាន់ ឬការផ្តន្ទាទោស ទៅលើជនណាមួយពាក់ព័ន្ធនឹងអំពើប្រព្រឹត្ត ឬការប៉ុនប៉ង មិនគួរចាត់ទុកថាជាបទល្មើសប្រឆាំងនឹងច្បាប់របស់ភាគីទទួលសំណើនោះទេ។
- ការផ្តល់ជំនួយនឹងប៉ះពាល់ដល់ អធិបតេយ្យភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាសារវន្តរបស់ភាគីទទួលសំណើ។
- ភាគីដាក់សំណើមិនអាចធានាបានថា ខ្លួននឹងអាចប្រតិបត្តិតាមសំណើនាពេលអនាគតនូវជំនួយផ្នែកព្រហ្មទណ្ឌ ដែលមានលក្ខណៈស្រដៀងគ្នានឹងភាគីទទួលសំណើបានឡើយ។
- ភាគីដាក់សំណើមិនអាចធានាបានថា កម្មវត្ថុដែលខ្លួនបានស្នើសុំនោះ នឹងមិនយកទៅប្រើប្រាស់ក្រៅពីរឿងក្តីព្រហ្មទណ្ឌទាក់ទងទៅនឹងសំណើដែលបានធ្វើឡើងឡើយ ហើយភាគីទទួលសំណើមិនបានយល់ព្រមបោះបង់ចោលនូវការធានាបែបនេះ។
- ភាគីដាក់សំណើមិនអាចធានា ក្នុងការប្រគល់ជូនភាគីទទួលសំណើវិញនូវវត្ថុតាងណាមួយ ដែលបានទទួលតាមសំណើរបស់ខ្លួន អនុលោមទៅតាមសំណើ នៅពេលបញ្ចប់រឿងក្តីព្រហ្មទណ្ឌទាក់ទងទៅនឹងការធ្វើសំណើនេះ។
- ការផ្តល់ជំនួយនោះ អាចធ្វើឱ្យប៉ះពាល់ដល់រឿងក្តីព្រហ្មទណ្ឌ នៅក្នុងភាគីទទួលសំណើ។

[51] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា៣ ចំណុច១។

លើសពីនេះទៅទៀត នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានអនុញ្ញាតឱ្យភាគីទទួលសំណើអាចបដិសេធក្នុងការផ្តល់ជំនួយ ប្រសិនបើភាគីទទួលសំណើយល់ឃើញថា៖

- ភាគីដាក់សំណើមិនបានប្រតិបត្តិទៅតាមខ្លឹមសារណាមួយនៃសន្ធិសញ្ញានេះ ឬការរៀបចំដទៃទៀតទាក់ទងទៅនឹងសំណើនោះ
- ការផ្តល់ជំនួយនោះនឹង ឬទំនងជានឹងធ្វើឱ្យប៉ះពាល់ដល់សុវត្ថិភាពរបស់ជនណាម្នាក់ ទោះបីជននោះស្ថិតនៅក្នុង ឬក្រៅដែនដីរបស់ភាគីទទួលសំណើក៏ដោយ ឬ
- ការផ្តល់ជំនួយនោះ នឹងដាក់បន្ទុកហួសប្រមាណទៅលើធនធានរបស់ភាគីទទួលសំណើ។[52]

ការផ្តល់ជំនួយ មិនត្រូវបដិសេធ ដោយគ្រាន់តែមានមូលហេតុភាពសម្ងាត់របស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ប្រហាក់ប្រហែល ឬដោយហេតុផលថា បទល្មើសនោះ ត្រូវបានចាត់ទុកផងដែរថាមានពាក់ព័ន្ធដល់បញ្ហាសារពើពន្ធ។ មុនពេលបដិសេធសំណើ ភាគីទទួលសំណើត្រូវពិចារណាថា តើជំនួយអាចផ្តល់ឱ្យ ដោយអាស្រ័យលើលក្ខខណ្ឌជាក់លាក់ដែរឬទេ។ ប្រសិនបើភាគីទទួលសំណើបដិសេធផ្តល់ជំនួយ នោះភាគីទទួលសំណើត្រូវជូនដំណឹងដល់ភាគីម្ចាស់សំណើភ្លាម អំពីមូលហេតុនៃការបដិសេធនោះ។

ជាមួយគ្នានេះដែរ តាមរយៈច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានអនុញ្ញាតឱ្យ អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា អាចបដិសេធសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់រដ្ឋផ្ញើសំណើជាសមាជិកអាស៊ានបាន ដែលសំណើសុំជំនួយផ្នែកច្បាប់នោះធ្វើប៉ះពាល់ដល់បញ្ហាមួយចំនួនទាំងធ្ងន់ ទាំងស្រាលទៅលើព្រះរាជាណាច្រកម្ពុជា។ អាស្រ័យហេតុនេះ អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបដិសេធសំណើសុំជំនួយផ្នែកច្បាប់របស់រដ្ឋផ្ញើសំណើ ក្នុងលក្ខខណ្ឌណាមួយដូចខាងក្រោម៖

១. ការអនុវត្តសំណើធ្វើឱ្យប៉ះពាល់ដល់អធិបតេយ្យ សន្តិសុខជាតិ សណ្តាប់ធ្នាប់សាធារណៈ ឬផលប្រយោជន៍សាធារណៈសំខាន់ៗដទៃទៀតរបស់ព្រះរាជាណាចក្រកម្ពុជា។

២. សំណើទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ ឬការជំនុំជម្រះ បុគ្គលណាមួយចំពោះបទល្មើសនយោបាយ។

៣. សំណើទាក់ទងនឹងការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ ឬការជំនុំជម្រះ បុគ្គលណាមួយចំពោះបទល្មើសយោធា។

៤. មានសំអាងគ្រប់គ្រាន់ដែលគួរឱ្យជឿជាក់ថា សំណើត្រូវបានធ្វើឡើងក្នុងគោលបំណងធ្វើការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ ឬការជំនុំជម្រះបុគ្គលណាមួយដោយមូលហេតុ ពូជសាសន៍ សាសនា ភេទ ជាតិពន្ធុ សញ្ជាតិ ឬទស្សនៈនយោបាយរបស់បុគ្គលនោះ។

[52] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា៣ ចំណុច២។

៥. មានសំអាងគ្រប់គ្រាន់ដែលគួរឱ្យជឿជាក់ថា ប្រសិនបើអនុវត្តសំណើ បុគ្គលនោះនឹងប្រឈមការធ្វើទារុណកម្ម។

លើសពីនេះទៅទៀត អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាក៏អាចបដិសេធនូវសំណើសុំជំនួយផ្នែកច្បាប់មួយចំនួនទៀត ក្នុងលក្ខខណ្ឌណាមួយដូចខាងក្រោម៖

១. សំណើទាក់ទងទៅនឹងការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ ឬការជំនុំជម្រះបុគ្គលណាមួយទាក់ទងដល់ការប្រព្រឹត្តអំពើដែលមិនត្រូវបានចាត់ទុកថាជាបទល្មើស តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអំពើនោះបានកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ប្រសិនបើអង្គហេតុដែលបានបង្ហាញដោយរដ្ឋធ្វើសំណើត្រូវបានចាត់ទុកជាបទល្មើសនៅក្រោមបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា ទោះបីជា៖

- ប្រភេទនៃបទល្មើសអាចត្រូវបានកំណត់ខុសៗគ្នា
- ឈ្មោះបទល្មើស ការប្រើប្រាស់បច្ចេកស័ព្ទ និយមន័យ ឬការកំណត់លក្ខណៈបទល្មើសមិនដូចគ្នា
- ធាតុផ្សំដែលកំណត់ពីបទល្មើស ដូចមានចែងក្នុងច្បាប់នៃរដ្ឋធ្វើសំណើមានលក្ខណៈខុសគ្នាពីធាតុផ្សំ ដែលមានចែងក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

២. ការផ្តល់ការជួយនឹងដាក់បន្ទុកហួសប្រមាណទៅលើធនធានរបស់ព្រះរាជាណាចក្រកម្ពុជា។

៣. ការផ្តល់ការជួយអាចធ្វើឱ្យប៉ះពាល់ដល់ការស៊ើបអង្កេត ឬនីតិវិធីទាក់ទងទៅនឹងរឿងក្តីព្រហ្មទណ្ឌនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤. មានភាពសមស្របក្នុងគ្រប់កាលៈទេសៈទាំងអស់ ដែលបង្ហាញថាសំណើមិនគួរត្រូវបានផ្តល់ឱ្យ។

៥. មានសំអាងគ្រប់គ្រាន់ដែលគួរឱ្យជឿជាក់ថា ប្រសិនបើអនុវត្តសំណើ បុគ្គលនោះនឹងត្រូវទទួលរងទោសប្រហារជីវិត ហើយរដ្ឋធ្វើសំណើមិនបានផ្តល់ការសន្យាថានឹងមិនដាក់ទោសប្រហារជីវិត ឬប្រសិនបើត្រូវបានដាក់ទោសនោះនឹងមិនត្រូវបានអនុវត្ត។

៦. សំណើសុំទាក់ទងនឹងការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ ឬការជំនុំជម្រះបុគ្គលណាមួយចំពោះបទល្មើសណាមួយ ប៉ុន្តែបុគ្គលនោះត្រូវបានសម្រេចឱ្យរួចខ្លួនហើយ ឬលើកលែងទោស ឬបានអនុវត្តទោសរួចរាល់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឬរដ្ឋបរទេស។

៧. សំណើសុំទាក់ទងនឹងការស៊ើបអង្កេត ការចោទប្រកាន់ ការស៊ើបសួរ ឬការជំនុំជម្រះបុគ្គលណាមួយចំពោះបទល្មើសណាមួយ ដែលបទល្មើសនោះបានផុតអាជ្ញាយុកាលដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ប៉ុន្តែ អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក៏មិនត្រូវបដិសេធចំពោះសំណើសុំជំនួយផ្នែកច្បាប់ដែលស្នើសុំដោយរដ្ឋផ្ញើសំណើជាសមាជិកអាស៊ានទាំងស្រុងនោះដែរ គឺមានសំណើមួយចំនួនដែលអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា មិនត្រូវបានបដិសេធសំណើដោយសំអាងតែលើមូលហេតុដូចជា ៖

១. ការរក្សាការសម្ងាត់របស់ធនាគារ ស្ថាប័នហិរញ្ញវត្ថុ ឬបុគ្គលរាយការណ៍ ដូចមានចែងក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬ

២. បទល្មើសត្រូវបានចាត់ទុកថាមានជាប់ពាក់ព័ន្ធនឹងបញ្ហាសារពើពន្ធ។[53]

### ១.១.៣. ការពិនិត្យ និងការសម្រេចលើសំណើ

នៅពេលទទួលបានសំណើពីរដ្ឋផ្ញើសំណើ អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវពិនិត្យ និងពិចារណាទៅលើសំណើព្រមទាំងលក្ខខណ្ឌទាំងឡាយនៃការអនុវត្តសំណើនោះ។ ប្រសិនបើសំណើបានបំពេញគ្រប់លក្ខខណ្ឌដើម្បីអាចអនុវត្តបានស្របតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាហើយ អាជ្ញាធរកណ្តាលចាត់នីតិវិធីបន្តដោយបញ្ជូនសំណើនេះទៅអាជ្ញាធរអនុវត្តសំណើដើម្បីអនុវត្ត។

ប្រសិនបើសំណើ មិនបានបំពេញទៅតាមលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាទេនោះ ធ្វើឱ្យសំណើដែលស្នើសុំដោយរដ្ឋផ្ញើសំណើនោះមិនអាចអនុវត្តបាន។ ដូចនេះ អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវជូនដំណឹងនេះទៅរដ្ឋផ្ញើសំណើវិញ។

ប្រសិនបើសំណើដែលស្នើសុំដោយរដ្ឋផ្ញើសំណើ មិនអាចអនុវត្តបានដោយហេតុថាខ្វះព័ត៌មាន នោះអាជ្ញាធរកណ្តាលត្រូវស្នើសុំព័ត៌មានបន្ថែមពីរដ្ឋផ្ញើសំណើ។ ទោះបីជាបានទទួលព័ត៌មានបន្ថែមពីរដ្ឋផ្ញើសំណើក៏ដោយ ប៉ុន្តែសំណើនោះនៅតែមិនអាចអនុវត្តបានស្របតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា នោះអាជ្ញាធរកណ្តាលត្រូវជូនដំណឹងទៅរដ្ឋផ្ញើសំណើអំពីការបដិសេធសំណើនោះ។[54]

### ១.១.៤. ការផ្អាកការអនុវត្តសំណើ

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា ភាគីទទួលសំណើអាចផ្អាកអនុវត្តសំណើ ប្រសិនបើការអនុវត្តនោះអាចជ្រៀតជ្រែកដល់ដំណើរការណាមួយនៃរឿងក្តីព្រហ្មទណ្ឌ នៅក្នុងដែនដីរបស់ភាគីទទួលសំណើ។ មុនពេលផ្អាកអនុវត្តសំណើរបស់ខ្លួន ភាគីទទួលសំណើត្រូវពិចារណាថា តើជំនួយអាចផ្តល់ឱ្យដោយអាស្រ័យលើលក្ខខណ្ឌជាក់លាក់ដែរឬទេ។ ប្រសិនបើភាគីទទួលសំណើផ្អាកផ្តល់ជំនួយ នោះភាគីទទួលសំណើត្រូវជូនដំណឹងដល់ភាគីម្ចាស់សំណើភ្លាមអំពីមូលហេតុនៃការផ្អាកនោះ។[55]

---

[53] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១០។

[54] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១១។

[55] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា៣ ចំណុច៦, ៧ និង៩។

នៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា ប្រសិនបើអាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជាយល់ឃើញថា ការអនុវត្តសំណើនេះអាចប៉ះពាល់ដល់ដំណើរការនៃការស៊ើបអង្កេត (ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌) ការចោទប្រកាន់ (ដំណាក់ព្រះរាជអាជ្ញា) ការស៊ើបសួរ (ដំណាក់កាលចៅក្រមស៊ើបសួរ) ការជំនុំជម្រះ (ដំណាក់កាលចៅក្រមជំនុំជម្រះ) ឬដំណើរការនីតិវិធីតុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជា នោះអាជ្ញាធរ កណ្ដាលអាចផ្អាកការអនុវត្តសំណើខាងលើ ឬអាចអនុវត្តសំណើនេះក្រោមលក្ខខណ្ឌជាក់លាក់ និងត្រូវជូនដំណឹងដល់រដ្ឋផ្ញើសំណើ។[56]

**១.១.៥. ការអនុវត្តសំណើដោយអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធ**

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌត្រូវអនុវត្តយ៉ាងរួសរាន់ទៅតាមរបៀបចែងដោយច្បាប់ និងការអនុវត្តនានារបស់ភាគីទទួលសំណើ។ ដោយអនុលោមទៅតាមច្បាប់ និងការអនុវត្តនៅក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើត្រូវអនុវត្តសំណើតាមរបៀបបញ្ជាក់ជូនដោយភាគីដាក់សំណើ។ ប្រសិនបើមានការស្នើសុំឱ្យធ្វើដូច្នេះ និងអនុលោមទៅតាមច្បាប់ និងការអនុវត្តក្នុងរដ្ឋរបស់ខ្លួននោះភាគីទទួលសំណើ តំណាងឱ្យភាគីដាក់សំណើ ត្រូវចាត់វិធានការចាំបាច់ទាំងអស់នៅក្នុងដំណើរការរឿងក្ដីព្រហ្មទណ្ឌណាមួយ ដែលកើតចេញពីសំណើសុំជំនួយផ្នែកច្បាប់ ហើយបើមិនដូច្នេះទេ គឺត្រូវតំណាងឱ្យអត្ថប្រយោជន៍របស់ភាគីដាក់សំណើ។

ភាគីទទួលសំណើ ត្រូវឆ្លើយតបឱ្យបានឆាប់តាមដែលអាចធ្វើបានទៅនឹងសំណើសុំការស៊ើបអង្កេតដែលមានលក្ខណៈសមហេតុផលរបស់ភាគីដាក់សំណើស្ដីអំពីការរីកចម្រើនក្នុងការអនុវត្តសំណើ។ ភាគីទទួលសំណើអាចសុំឱ្យភាគីដាក់សំណើផ្ដល់ ព័ត៌មាននៅក្នុងទម្រង់ដែលអាចជាការចាំបាច់ ដើម្បីឱ្យខ្លួនអាចអនុវត្តសំណើ ឬចាត់វិធានការនានាដែលអាចចាំបាច់ យោងទៅតាមច្បាប់ និងការអនុវត្តរបស់ភាគីទទួលសំណើ ដើម្បីអនុវត្តឱ្យមានប្រសិទ្ធិភាពដល់សំណើ ដែលទទួលបានពីភាគីដាក់សំណើ។[57]

ចំណែកនៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាវិញបានកំណត់ថា នៅពេលដែលអាជ្ញាធរកណ្ដាលបានទទួលសំណើពីរដ្ឋផ្ញើសំណើ ហើយពិនិត្យឃើញថាសំណើនេះស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយនោះ អាជ្ញាធរកណ្ដាលបានបញ្ជូនសំណើនេះបន្តទៅអាជ្ញាធរអនុវត្តសំណើ ដើម្បីអនុវត្តសំណើដែលស្នើសុំនេះ។ បន្ទាប់ពីទទួលបានសំណើពីអាជ្ញាធរកណ្ដាល អាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធដូចជាស្ថាប័នរដ្ឋ ឬអយ្យការអមសាលាដំបូងរាជធានី/ខេត្ត ត្រូវអនុវត្តសំណើនេះ ដោយស្វែងរកព័ត៌មាន ឬឯកសារ ដើម្បីជាលទ្ធផលក្នុងការឆ្លើយតបទៅនឹងសំណើដែលរដ្ឋផ្ញើសំណើបានស្នើសុំនោះ។ ក្រោយពីបាន

[56] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១២។

[57] សន្ធិសញ្ញា ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា៧។

បញ្ចប់ការអនុវត្តសំណើ ដោយស្វែករកព័ត៌មាន ឬឯកសារបានគ្រប់គ្រាន់ហើយនោះ អាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវបញ្ជូនលទ្ធផលដោយភ្ជាប់មកជាមួយនូវឯកសារ និងវត្ថុពាក់ព័ន្ធមកអាជ្ញាធរកណ្ដាល ដើម្បីអាជ្ញាធរកណ្ដាលមានលទ្ធភាពក្នុងការបញ្ជូនលទ្ធផលនៃសំណើត្រឡប់ទៅរដ្ឋធ្វើសំណើវិញតាមរយៈស្ថាប័នសម្របសម្រួលដែលមានសមត្ថកិច្ច (ស្ថានទូត ឬស្ថានកុងស៊ុលរបស់រដ្ឋធ្វើសំណើដែលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា) ដូចមាននៅចំណុច ១.១.៧.ការបញ្ជូនលទ្ធផលនៃការអនុវត្តសំណើទៅរដ្ឋធ្វើសំណើ។

ក្នុងករណីមានឧបសគ្គ ឬមិនមានលទ្ធភាពអនុវត្តសំណើ អាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធត្រូវរាយការណ៍មកអាជ្ញាធរកណ្ដាលអំពីមូលហេតុនៃការខកខានក្នុងការអនុវត្តសំណើ។ ក្នុងករណីដែលសំណើមិនអាចអនុវត្តបាន ហើយអាជ្ញាធរកណ្ដាលត្រូវជូនដំណឹងទៅរដ្ឋធ្វើសំណើ តាមរយៈមធ្យោបាយដែលបានរៀបរាប់ខាងលើនេះ។[58]

### ១.១.៦. ការបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារ

ប្រសិនបើសន្ធិសញ្ញា ឬអនុសញ្ញាស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋធ្វើសំណើទាមទារឯកសារដែលមានការបញ្ជាក់ពីភាពត្រឹមត្រូវ អាជ្ញាធរកណ្ដាលត្រូវស្នើសុំឱ្យអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធធ្វើការបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារនោះ ស្របតាមទម្រង់ និងបែបបទដូចមានចែងក្នុងសន្ធិសញ្ញា ឬអនុសញ្ញា ឬតាមការកំណត់ដោយអាជ្ញាធរកណ្ដាល[59]។

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជាអនុម័តលើសន្ធិសញ្ញាដែលពាក់ព័ន្ធនឹងការធ្វើជំនួយផ្នែកច្បាប់ ដូចជាសន្ធិសញ្ញាទ្វេភាគីស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាង ព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម និងសន្ធិសញ្ញារួមស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃអាស៊ាន ឆ្នាំ២០០៤ ដែលជាសន្ធិសញ្ញារវាងរដ្ឋជាសមាជិកអាស៊ានពេញសិទ្ធិទាំងអស់។

### ១.១.៧. ការបញ្ជូនលទ្ធផលនៃការអនុវត្តសំណើទៅរដ្ឋធ្វើសំណើ

បន្ទាប់ពីអាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជា បានទទួលសំណើពីរដ្ឋធ្វើសំណើជាសមាជិកអាស៊ានណាមួយ នោះអាជ្ញាធរកណ្ដាលនៃរដ្ឋទទួលសំណើត្រូវបញ្ជូនឯកសារ ឬសំណើសុំនេះ ទៅអាជ្ញាធរធ្វើសំណើដែលជាស្ថាប័នរដ្ឋ ឬអយ្យការអមសាលាដំបូងរាជធានី/ខេត្តណាមួយ ដើម្បីអនុវត្តសំណើនេះ ឬឆ្លើយតបទៅនឹងសំណើសុំជំនួយផ្នែកច្បាប់របស់រដ្ឋធ្វើសំណើ។ បន្ទាប់ពីបានទទួលចម្លើយនៃការឆ្លើយតបទៅនឹងសំណើ ឬលទ្ធផលនៃការអនុវត្តសំណើពីអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធរួចមក អាជ្ញាធរកណ្ដាលត្រូវ

[58] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១៣។

[59] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១៤។

បញ្ជូនលទ្ធផលនេះដោយភ្ជាប់ជាមួយនូវឯកសារ និងវត្ថុពាក់ព័ន្ធប្រសិនបើមាន ទៅរដ្ឋធ្វើសំណើជាសមាជិកអាស៊ាន ក្រោមលក្ខខណ្ឌនៃការព្រមព្រៀងគ្នារវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋធ្វើសំណើ[60] ឬក្រោមសន្ធិសញ្ញារបស់អាស៊ាន ដែលបច្ចុប្បន្ននេះ អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជូនលទ្ធផលនៃការអនុវត្តសំណើទៅរដ្ឋធ្វើសំណើ តាមរយៈស្ថាប័នសម្របសម្រួលដែលមានសមត្ថកិច្ច (ស្ថានទូត ឬស្ថានកុងស៊ុលរបស់រដ្ឋធ្វើសំណើដែលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា)។

### ១.១.៨. ការរក្សាការសម្ងាត់

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា ដោយអនុលោមទៅតាមច្បាប់ក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើ ត្រូវចាត់វិធានការសមស្របទាំងអស់ដើម្បីរក្សាការសម្ងាត់ចំពោះសំណើសុំជំនួយផ្នែកច្បាប់ ខ្លឹមសារ និងឯកសារគាំទ្ររបស់សំណើ ហេតុការណ៍នៃការផ្តល់ជំនួយ និងចំណាត់ការណាមួយដែលអនុវត្តទៅតាមសំណើ។ ប្រសិនបើ សំណើមិនអាចអនុវត្តបានដោយគ្មានបំពានលើតម្រូវការរក្សាការសម្ងាត់ នោះភាគីទទួលសំណើត្រូវជូនដំណឹងឱ្យភាគីដាក់សំណើជ្រាបពីបញ្ហានេះ ហើយបន្ទាប់មក ភាគីដាក់សំណើត្រូវកំណត់ថា តើគួរតែនៅឱ្យអនុវត្តសំណើបន្តទៀត ឬមិនឱ្យអនុវត្តសំណើបន្តទៀតទេ។

អនុលោមតាមច្បាប់ក្នុងរដ្ឋរបស់ខ្លួន ភាគីដាក់សំណើត្រូវចាត់វិធានការសមស្របទាំងអស់ដើម្បី ៖

- រក្សាការសម្ងាត់នូវព័ត៌មាន និងភស្តុតាងដែលផ្តល់ឱ្យដោយភាគីទទួលសំណើ លើកលែងតែតាមវិសាលភាពថា ភស្តុតាង និងព័ត៌មាននោះ ចាំបាច់សម្រាប់គោលបំណងដែលបានរៀបរាប់នៅក្នុងសំណើ និង
- ធានាថា ព័ត៌មាន និងភស្តុតាង ត្រូវបានការពារមិនឱ្យបាត់បង់ និងការទទួលបានការប្រើប្រាស់ ការកែប្រែ ការបង្ហាញដោយគ្មានការអនុញ្ញាត ឬការប្រើប្រាស់មិនត្រឹមត្រូវផ្សេងៗ។[61]

ចំណែកនៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាវិញ បានកំណត់ឱ្យអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់រាល់វិធានការសមស្របដើម្បីរក្សាការសម្ងាត់នៃខ្លឹមសារ នៃការធ្វើសំណើសុំជំនួយផ្នែកច្បាប់ ឯកសារយោងនៃសំណើ ការសម្រេចផ្តល់ជំនួយ និងចំណាត់ការណាមួយនៃការអនុវត្តសំណើសុំជំនួយផ្នែកច្បាប់នេះ ប្រសិនបើមានការស្នើសុំឱ្យរក្សាការសម្ងាត់ពីសំណាក់រដ្ឋធ្វើសំណើ។ ប្រសិនបើសំណើសុំជំនួយផ្នែកច្បាប់នោះមិនអាចអនុវត្តបាន ហើយដោយមិនអាចបំពានលើតម្រូវការរក្សាការសម្ងាត់ទេនោះ អាជ្ញាធរកណ្តាលត្រូវជូនដំណឹងអំពីបញ្ហានេះ ទៅឱ្យរដ្ឋធ្វើសំណើបានដឹង និងដើម្បីកំណត់ថា "តើសំណើត្រូវអនុវត្តដែរ ឬទេ"។

[60] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១៥។

[61] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា៩។

អាជ្ញាធរកណ្ដាលអាចសុំឱ្យរដ្ឋធ្វើសំណើរក្សាការសម្ងាត់ចំពោះព័ត៌មាន ឬភស្តុតាងដែលផ្តល់ឱ្យ ឬប្រភពនៃព័ត៌មាន ឬភស្តុតាងទាំងនោះ។ អាជ្ញាធរកណ្ដាលត្រូវភ្ជាប់នូវលក្ខខណ្ឌទាក់ទងនឹងការប្រើប្រាស់ ឬការទម្លាយព័ត៌មាន ឬភស្តុតាងទាំងនោះ នៅពេលបញ្ជូនលទ្ធផលនៃការអនុវត្តសំណើទៅកាន់រដ្ឋធ្វើសំណើវិញ។[62]

### ១.២. វិធានជាក់លាក់ (នីតិវិធីដោយឡែក)

#### ១.២.១. ជំនួយទាក់ទងនឹងការស្ដាប់ចម្លើយ និងការប្រមូលភស្តុតាង

##### ១.២.១.១. គោលការណ៍ទាក់ទងនឹងការស្ដាប់ចម្លើយ

នៅពេលដែលរដ្ឋធ្វើសំណើ ធ្វើសំណើសុំជំនួយផ្នែកច្បាប់មកព្រះរាជាណាចក្រកម្ពុជាដោយស្នើសុំការស្តាប់ចម្លើយរបស់បុគ្គលណាមួយដែលអាចជាជនជាប់ឃុំ (ជនត្រូវចោទ ជនជាប់ចោទ ពិរុទ្ធជន និងទណ្ឌិត) ឬជនជាប់សង្ស័យដែលពាក់ព័ន្ធនឹងបុគ្គលដែលបានប្រព្រឹត្តបទល្មើស ហើយបន្ទាប់មកអាជ្ញាធរកណ្ដាលបានពិនិត្យ និងបញ្ជូនសំណើនេះទៅកាន់អាជ្ញាធរអនុវត្តសំណើដើម្បីចាត់ការលើសំណើដែលស្នើសុំនេះ។ បន្ទាប់ពីទទួលបានសំណើសុំឱ្យស្តាប់ចម្លើយពីបុគ្គលណាមួយពីអាជ្ញាធរកណ្ដាល អាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធត្រូវកំណត់ទីតាំងរបស់បុគ្គលនោះ ហើយស្នើឱ្យបុគ្គលនោះផ្តល់ចម្លើយដោយអនុលោមទៅតាមសំណើរបស់រដ្ឋធ្វើសំណើដែលស្នើសុំ។ បើមានសំណើសុំឱ្យយកចម្លើយពីជនណាម្នាក់ សម្រាប់គោលបំណងនៃរឿងក្តីព្រហ្មទណ្ឌរបស់ភាគីដាក់សំណើ នោះភាគីទទួលសំណើ ដោយមានការយល់ព្រមពីជននោះ ត្រូវខិតខំខ្នះខ្នែងដើម្បីទទួលយកចម្លើយនោះ។ ប្រសិនបើបុគ្គលនោះបដិសេធក្នុងការផ្តល់ចម្លើយតាមការស្នើសុំរបស់រដ្ឋធ្វើសំណើនោះអាជ្ញាធរអនុវត្តសំណើត្រូវរាយការណ៍អំពីព័ត៌មាននៃការបដិសេធមិនព្រមផ្តល់ចម្លើយនេះ ទៅកាន់អាជ្ញាធរកណ្ដាល ដើម្បីអាជ្ញាធរកណ្ដាលអាចបញ្ជូនព័ត៌មានអំពីការបដិសេធនេះទៅរដ្ឋធ្វើសំណើវិញ។[63]

##### ១.២.១.២. នីតិវិធីនៃការអនុវត្តសំណើទាក់ទងនឹងការស្តាប់ចម្លើយនិងការប្រមូលភស្តុតាង

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា យោងទៅតាមច្បាប់ក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើត្រូវរៀបចំទទួលយកភស្តុតាងរួមមាន សក្ខីភាព ឯកសារ ឬរបាយការណ៍ដែលមានបញ្ជាក់ថាពិត ទទួលពីសាក្សីសម្រាប់គោលបំណងនៃរឿងក្តីព្រហ្មទណ្ឌដើម្បីបញ្ជូនទៅឱ្យភាគីដាក់សំណើ។ នៅក្នុងចំណុចនេះ មិនបានរារាំងការប្រើប្រាស់ការតភ្ជាប់វីដេអូ ឬទូរទស្សន៍ដែលបញ្ចាំងផ្ទាល់ ឬឧបករណ៍សំរួលដល់ការប្រាស្រ័យទាក់ទងសមស្របដទៃទៀត ដោយអនុលោមតាមច្បាប់ និងការអនុវត្តរបស់ភាគីទទួលសំណើ ក្នុងគោលបំណងអនុវត្តមាត្រានេះ ប្រសិនបើការប្រើប្រាស់ឧបករណ៍ទាំងអស់នេះបម្រើដល់ផលប្រយោជន៍យុត្តិធម៌។[64]

---

[62] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១៦។

[63] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១៧។

[64] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១១។

ជនដែលតម្រូវឱ្យផ្តល់សក្ខីភាព ឬបង្កើតឯកសារ ឬរបាយការណ៍ ឬភស្តុតាងផ្សេងៗ ដោយមានការបញ្ជាក់ថាត្រឹមត្រូវ នៅក្នុងដែនដីនៃភាគីទទួលសំណើអាចបដិសេធមិនធ្វើ ប្រសិនបើ៖

- ច្បាប់របស់ភាគីដាក់សំណើអនុញ្ញាត ឬតម្រូវឱ្យជននោះ បដិសេធក្នុងការធ្វើយ៉ាងដូច្នេះ នៅក្នុងកាលៈទេសៈដូចគ្នា នៅក្នុងដំណើរការរឿងក្តីធ្វើឡើងនៅក្នុងភាគីទទួលសំណើ ឬ
- ច្បាប់របស់ភាគីដាក់សំណើអនុញ្ញាត ឬតម្រូវឱ្យជននោះ បដិសេធក្នុងការធ្វើដូច្នេះ នៅក្នុងកាលៈទេសៈដូចគ្នា នៅក្នុងដំណើរការរឿងក្តីធ្វើឡើងនៅក្នុងភាគីដាក់សំណើ។[65]

ប្រសិនបើជននេះ អះអាងថាមានសិទ្ធិបដិសេធក្នុងការផ្តល់សក្ខីភាព ឬបង្កើតឯកសារ ឬរបាយការណ៍ ឬភស្តុតាងផ្សេងៗ ដោយមានការបញ្ជាក់ថាត្រឹមត្រូវ ភាគីដាក់សំណើត្រូវផ្តល់លិខិតបញ្ជាក់ដល់ភាគីទទួលសំណើពីវត្តមាននៃសិទ្ធិនេះ ឬអវត្តមាននៃសិទ្ធិនោះ។

នៅពេលបញ្ចប់រឿងក្តីព្រហ្មទណ្ឌទាក់ទងដល់សំណើសុំជំនួយ ភាគីដាក់សំណើត្រូវបញ្ជូនត្រឡប់ទៅឱ្យភាគីទទួលសំណើវិញនូវឯកសារ កំណត់ហេតុ ឬសម្ភារៈដែលបានផ្តល់ជូនភាគីដាក់សំណើយោងតាមសំណើក្រោមសន្ធិសញ្ញានេះ។

ភាគីដាក់សំណើនៅពេលណាក៏ដោយ បើមានសំណើត្រូវបញ្ជូនត្រឡប់មកឱ្យភាគីទទួលសំណើវិញជាបណ្តោះអាសន្ននូវឯកសារ កំណត់ហេតុ ឬសម្ភារៈដែលបានផ្តល់ជូនភាគីដាក់សំណើ ប្រសិនបើភាគីទទួលសំណើត្រូវការចាំបាច់ចំពោះឯកសារ កំណត់ហេតុ ឬសម្ភារៈទាំងនេះ នៅក្នុងរឿងក្តីព្រហ្មទណ្ឌរបស់ខ្លួន។[66]

ចំណែកនៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា នៅពេលទទួលបានសំណើពីរដ្ឋធ្វើសំណើឱ្យស្តាប់ចម្លើយ ឬប្រមូលភស្តុតាង ដោយផ្អែកតាមនីតិវិធីតុលាការកម្ពុជា អាជ្ញាធរកណ្តាលត្រូវបញ្ជូនសំណើទៅអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធ។

នីតិវិធីដែលបានកំណត់ដោយរដ្ឋធ្វើសំណើត្រូវយកមកអនុវត្ត លើកលែងតែនីតិវិធីនោះផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីដែលនីតិវិធីនោះផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬពុំមានការកំណត់អំពីនីតិវិធីនៅក្នុងសំណើទេ នីតិវិធីនៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាត្រូវយកមកអនុវត្ត លើកលែងតែមានការព្រមព្រៀងផ្សេងរវាងព្រះរាជាណាចក្រកម្ពុជានិងរដ្ឋធ្វើសំណើ។

ក្រោយពីបញ្ចប់ការអនុវត្តសំណើ អាជ្ញាធរអនុវត្តសំណើត្រូវបញ្ជូនកំណត់ហេតុស្តាប់ចម្លើយ ឬភស្តុតាងដែលប្រមូលបានទៅអាជ្ញាធរកណ្តាលដើម្បីចាត់ការបន្ត។[67]

[65] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១២។

[66] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១៩។

[67] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១៨។

### ១.២.២. ជំនួយទាក់ទងនឹងការឆែកឆេរ និងការចាប់យក

#### ១.២.២.១. គោលការណ៍ទាក់ទងនឹងការឆែកឆេរ និងការចាប់យក

នៅពេលទទួលបានសំណើពីរដ្ឋផ្ញើសំណើសុំឱ្យឆែកឆេរ ឬចាប់យកវត្ថុ ដើម្បីជាប្រយោជន៍នៃការប្រមូលភស្តុតាង អាជ្ញាធរកណ្តាលត្រូវបញ្ជូនសំណើនោះទៅអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ច ដើម្បីអនុវត្តទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

អាជ្ញាធរអនុវត្តសំណើ អាចឆែកឆេរនិងចាប់យកទ្រព្យឬវត្ថុ ដែលជាឧបករណ៍មធ្យោបាយប្រព្រឹត្តបទល្មើស ត្រូវបានប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសឬជាផលនៃបទល្មើស។ អាជ្ញាធរអនុវត្តសំណើក៏អាចឆែកឆេរ និងចាប់យកឯកសារ ឬព័ត៌មានដែលកំណត់ពីអត្តសញ្ញាណនៃទ្រព្យ ឬវត្ថុដែលជាឧបករណ៍មធ្យោបាយប្រព្រឹត្តបទល្មើស ឬជាផលនៃបទល្មើសផងដែរ។

ក្នុងករណីដែលសំណើទាក់ទងនឹងព័ត៌មានដែលកាន់កាប់ដោយស្ថាប័នធនាគារ ឬស្ថាប័នហិរញ្ញវត្ថុ ឬអង្គភាព ឬបុគ្គលផ្សេងទៀត អាជ្ញាធរអនុវត្តសំណើមានសិទ្ធិអំណាចតាមច្បាប់នេះ ឱ្យស្ថាប័នធនាគារ ឬស្ថាប័នហិរញ្ញវត្ថុ ឬអង្គភាព ឬបុគ្គលនោះផ្តល់ព័ត៌មាន ដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[68]

#### ១.២.២.២. នីតិវិធីអនុវត្តទាក់ទងការឆែកឆេរ និងការចាប់យក

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា ដោយអនុលោមតាមច្បាប់ក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើត្រូវអនុវត្តសំណើសុំឆែកឆេរ រឹបអូស និងប្រគល់ឯកសារ កំណត់ហេតុ ឬសម្ភារៈណាមួយ ឱ្យទៅភាគីដាក់សំណើ ប្រសិនបើមានហេតុផលសមរម្យជឿថា ឯកសារ កំណត់ហេតុ ឬសម្ភារៈទាំងនោះ មានជាប់ពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌនៅក្នុងភាគីដាក់សំណើ។

ភាគីដាក់សំណើត្រូវគោរពទៅតាមលក្ខខណ្ឌនានាដែលភាគីទទួលសំណើបានដាក់ ទាក់ទងទៅនឹងការរឹបអូសឯកសារ កំណត់ហេតុ ឬសម្ភារៈណាមួយ ដែលអាចត្រូវប្រគល់ជូនភាគីដាក់សំណើ ហើយដែលភាគីទទួលសំណើយល់ឃើញថាចាំបាច់ដើម្បីការពារ ឯកសារ កំណត់ហេតុ ឬសម្ភារៈ ដែលបានផ្ទេរទាំងនោះ។

ភាគីទទួលសំណើ ត្រូវជូនដំណឹងទៅភាគីដាក់សំណើ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបានពីលទ្ធផលនៃការឆែកឆេរ ទីកន្លែង និងកាលៈទេសៈនៃការរឹបអូស និងការថែរក្សា ឯកសារ កំណត់ហេតុ ឬសម្ភារៈដែលបានដកហូតជាបន្តបន្ទាប់មក។[69]

នៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ឱ្យ អាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចធ្វើការឆែកឆេរ និងការចាប់យកវត្ថុតាមសំណើ ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ និងការចាប់យកវត្ថុ ដោយ

---

[68] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា១៩។

[69] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១៨។

អនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង បញ្ជូនកំណត់ហេតុ និងវត្ថុដែលបានចាប់យកនោះទៅអាជ្ញាធរកណ្តាលដើម្បីអនុវត្តបន្ត។ កំណត់ហេតុនោះត្រូវធ្វើតាមទម្រង់ និងបែបបទដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ បទប្បញ្ញត្តិដទៃទៀតទាក់ទងនឹងការឆែកឆេរ និងការចាប់យកដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ត្រូវយកមកអនុវត្តផងដែរ ទោះបីជាបទល្មើសដែលនាំឱ្យមានការឆែកឆេរ ឬការចាប់យកនោះមិនកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដោយ។[70]

### ១.២.៣. ជំនួយទាក់ទងនឹងការផ្តល់ឯកសារ និងព័ត៌មាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋ

#### ១.២.៣.១. នីតិវិធីអនុវត្តទាក់ទងនឹងសំណើសុំឯកសារ ឬព័ត៌មាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋ

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា នៅក្នុងភាគីទទួលសំណើ ត្រូវផ្តល់ឱ្យភាគីដាក់សំណើនូវច្បាប់ចម្លងនៃឯកសារ ឬរបាយការណ៍ដែលមានជាសាធារណៈ ជាកម្មសិទ្ធិរបស់ក្រសួង និងស្ថាប័នរដ្ឋាភិបាល។

អនុលោមតាមច្បាប់ និងការអនុវត្តក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើអាចផ្តល់ឱ្យភាគីដាក់សំណើនូវច្បាប់ចម្លងនៃឯកសារ ឬរបាយការណ៍ណាមួយ ដែលជាកម្មសិទ្ធិរបស់ក្រសួង និងស្ថាប័នរដ្ឋាភិបាល ប៉ុន្តែមិនប្រើសម្រាប់ជាសាធារណៈនោះទេ។ ភាគីទទួលសំណើ អាចប្រើឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីបដិសេធទាំងស្រុង ឬដោយផ្នែកខ្លះចំពោះសំណើ ដោយអនុលោមតាមកថាខណ្ឌនេះ។[71]

នៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា នៅពេលទទួលបានសំណើពីរដ្ឋធ្វើសំណើដែលស្នើសុំឯកសារ ឬព័ត៌មានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋណាមួយនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរកណ្តាលត្រូវបញ្ជូនសំណើនោះទៅស្ថាប័នរដ្ឋដែលមានការពាក់ព័ន្ធដើម្បីអនុវត្តសំណើរបស់រដ្ឋធ្វើសំណើ។ ស្ថាប័នរដ្ឋនោះត្រូវផ្តល់លទ្ធផលនៃការអនុវត្តសំណើទៅអាជ្ញាធរកណ្តាល។[72]

#### ១.២.៣.២. លក្ខខណ្ឌនៃការផ្តល់ឯកសារ ឬព័ត៌មាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋ

ប្រសិនបើឯកសារ ឬព័ត៌មាន ដែលជាកម្មវត្ថុនៃសំណើរបស់រដ្ឋធ្វើសំណើ ដូចមាននៅក្នុងចំណុច១.២.៣.១ (នីតិវិធីអនុវត្តទាក់ទងនឹងសំណើសុំឯកសារ ឬព័ត៌មាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋ) ខាងលើជាឯកសារ ឬព័ត៌មានដែលមិនអាចផ្សព្វផ្សាយបាន ហើយស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងឯកសារ ឬព័ត៌មាននោះ ចាត់ទុកថាឯកសារ ឬព័ត៌មាននោះមិនអាចផ្តល់ជូនបានដោយសារភាពសម្ងាត់នៃឯកសារ ឬព័ត៌មាននោះ ឬអាចត្រូវបានផ្តល់ឱ្យក្រោមលក្ខខណ្ឌជាក់លាក់ ស្ថាប័នសាមីត្រូវជូនដំណឹងទៅអាជ្ញាធរកណ្តាលអំពីមូលហេតុនោះ ឬអំពីលក្ខខណ្ឌសម្រាប់ការផ្តល់ជូនឯកសារ ឬព័ត៌មានដែលបានស្នើសុំ។[73]

---

[70] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២០។

[71] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១៣។

[72] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២១។

[73] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២២។

**១.២.៣.៣.ការបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្ថាប័នរដ្ឋ**

ក្នុងការផ្តល់ឯកសារតាមសំណើរបស់រដ្ឋផ្ញើសំណើ ដូចមានចែងក្នុងអនុផ្នែកនេះ អាជ្ញាធរកណ្តាលត្រូវស្នើសុំឱ្យអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារ ដោយអនុលោមតាមទម្រង់ បែបបទ និងលក្ខខណ្ឌ ដែលត្រូវបានស្នើសុំដោយរដ្ឋផ្ញើសំណើដូចមានចែងក្នុងសន្ធិសញ្ញា ឬអនុសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋផ្ញើសំណើ ឬតាមការកំណត់ដោយអាជ្ញាធរកណ្តាល។[74]

**១.២.៤. ជំនួយទាក់ទងនឹងសេវាកម្មឯកសារតុលាការ**

**១.២.៤.១. ការអនុវត្តសំណើទាក់ទងនឹងសេវាកម្មឯកសារតុលាការ**

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា ដោយអនុលោមតាមច្បាប់ក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើត្រូវប្រើប្រាស់ឱ្យអស់នូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីផ្តល់សេវាផ្នែកឯកសារណាមួយទាក់ទងនឹងរឿងក្តីព្រហ្មទណ្ឌ ដែលចេញដោយតុលាការរបស់ភាគីដាក់សំណើ។ ភាគីដាក់សំណើ ត្រូវបញ្ជូនសំណើសម្រាប់សេវាឯកសារ ដែលតម្រូវឱ្យមានការឆ្លើយតប ឬការបង្ហាញខ្លួននៅក្នុងភាគីដាក់សំណើ មិនឱ្យយឺតជាង ៣០ថ្ងៃមុនកាលកំណត់ឱ្យឆ្លើយតប ឬការបង្ហាញខ្លួនឡើយ។ ភាគីទទួលសំណើ ត្រូវបញ្ជូនត្រឡប់មកវិញនូវសំអាងនៃសេវា នៅក្នុងរបៀបដែលបានព្រមព្រៀងគ្នាទៅវិញទៅមកដោយភាគីពាក់ព័ន្ធ។[75]

នៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា នៅពេលទទួលបានសំណើពីរដ្ឋផ្ញើសំណើឱ្យផ្តល់សេវាកម្មឯកសារតុលាការ អាជ្ញាធរកណ្តាលត្រូវបញ្ជូនសំណើទៅអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ច ហើយអាជ្ញាធរអនុវត្តសំណើនោះត្រូវអនុវត្តសំណើនិងផ្តល់លទ្ធផលនៃការអនុវត្តទៅអាជ្ញាធរកណ្តាលវិញ។

អាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចអនុវត្តសំណើ អាចប្រើប្រាស់គ្រប់មធ្យោបាយស្របតាមបទប្បញ្ញត្តិនៃច្បាប់ដើម្បីអនុវត្តសំណើឱ្យបានឆាប់រហ័ស។

ប្រសិនបើឯកសារតុលាការដែលត្រូវបញ្ជូន បង្គាប់ឱ្យបុគ្គលណាមួយបង្ហាញខ្លួននៅចំពោះមុខមន្ត្រី ឬតុលាការនៅក្នុងរដ្ឋផ្ញើសំណើ អាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចត្រូវបញ្ជូនឯកសារនោះទៅបុគ្គលនោះក្នុងរយៈពេលសមស្របមុនកាលបរិច្ឆេទដែលត្រូវបង្ហាញខ្លួននៅក្នុងរដ្ឋផ្ញើសំណើ។

លទ្ធផលនៃការបញ្ជូនឯកសារតុលាការត្រូវរាយការណ៍តាមទម្រង់ និងបែបបទដែលកំណត់ដោយអាជ្ញាធរកណ្តាល លើកលែងតែមានសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋផ្ញើសំណើចែងផ្សេងពីនេះ។

[74] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២៣។

[75] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា២១។

អាជ្ញាធរកណ្តាលត្រូវបញ្ជូនបន្តទៅរដ្ឋធ្វើសំណើនូវភស្តុតាងនៃការបញ្ជូនឯកសារតុលាការ។ ប្រសិនបើការបញ្ជូនឯកសារនោះមិនអាចសម្រេចបាន អាជ្ញាធរកណ្តាលត្រូវជូនដំណឹងទៅរដ្ឋធ្វើសំណើដោយបញ្ជាក់ពីមូលហេតុនៃការមិនអាចសម្រេចបាននៃការបញ្ជូនឯកសារនោះ។[76]

**១.២.៤.២. ភាពគ្មានទោសចំពោះការមិនអនុវត្តតាមដីកាកោះរបស់រដ្ឋធ្វើសំណើ**

ប្រសិនបើបុគ្គលណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានកោះហៅជាសាក្សីនៅក្នុងរដ្ឋធ្វើសំណើ បុគ្គលនោះមិនត្រូវទទួលរងនូវការទទួលខុសត្រូវណាមួយទាំងខាងព្រហ្មទណ្ឌ ទាំងខាងរដ្ឋប្បវេណី នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយសារការបដិសេធ ឬការខកខានមិនបានអនុវត្តតាមដីកាកោះនោះឡើយ ទោះបីជាការបដិសេធ ឬការខកខាននោះ ផ្ទុយទៅនឹងការកំណត់នៅក្នុងដីកាកោះនោះក៏ដោយ។[77]

**១.២.៥.ជំនួយទាក់ទងនឹងការផ្ទេរបុគ្គលជាប់ឃុំដើម្បីផ្តល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេតក្នុងរដ្ឋធ្វើសំណើ**

**១.២.៥.១.លក្ខខណ្ឌនៃការផ្ទេរបុគ្គលជាប់ឃុំ ដើម្បីផ្តល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេតក្នុងរដ្ឋធ្វើសំណើ**

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា ដោយអនុលោមទៅតាមច្បាប់ និងការអនុវត្តនៅក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើអាចជួយរៀបចំឱ្យជនណាមួយដែលមានវត្តមានមាននៅក្នុងភាគីទទួលសំណើចូលទៅក្នុងភាគីដាក់សំណើ ដោយយោងតាមការយល់ព្រមពីជននោះ ៖

- ជួយក្នុងការស៊ើបអង្កេត ទាក់ទងនឹងរឿងក្តីព្រហ្មទណ្ឌ នៅក្នុងភាគីដាក់សំណើ ឬ
- ចូលខ្លួនក្នុងដំណើរការរឿងក្តីព្រហ្មទណ្ឌណាមួយនៅក្នុងភាគីដាក់សំណើ លើកលែងតែជននោះគឺជាជនដែលត្រូវចោទប្រកាន់។

ប្រសិនបើភាគីទទួលសំណើ ពេញចិត្តនឹងការរៀបចំសម្រាប់សុវត្ថិភាពរបស់ជននោះ ដែលនឹងត្រូវធ្វើឡើងដោយភាគីដាក់សំណើ នោះភាគីទទួលសំណើត្រូវអញ្ជើញជននោះឱ្យមកបង្ហាញ ឬផ្តល់ភស្តុតាង ឬជំនួយទាក់ទងរឿងក្តីព្រហ្មទណ្ឌនៅក្នុងភាគីដាក់សំណើ។ ជននោះត្រូវទទួលបានព័ត៌មានអំពីការចំណាយ ឬប្រាក់ឧបត្ថម្ភសម្រាប់បង់ឱ្យខ្លួន។

ប្រសិនបើជននោះយល់ព្រម ភាគីទទួលសំណើត្រូវជូនដំណឹងភ្លាមដល់ភាគីដាក់សំណើពីការឆ្លើយតបរបស់ជននោះ និងចាត់វិធានការចាំបាច់នានាដើម្បីបង្កលក្ខណៈងាយស្រួលដល់វត្តមានរបស់ជននោះនៅក្នុងភាគីដាក់សំណើ។

[76] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២៤។
[77] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២៥។

នៅក្នុងមាត្រានេះគ្មានការរារាំង ដល់ការប្រើប្រាស់ ការតភ្ជាប់បណ្តាញជាវីដេអូ ឬទូរទស្សន៍បញ្ចាំងដោយផ្ទាល់ ឬឧបករណ៍ប្រាស្រ័យទាក់ទងសមស្របដទៃទៀតនោះទេ យោងទៅតាមច្បាប់ និងការអនុវត្តរបស់ភាគីទទួលសំណើ ប្រសិនបើវាបម្រើដល់ផលប្រយោជន៍យុត្តិធម៌ឱ្យធ្វើដូចនេះ។[78]

នៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា នៅពេលទទួលបានសំណើសុំឱ្យផ្ទេរបណ្តោះអាសន្ននូវបុគ្គលណាមួយដែលស្ថិតក្នុងការឃុំខ្លួន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្តល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេតក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការក្នុងឋានៈជាសាក្សីក្នុងរដ្ឋធ្វើសំណើ អាជ្ញាធរកណ្តាលត្រូវបញ្ជូនសំណើសុំទៅអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចដើម្បីចាត់ការ ដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាប្រសិនបើអាជ្ញាធរកណ្តាលចាត់ទុកថាការផ្ទេរនោះមានការចាំបាច់។

ការផ្ទេរបុគ្គលជាប់ឃុំនេះអាចធ្វើទៅបាន ដោយគោរពលក្ខខណ្ឌដូចតទៅ៖

- បុគ្គលជាប់ឃុំស្ម័គ្រចិត្តយល់ព្រមចំពោះការផ្ទេរដើម្បីផ្តល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេតដែលបានស្នើសុំនោះ និង
- រដ្ឋធ្វើសំណើយល់ព្រមគោរពតាមលក្ខខណ្ឌជាក់លាក់ ដែលបានតម្រូវដោយអាជ្ញាធរកណ្តាល ជាអាទិ៍ ពាក់ព័ន្ធនឹងចំណាយនានាទាក់ទងនឹងការអនុវត្តជំនួយនេះ ព្រមទាំងវិធានផ្នែកសុវត្ថិភាពដូចជាការឃុំខ្លួន និងការធានាសុវត្ថិភាពរបស់បុគ្គលជាប់ឃុំដែលត្រូវបានផ្ទេរ ការមិនទទួលរងការចោទប្រកាន់ចំពោះបុគ្គលជាប់ឃុំពីបទល្មើសព្រហ្មទណ្ឌណាមួយក្នុងរដ្ឋធ្វើសំណើ និងការប្រគល់ត្រឡប់មកវិញនូវបុគ្គលជាប់ឃុំ។[79]

#### ១.២.៥.២. ថិរវេលានៃការឃុំខ្លួនបុគ្គលជាប់ឃុំ

ថិរវេលានៃការផ្ទេរបុគ្គលជាប់ឃុំទៅរដ្ឋធ្វើសំណើ និងថិរវេលានៃការឃុំខ្លួនរបស់បុគ្គលជាប់ឃុំក្នុងរដ្ឋធ្វើសំណើដើម្បីផ្តល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេត ត្រូវរាប់បញ្ចូលជាថិរវេលានៃការឃុំខ្លួនបុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[80]

#### ១.២.៥.៣. ការឆ្លងកាត់របស់បុគ្គលជាប់ឃុំ

- ❖ **ការបញ្ជូនជនជាប់ឃុំឃាំងទៅភាគីដាក់សំណើ**

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា ដោយអនុលោមតាមច្បាប់ក្នុងរដ្ឋ និងការអនុវត្តរបស់ខ្លួនភាគីទទួលសំណើអាចយល់ព្រមអនុញ្ញាតឱ្យជនជាប់ឃុំឃាំងនៅក្នុងភាគីទទួលសំណើ ផ្ទេរជាបណ្តោះអាសន្នទៅឱ្យភាគីដាក់សំណើ ដើម្បីផ្តល់ភស្តុតាង ឬជួយនៅក្នុងការស៊ើបអង្កេត បើមានការយល់ព្រមពីជននោះ។

---

[78] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១៤។

[79] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២៦។

[80] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២៧។

បើជនត្រូវផ្ទេរតម្រូវឱ្យធ្វើការឃុំឃាំង យោងតាមច្បាប់របស់ភាគីទទួលសំណើ នោះភាគីដាក់សំណើត្រូវឃុំខ្លួនជននោះ និងត្រូវបញ្ជូនជនជាប់ឃុំឃាំងនោះមកឱ្យភាគីទទួលសំណើវិញ នៅពេលបញ្ចប់រឿងក្តីទាក់ទងនឹងការស្នើសុំផ្ទេរ ឬ បញ្ជូនត្រឡប់មកភ្លាមនៅពេលវត្តមានរបស់ជននោះ លែងតម្រូវតទៅទៀតហើយ។

នៅពេលភាគីទទួលសំណើ ជូនដំណឹងដល់ភាគីដាក់សំណើថា ជនដែលផ្ទេរនោះ លែងតម្រូវឱ្យឃុំខ្លួនតទៅទៀតហើយ ជននោះនឹងត្រូវបានដោះលែងពីការឃុំខ្លួន ហើយត្រូវទទួលបានការប្រព្រឹត្តចំពោះខ្លួន ដូចជនដែលផ្ទេរនៅក្នុងមាត្រា ១៤ នៃសន្ធិសញ្ញានេះ។

ភាគីដាក់សំណើ មិនតម្រូវឱ្យភាគីទទួលសំណើផ្តួចផ្តើមដំណើរការនីតិវិធីបត្យាប័ន សម្រាប់ការបញ្ជូនជនដែលផ្ទេរនោះត្រឡប់មកវិញឡើយ។

រយៈពេលជននេះស្ថិតក្រោមការឃុំខ្លួនដោយភាគីដាក់សំណើ ត្រូវរាប់បញ្ចូលទៅក្នុងរយៈពេលនៃការជាប់ពន្ធនាគារ ឬ ឃុំឃាំងនៅក្នុងភាគីទទួលសំណើ។

ការផ្ទេរតាមមាត្រានេះ មិនអាចប្រព្រឹត្តទៅបាននោះទេ បើគ្មានការធានារ៉ាប់រងពីភាគីដាក់សំណើថា ៖

- ទទួលខុសត្រូវលើការចំណាយទាំងអស់ក្នុងការផ្ទេរជនជាប់ឃុំឃាំង។
- រក្សាទុកជននោះឱ្យស្ថិតនៅក្រោមការឃុំខ្លួនស្របច្បាប់ នៅក្នុងអំឡុងពេលនៃការផ្ទេរជនជាប់ឃុំឃាំងនោះ និង
- ត្រូវបញ្ជូនជននោះ មកឱ្យស្ថិតនៅក្រោមការឃុំឃាំងរបស់ភាគីទទួលសំណើវិញភ្លាម បន្ទាប់ពីវត្តមានរបស់ជននោះនៅចំពោះមុខអាជ្ញាធរ ឬតុលាការមានសមត្ថកិច្ចរបស់ភាគីដាក់សំណើលែងត្រូវការតទៅទៀតហើយ។

នៅក្នុងមាត្រានេះគ្មានការរារាំង ដល់ការប្រើប្រាស់ការតភ្ជាប់បណ្តាញជាវីដេអូ ឬទូរទស្សន៍បញ្ចាំងដោយផ្ទាល់ ឬឧបករណ៍ប្រាស្រ័យទាក់ទងសមស្របដទៃទៀតនោះទេ យោងទៅតាមច្បាប់ និងការអនុវត្តន៍របស់ភាគីទទួលសំណើ ប្រសិនបើវាបម្រើដល់ផលប្រយោជន៍យុត្តិធម៌ឱ្យធ្វើដូចនេះ។[81]

### ❖ ការឆ្លងកាត់របស់ជនស្ថិតនៅក្នុងការឃុំឃាំង

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា យោងតាមច្បាប់ និងការអនុវត្តនៅក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើអាចអនុញ្ញាតឱ្យ ភាគីដាក់សំណើ ឬរដ្ឋទីបី បញ្ជូនជនស្ថិតនៅក្នុងការឃុំឃាំងឆ្លងកាត់ទឹកដីរបស់ខ្លួន។ ការបង្ហាញខ្លួនដោយផ្ទាល់របស់ ជននោះនៅក្នុងរឿងក្តីព្រហ្មទណ្ឌ បានស្នើសុំឡើងដោយភាគីដាក់សំណើ។

---

[81] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១៥។

បើជននោះត្រូវបានដឹកជញ្ជូន ចុះចត ឬឈប់ ដោយយន្តហោះ នាវា ឬរថភ្លើង នៅក្នុងភាគីទទួលសំណើ នោះមន្ត្រីទទួលបន្ទុកគ្រប់គ្រង ឬការពាររបស់ភាគីដាក់សំណើ ឬបើអាចអនុវត្តទៅបាន ប្រទេសទីបី ដែលជួយភាគីដាក់សំណើ ដើម្បីបង្កភាពងាយស្រួលដល់ការបញ្ជូននោះ ត្រូវបន្តទទួលខុសត្រូវលើការឃុំឃាំងជនដែលត្រូវដឹកជញ្ជូននោះ នៅពេលជននោះធ្វើដំណើរឆ្លងកាត់ភាគីទទួលសំណើ លើកលែងតែភាគីទទួលសំណើមានការយល់ព្រមផ្សេងពីនេះ។

ដោយមិនធ្វើឱ្យប៉ះពាល់ដល់កថាខណ្ឌ ២ និងដោយមានការយល់ព្រមពីភាគីទទួលសំណើ ជនដែលត្រូវដឹកជញ្ជូន អាចត្រូវរក្សាទុកជាបណ្ដោះអាសន្នឱ្យស្ថិតនៅការឃុំខ្លួន របស់អាជ្ញាធរមានសមត្ថកិច្ចនៃភាគីទទួលសំណើ រហូតដល់ការដឹកជញ្ជូនជននេះចាប់បន្តដំណើរទៀត។

បើជនស្ថិតក្រោមការឃុំឃាំងនៅក្នុងភាគីទទួលសំណើ កំពុងធ្វើដំណើរឆ្លងកាត់ ហើយការដឹកជញ្ជូនជននោះ មិនអាចបន្តដំណើរនៅក្នុងពេលវេលាសមហេតុផលនោះទេ ភាគីទទួលសំណើអាចបង្គាប់ឱ្យដឹកជញ្ជូននោះយកទៅឃុំខ្លួននៅក្នុងរដ្ឋទីមួយដែលជននោះត្រូវបានគេដឹកជញ្ជូនចេញមក។

រាល់ការចេញចំណាយនិងសោហ៊ុយរបស់រដ្ឋទទួលសំណើ ទាក់ទងនឹងកថាខណ្ឌ ៣ និង ៤ ត្រូវចេញសងវិញដោយភាគីដាក់សំណើ។[82]

នៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា នៅពេលទទួលបានសំណើពីរដ្ឋធ្វើសំណើ ដើម្បីអនុញ្ញាតឱ្យបុគ្គលណាមួយដែលស្ថិតនៅក្រោមការឃុំខ្លួនដោយរដ្ឋបរទេស ធ្វើការឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាទៅផ្ដល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេត ក្នុងដែនដីនៃរដ្ឋធ្វើសំណើ អាជ្ញាធរកណ្ដាលត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដែលមានសមត្ថកិច្ច ដើម្បីសម្របសម្រួលក្នុងដំណើរការឆ្លងកាត់នៃបុគ្គលនោះ ប្រសិនបើ អាជ្ញាធរកណ្ដាលយល់ឃើញថារដ្ឋធ្វើសំណើបានបំពេញលក្ខខណ្ឌដើម្បីទទួលជំនួយនេះ។

បុគ្គលនោះត្រូវឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ដែលអនុញ្ញាតដោយអាជ្ញាធរកណ្ដាល និងតាមលក្ខខណ្ឌនៃការព្រមព្រៀងគ្នាជាមួយរដ្ឋធ្វើសំណើ។ ប្រសិនបើ រយៈពេលអនុញ្ញាតនោះបានផុតកំណត់ ឬលក្ខខណ្ឌមិនត្រូវបានអនុវត្ត បុគ្គលនោះនឹងត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញ ឬត្រូវបានបណ្ដេញចេញដោយអនុវត្តតាមច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានការព្រមព្រៀងផ្សេងពីនេះរវាងរដ្ឋធ្វើសំណើនិងអាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជា។[83]

❖ **សុវត្ថិភាព**

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា យោងតាមកថាខណ្ឌ ២ នៅពេលជនណាមានវត្តមាននៅក្នុងភាគីដាក់សំណើ អនុលោមទៅតាមសំណើបានធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥ នៃសិទ្ធិសញ្ញានេះ ៖

[82] សន្ធិសញ្ញា ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១៧។

[83] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២៨។

- ជននោះមិនត្រូវបានឃុំខ្លួន ចោទប្រកាន់ ផ្តន្ទាទោស ឬទទួលរងនូវការដាក់កំហិតផ្សេងៗលើសេរីភាពបុគ្គលនៅក្នុងភាគីដាក់សំណើ ទាក់ទងទៅនឹងអំពើប្រព្រឹត្ត ឬការប៉ុនប៉ង ឬការផ្តន្ទាទោសពីបទល្មើសណាមួយ ប្រឆាំងនឹងច្បាប់របស់ភាគីដាក់សំណើ ដោយសារមានការចោទថាបានប្រព្រឹត្តបទល្មើសនោះ មុនពេលចេញដំណើររបស់ជននោះពីភាគីទទួលសំណើ។
- បើគ្មានការយល់ព្រមពីជននោះទេ ជននោះមិនតម្រូវឱ្យផ្តល់ភស្តុតាងនៅក្នុងរឿងក្តីព្រហ្មទណ្ឌណាមួយនៅក្នុងភាគីដាក់សំណើឡើយ ក្រៅពីរឿងក្តីព្រហ្មទណ្ឌដែលទាក់ទងនឹងសំណើ ឬ
- ជននោះមិនត្រូវទទួលរងនូវបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងអំពើប្រព្រឹត្ត ឬការប៉ុនប៉ងណាមួយដែលជននោះត្រូវបានចោទថា អំពើប្រព្រឹត្ត ឬការប៉ុនប៉ងបានកើតឡើង នៅមុនពេលជននោះចេញដំណើរពីភាគីទទួលសំណើ។

កថាខណ្ឌ១ ត្រូវឈប់អនុវត្ត ប្រសិនបើជននោះមានសេរីភាព និងអាចចាកចេញបាន ប៉ុន្តែមិនទាន់បានចាកចេញពីភាគីដាក់សំណើ ក្នុងរយៈពេល ១៥ថ្ងៃជាប់ៗគ្នា បន្ទាប់ពីជននោះត្រូវបានប្រាប់ ឬជូនដំណឹងជាផ្លូវការថាវត្តមានរបស់គាត់លែងចាំបាច់ទៀតហើយ ឬជននោះបានចាកចេញហើយបានវិលត្រឡប់មកវិញដោយស្ម័គ្រចិត្ត។

ជនណាមានវត្តមាននៅចំពោះមុខអាជ្ញាធរ ឬតុលាការមានសមត្ថកិច្ច នៅក្នុងភាគីដាក់សំណើ យោងតាមសំណើធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥ នៃសន្ធិសញ្ញានេះ មិនត្រូវរងនូវការចោទប្រកាន់ ដោយឈរលើការផ្តល់ចម្លើយបែបនេះទេ លើកលែងតែជននោះត្រូវស្ថិតនៅក្រោមច្បាប់របស់ភាគីដាក់សំណើទាក់ទងនឹងការប្រមាថតុលាការ និងសក្ខីភាពទុច្ចរិត។

ជនណាមិនយល់ព្រមចូលទៅក្នុងភាគីដាក់សំណើ យោងតាមសំណើធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥ នៃសន្ធិសញ្ញានេះ មិនត្រូវទទួលទោស ឬទទួលខុសត្រូវ ដោយគ្រាន់តែផ្អែកលើមូលហេតុនៃការបដិសេធ ឬមិនបានយល់ព្រមនោះទេ ឬបើមិនដូច្នោះទេវាធ្វើឱ្យខូចប្រយោជន៍ខាងផ្នែកច្បាប់ ទោះបីវាផ្ទុយទៅនឹងសំណើក៏ដោយ។[84]

**១.២.៦. ជំនួយទាក់ទងនឹងការស្វែងរកមនុស្ស**

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា ដោយទៅយោងតាមច្បាប់ក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើត្រូវប្រើប្រាស់ឱ្យអស់នូវកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបញ្ជាក់ឱ្យច្បាស់ពី ទីកន្លែង ឬអត្តសញ្ញាណរបស់ជនដូចបានបញ្ជាក់ជូនក្នុងសំណើ ហើយជាជនដែលត្រូវបានគេជឿជាក់ដោយសមហេតុផលថា កំពុងស្ថិតនៅក្នុងទឹកដីរបស់ខ្លួន។[85]

[84] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា១៦។

[85] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា២០។

ចំណែកនៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា នៅពេលទទួលបានសំណើសុំជំនួយឱ្យស្វែងរកជនណាម្នាក់ ដែលគេជឿជាក់ថាកំពុងស្ថិតក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលរដ្ឋធ្វើសំណើត្រូវការជននោះសម្រាប់គោលបំណងក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការនៅក្នុងដែនដីរបស់ខ្លួន អាជ្ញាធរកណ្តាលត្រូវបញ្ជូនសំណើនេះទៅអាជ្ញាធរអនុវត្តសំណើ ដែលមានសមត្ថកិច្ចដើម្បីស្វែងរកទីតាំងជននោះ។ អាជ្ញាធរអនុវត្តសំណើត្រូវរាយការណ៍ពីលទ្ធផលនៃការស្វែងរកជននោះមកអាជ្ញាធរកណ្តាលវិញ ដើម្បីចាត់ការបន្ត។[86]

### ១.២.៧. ជំនួយទាក់ទងនឹងការបង្កក ការចាប់យក និងការរឹបអូសទ្រព្យ

#### ១.២.៧.១.ការបង្កក ឬការចាប់យកទ្រព្យ តាមសេចក្តីសម្រេចមិនទាន់ស្ថាពររបស់តុលាការនៃរដ្ឋធ្វើសំណើ

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា ដោយអនុលោមតាមច្បាប់ក្នុងរដ្ឋរបស់ខ្លួន ភាគីទទួលសំណើត្រូវខិតខំប្រឹងប្រែងរកឱ្យឃើញទីតាំង តាមដាន រារាំង បង្កក ដកហូត ឬរឹបអូសទ្រព្យសម្បត្តិបានមកពីការប្រព្រឹត្តបទល្មើស និងជាមធ្យោបាយបទល្មើសដើម្បីឱ្យជំនួយរបៀបនេះអាចផ្តល់បាន លុះត្រាតែភាគីដាក់សំណើផ្តល់ព័ត៌មានទាំងអស់ដែលភាគីទទួលសំណើយល់ឃើញថាចាំបាច់។ សំណើនោះត្រូវអមជាមួយដីកាច្បាប់ដើមដែលមានចុះហត្ថលេខា ឬច្បាប់ចម្លងដីកាបញ្ជាក់ថាត្រឹមត្រូវ។

យោងតាមច្បាប់ក្នុងរដ្ឋភាគីទទួលសំណើ និងអនុលោមតាមកិច្ចព្រមព្រៀងជាមួយភាគីដាក់សំណើ ភាគីទទួលសំណើត្រូវផ្ទេរទៅឱ្យ ភាគីដាក់សំណើនូវចំណែកទ្រព្យសម្បត្តិដែលបានព្រមព្រៀង និងជាទ្រព្យសម្បត្តិទទួលបានតាមរយៈការរឹបអូស ដើម្បីទូទាត់ថ្លៃចំណាយ និងសោហ៊ុយរបស់ភាគីទទួលសំណើ ទៅលើការអនុវត្តដីការឹបអូស។[87]

ចំណែកនៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា នៅពេលទទួលបានសំណើសុំឱ្យបង្កក ឬចាប់យកទ្រព្យណាមួយ តាមសេចក្តីសម្រេចមិនទាន់ចូលជាស្ថាពររបស់តុលាការនៃរដ្ឋធ្វើសំណើ អាជ្ញាធរកណ្តាលត្រូវបញ្ជូនសំណើនេះទៅសាលាដំបូងរាជធានី/ខេត្ត ដែលមានសមត្ថកិច្ចដើម្បីបង្កក ឬចាប់យកទ្រព្យនោះ។ ប្រសិនបើសាលាដំបូងច្រើនមានសមត្ថកិច្ចលើករណីនេះ អាជ្ញាធរកណ្តាលអាចបញ្ជូនសំណើនេះទៅសាលាដំបូងណាមួយក៏បាន។ ការសម្រេចបង្កក ឬចាប់យកទ្រព្យត្រូវធ្វើក្រោមទម្រង់ជាដីកាសម្រេចរបស់ប្រធានសាលាដំបូង ដោយមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

[86] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា២៩។

[87] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា២២។

សាលាដំបូងត្រូវចាត់ទុកសំណើនៅក្នុងកថាខណ្ឌទី១ខាងលើនេះជាការប្រញាប់។ សាលាដំបូងត្រូវចេញដីកាសម្រេចបង្កកឬចាប់យកទ្រព្យនោះ ប្រសិនបើ៖

- ទ្រព្យនោះអាចបង្កកឬចាប់យកបាន តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង
- មានហេតុផលសមរម្យដែលជឿជាក់ថា អាចនឹងមានការលក់ ការផ្ទេរ ការលាក់បំបាំង ឬមានវិធានការចំពោះទ្រព្យនោះ ដើម្បីឱ្យទ្រព្យនោះរួចពីការរឹបអូសឬធ្វើឱ្យទ្រព្យនោះលែងមានប្រយោជន៍។

ដីកាសម្រេចបង្កក ឬចាប់យកទ្រព្យរបស់សាលាដំបូងត្រូវជូនដំណឹងតាមរយៈការបិទផ្សាយនៅបញ្ជរបិទផ្សាយព័ត៌មានរបស់សាលាដំបូង និងត្រូវជូនដំណឹងទៅបុគ្គលដែលមានការពាក់ព័ន្ធប្រសិនបើមាន ឬក្នុងករណីចាំបាច់ត្រូវផ្សព្វផ្សាយជាសាធារណៈ តាមសារព័ត៌មាន ឬតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

តតិយជន ឬបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធនឹងដីកាសម្រេចបង្កក ឬចាប់យកទ្រព្យ អាចប្ដឹងតវ៉ាទៅសាលាដំបូងដើម្បីសុំលុបដីកាសម្រេចនោះ ក្នុងរយៈពេល ១៥ថ្ងៃ គិតពីថ្ងៃជូនដំណឹងអំពីដីកាសម្រេច។ ប្រសិនបើមានភស្តុតាងបញ្ជាក់ថា ទ្រព្យនោះមិនពាក់ព័ន្ធដូចអ្វីដែលរដ្ឋធ្វើសំណើបានស្នើសុំ ឬបុគ្គលពាក់ព័ន្ធមិនបានធ្វើសកម្មភាពណាមួយដូចការចោទប្រកាន់ដែលមានក្នុងកថាខណ្ឌទី២ខាងលើ សាលាដំបូងត្រូវលុបចោលសេចក្ដីសម្រេចនោះ ហើយសេចក្ដីសម្រេចនេះ គឺបិទផ្លូវតវ៉ា។ បែបបទ និងនីតិវិធីនៃការប្ដឹងទាស់ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តចំពោះការប្ដឹងតវ៉ានៅក្នុងកថាខណ្ឌនេះ។

តតិយជន ឬបុគ្គលដែលមានប្រយោជន៍ពាក់ព័ន្ធនឹងដីកាសម្រេចបង្កក ឬចាប់យកទ្រព្យ អាចប្ដឹងទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចបង្កក ឬចាប់យកទ្រព្យ របស់សាលាដំបូងក្នុងរយៈពេល ១ខែ គិតពីថ្ងៃផុតកំណត់រយៈពេលប្ដឹងតវ៉ា ហើយសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ គឺបិទផ្លូវតវ៉ា។ បណ្ដឹងឧទ្ធរណ៍ក៏អាចធ្វើបានដែរចំពោះដីកាសម្រេចបដិសេធពាក្យប្ដឹងតវ៉ារបស់បុគ្គលពាក់ព័ន្ធក្នុងរយៈពេល ១ខែ គិតពីថ្ងៃជូនដំណឹងពីដីកាសម្រេចបដិសេធ ហើយសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍នេះក៏បិទផ្លូវតវ៉ាដែរ។ បែបបទ និងនីតិវិធីនៃការប្ដឹងឧទ្ធរណ៍ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្តចំពោះករណីនេះ។

សេចក្ដីសម្រេចបដិសេធសំណើសុំបង្កក ឬចាប់យកទ្រព្យ របស់សាលាដំបូង ឬសេចក្ដីសម្រេចលុបចោលសេចក្ដីសម្រេចបង្កក ឬចាប់យកទ្រព្យ របស់សាលាដំបូងតាមសំណើរបស់រដ្ឋធ្វើសំណើ មិនរារាំងដល់អាជ្ញាធរកណ្ដាលក្នុងការដាក់សំណើថ្មីទៅសាលាដំបូង ដើម្បីចេញសេចក្ដីសម្រេចបង្កក ឬចាប់យកទ្រព្យ ម្ដងទៀត ប្រសិនបើមានភស្តុតាងថ្មី ដែលអាចឱ្យសាលាដំបូងចេញសេចក្ដីសម្រេចបង្កក ឬចាប់យកទ្រព្យនោះ។

ក្នុងករណីសាលាដំបូងសម្រេចបដិសេធសំណើរបស់រដ្ឋធ្វើសំណើ ដីកាសម្រេចនេះបិទផ្លូវតវ៉ា និងត្រូវរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរកណ្ដាល។[88]

[88] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣០។

**១.២.៧.២. ការរឹបអូសទ្រព្យតាមសេចក្ដីសម្រេចស្ថាពររបស់តុលាការនៃរដ្ឋធ្វើសំណើ**

នៅពេលទទួលបានសំណើសុំឱ្យរឹបអូសទ្រព្យ តាមសេចក្ដីសម្រេចស្ថាពររបស់តុលាការនៃរដ្ឋធ្វើសំណើ អាជ្ញាធរកណ្ដាលត្រូវបញ្ជូនសំណើនេះទៅសាលាដំបូងដែលមានសមត្ថកិច្ចដើម្បីសម្រេចរឹបអូសទ្រព្យ។ ប្រសិនបើសាលាដំបូងច្រើនមានសមត្ថកិច្ចលើករណីនេះ អាជ្ញាធរកណ្ដាលអាចបញ្ជូនសំណើនេះទៅសាលាដំបូងណាមួយក៏បាន។ ការសម្រេចរឹបអូសទ្រព្យត្រូវធ្វើឡើងក្រោមទម្រង់ជាសាលក្រមដោយមានសំអាងហេតុ និងសំអាងច្បាប់។ សាលាដំបូងធ្វើការសម្រេចដោយចៅក្រមទោលដែលជាប្រធានសាលាដំបូង ឬដោយក្រុមប្រឹក្សាជំនុំជម្រះដែលមានប្រធានសាលាដំបូងជាប្រធាន និងមានចៅក្រមប្រឹក្សាពីររូបផ្សេងទៀតតាមការចាត់តាំងរបស់ប្រធានសាលាដំបូងក្នុងករណីដែលរឿងក្ដីមានភាពស្មុគស្មាញ។

នៅពេលទទួលបានសំណើ សាលាដំបូងត្រូវរៀបចំសវនាការ ដើម្បីពិភាក្សាដេញដោល និងធ្វើការពិនិត្យភស្ដុតាងនានា ព្រមទាំងស្ដាប់សក្ខីកម្មពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់។ បទប្បញ្ញត្តិពាក់ព័ន្ធនឹងសមាសភាព និងដំណើរប្រព្រឹត្តទៅនៃសវនាការដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធផ្សេងទៀតត្រូវយកមកអនុវត្តនៅក្នុងករណីនេះ។

ក្នុងករណីពិនិត្យឃើញមានមូលដ្ឋានគ្រប់គ្រាន់ សាលាដំបូងអាចសម្រេចរឹបអូសទ្រព្យតាមសេចក្ដីសម្រេចស្ថាពររបស់តុលាការនៃរដ្ឋធ្វើសំណើ ប្រសិនបើ៖

- ទ្រព្យនោះអាចរឹបអូសបានតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង
- តុលាការនៃរដ្ឋធ្វើសំណើមានយុត្តាធិការ ដើម្បីសម្រេចលើករណីនេះ។

ក្នុងករណីសាលក្រមរបស់តុលាការនៃរដ្ឋធ្វើសំណើ ត្រូវបានធ្វើឡើងដោយមិនស្របតាមគោលការណ៍គ្រឹះនៃការជម្រះក្ដីដោយយុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌជាអាទិ៍ សិទ្ធិការពារខ្លួនរបស់ជនជាប់ចោទ ឬការអនុវត្តតាមសាលក្រមនៃរដ្ឋធ្វើសំណើប៉ះពាល់ធ្ងន់ធ្ងរដល់សណ្ដាប់ធ្នាប់សាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា តុលាការត្រូវបដិសេធសំណើខាងលើនេះ។[89]

**១.២.៧.៣. សេចក្ដីសម្រេចស្ដីពីការបង្កក ការចាប់យក ឬការរឹបអូសទ្រព្យ**

សាលាដំបូងមានសិទ្ធិសម្រេចអំពីការបង្កក ការចាប់យក ឬការរឹបអូសទ្រព្យ ទោះបីជាបទល្មើសដែលនាំឱ្យមានការបង្កក ការចាប់យក ឬការរឹបអូសទ្រព្យមិនត្រូវបានប្រព្រឹត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាក៏ដោយ។ សាលាដំបូងក៏អាចសម្រេចបង្កក ចាប់យក ឬរឹបអូសទ្រព្យ ទោះបីជាជនល្មើស ឬជនជាប់ចោទបានទទួលមរណភាព ឬមិនត្រូវបានគេស្គាល់អត្តសញ្ញាណ ឬបានរត់គេចខ្លួន នៅពេលដែលតុលាការនៃរដ្ឋធ្វើសំណើបានចេញសេចក្ដីសម្រេចថា ទ្រព្យនោះជាផលនៃបទល្មើស ឬជាឧបករណ៍មធ្យោបាយប្រព្រឹត្តបទល្មើសដែលត្រូវ

[89] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣១។

រឹបអូស។ នៅពេលមានការស្នើសុំជំនួយឱ្យបង្កក ចាប់យក ឬរឹបអូសទ្រព្យរបស់ជនល្មើសឬជនជាប់ចោទដែលទទួលមរណភាព ឬមិនត្រូវបានគេស្គាល់អត្តសញ្ញាណ ឬបានរត់គេចខ្លួន លក្ខខណ្ឌតម្រូវទាក់ទងនឹងសិទ្ធិការពារខ្លួនដែលមាននៅក្នុងចំណុច ១.២.៧.៣ (ការរឹបអូសទ្រព្យតាមសេចក្ដីសម្រេចស្ថាពររបស់តុលាការនៃរដ្ឋផ្ញើសំណើ) ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ។[90]

**១.២.៧.៤. ការសម្របសម្រួលការចាប់យកនិងការរឹបអូស**

អាជ្ញាធរកណ្ដាលអាចចុះកិច្ចព្រមព្រៀងជាមួយរដ្ឋផ្ញើសំណើក្នុងគោលបំណង ដើម្បីសម្របសម្រួលការចាប់យក និងការរឹបអូស តាមសំណើរបស់រដ្ឋផ្ញើសំណើដោយអនុលោមតាមច្បាប់នេះ។[91]

**១.២.៧.៥. ការគ្រប់គ្រង ការចាត់ចែង និងការបែងចែកទ្រព្យដែលត្រូវបានរឹបអូស**

ទ្រព្យដែលត្រូវបានបង្កក ចាប់យក ឬរឹបអូសដោយអនុលោមតាមច្បាប់នេះ ត្រូវគ្រប់គ្រងនិងចាត់ចែងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ទ្រព្យដែលត្រូវបានរឹបអូសតាមសេចក្ដីសម្រេចស្ថាពររបស់តុលាការកម្ពុជា ស្របតាមបទប្បញ្ញត្តិនៃអនុផ្នែកនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងការចាត់ចែងរបស់អាជ្ញាធរកណ្ដាល។

ដោយផ្អែកតាមការព្រមព្រៀងគ្នារវាងអាជ្ញាធរកណ្ដាលនិងរដ្ឋផ្ញើសំណើ និងក្នុងករណីដែលអនុញ្ញាតដោយច្បាប់របស់ខ្លួន អាជ្ញាធរកណ្ដាលអាចផ្ទេរទៅឱ្យរដ្ឋផ្ញើសំណើនូវទ្រព្យដែលត្រូវបានរឹបអូសទាំងអស់ឬចំណែកណាមួយ លើកលែងតែការផ្ទេរទ្រព្យនោះធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬសីលធម៌សង្គមនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងគ្រប់ករណីទាំងអស់អាជ្ញាធរកណ្ដាល ត្រូវកាត់ចេញពីទ្រព្យរឹបអូសនូវរាល់ការចំណាយនានាដែលទាក់ទងទៅដល់ប្រតិបត្តិការនៃការបង្កក ការចាប់យកនិងការរឹបអូសទ្រព្យរហូតដល់ការផ្ទេរទ្រព្យនោះឱ្យទៅរដ្ឋផ្ញើសំណើ។ ក្នុងករណីចាំបាច់ អាជ្ញាធរកណ្ដាលត្រូវចាត់ចែងលក់ទ្រព្យដែលត្រូវបានរឹបអូសដែលមិនមែនជាសាច់ប្រាក់ ដោយអនុវត្តតាមនីតិវិធីជាធរមាន។

ទ្រព្យរឹបអូសដែលមិនត្រូវបានផ្ទេរទៅឱ្យរដ្ឋផ្ញើសំណើត្រូវដាក់ចូលទៅក្នុងមូលនិធិមួយ សម្រាប់អាជ្ញាធរកណ្ដាលប្រើប្រាស់នៅក្នុងការងារនៃការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ជាមួយរដ្ឋបរទេស ឬការងារទាក់ទងនឹងកិច្ចសហប្រតិបត្តិការក្នុងវិស័យព្រហ្មទណ្ឌផ្សេងទៀត។

ចំពោះទ្រព្យរឹបអូសដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬទ្រព្យសម្បត្តិ ឬបរិស្ថាន ព្រមទាំងទ្រព្យដែលមិនអាចកាន់កាប់បានដោយស្របច្បាប់ អាជ្ញាធរកណ្ដាលអាចប្ដឹងសុំទៅតុលាការសាមីដែលបានចេញសេចក្ដីសម្រេចរឹបអូសដើម្បីបំផ្លាញចោល។[92]

---

[90] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣២។

[91] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣៣។

[92] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣៤។

## ២. សំណើសុំជំនួយដោយព្រះរាជាណាចក្រកម្ពុជា

### ២.១. វិធានទូទៅ (នីតិវិធីទូទៅ)

#### ២.១.១. សំណើដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អាចស្នើសុំការជួយផ្នែកច្បាប់ពីរដ្ឋបរទេសតាមរយៈអាជ្ញាធរកណ្តាល។

អាជ្ញាធរកណ្តាល ត្រូវពិចារណាលើភាពសមស្របនៃសំណើដោយពិចារណាលើបទប្បញ្ញត្តិ ព័ត៌មានលម្អិត អង្គហេតុ និងឯកសារពាក់ព័ន្ធ ហើយត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចដែលដាក់សំណើអំពីការសម្រេចរបស់ខ្លួន។ ក្នុងករណីចាំបាច់ អាជ្ញាធរកណ្តាលអាចស្នើសុំការសម្រេចពីរាជរដ្ឋាភិបាលមុននឹងអនុវត្តនីតិវិធីបន្ត។[93]

#### ២.១.២. បែបបទនៃការស្នើសុំជំនួយ

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវបំពេញសំណុំបែបបទនៃការស្នើសុំជំនួយ ដែលនឹងត្រូវកំណត់ដោយអាជ្ញាធរកណ្តាល។ ក្នុងករណីចាំបាច់ អាជ្ញាធរកណ្តាលអាចស្នើសុំនូវព័ត៌មានបន្ថែម ដើម្បីធានាថាសំណើសុំជំនួយនោះនឹងអាចទទួលយកដោយរដ្ឋទទួលសំណើ។[94]

#### ២.១.៣. លក្ខខណ្ឌនៃការប្រើប្រាស់ព័ត៌មាននិងភស្តុតាង

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលធ្វើសំណើ មិនត្រូវប្រើប្រាស់ ឬទម្លាយព័ត៌មាន ឬភស្តុតាងដែលផ្តល់ដោយរដ្ឋទទួលសំណើ ក្នុងគោលបំណងក្រៅពីការកំណត់នៅក្នុងសំណើ ដោយគ្មានការយល់ព្រមជាមុនពីរដ្ឋទទួលសំណើឡើយ។

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលធ្វើសំណើ ត្រូវចាត់វិធានការសមស្របទាំងឡាយដើម្បីរក្សាព័ត៌មានសម្ងាត់និងភស្តុតាង ដែលផ្តល់ដោយរដ្ឋទទួលសំណើ លើកលែងតែភស្តុតាង និងព័ត៌មានដែលចាំបាច់សម្រាប់គោលបំណងដែលបានកំណត់នៅក្នុងសំណើ។[95]

#### ២.១.៤. ភាពទទួលយកបាននៃភស្តុតាង

តុលាការត្រូវទទួលយកភស្តុតាងទាំងអស់ ដែលបានពីការជួយផ្នែកច្បាប់ដែលព្រះរាជាណាចក្រកម្ពុជាបានទទួលពីរដ្ឋទទួលសំណើដើម្បីពិចារណាដោយអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[96]

### ២.២. វិធានជាក់លាក់ (នីតិវិធីដោយឡែក)

វិធានដោយឡែកទាក់ទងនឹងសំណើសុំបុគ្គលជាប់ឃុំឬបុគ្គលផ្សេងទៀតដើម្បីផ្តល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេតក្នុងព្រះរាជាណាចក្រកម្ពុជា។

---

[93] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣៥។
[94] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣៦។
[95] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣៧។
[96] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣៨។

**២.២.១.លក្ខខណ្ឌនៃការស្នើសុំបុគ្គលដើម្បីផ្ដល់សក្ខីកម្មឬជួយដល់ការស៊ើបអង្កេត**

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធអាចធ្វើសំណើទៅរដ្ឋទទួលសំណើ តាមរយៈអាជ្ញាធរកណ្ដាលដើម្បីសុំផ្ទេរជាបណ្ដោះអាសន្ននូវបុគ្គលជាប់ឃុំ ឬបញ្ជូនបុគ្គលផ្សេងទៀតដែលនៅក្នុងរដ្ឋទទួលសំណើដើម្បីផ្ដល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេតក្នុងកិច្ចដំណើរការនីតិវិធីតុលាការនៃព្រះរាជាណាចក្រកម្ពុជា ក្នុងលក្ខខណ្ឌដែល ៖

១. សំណុំរឿងព្រហ្មទណ្ឌបានចាប់ផ្ដើមនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង

២. បុគ្គលជាប់ឃុំ ឬបុគ្គលផ្សេងទៀតនោះ អាចផ្ដល់ភស្តុតាងដែលមានប្រយោជន៍ដល់នីតិវិធីតុលាការ ហើយយល់ព្រមផ្ដល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេតក្នុងនីតិវិធីតុលាការកម្ពុជា។

នៅពេលទទួលបានបុគ្គលជាប់ឃុំណាមួយពីរដ្ឋទទួលសំណើ ដើម្បីផ្ដល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការកម្ពុជាឬផ្ដល់ជំនួយទាក់ទងនឹងការស៊ើបអង្កេត ការឃុំខ្លួនខ្លួនបុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវធ្វើឡើង តាមលក្ខខណ្ឌនៃការព្រមព្រៀងគ្នាជាមួយរដ្ឋទទួលសំណើ ឬតាមការកំណត់របស់អាជ្ញាធរកណ្ដាល។ ការទទួលយកនិងការឃុំខ្លួនបុគ្គលជាប់ឃុំត្រូវធ្វើឡើងស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។[97]

**២.២.២. សិទ្ធិរបស់បុគ្គលដែលផ្ដល់សក្ខីកម្មឬជួយដល់ការស៊ើបអង្កេត**

ក្រៅពីលក្ខខណ្ឌដែលព្រមព្រៀងគ្នាជាមួយរដ្ឋទទួលសំណើ បុគ្គលណាមួយទោះបីជាបុគ្គលជាប់ឃុំ ឬបុគ្គលផ្សេងទៀតដែលមកព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងផ្ដល់សក្ខីកម្ម ឬជួយដល់ការស៊ើបអង្កេតតាមច្បាប់នេះ៖

- មិនអាចត្រូវបានចោទប្រកាន់ ឃុំខ្លួន ផ្ដន្ទាទោស ឬកម្រិតសេរីភាពបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមូលហេតុនៃអំពើល្មើសណាមួយផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានចោទប្រកាន់ ឬបានប្រព្រឹត្តមុនពេលចាកចេញពីរដ្ឋទទួលសំណើ។
- មិនត្រូវបានតម្រូវឱ្យផ្ដល់ភស្តុតាងដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រៅពីបទល្មើសព្រហ្មទណ្ឌដែលបានកំណត់នៅក្នុងសំណើឡើយ លើកលែងតែមានការយល់ព្រមពីបុគ្គលនោះ។
- មិនត្រូវទទួលរងនូវបណ្ដឹងរដ្ឋប្បវេណី ឬបណ្ដឹងផ្សេងទៀត ទាក់ទងទៅនឹងអំពើនិងសកម្មភាពណាមួយដែលបុគ្គលនោះ ត្រូវបានចោទថាអំពើ ឬសកម្មភាពប្រព្រឹត្តបានកើតឡើងនៅមុនពេលបុគ្គលនោះចាកចេញពីរដ្ឋទទួលសំណើ។

---

[97] ច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៣៩។

សិទ្ធិខាងលើនេះត្រូវរលត់ នៅពេលបុគ្គលនោះមានឱកាសចាកចេញពីព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ១៥ថ្ងៃ ក្រោយការជូនដំណឹងពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធថាវត្តមានរបស់បុគ្គលនោះលែងចាំបាច់ទៀតហើយ ប៉ុន្តែបុគ្គលនោះនៅតែបន្តស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឬត្រឡប់មកវិញដោយខ្លួនឯងក្រោយពីបានចាកចេញពីព្រះរាជាណាចក្រកម្ពុជារួចហើយ។[98]

**២.២.៣. របាយការណ៍ស្តីពីការបញ្ចប់ការផ្តល់សក្ខីកម្មឬការជួយដល់ការស៊ើបអង្កេត**

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវធ្វើរបាយការណ៍ ជូនទៅអាជ្ញាធរកណ្តាល នៅពេលដែលបុគ្គលជាប់ឃុំ ឬបុគ្គលផ្សេងទៀត បានបញ្ចប់ការផ្តល់សក្ខីកម្ម ឬការជួយដល់ការស៊ើបអង្កេត។[99]

**២.២.៤. ការផ្ទេរត្រឡប់ទៅវិញនូវបុគ្គលជាប់ឃុំ**

នៅពេលទទួលបានរបាយការណ៍ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរកណ្តាលត្រូវធ្វើការសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីបញ្ជូនបុគ្គលជាប់ឃុំត្រឡប់ទៅរដ្ឋទទួលសំណើវិញជាបន្ទាន់។[100]

**៣. ការចំណាយ**

នៅក្នុងសន្ធិសញ្ញារបស់អាស៊ានបានកំណត់ថា ភាគីទទួលសំណើ ត្រូវចេញរាល់ការចំណាយធម្មតាក្នុងការបំពេញតាមសំណើសុំជំនួយ លើកលែងតែភាគីដាក់សំណើទទួលខុសត្រូវក្នុងការចំណាយ ៖

- សោហ៊ុយសេវាអ្នកប្រឹក្សាដែលបានជួល តាមសំណើរបស់ភាគីដាក់សំណើ
- សោហ៊ុយ និងថ្លៃចំណាយលើសាក្សីជំនាញ
- ថ្លៃចំណាយបកប្រែភាសាជាឯកសារ បកប្រែផ្ទាល់មាត់ និងការកត់ត្រា
- សោហ៊ុយចំណាយទាក់ទងនឹងការដឹកជញ្ជូនជនណាមួយ ទៅកាន់ ឬមកពីដែនដីរបស់ភាគីទទួលសំណើ និងសោហ៊ុយ ប្រាក់ឧបត្ថម្ភ និងថ្លៃចំណាយទៅលើជនពាក់ព័ន្ធនោះ ក្នុងខណៈដែលជននោះស្ថិតនៅក្នុងភាគីដាក់សំណើ អនុលោមតាមសំណើធ្វើឡើងក្រោមមាត្រា ១៤ ឬ ១៥ នៃសន្ធិសញ្ញានេះ
- ចំណាយទាក់ទងដល់មន្ត្រីទទួលបន្ទុកដឹកជញ្ជូន ឃុំឃាំង ឬការពារ។

ដរាបណាបណ្តាភាគីមានការព្រមព្រៀងផ្សេងពីនេះ ភាគីដាក់សំណើត្រូវចេញសងឱ្យទៅភាគីទទួលសំណើវិញទៅលើ ថ្លៃចំណាយក្នុងការបង្កើតការតភ្ជាប់បណ្តាញវីដេអូ ឬទូរទស្សន៍បន្តផ្ទាល់ ឬឧបករណ៍សម្រួលដល់ការប្រាស្រ័យទាក់ទងសមស្របផ្សេងៗទៀត ថ្លៃចំណាយទាក់ទងនឹងសេវាតភ្ជាប់បណ្តាញវីដេអូ ឬទូរទស្សន៍

[98] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៤០។

[99] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៤១។

[100] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៤២។

បន្តផ្ទាល់ ឬឧបករណ៍សំរួលដល់ការប្រាស្រ័យទាក់ទងសមស្របផ្សេងៗទៀត ប្រាក់ឈ្នួលបកប្រែភាសាដោយផ្ទាល់មាត់ផ្តល់ដោយភាគីទទួលសំណើ និងប្រាក់ឧបត្ថម្ភដល់សាក្សី និងថ្លៃចំណាយលើការធ្វើដំណើររបស់ពួកគេទៅក្នុងភាគីទទួលសំណើ។

ប្រសិនបើ ក្នុងអំឡុងពេលនៃការអនុវត្តសំណើ បានបង្ហាញច្បាស់ពីតម្រូវការបំពេញតាមសំណើដោយការចំណាយមានលក្ខណៈខុសធម្មតា ឬតំលៃថ្លៃ នោះគូភាគីត្រូវពិគ្រោះយោបល់គ្នា ដើម្បីកំណត់លក្ខខណ្ឌអនុវត្តសំណើ ឱ្យអនុវត្តបាន ឬបន្តទៅទៀត។[101]

នៅក្នុងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា រាល់ការចំណាយទាំងអស់របស់អាជ្ញាធរកណ្តាលទាក់ទងនឹង ការសម្របសម្រួលការជួយផ្នែកច្បាប់ដល់រដ្ឋផ្ញើសំណើ និងការស្នើសុំការជួយផ្នែកច្បាប់ពីរដ្ឋទទួលសំណើជាបន្ទុករបស់ក្រសួងយុត្តិធម៌។ ការចំណាយក្នុងការអនុវត្តសំណើ ត្រូវជាបន្ទុករបស់អាជ្ញាធរអនុវត្តសំណើ ហើយចំណាយពាក់ព័ន្ធនឹងការស្នើសុំជំនួយជាបន្ទុករបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ ក្នុងករណីដែលការចំណាយលើការផ្តល់ការជួយផ្នែកច្បាប់នេះជាបន្ទុកធ្ងន់ធ្ងរចំពោះព្រះរាជាណាចក្រកម្ពុជា ព្រះរាជាណាចក្រកម្ពុជាអាចស្នើសុំឱ្យរដ្ឋផ្ញើសំណើផ្តល់វិភាគទានលើការចំណាយនោះ។[102]

[101] សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន, ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤, មាត្រា២៥។

[102] ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, លេខ នស/រកម/០៦២០/០២០, ២៧ ខែមិថុនា ឆ្នាំ២០២០, មាត្រា៤៣។

# ជំពូកទី៣
# បែបបទរដ្ឋបាលនៃការធ្វើសំណើជំនួយ
# ផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ
# ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌

# ជំពូកទី៣
# បែបបទរដ្ឋបាលនៃការធ្វើសំណើជំនួយទៅវិញទៅមកផ្នែកច្បាប់ ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌

## ១. សំណើចូល ( Incoming )

សំណើចូលនៅទីនេះ សំដៅដល់សំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីសំណាក់រដ្ឋដែលជាសមាជិកអាស៊ាន ស្នើសុំមកកាន់ព្រះរាជាណាចក្រកម្ពុជា ដែលសំណើនេះភាគច្រើនត្រូវបានធ្វើតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាអាជ្ញាធរសម្របសម្រួលទទួល និងបញ្ជូនឯកសារទៅក្រៅប្រទេស ហើយក្រសួងនេះក៏បានផ្ញើឯកសារបន្តមកក្រសួងយុត្តិធម៌ដែលជាអាជ្ញាធរកណ្តាលនៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

បែបបទរដ្ឋបាលនៃក្រសួងយុត្តិធម៌ ចំពោះលិខិតដែលជាសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសដែលជាសមាជិកអាស៊ាន ដែលបញ្ជូនមកតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនោះ ដំបូងគឺចូលទៅក្នុងនាយកដ្ឋានកិច្ចការរដ្ឋបាល នៃអគ្គលេខាធិការដ្ឋាន ដើម្បីបោះត្រាលើឯកសារចូលមកក្នុងក្រសួងនៅថ្ងៃខែឆ្នាំណា ពេលវេលាណា បន្ទាប់មកនាយកដ្ឋានកិច្ចការរដ្ឋបាលត្រូវបញ្ជូនឯកសារនេះទៅកាន់ខុទ្ទកាល័យរបស់រដ្ឋមន្ត្រីដើម្បីបោះត្រាចូលខុទ្ទកាល័យ និងដាក់ជូនរដ្ឋមន្ត្រីពិនិត្យ និងធ្វើចំណារទៅឱ្យអង្គភាពដែលទទួលបន្ទុក បន្ទាប់មកទៀតខុទ្ទកាល័យបញ្ជូនឯកសារនេះទៅកាន់អង្គភាពទទួលបន្ទុក គឺអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌[103] ហើយអគ្គនាយកដ្ឋានក៏បោះត្រាចូលលើឯកសារនោះ ហើយអគ្គនាយកនឹងធ្វើចំណារបញ្ជូនសំណុំរឿងបន្តទៅកាន់នាយកដ្ឋានទទួលបន្ទុកលើរឿងនេះ នោះគឺនាយដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន ដែលជាអង្គភាពជំនាញទទួលបន្ទុកលើសំណុំរឿងនៃក្របខណ្ឌអាស៊ានផ្តាច់មុខនៅក្នុងក្រសួងយុត្តិធម៌ ដើម្បីឱ្យនាយកដ្ឋានចាត់ការលើសំណុំរឿងសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវស័យព្រហ្មទណ្ឌដែលបញ្ជូនមកនេះ។

### ១.១. កំណត់បន្ទាញ

បន្ទាប់ពីបានទទួលឯកសារ និងចំណារពីអគ្គនាយក ដែលបានចារមកឱ្យនាយកដ្ឋានទទួលបន្ទុករៀបចំឯកសារនេះមក នាយកដ្ឋានក៏ត្រូវបោះត្រាចូលលើឯកសារនោះដែរ និងឱ្យប្រធាននាយកដ្ឋានពិនិត្យ ដើម្បីចាត់ឱ្យមន្ត្រីជំនាញចាប់ផ្តើមរៀបចំចាត់ការធ្វើសំណុំឯកសារសំណើជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ។

---

[103] តាមអនុក្រឹត្យលេខ ១៣០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ ដែលបានផ្តល់អំណាចឱ្យអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ ត្រូវបង្កើតអង្គភាពមួយក្រោមចំណុះដើម្បីទទួលបន្ទុកលើសំណុំរឿងនេះ

មុននឹងរៀបចំកំណត់បង្ហាញជូនឯកឧត្តមរដ្ឋមន្ត្រី មន្ត្រីជំនាញត្រូវពិនិត្យមើលសំណុំរឿងនោះជាមុនសិន ថាតើជាការស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌមកពីប្រទេសជាសមាជិកអាស៊ានមួយណា ហើយត្រូវពិនិត្យមើលអត្តសញ្ញាណនៃបុគ្គលដែលគេស្នើសុំជំនួយផ្នែកច្បាប់នេះ ដោយផ្តោតសំខាន់លើ ឈ្មោះ ភេទ អាយុ ថ្ងៃខែឆ្នាំកំណើត ជនជាតិ សញ្ជាតិ អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងអាសយដ្ឋានបច្ចុប្បន្ន។ បន្ទាប់មកត្រូវពិនិត្យអង្គហេតុនៃសំណើសុំជំនួយផ្នែកច្បាប់នោះ ថាតើបុគ្គលដែលគេស្នើសុំជំនួយផ្នែកច្បាប់នេះបានប្រព្រឹត្តបទល្មើសអ្វីក្នុងរឿងព្រហ្មទណ្ឌ ហើយប្រព្រឹត្តនៅកន្លែងណា ថ្ងៃខែឆ្នាំណា ត្រូវបានច្បាប់នៃប្រទេសដែលស្នើសុំនោះផ្តន្ទាទោសពីបទអ្វី ហើយស្ថិតនៅក្នុងនីតិវិធីព្រហ្មទណ្ឌមួយណា (នគរបាលយុត្តិធម៌ អយ្យការ ឬចៅក្រមស៊ើបសួរ) ជាពិសេសនិងសំខាន់ជាងគេនោះ គឺពិនិត្យមើលខ្លឹមសារនៃសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ របស់អាជ្ញាធរកណ្តាលនៃប្រទេសជាសមាជិកអាស៊ាន ដែលបានស្នើសុំមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ថាតើប្រទេសដែលស្នើសុំជំនួយផ្នែកច្បាប់នោះចង់ឱ្យអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាធ្វើអ្វីខ្លះ?

បន្ទាប់ពីបានសិក្សា និងត្រួតពិនិត្យលើចំណុចសំខាន់ៗខាងលើនេះរួចហើយ មន្ត្រីជំនាញត្រូវរៀបចំកំណត់បង្ហាញគោរពជូនឯកឧត្តមរដ្ឋមន្ត្រីនៃក្រសួងយុត្តិធម៌។ ក្នុងការរៀបចំកំណត់បង្ហាញត្រូវបានបែងចែកចេញជា៣ផ្នែក គឺក្បាលលិខិត ខ្លឹមសារ និងបញ្ចប់សេចក្តី ដូចខាងក្រោមនេះ៖

**១.១.១.ផ្នែកទី១** (**ក្បាលលិខិត**)

នៅក្នុងផ្នែកទី១ រឿងដែលត្រូវធ្វើដំបូងគេ គឺត្រូវដាក់ ឈ្មោះប្រទេស និងបាវចនាជាតិ (ព្រះរាជាណាចក្រកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ) ហើយដាច់ខាតត្រូវតែដាក់ឈ្មោះអគ្គនាយកដ្ឋាន និងអង្គភាពជំនាញក្រោមចំណុះអគ្គនាយកដ្ឋាននោះ ដែលទទួលបន្ទុកធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌក្នុងក្របខណ្ឌអាស៊ាននេះ ដែលនាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន និងដាក់កន្លែងចុះលេខលិខិតចេញពីនាយកដ្ឋាន។[104] ហើយបន្ទាប់មកត្រូវដាក់ពាក្យថា «**កំណត់បង្ហាញ គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌**» និងបន្ទាប់មកទៀតត្រូវដាក់តាមរយៈ ដោយដាក់រាយនាមឈ្មោះថ្នាក់ដឹកនាំ ពីថ្នាក់លើមកថ្នាក់ក្រោមដូចជា រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងអគ្គនាយក ដែលជាបុគ្គលទទួលបន្ទុកលើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ។ បន្ទាប់មកទៀតត្រូវដាក់កម្មវត្ថុនៃសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ ដែលភាគច្រើនក្នុងកម្មវត្ថុនៃសំណុំរឿង MLA គេផ្តោតសំខាន់តែទៅលើ

[104] ការដែលដាក់ឈ្មោះអង្គភាពជំនាញនេះ គឺដើម្បីឱ្យដឹងថាអង្គភាពមួយណាដែលទទួលបន្ទុកលើសំណុំរឿងនេះ ហើយងាយស្រួលក្នុងការចុះលេខចេញ (ឯកសារដែលត្រូវបញ្ជូនចេញទៅក្រៅស្ថាប័ន ឧទាហរណ៍ នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន ត្រូវចុះលេខ កយ.ចសអ/២៣)

ប្រទេស និងបុគ្គលដែលគេបានស្នើសុំជំនួយផ្នែកច្បាប់តែប៉ុណ្ណោះ គឺនៅក្នុងកម្មវត្ថុគេដាក់ត្រឹមតែ"អំពីសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេស (ឈ្មោះប្រទេសដែលស្នើសុំ MLA ៖ ឧទាហរណ៍. ព្រះរាជាណាចក្រថៃ) ពាក់ព័ន្ធនឹងបុគ្គលឈ្មោះ (ឈ្មោះបុគ្គលដែលគេស្នើសុំ MLA)" ប៉ុណ្ណោះ។ ហើយបន្ទាប់មកដាក់ឯកសារយោងដែលឯកសារយោងនេះភាគច្រើនជាលិខិតដែលផ្ញើមកតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬកំណត់ទូតដែលផ្ញើមកតាមរយៈស្ថានទូត ឬស្ថានឯកអគ្គរាជទូតផ្ទាល់របស់ប្រទេសដែលស្នើសុំ ដែលមានទីស្នាក់ការប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា[105] ដូចមាននៅក្នុងឧបសម្ព័ន្ធទី៤។

**១.១.២.ផ្នែកទី២ (ខ្លឹមសារ)**

នៅក្នុងផ្នែកទី២ មន្ត្រីជំនាញត្រូវសរសេរខ្លឹមសារនៃកំណត់បង្ហាញដោយដាក់ផ្តោតសំខាន់ទៅលើអង្គហេតុនៃសំណុំរឿង MLA និងខ្លឹមសារនៃសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីរដ្ឋផ្ញើសំណើ ដែលបានរៀបរាប់នៅខាងលើនេះ។ រួចហើយកំណត់ស្ថាប័ន ឬអង្គភាពណាដែលទទួលបន្ទុកក្នុងការផ្តល់ជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ។

**១.១.៣.ផ្នែកទី៣ (បញ្ចប់សេចក្តី)**

នៅក្នុងផ្នែកទី៣ មន្ត្រីជំនាញត្រូវសរសេរថា " សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច ព្រមទាំងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។ ក្នុងករណី **ឯកឧត្តមរដ្ឋមន្ត្រី** ផ្តល់ការឯកភាព ខ្ញុំបាទសូមគោរពស្នើសុំហត្ថលេខាដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមរដ្ឋមន្ត្រី** លើលិខិតដែលបានគោរពភ្ជាប់ជូនមកជាមួយ (លិខិតផ្ញើចេញទៅកាន់អាជ្ញាធរអនុវត្តសំណើ)។ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ"។ រួចហើយត្រូវដាក់កន្លែងចុះហត្ថលេខារបស់ប្រធាននាយកដ្ឋានដោយភ្ជាប់ជាមួយនឹងថ្ងៃខែឆ្នាំទាំងព.ស និងគ.ស។ ហើយចំណុចចុងក្រោយ នោះគឺចំណុច មតិយោបល់និងការសម្រេចរបស់ថ្នាក់ដឹកនាំចាប់ពី អគ្គនាយក ទៅអនុរដ្ឋលេខាធិការ ទៅរដ្ឋលេខាធិការ និងរដ្ឋមន្ត្រី ដូចមាននៅក្នុងឧបសម្ព័ន្ធទី៤។

សួរថាតើហេតុអ្វីបានជាក្រសួងយុត្តិធម៌មិនផ្តល់ជំនួយផ្នែកច្បាប់តែម្តងទៅ ចាំបាច់អ្វីត្រូវបញ្ជូនបន្តទៅស្ថាប័ន ឬអង្គភាពពាក់ព័ន្ធនឹងសំណើនេះដើម្បីផ្តល់ជំនួយផ្នែកច្បាប់ធ្វើអ្វី?

ចម្លើយនោះគឺថា នៅក្នុងច្បាប់ស្តីពីជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២០ បានបញ្ញត្តិថា ក្រសួងយុត្តិធម៌ គឺជាអាជ្ញាធរកណ្តាលនៃការធ្វើជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ ហេតុនេះក្រសួងយុត្តិធម៌មិនអាចផ្តល់ជំនួយផ្នែកច្បាប់បាននោះទេ លើកលែងតែសំណើសុំជំនួយផ្នែកច្បាប់នោះស្នើសុំប្រវត្តិនៃការផ្តន្ទាទោសរបស់បុគ្គលស្នើសុំនេះ ទើបក្រសួងយុត្តិធម៌អាចផ្តល់ឱ្យបាន

[105] យោងតាមការផ្តល់យោបល់ និងការណែនាំរបស់ប្រធាននាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន។

គឺផ្តល់តាមរយៈលិខិតដែលចេញមកពីនាយកដ្ឋានកិច្ចការច្បាប់ទោស នៃអគ្គនាយកដ្ឋានកិច្ចការទោសព្រហ្មទណ្ឌ[106] នៃក្រសួងយុត្តិធម៌ ក្រៅពីនោះក្រសួងយុត្តិធម៌ត្រូវធ្វើលិខិតទៅស្ថាប័ន ឬអង្គភាពដែលពាក់ព័ន្ធនឹងសំណើសុំនោះ ដែលភាគច្រើនស្នើសុំផ្តល់ ឬផ្ទៀងផ្ទាត់ ឬបញ្ជាក់អត្តសញ្ញាណ ឬប្រវត្តិរូប គឺក្រសួងបញ្ជូនលិខិតទៅក្រសួងមហាផ្ទៃ ហើយចំពោះការសាកសួរចម្លើយ ឬស៊ើបអង្កេតនានា គឺក្រសួងយុត្តិធម៌ធ្វើលិខិតតាមគ្រប់សាលាដំបូងរាជធានី/ខេត្ត ឬអយ្យការអមសាលាដំបូងគ្រប់រាជធានី/ខេត្ត ដែលមានមានសមត្ថកិច្ចពាក់ព័ន្ធនឹងសំណើសុំ MLA នេះ។

## ១.២. លិខិតផ្ញើចេញទៅកាន់អាជ្ញាធរអនុវត្តសំណើ

បន្ទាប់ពីបានពិនិត្យ និងសិក្សាទៅលើសំណុំរឿងនៃសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌដើម្បីធ្វើកំណត់បង្ហាញជូនឯកឧត្តមរដ្ឋមន្ត្រីរួចមក មន្ត្រីជំនាញត្រូវកំណត់ឱ្យបាននូវស្ថាប័នអាជ្ញាធរអនុវត្តសំណើមួយណាដែលមានសមត្ថកិច្ចក្នុងការផ្តល់សំណើសុំជំនួយនេះ ព្រោះត្រូវធ្វើលិខិតមួយទៀតដែលបញ្ជាក់អំពីខ្លឹមសារនៃការស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ពីសំណាក់រដ្ឋសមាជិកអាស៊ានដែលបានស្នើសុំជំនួយមកព្រះរាជាណាចក្រកម្ពុជា ទៅស្ថាប័នអាជ្ញធរអនុវត្តសំណើដែលមានសមត្ថកិច្ចនោះ ដើម្បីឱ្យផ្តល់ជំនួយផ្នែកច្បាប់តាមអ្វីដែលរដ្ឋធ្វើសំណើស្នើសុំចង់បាន។

អាជ្ញាធរអនុវត្តសំណើ ត្រូវបានបែងចែកទៅតាមខ្លឹមសារនៃការស្នើសុំដូចតទៅ៖

- ចំពោះសំណើសុំបញ្ជាក់អត្តសញ្ញាណ ប្រវត្តិរូប សញ្ជាតិ ជាអាទិ៍ គឺជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា។
- ចំពោះសំណើសុំបញ្ជាក់ប្រវត្តិនៃការផ្តន្ទាទោស គឺជាសមត្ថកិច្ចរបស់ក្រសួងយុត្តិធម៌ ដែលមាននាយកដ្ឋានកិច្ចការច្បាប់ទោស នៃអគ្គនាយកដ្ឋានកិច្ចការទោសព្រហ្មទណ្ឌ ជាអ្នកទទួលបន្ទុក។
- ចំពោះការស្នើសុំឱ្យស៊ើបអង្កេត ផ្ទៀងផ្ទាត់ចម្លើយ ចាប់ខ្លួន ឬឃាត់ខ្លួន បង្កកទ្រព្យសម្បត្តិ ជាអាទិ៍ គឺជាសមត្ថកិច្ចរបស់អយ្យការអមសាលាដំបូងរាជធានី/ខេត្ត ដែលត្រូវធ្វើការងារនេះជាមួយអាជ្ញាធរឬភ្នាក់ងារមានសមត្ថកិច្ចផ្សេងទៀត ដូចជាមន្ត្រីនគរបាលយុត្តិធម៌ជាដើម។

ចំពោះលិខិតដែលត្រូវផ្ញើទៅកាន់អាជ្ញាធរអនុវត្តសំណើ ដែលបានរៀបរាប់ខាងលើនេះ ត្រូវបានបែងចែកចេញជា ២ គឺ៖

### ១.២.១.អាជ្ញាធរអនុវត្តសំណើ ជាក្រសួង ឬស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចពាក់ព័ន្ធ

មន្ត្រីជំនាញនៃនាយកដ្ឋានទទួលបន្ទុកកិច្ចការអាស៊ាន ដំបូងត្រូវរៀបចំលិខិតដោយដាក់ ថ្ងៃខែឆ្នាំទាំង ព.ស និងគ.ស បន្ទាប់មកគឺដាក់ពាក្យថា "សូមគោរពជូន (បើរដ្ឋមន្ត្រីទទួលបន្ទុក មានឋានៈចាប់ពីទេសរដ្ឋមន្ត្រី

[106] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ១៣០ អនក្រ.បក, ១ ខែកក្កដា ឆ្នាំ២០២២, មាត្រា៣៣។

ឡើងទៅ) ឬគោរពជូន (បើរដ្ឋមន្ត្រីទទួលបន្ទុកមានឋានៈស្មើគ្នា) ហើយដាច់ខាតត្រូវតែដាក់ឈ្មោះក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនោះ ព្រមទាំងដាក់ឈ្មោះរដ្ឋមន្ត្រីទទួលបន្ទុកក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនោះ និងគោរមងារប្រសិនជាមាន (ឧទាហរណ៍. សម្តេចក្រឡាហោម ជាអាទិ៍)។ បន្ទាប់មកត្រូវដាក់កម្មវត្ថុ និងយោងឱ្យដូចដែលបានដាក់នៅក្នុងកំណត់បង្ហាញដែរ ប៉ុន្តែមិនត្រូវដាក់តាមរយៈថ្នាក់ដឹកនាំដែលទទួលបន្ទុកនោះទេ ព្រោះថាជាលិខិតដែលផ្ញើចេញទៅក្រៅក្រសួង។ បន្ទាប់មកទៀតមន្ត្រីជំនាញត្រូវរៀបរាប់ថា សំណើជំនួយផ្នែកច្បាប់នេះទទួលបានតាមរយៈស្ថាប័នណា ហើយស្នើសុំមកពីរដ្ឋជាសមាជិកអាស៊ានមួយណា និងឈ្មោះបុគ្គលដែលពាក់ព័ន្ធនឹងការស្នើសុំនេះ ព្រមជាមួយខ្លឹមសារនៃសំណើសុំជំនួយផ្នែកច្បាប់ដែលត្រូវនឹងសមត្ថកិច្ចរបស់ស្ថាប័ននោះផងដែរ។ ចុងក្រោយត្រូវភ្ជាប់មកជានិច្ចនូវឃ្លាថា៖

- បើរដ្ឋមន្ត្រីទទួលបន្ទុកមានឋានៈពីថ្នាក់ទេសរដ្ឋមន្ត្រីឡើងទៅ ត្រូវសរសេរថា "សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម (ឧទាហរណ៍.សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី) មេត្តាពិនិត្យ និងចាត់នីតិវិធីបន្តដោយក្តីអនុគ្រោះបំផុត។ សូម (ឧទាហរណ៍សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ) មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ"។
- បើរដ្ឋមន្ត្រីទទួលបន្ទុកមានឋានៈស្មើគ្នា ត្រូវសរសេរថា "សេចក្តីដូចបានជម្រាបជូនខាងលើ សូម (ឧទាហរណ៍ឯកឧត្តមរដ្ឋមន្ត្រី) ជ្រាបជាព័ត៌មាន និងចាត់នីតិវិធីបន្ត។ សូម (ឧទាហរណ៍ឯកឧត្តមរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) ទទួលនូវការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

ហើយចំណុចមួយដែលត្រូវតែមាន និងចាំបាច់បំផុតនោះ គឺហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ដែលច្បាប់បានផ្តល់សមត្ថកិច្ចជាស្ថាប័នអាជ្ញាធរកណ្តាល ឬអាជ្ញាធរសម្របសម្រួលនៃការផ្ញើសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុង វិស័យព្រហ្មទណ្ឌនេះ។ នៅកន្លែងរបស់រដ្ឋមន្ត្រីចុះហត្ថលេខានេះ ត្រូវដាក់ថា "រដ្ឋមន្ត្រីក្រសួងយុត្តិធម៌" ដូចមាននៅក្នុងឧបសម្ព័ន្ធទី៤។ រួចព្រីនដាក់ក្បាលលិខិត ដែលមានកន្លែងចុះលេខចេញរបស់ក្រសួងយុត្តិធម៌។

**១.២.២.អាជ្ញាធរអនុវត្តសំណើ ជាអយ្យការអមសាលាដំបូងរាជធានី/ខេត្ត**

មន្ត្រីជំនាញនៃនាយកដ្ឋានទទួលបន្ទុកកិច្ចការអាស៊ាន ដំបូងត្រូវរៀបចំលិខិតដោយដាក់ ថ្ងៃខែឆ្នាំទាំងព.ស និងគ.ស បន្ទាប់មកគឺដាក់ពាក្យថា "រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជម្រាបមក" រួចហើយត្រូវដាក់ឈ្មោះរបស់ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងរាជធានី/ខេត្ត។ បន្ទាប់មកត្រូវដាក់កម្មវត្ថុ យោង និងខ្លឹមសារដូចបានរៀបរាប់នៅក្នុងចំណុច ១.២.១ (អាជ្ញាធរអនុវត្តសំណើ ជាក្រសួង ឬស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចពាក់ព័ន្ធ) ខាងលើនេះ ខុសគ្នាត្រង់ឃ្លាបញ្ចប់នៃលិខិតត្រូវសរសេរថា "អាស្រ័យហេតុនេះ សូម (ឧទាហរណ៍ឯកឧត្តមព្រះរាជអាជ្ញា) ពិនិត្យ និងចាត់ការតាមនីតិវិធីច្បាប់ និងរាយការណ៍ករណីនេះមកក្រសួងយុត្តិធម៌

ដើម្បីក្រសួងមានមូលដ្ឋានចាត់ការបន្ត។ សូម (ឧទាហរណ៍ឯកឧត្តមព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង) ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ" ដូចមាននៅក្នុងឧបសម្ព័ន្ធទី៤។ និងនៅកន្លែងចុះហត្ថលេខារបស់រដ្ឋមន្ត្រី ដាក់ត្រឹមតែ "រដ្ឋមន្ត្រី" ប៉ុណ្ណោះ មិនដាក់ "រដ្ឋមន្ត្រីក្រសួងយុត្តិធម៌" ដូចនៅក្នុងចំណុច ១.២.១ (អាជ្ញាធរអនុវត្តសំណើជាក្រសួង ឬស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចពាក់ព័ន្ធ) នោះទេ ព្រោះបានបញ្ជាក់នៅខាងលើរួចហើយនៅខាងលើក្បាលលិខិត។ រួចព្រីនដាក់ក្បាលលិខិត ដែលមានកន្លែងចុះលេខចេញរបស់ក្រសួងយុត្តិធម៌។

បន្ទាប់ពីធ្វើកំណត់បង្ហាញ និងលិខិតផ្ញើចេញទៅអាជ្ញាធរអនុវត្តសំណើរួចហើយ តាមបែបរដ្ឋបាលគឺត្រូវយកលិខិតទាំងពីរនេះទៅឱ្យប្រធាននាយកដ្ឋានចុះហត្ថលេខាលើកំណត់ និងគ្រីសលើលិខិតដែលត្រូវផ្ញើចេញ បន្ទាប់មកត្រូវបញ្ជូនសំណុំរឿងដើម និងលិខិតទាំងពីរនេះទៅឱ្យថ្នាក់ដឹកនាំដែលទទួលបន្ទុកនៅក្នុងរឿងនេះដូចបានដាក់នៅត្រង់ចំណុច "តាមរយៈ" នៅក្នុងកំណត់បង្ហាញខាងលើនេះ ដើម្បីឆ្លងមតិយោបល់លើកំណត់បង្ហាញ និងគ្រីសលើលិខិតផ្ញើចេញ ដែលបញ្ជូនទៅតាមលំដាប់ថ្នាក់ដឹកនាំ គឺពីថ្នាក់អគ្គនាយកទៅថ្នាក់អនុរដ្ឋលេខាធិការ ទៅថ្នាក់រដ្ឋលេខាធិការ និងចុងក្រោយគឺបញ្ជូនលិខិតទៅខុទ្ទកាល័យដើម្បីស្នើសុំឆ្លងមតិយោបល់របស់រដ្ឋមន្ត្រី និងចុះហត្ថលេខាលើលិខិតដែលត្រូវផ្ញើចេញ។ បន្ទាប់ពីរដ្ឋមន្ត្រីចុះហត្ថលេខាហើយត្រូវយកលិខិតនេះទៅចុះលេខចេញរបស់ក្រសួងយុត្តិធម៌ នៅនាយកដ្ឋានកិច្ចការរដ្ឋបាល នៃអគ្គលេខាធិការដ្ឋាន[107] បន្ទាប់មកទៀតត្រូវយកលិខិតនេះទៅបោះត្រានៅខុទ្ទកាល័យវិញ រួចហើយនាយកដ្ឋានត្រូវរៀបចំសំបុត្រផ្ញើចេញ ដែលនៅក្នុងនោះមានលិខិតផ្ញើចេញ បូករួមទាំងសំណុំរឿងដើមផងដែរ។ បន្ទាប់មកទៀត ត្រូវយកលិខិតនេះទៅដាក់នៅនាយកដ្ឋានកិច្ចការរដ្ឋបាល នៃអគ្គលេខាធិការដ្ឋាន វិញដើម្បីផ្ញើចេញ។

### ១.៣. លិខិតឆ្លើយតបទៅកាន់រដ្ឋធ្វើសំណើ (ប្រទេសសមាជិកអាស៊ាន)

បន្ទាប់ពីទទួលបានលិខិតឆ្លើយតបចំពោះសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលបានបញ្ជូនមកពីអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចវិញ មន្ត្រីជំនាញដាច់ខាតត្រូវពិនិត្យ និងសិក្សាលម្អិតទៅលើការឆ្លើយតបដែលបានផ្តល់ឱ្យពីអាជ្ញាធរអនុវត្តសំណើនោះ ថាតើចម្លើយដែលបានឆ្លើយតបនោះ គ្រប់គ្រាន់ ឬត្រឹមត្រូវទៅនឹងខ្លឹមសារដែលគេបានស្នើសុំហើយឬនៅ?

បើការឆ្លើយតបនោះមិនត្រឹមត្រូវ ឬមិនគ្រប់គ្រាន់ នោះត្រូវបញ្ជូនលិខិតទៅឱ្យអាជ្ញាធរអនុវត្តសំណើឆ្លើយតបម្តងទៀត ប៉ុន្តែបើខ្លឹមសារនៃការឆ្លើយតបនោះគ្រប់គ្រាន់តាមការចង់បានពីរដ្ឋធ្វើសំណើហើយ មន្ត្រីជំនាញត្រូវរៀបចំកំណត់បង្ហាញជម្រាបទៅរដ្ឋមន្ត្រី ដែលទម្រង់នៃការធ្វើកំណត់បង្ហាញត្រូវរៀបចំទៅតាមទម្រង់ដូចបានរៀបរាប់នៅក្នុងចំណុច ១.១ (កំណត់បង្ហាញ) ខាងលើនេះ លើកលែងតែខ្លឹមសារត្រូវប្តូរមកដាក់ខ្លឹមសារនៃ

[107] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌, លេខ ១៣០ អនក្រ.បក, ១ ខែកក្កដា ឆ្នាំ២០២២, មាត្រា១១។

ការឆ្លើយតបដែលបានមកពីអាជ្ញាធរអនុវត្តសំណើវិញ និងរំលេចឡើងនូវចំណុចមួយតាមបែបបទរដ្ឋបាល គឺស្នើសុំហត្ថលេខារបស់រដ្ឋមន្ត្រី ទៅលើលិខិតឆ្លើយតបនឹងសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ ដែលត្រូវផ្ញើលិខិតឆ្លើយតបនេះតាមរយៈស្ថាប័នសម្របសម្រួលកិច្ចការបរទេសមួយទៀត គឺក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ឬផ្ញើលិខិតនេះដោយផ្ទាល់ពីក្រសួងយុត្តិធម៌ ទៅកាន់ស្ថានទូត ឬស្ថានឯអគ្គរាជទូត ឬស្ថានឯកអគ្គរដ្ឋទូត ឬស្ថានកុងស៊ុល របស់ប្រទេសជាសមាជិកអាស៊ានប្រចាំនៅព្រះរាជាណាចក្រកម្ពុជា (ក្នុងករណីប្រញាប់)។ ក្នុងករណីផ្ញើលិខិតនេះតាមរយៈក្រ.កបទសអ នោះស្ថាប័នសម្របសម្រួលមួយនេះ នឹងផ្ញើលិខិតនេះបន្តទៅស្ថានទូត ឬស្ថានឯកអគ្គរាជទូត ឬស្ថានអគ្គរដ្ឋទូត ឬស្ថានកុងស៊ុល ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ហើយឱ្យស្ថានទូត ឬស្ថានកុងស៊ុលទាំងនោះផ្ញើលិខិតទៅកាន់ក្រសួងការបរទេស របស់រដ្ឋផ្ញើសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធទាំងនោះ ដើម្បីចាត់ការបន្តលើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ។

ចំពោះលិខិតឆ្លើយតបទៅនឹងសំណើសុំជំនួយផ្នែកច្បាប់របស់រដ្ឋផ្ញើសំណើ ដោយផ្ញើលិខិតនេះតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាអាជ្ញាធរសម្របសម្រួលក្នុងការផ្ញើលិខិតឆ្លើយតបនេះទៅកាន់រដ្ឋផ្ញើសំណើសុំជំនួយផ្នែកច្បាប់នេះ អាចរៀបចំបានជា ២ បែប គឺទី១ រៀបរាប់ខ្លឹមសារដែលអាជ្ញាធរអនុវត្តសំណើបានឆ្លើយតបមកនោះទាំងអស់ និងទី២ រៀបរាប់តែខ្លឹមសារបន្តិចបន្តួច (ប្រហែលជា ៣ ទី ៤ បន្ទាត់តាមជាក់ស្តែង) រួចដាក់ពាក្យថា "ដូចបានគោរពជូនភ្ជាប់មកជាមួយ ឬដូចបានភ្ជាប់មកជាមួយ" រួចដាក់ឯកសារដែលជាការឆ្លើយតបពីអាជ្ញាធរអនុវត្តសំណើនោះ ភ្ជាប់ទៅជាមួយនឹងលិខិតនេះផ្ញើទៅកាន់ក្រ.កបរសអ ដើម្បីចាត់ការផ្ញើចេញបន្ត។ ហើយចំពោះទម្រង់នៃការផ្ញើលិខិតឆ្លើយតបដែលផ្ញើតាមរយៈក្រ.កបទសអ នេះ គឺដូចគ្នានឹងទម្រង់ដែលបានរៀបរាប់ក្នុងចំណុច ១.២.១ (អាជ្ញាធរអនុវត្តសំណើ ជាក្រសួង ឬស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចពាក់ព័ន្ធ) ខាងលើនេះ ដោយគ្រាន់តែប្តូរឈ្មោះស្ថាប័ន និងឈ្មោះថ្នាក់ដឹកនាំ (រដ្ឋមន្ត្រី) របស់ស្ថាប័ននេះ (ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ / ក្រ.កបទសអ) តែប៉ុណ្ណោះ។

**២. សំណើចេញ** ( Outgoing )

សំណើចេញ គឺជាសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ របស់ព្រះរាជាណាចក្រកម្ពុជា ស្នើទៅកាន់រដ្ឋទទួលសំណើជារដ្ឋសមាជិកអាស៊ាន ដែលជនល្មើសជាជនជាតិនៃរដ្ឋទាំងនោះ។ សំណើចេញនេះភាគច្រើន គឺបញ្ជូនមកពីស្ថាប័នតុលាការ ដែលនីតិវិធីក្នុងសំណុំរឿងព្រហ្មទណ្ឌដើរដល់ដំណាក់កាលអយ្យការ ឬដំណាក់កាលចៅក្រមស៊ើបសួរ ហើយសំណើនេះត្រូវបានផ្ញើចេញពីស្ថាប័នតុលាការមកក្រសួងយុត្តិធម៌ដោយផ្ទាល់ ដោយមិនចាំបាច់ឆ្លងកាត់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចសំណើចូលនោះទេ ព្រោះជាការស្នើសុំរបស់ស្ថាប័នក្នុងរង្វង់ដែនដីនៃព្រះរាជាណាចក្រកម្ពុជា ប៉ុន្តែលើកលែងតែលិខិតផ្ញើទៅរដ្ឋទទួល

សំណើទើបយើងផ្ញើលិខិតនេះតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ ចំណែកទម្រង់នៃការស្នើសុំជំនួយផ្នែកច្បាប់ដែលផ្ញើពីស្ថាប័នតុលាការនេះត្រូវភ្ជាប់មកជាមួយ ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធនឹងសំណើ អង្គហេតុ ដំណាក់កាលនៃសំណុំរឿង(ស៊ើបអង្កេត ចោទប្រកាន់ ឬស៊ើបសួរ) បទបញ្ញត្តិនៃច្បាប់ សំណើសុំជំនួយជាអាទិ៍។

## ២.១. កំណត់បង្ហាញ

នៅពេលដែលសំណុំរឿងសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ បានចូលមកក្នុងក្រសួង តាមនីតិវិធីដែលបានរៀបរាប់នៅក្នុងចំណុច ២ (សំណើចូល) ខាងលើនេះ ហើយរដ្ឋមន្ត្រីបានចំណារមកអគ្គនាយកដ្ឋាន ហើយអគ្គនាយកដ្ឋានបញ្ជូនសំណុំរឿងនេះមកកាន់នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន ដែលជានាយកដ្ឋានជំនាញក្នុងការរៀបចំសំណុំរឿង MLA ជាមួយប្រទេសមាជិកអាស៊ាននេះ។

បន្ទាប់ពីនាយកដ្ឋានជំនាញបានទទួលសំណុំរឿងហើយ មន្ត្រីជំនាញនៅក្នុងនាយកដ្ឋានត្រូវធ្វើការពិនិត្យមើល និងសិក្សាលម្អិតទៅលើសំណុំរឿងដែលស្ថាប័នតុលាការបញ្ជូនមកនោះ ហើយរៀបចំធ្វើបទបង្ហាញជម្រាបជូនរដ្ឋមន្ត្រី។ ទម្រង់នៃការធ្វើកំណត់បង្ហាញនេះត្រូវរៀបចំដូចក្នុងចំណុច ១.១.១. (ក្បាលលិខិត) ១.១.២. (ខ្លឹមសារ) ១.១.៣. (បញ្ចប់សេចក្តី) នៃចំណុច ១.១ (កំណត់បង្ហាញ) ខាងលើនេះ ហើយខុសគ្នាត្រង់ចំណុចឯកសារយោង ដែលភាគច្រើនគឺជាលិលិខិតដែលផ្ញើមកពីស្ថាប័នតុលាការ ឬស្ថាប័នដែលស្នើសុំ MLA នេះដទៃផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងខុសគ្នាត្រង់ចំណុចខ្លឹមសារ ដែលត្រូវរំលេចឡើងដូចជា ក្រសួងយុត្តិធម៌បានទទួលលិខិតមកពីស្ថាប័នតុលាការមួយណា ហើយស្នើសុំជំនួយផ្នែកច្បាប់ទៅប្រទេសជាសមាជិកអាស៊ានមួយណា។ បន្ទាប់មកត្រូវរំលេចឡើងនូវអត្តសញ្ញាណ រួមទាំងអង្គហេតុរបស់បុគ្គលដែលស្នើសុំជំនួយផ្នែកច្បាប់នេះ និងបញ្ជាក់អំពីស្ថាប័ន (ក្រ.កបទសអ) ដែលត្រូវបញ្ជូនសំណើនេះទៅកាន់រដ្ឋទទួលសំណើជារដ្ឋសមាជិក បូករួមទាំងចំណុចស្នើសុំរដ្ឋមន្ត្រីចុះហត្ថលេខាលើលិខិតផ្ញើទៅកាន់ស្ថាប័នសម្របសម្រួលផ្ញើលិខិតទៅរដ្ឋទទួលសំណើ គឺក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាស្ថាប័នសម្របសម្រួលកិច្ចការអន្តរជាតិ និងកិច្ចការអាស៊ានឈានមុខនៅព្រះរាជាណាចក្រកម្ពុជា និងលិខិតដែលផ្ញើទៅកាន់អាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើជាសមាជិកអាស៊ាននោះផងដែរ ដូចមាននៅក្នុងឧបសម្ព័ន្ធទី៥។

## ២.២. លិខិតផ្ញើទៅកាន់អាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើ

នៅក្នុងសំណើចេញ លិខិតដែលផ្ញើទៅក្រការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (ក្រ.កបទសអ) មាន ២ លិខិត គឺទី១ ជាលិខិតផ្ញើទៅកាន់ ក្រ.កបទសអ ផ្ទាល់តែម្តង ដែលលិខិតនេះជាលិខិតដែលស្នើសុំ ក្រ.កបទសអ ជួយផ្ញើសំណុំឯកសារ MLA ទៅរដ្ឋទទួលសំណើ និងលិខិតទី២ គឺជាលិខិតផ្ញើទៅអាជ្ញាធរ

កណ្តាលនៃរដ្ឋទទួលសំណើ ដើម្បីឱ្យអាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើនោះ ជួយសម្របសម្រួលក្នុងការធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

**២.២.១. លិខិតផ្ញើទៅកាន់ ក្រសួងការបរទេស និងសហប្រតិបត្តិការ (ក្រ.កបទសអ)**

ចំពោះលិខិតទី១ ដែលជាលិខិតត្រូវផ្ញើទៅកាន់ក្រ.កបទសអ នេះ ទម្រង់នៃការរៀបចំលិខិត គឺដូចគ្នាទៅនឹងទម្រង់លិខិតដែលបានរៀបរាប់ក្នុងចំណុច ១.២.១ (អាជ្ញាធរអនុវត្តសំណើ ជាក្រសួង ឬស្ថាប័នរដ្ឋដែលមានសមត្ថកិច្ចពាក់ព័ន្ធ) ខាងលើនេះ ដោយគ្រាន់តែប្តូរមកដាក់ឈ្មោះស្ថាប័ន និងឈ្មោះរដ្ឋមន្ត្រីនៃស្ថានប័នសម្របសម្រួលនេះ និងបញ្ជាក់ចំណុចមួយចំនួនដូចជា ក្រសួងយុត្តិធម៌បានទទួលលិខិតសំណើសុំជំនួយពីស្ថាប័នណា ហើយស្នើសុំជំនួយទៅប្រទេសអាស៊ានមួយណា និងទៅលើបុគ្គលឈ្មោះអ្វី (អត្តសញ្ញាណនៃបុគ្គលដែលស្នើសុំជំនួយផ្នែកច្បាប់) រួមទាំងបញ្ជាក់ខ្លឹមសារបន្ថែមមួយចំនួនដូចជា ៖

- ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំសំណើ និងលិខិតផ្ញើជូនអាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើ ដើម្បីស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។
- ស្នើសុំ ក្រ.កបទសអ ពិនិត្យ និងចាត់នីតិវិធីក្នុងការបញ្ជូនសំណើបន្តទៀត។
- និងសរសេររៀបរាប់អំពីសេចក្តីគោរពចំពោះ ក្រ.កបទសអ បូករួមទាំងកន្លែងដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវចុះហត្ថលេខា និងបោះត្រា ដូចមាននៅក្នុងឧបសម្ព័ន្ធទី៥។

**២.២.២. លិខិតផ្ញើទៅកាន់អាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើ**

លិខិតទី២ ដែលជាលិខិតផ្ញើទៅកាន់អាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើ គឺត្រូវសរសេរជាភាសាអង់គ្លេស ព្រោះនៅក្នុងក្របខណ្ឌអាស៊ាន រដ្ឋដែលជាសមាជិកអាស៊ានទាំងអស់បានព្រមព្រៀងគ្នាក្នុងការប្រើភាសាអង់គ្លេសដើម្បីធ្វើការទំនាក់ទំនងក្នុងសំណុំរឿង MLA នេះ ដែលទម្រង់នៃការរៀបចំលិខិតនេះ ត្រូវរៀបរាប់អំពីចំណុចមួយចំនួនដូចជា ៖

- ទីតាំងអាសយដ្ឋាននៃស្ថាប័ន ដែលជាអាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើ ទៅតាមច្បាប់នៃប្រទេសរដ្ឋទទួលសំណើបានកំណត់ (ឧទាហរណ៍៖ អាជ្ញាធរកណ្តាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមក្នុងសំណុំរឿង MLA គឺស្ថាប័នតុលាការកំពូលប្រជាជននៃសាធារណរដ្ឋសង្គមនិយមវៀតណាមជាអ្នកទទួលបន្ទុក)។
- កម្មវត្ថុ ត្រូវដាក់ឱ្យបានច្បាស់លាស់ក្នុងគោលបំណងនៃការស្នើសុំជំនួយផ្នែកច្បាប់ ដូចជាស្វែករកអត្តសញ្ញាណ បញ្ជាក់អត្តសញ្ញាណ ឬបញ្ជាក់ពីប្រវត្តិនៃការផ្តន្ទាទោសជាអាទិ៍ (ឧទាហរណ៍៖ The request for legal assistance in criminal matters to research the history of convictions of Mr.ABC)

- លិខិតយោង ត្រូវដាក់លិខិតយោងដែលផ្ញើមកពីស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា ដែលស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ និងយោងសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន ឬច្បាប់ដែលកម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាខាងលើនេះ ឬច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ របស់ព្រះរាជាណាចក្រកម្ពុជា ឬសន្ធិសញ្ញាទ្វេភាគីស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាមួយរដ្ឋទទួលសំណើបើមាន។
- នៅត្រង់ចំណុចខ្លឹមសារនៃការស្នើសុំ ត្រូវសរសេរទៅតាមគំរូលិខិតរដ្ឋបាលដែលត្រូវបានដាក់ឱ្យប្រើប្រាស់ តាមរយៈអគ្គនាយកកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌ ដោយគ្រាន់តែប្តូរកម្មវត្ថុនៃការស្នើសុំជំនួយផ្នែកច្បាប់តែប៉ុណ្ណោះ គឺ "With reference to the above subject, the Ministry of Justice of the Kingdom of Cambodia presents its compliments to the (central authority of the country that we request for MLA) and has the honor to inform that the Ministry of Justice of the Kingdom of Cambodia would like to request the (central authority of the country that we request for MLA) to assist in executing the request for legal assistance to research the history of convictions of Mr.ABC." ចុះបន្ទាត់មួយ បន្ទាប់មកត្រូវរៀបរាប់ថា "The detailed contents of the request are specified in the attachment herewith. The Ministry of Justice of the Kingdom of Cambodia highly appreciates the assistance of the (central authority of the country that we request for MLA) in executing the aforesaid request as soon as possible." បន្ទាប់មកចុះបន្ទាត់ម្តងទៀត រួចសរសេរថា "The Ministry of Justice of the Kingdom of Cambodia avails itself of this opportunity to renew to the (central authority of the country that we request for MLA) the assurances of its high consideration."
- កន្លែងចុះហត្ថលេខា និងឈ្មោះរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជាភាសាអង់គ្លេស និង
- ដាក់សារអេឡិចត្រូនិចរបស់អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា (E-mail ផ្លូវការរបស់អាជ្ញាធរកណ្តាលនៃក្រសួងយុត្តិធម៌ គឺ ca_cambodia@moj.gov.kh) ដើម្បីឱ្យរដ្ឋទទួលសំណើអាចធ្វើការទំនាក់ទំនង ដូចមាននៅក្នុងឧបសម្ព័ន្ធទី៥។

## ២.៣. ទម្រង់លិខិតសំណើសុំជំនួយផ្នែកច្បាប់ (MLA) ទៅរដ្ឋទទួលសំណើ

សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌទៅប្រទេសជាសមាជិកអាស៊ាន ត្រូវបានរៀបចំដោយមានចំនួន ២ ភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស (បកប្រែពីភាសារខ្មែរទៅជាភាសាអង់គ្លេស) ដែលទម្រង់នៃការធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ ត្រូវបានរៀបចំតាមទម្រង់ដូចខាងក្រោម ៖

**១. ទម្រង់នៃសំណើ ៖** សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ និងភាសាអង់គ្លេស។

**២. ឈ្មោះស្ថាប័ន អង្គភាពដែលមានសមត្ថកិច្ចក្នុងសំណើ ៖** នៅក្នុងសំណើនេះត្រូវបញ្ជាក់អំពីលេខនៃសំណុំរឿង និងឈ្មោះអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលស្នើសុំជំនួយផ្នែកច្បាប់។

**៣. ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធនឹងសំណើ ៖** នៅក្នុងសំណើនេះ ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធមានដូចជានាមត្រកូល នាមខ្លួន ភេទ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត លិខិតឆ្លងដែន អត្តសញ្ញាប័ណ្ណ និងអាសយដ្ឋានបច្ចុប្បន្នរបស់បុគ្គលស្នើសុំ។

**៤. អង្គហេតុ ៖** ការពណ៌នាអំពីសញ្ញាណនៃរឿងក្តីព្រហ្មទណ្ឌ រួមបញ្ចូលទាំងសេចក្តីសង្ខេបអង្គហេតុ ឈ្មោះនៃបទល្មើស និងទោសដែលត្រូវអនុវត្ត ដែលជាអំពើបង្កើតបានជាបទល្មើសព្រហ្មទណ្ឌហើយត្រូវបានផ្តន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋទទួលសំណើ។

**៥. ព័ត៌មានអំពីកិច្ចនីតិវិធីរបស់តុលាការ ឬមន្ត្រីនគរបាលយុត្តិធម៌ ៖** ចំណាត់ការនៃនីតិវិធីពាក់ព័ន្ធនឹងបុគ្គលស្នើសុំ។

**៦. បទប្បញ្ញត្តិនៃច្បាប់ ៖** អត្ថបទច្បាប់ដែលចែងអំពីបទល្មើស ព្រមទាំងសេចក្តីបង្គាប់របស់តុលាការ។

**៧. កម្មវត្ថុនៃការស្នើសុំ ៖** ការពិពណ៌នាអំពីគោលបំណងនៃការស្នើសុំជំនួយ និងប្រភេទនៃជំនួយដែលត្រូវស្វែករកស្របតាមបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋទទួលសំណើ។

**៨. ការបញ្ជាក់ពីមូលហេតុ និងតម្រូវការជាក់លាក់ក្នុងសំណើ ៖** ការរៀបរាប់របស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធរបស់ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋធ្វើសំណើអំពីសារៈសំខាន់នៃការអនុវត្តសំណើសុំការជួយផ្នែកច្បាប់ និងការប្រើប្រាស់សំណើបម្រើដល់ដំណើរការនីតិវិធីនានាពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ។

**៩. ការកំណត់កាលបរិច្ឆេទនៃការផ្តល់ព័ត៌មាន ៖** យោងតាម សេចក្តីណែនាំលេខ ០៣ កយ.សណន/២០ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកំណត់អាទិភាពនៃការកំណត់សំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងករណីចាំបាច់ សំណើសុំការជួយផ្នែកច្បាប់ អាចបញ្ជាក់ពេលវេលាជាក់លាក់របស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ឬរដ្ឋបរទេស ក្នុងការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តសំណើ។

**១០. ការរក្សាការសម្ងាត់ ៖** មន្ត្រីទទួលបន្ទុកការងារពាក់ព័ន្ធនឹងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា (សំណើចូល) និងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនោះទៅកាន់រដ្ឋទទួលសំណើ (សំណើចេញ) ត្រូវចាត់វាល់វិធានការសមស្របដើម្បីរក្សាការសម្ងាត់នៃសំណើសុំជំនួយ ខ្លឹមសារ និងឯកសារយោងនៃសំណើ ការសម្រេចផ្តល់ជំនួយ និងចំណាត់ការណាមួយនៃការអនុវត្តសំណើ ប្រសិនបើមានការស្នើសុំដូច្នេះពីរដ្ឋផ្ញើសំណើ។ ប្រសិនបើសំណើមិនអាចអនុវត្តបានដោយមិនបំពានលើតម្រូវការរក្សាការសម្ងាត់នោះ មន្ត្រីនៃអាជ្ញាធរកណ្តាលត្រូវជូនដំណឹងអំពីបញ្ហានេះទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋផ្ញើសំណើដើម្បីកំណត់ថាតើត្រូវអនុវត្តដែរឬទេ។[108]

**២.៣.១. សេចក្តីផ្តើមនៃសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ**

សេចក្តីផ្តើមនៃការធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ គឺត្រូវរៀបរាប់អំពីឈ្មោះអាជ្ញាធរកណ្តាលនៃរដ្ឋដែលផ្ញើសំណើ (ឧទាហរណ៍អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា) ទៅអាជ្ញាធរកណ្តាលនៃរដ្ឋដែលទទួលសំណើ (ឧទាហរណ៍អាជ្ញធរកណ្តាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ) ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦។ បន្ទាប់មកត្រូវរៀបរាប់អំពីច្បាប់ ឬសន្ធិសញ្ញាដែលយកមកផ្អែកក្នុងការធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ ដែលច្បាប់ ឬសន្ធិសញ្ញាទាំងនោះមានដូចខាងក្រោម ៖

- បើព្រះរាជាណាចក្រកម្ពុជាបានចុះសន្ធិសញ្ញាទ្វេភាគី ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ជាមួយរដ្ឋជាសមាជិកអាស៊ានមួយណា នោះការធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ ត្រូវផ្អែកទៅតាមសន្ធិសញ្ញាមួយនោះ។ តួយ៉ាងព្រះរាជាណាចក្រកម្ពុជាបច្ចុប្បន្ននេះ មានសន្ធិសញ្ញាទ្វេភាគីជាសាធារណរដ្ឋសង្គមនិយមវៀតណាមតែមួយប៉ុណ្ណោះ គឺសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។
- បើមិនមានសន្ធិសញ្ញាទ្វេភាគីក្នុងរឿង MLA នោះទេ គឺត្រូវផ្អែកតាមសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន ដែលប្រទេសជាសមាជិកអាស៊ានបានរួមគ្នាចុះហត្ថលេខាលើសន្ធិសញ្ញាមួយនេះ កាលពីឆ្នាំ២០០៤ ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ២០១០។
- មួយវិញទៀតបើចំពោះប្រទេសដទៃទៀតមិនមែនជាសមាជិកអាស៊ាន ហើយកម្ពុជាក៏មិនបានចុះសន្ធិសញ្ញាទ្វេភាគីក្នុងរឿង MLA ជាមួយប្រទេសនោះដែរ គឺត្រូវផ្អែកតាមច្បាប់ស្តីពីជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា ឬគេហៅថាទម្រង់បដិការ (គេជួយ យើង យើងជួយគេ)។

[108] សេចក្តីណែនាំស្តីពីការកំណត់ទម្រង់នៃការអនុវត្តសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ, ២៧ ខែវិច្ឆិកា ឆ្នាំ២០២០។

### ២.៣.២. ព័ត៌មានរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៅទីនេះចង់សំដៅដល់ ស្ថាប័នមានសមត្ថកិច្ចដែលបានស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ ដែលភាគច្រើនគឺស្ថាប័នតុលាការ (សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី/ខេត្ត)។ មួយវិញទៀត ចំពោះព័ត៌មានរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនេះ គឺយើងត្រូវរៀបរាប់ចំនួន ២ ចំណុចដូចខាងក្រោម៖

- លិខិត/សំណុំរឿង ៖ គឺលេខរបស់សំណុំរឿងព្រហ្មទណ្ឌនោះ និងថ្ងៃខែឆ្នាំរបស់លិខិត/សំណុំរឿងនោះ ហើយឈ្មោះរបស់ស្ថាប័នដែលស្នើសុំជំនួយផ្នែកច្បាប់។
- អាជ្ញាធរធ្វើសំណើ ៖ គឺអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងការស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ គឺស្ថាប័នតុលាការ។ សាលាដំបូងរាជធានី/ខេត្ត បើសំណុំរឿងព្រហ្មទណ្ឌនេះដើរដល់ដំណាក់កាលស៊ើបសួរ ឬចៅក្រមស៊ើបសួរ ឬអយ្យការអមសាលាដំបូងរាជធានី/ខេត្ត បើសំណុំរឿងនេះនៅត្រឹមដំណាក់កាលចោទប្រកាន់ ឬព្រះរាជអាជ្ញា ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦។

### ២.៣.៣. ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធនឹងសំណើ

បុគ្គលពាក់ព័ន្ធនឹងសំណើ ចង់សំដៅដល់បុគ្គលដែលយើងបានធ្វើការស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះឯង។ ហើយនៅចំណុចព័ត៌មានរបស់បុគ្គលពាក់ព័ន្ធនឹងសំណើនេះ យើងត្រូវរៀបរាប់អត្តសញ្ញាណរបស់បុគ្គលទាំងនោះ (មានប៉ុន្មាននាក់ ដាក់ប៉ុណ្ណឹងនាក់) ដោយត្រូវដាក់ឈ្មោះ អាយុ ភេទ មុខរបរ ជនជាតិ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន (បើមាន) អាសយដ្ឋានបច្ចុប្បន្ន និងព័ត៌មានអំពីគ្រួសារ ដូចជាឈ្មោះឪពុកម្តាយ ឈ្មោះប្រពន្ធកូន (បើមាន) និងត្រូវបញ្ជាក់ថាគ្រួសារស្លាប់ ឬនៅរស់ (ឧទាហរណ៍មានម្តាយអត់ឪពុក ដាក់ថា ម្តាយ(រ=រស់) ឪពុក (ស=ស្លាប់) ហើយបើគ្មានប្រពន្ធកូន ត្រូវដាក់ថានៅលីវ ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦។

### ២.៣.៤. អង្គហេតុ

ចំពោះអង្គហេតុ យើងត្រូវសរសេររៀបរាប់អំពីហេតុការណ៍ជាក់ស្តែង ដែលបណ្តាលឱ្យកើតមានបទល្មើសដែលវាជាអង្គហេតុដែលត្រូវបានបញ្ជូនមកពីស្ថាប័នតុលាការ ឬស្ថាប័នដែលស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ។ ចំណុចដែលលម្អិតជាគេនោះ គឺត្រូវរៀបរាប់អំពីពេលវេលា ថ្ងៃខែឆ្នាំ ទីកន្លែងប្រព្រឹត្តបទល្មើស ឈ្មោះរបស់ជនល្មើស និងបុគ្គលដែលពាក់ព័ន្ធជាមួយជនល្មើស (អាចជាអ្នកផ្តើមគំនិត អ្នកសមគំនិត ឬសហចារីជាអាទិ៍) ឱ្យបានច្បាស់លាស់ ហើយជាពិសេសទៅទៀតនោះ គឺត្រូវសរសេរបញ្ចូលទាំងសកម្មភាពក្នុងការប្រព្រឹត្តបទល្មើសរបស់ចារី ឬសហចារីផងដែរ ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦។

### ២.៣.៥. ដំណើរការនៃសំណុំរឿង

ដំណាក់កាលនៃសំណុំរឿង នៅទីនេះចែកចេញជា ៣ ដំណាក់កាល ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦ គឺ ៖

- ដំណាក់កាលទី១ គឺការស្រាវជ្រាវរបស់សមត្ថកិច្ច ៖ ដំណាក់កាលនេះ គឺជាដំណាក់ដំបូងបំផុតក្នុងការដំណើការសំណុំរឿងក្តីព្រហ្មទណ្ឌ ដែលក្នុងនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានឱ្យឈ្មោះដំណាក់កាលនេះថា ដំណាក់កាលស៊ើបអង្កេត ឬដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌នេះ ជាអ្នកដែលស៊ើបអង្កេត ស្រាវជ្រាវ តាមដាន រើកមុខរកជនល្មើស ឬចារី និងបុគ្គលដែលពាក់ព័ន្ធជាមួយបទល្មើស ដើម្បីកសាងសំណុំរឿងបញ្ជូនទៅស្ថាប័នអយ្យការអមសាលាដំបូងរាជធានី/ខេត្ត (ដំណាក់កាលទី២ នៃសំណុំរឿងព្រហ្មទណ្ឌ)។ នៅក្នុងដំណាក់កាលនេះត្រូវសរសេររៀបរាប់លម្អិតអំពីដំណើរការនៃការចាប់ជនល្មើស និងវត្ថុតាង ដើម្បីបញ្ជូនខ្លួនទៅស្ថាប័នអយ្យការអមសាលាដំបូងរាជធានី/ខេត្ត។
- ដំណាក់កាលទី២ គឺការស្រាវជ្រាវរបស់តំណាងអយ្យការ ៖ នៅក្នុងនីតិវិធីព្រហ្មទណ្ឌនៅពេលដែលស្ថាប័នអយ្យការអមសាលាដំបូងរាជធានី/ខេត្ត បានទទួលសំណុំរឿងព្រហ្មទណ្ឌពីដៃរបស់នគរបាលយុត្តិធម៌រួចហើយ នោះតំណាងអយ្យការ ឬព្រះរាជអាជ្ញា នឹងធ្វើការស៊ើបអង្កេត ស្រាវជ្រាវ សាកសួរនាំជនល្មើស និងសិក្សាទៅលើសំណុំរឿងសារជាថ្មីម្តងទៀត ដើម្បីធានាតម្លាភាពនៃប្រព័ន្ធយុត្តិធម៌នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅពេលដែលតំណាងអយ្យការ ឬព្រះរាជអាជ្ញា បានធ្វើការសិក្សាទៅលើសំណុំរឿងរួចហើយ រកឃើញថាពិតជាមានបទល្មើសពិតប្រាកដមែននោះ តំណាងអយ្យការ ឬព្រះរាជអាជ្ញា នឹងធ្វើការចោទប្រកាន់ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត និងបុគ្គលដែលពាក់ព័ន្ធនឹងបទល្មើសដទៃទៀត ពីបទល្មើសដែលខ្លួនបានប្រព្រឹត្ត ឬចូលរួមប្រព្រឹត្ត រួចបញ្ជូនជនទាំងនេះបូករួមទាំងសំណុំរឿង និងភស្តុតាងទៅកាន់ចៅក្រមស៊ើបសួរតាមនីតិវិធីព្រហ្មទណ្ឌ (ដំណាក់កាលទី៣ជាដំណាក់កាលស៊ើបសួរ)។ នៅក្នុងចំណុចនេះ ត្រូវសរសេររៀបរាប់លម្អិតអំពី ការស៊ើបអង្កេតស្រាវជ្រាវ សាកសួរនាំជនល្មើសសារជាថ្មីម្តងទៀតរបស់តំណាងអយ្យការ និងការចោទប្រកាន់អំពីបទល្មើសរបស់តំណាងអយ្យការទៅលើជនល្មើស រួមទាំងការបញ្ជូនខ្លួនជនត្រូវចោទទៅកាន់ចៅក្រមស៊ើបសួរផងដែរ។
- ដំណាក់កាលទី៣ គឺការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ ៖ មុននឹងបញ្ជូនជនជាប់ចោទទៅជំនុំជម្រះនៅក្នុងនីតិវិធីព្រហ្មទណ្ឌត្រូវឆ្លងកាត់ដំណាក់កាលស៊ើបសួរជាមុនសិន ដែលមានចៅក្រមស៊ើបសួរជាអ្នកទទួលបន្ទុក។ ដើម្បីឱ្យភាពយុត្តិធម៌ប្រព្រឹត្តទៅដោយរលូន គេបានបង្កើតឱ្យមានដំណាក់កាលស៊ើបសួរមួយទៀត ដើម្បីបើកការស៊ើបសួរទៅលើជនត្រូវចោទ ដែលត្រូវព្រះរាជអាជ្ញាបានធ្វើការ

ចោទប្រកាន់អំពីបទល្មើសនោះ ថាត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់ដែរឬទេ។ នៅក្នុងដំណាក់កាលនេះ គឺពិសេសត្រង់ថា បើចៅក្រមស៊ើបសួរបើកការស៊ើបសួរហើយ ពុំរកឃើញថាមានភស្តុតាងណាមួយដែលនាំឱ្យជនត្រូវចោទមានពិរុទ្ធភាពនោះទេ នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យដោះលែងជនត្រូវចោទនោះឱ្យមានសេរីភាពវិញបាន ឬចៅក្រមស៊ើបសួររកឃើញថា តំណាងអយ្យការបានចោទប្រកាន់លើជនត្រូវចោទចំពោះបទល្មើស ដែលមិនត្រឹមត្រូវតាមអង្គហេតុនៃសំណុំរឿងនោះទេ នោះចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឱ្យតំណាងអយ្យការធ្វើការចោទប្រកាន់ ឬស៊ើបអង្កេតសារជាថ្មីម្តងទៀត។ ក៏ប៉ុន្តែបើ ចៅក្រមស៊ើបសួរបើកការស៊ើបសួរហើយ រកឃើញនូវពិរុទ្ធភាពរបស់ជនត្រូវចោទ ដូចដែលតំណាងអយ្យការបានចោទប្រកាន់មែននោះ ចៅក្រមស៊ើបសួរនឹងចេញដីកាបង្គាប់បញ្ជូនជនជាប់ចោទទៅជំនុំជម្រះក្តីតាមនីតិវិធីព្រហ្មទណ្ឌតែម្តង (នីតិវិធីចុងក្រោយក្នុងសំណុំរឿងព្រហ្មទណ្ឌក្នុងសាលាដំបូងរាជធានី/ខេត្ត ដែលចៅក្រមជំនុំជម្រះជាអ្នកមានសមត្ថកិច្ច)។ នៅក្នុងដំណាក់កាលនេះ ភាគច្រើនជាដំណាក់កាលដែលត្រូវធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌទៅរដ្ឋទទួលសំណើហើយ ព្រោះដើម្បីធ្វើឱ្យការជំនុំជម្រះប្រព្រឹត្តទៅដោយរលូន និងមានតម្លាភាពចំពោះគូភាគី។ នៅត្រង់ចំណុចនេះ យើងត្រូវរៀបរាប់អំពីការដែលចៅក្រមស៊ើបសួរទទួលបានសំណុំរឿងពីតំណាងអយ្យការ ហើយសម្រេចឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទ ដើម្បីបន្តស្រាវជ្រាវបន្ថែមទៀតពាក់ព័ន្ធនឹងសំណុំរឿងក្តីព្រហ្មទណ្ឌ ឬដើម្បីធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌទៅរដ្ឋទទួលសំណើនេះតែម្តង។

ដំណាក់កាលទាំង ៣ ខាងលើនេះ ភាគច្រើនគឺមាននៅក្នុងឯកសារដែលស្ថាប័នតុលាការបានផ្ញើមករួចហើយ ដោយយើងគ្រាន់តែចម្លងចូលទៅក្នុងលិខិតនៃសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌតែប៉ុណ្ណោះ។

### ២.៣.៦. បទប្បញ្ញត្តិនៃច្បាប់

បទប្បញ្ញត្តិនៃច្បាប់នៅទីនេះ គឺជាបទប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ដែល ជនល្មើសបានប្រព្រឹត្ត (ឧទាហរណ៍ ជនល្មើសបានប្រព្រឹត្តបទល្មើសជួញដូរគ្រឿងញៀន) នោះយើងត្រូវលើកយកខ្លឹមសារទាំងអស់នៃមាត្រាណាដែលបានចែងច្បាស់លាស់អំពីការជួញដូរគ្រឿងញៀន នៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន មកសរសេរបញ្ចូលទៅក្នុងសំណើនេះ ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦។ គួរបញ្ជាក់ផងដែរថា បច្ចុប្បន្ននៅក្នុងក្រសួងយុត្តិធម៌ សំណុំរឿងសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌទៅកាន់រដ្ឋទទួលសំណើជាសមាជិកអាស៊ាន ភាគច្រើនជាសំណុំរឿងដែលពាក់ព័ន្ធនឹងបទល្មើស ជួញដូរគ្រឿងញៀន សម្អាតប្រាក់ និងជួញដូរ

មនុស្ស ដែលភាគច្រើនត្រូវប្រើបទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលជាច្បាប់ត្រូវយកមកប្រើច្រើនជាងគេ។

**២.៣.៧. សំណើសុំជំនួយ**

សំណើសុំជំនួយ គឺសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌទៅរដ្ឋទទួលសំណើជាសមាជិកអាស៊ាននេះឯង ដែលនៅក្នុងចំណុចនេះត្រូវរៀបរាប់ឱ្យបានច្បាស់អំពីការស្នើសុំជំនួយផ្នែកច្បាប់របស់ស្ថាប័នអាជ្ញាធរធ្វើសំណើទៅរដ្ឋទទួលសសំណើជាសមាជិកអាស៊ាន។ សំណើទាំងនោះមានជាអាទិ៍ដូចជា ការស្នើសុំប្រវត្តិនៃការផ្តន្ទាទោសលើជនល្មើស ឬស្វែងរកអត្តសញ្ញាណ ឬបញ្ជាក់អត្តសញ្ញាណ ឬសាកសួរចម្លើយ ឬស៊ើបអង្កេតជនដែលពាក់ព័ន្ធនឹងជនល្មើស។ ហើយនៅទីនេះត្រូវប្រើពាក្យថាអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាស្នើសុំជំនួយផ្នែកច្បាប់ ពីអាជ្ញាធរកណ្តាលនៃប្រទេសសមាជិកអាស៊ាន (ឈ្មោះហៅជាផ្លូវការនៃប្រទេសសមាជិកអាស៊ាន) ដើម្បីស្នើសុំ...(រៀបរាប់ខ្លឹមសារនៃការស្នើសុំជំនួយផ្នែកច្បាប់) ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦។

**២.៣.៨. កាលបរិច្ឆេទកំណត់នៃការផ្តល់ជំនួយផ្នែកច្បាប់**

កាលបរិច្ឆេទកំណត់នៃការផ្តល់ជំនួយផ្នែកច្បាប់ គឺជាកាលបរិច្ឆេទមួយដើម្បីកំណត់ថេរវេលា ដើម្បីឱ្យរដ្ឋទទួលសំណើជាសមាជិកអាស៊ានផ្តល់ជំនួយផ្នែកច្បាប់មកឱ្យព្រះរាជាណាចក្រកម្ពុជាវិញ ទៅតាមពេលវេលាដែលព្រះរាជាណាចក្រកម្ពុជាបានកំណត់ឱ្យ។ ចំពោះកាលបរិច្ឆេទកំណត់នេះទៀតសោត គឺជាការកំណត់របស់ចៅក្រមស៊ើបសួរ ដែលជាអ្នកស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះផ្ទាល់តែម្តង។ ហើយភាគច្រើននោះថេរវេលានេះ គឺស៊ីមេទ្រីគ្នាជាមួយនឹងថេរវេលានៃការឃុំខ្លួនលើជនល្មើសតែម្តង ជាគោលការណ៍គឺចំនួន ៦ខែ។ ក៏ប៉ុន្តែ បើអាជ្ញាធរធ្វើសំណើមិនបានបញ្ជាក់អំពីថេរវេលាច្បាស់លាស់ទេនោះ យើងត្រូវសរសេរថា "អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំអាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើ ជួយផ្តល់នូវព័ត៌មានដែលបានស្នើសុំខាងលើឱ្យបានឆាប់ ដើម្បីជួយដល់នីតិវិធីនៃដំណើរការរឿងក្តីក្នុងសំណុំរឿងព្រហ្មទណ្ឌ នៅក្នុងព្រះរាជាណាចក្រកម្ពុជា" ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦។

**២.៣.៩. ការរក្សាការសម្ងាត់**

ការរក្សាការសម្ងាត់នេះ គឺធ្វើឡើងដើម្បីគោរពដល់គោលការណ៍នៃការធ្វើសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាមួយរដ្ឋទទួលសំណើជាសមាជិកអាស៊ាន។ នៅចំណុចនេះត្រូវសរសេររៀបរាប់ថា "អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យអាជ្ញាធរកណ្តាលនៃរដ្ឋទទួលសំណើ (ឈ្មោះហៅជាផ្លូវការនៃប្រទេសសមាជិកអាស៊ាន ដែលស្នើសុំ) ជួយរក្សាការសម្ងាត់នៃសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះរួមទាំងឯកសារទាំងឡាយដែលបានភ្ជាប់ជូននៅក្នុងសំណើនេះ ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦។

### ២.៣.១០. ការអះអាងចំពោះសំណើ

ការអះអាងចំពោះសំណើនេះ គឺជាការធានាលើព័ត៌មានអំពីជំនួយផ្នែកច្បាប់ដែលបានផ្ដល់ឱ្យដោយរដ្ឋទទួលសំណើ។ នៅក្នុងចំណុចនេះត្រូវសរសេររៀបរាប់ថា "អាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជាអះអាងថា ជំនួយផ្នែកច្បាប់ដែលបានផ្ដល់ឱ្យដោយរដ្ឋទទួលសំណើ (ឈ្មោះហៅជាផ្លូវការនៃប្រទេសសមាជិកអាស៊ាន ដែលស្នើសុំ) ចំពោះសំណើនេះនឹងត្រូវបានរក្សាការសម្ងាត់ និងត្រូវប្រើប្រាស់សម្រាប់តែគោលបំណងដែលមានចែងក្នុងសំណើនេះតែប៉ុណ្ណោះ។ អាជ្ញាធរកម្ពុជានឹងផ្ដល់ជំនួយផ្នែកច្បាប់ឱ្យរដ្ឋទទួលសំណើ (ឈ្មោះហៅជាផ្លូវការនៃប្រទេសសមាជិកអាស៊ាន ដែលស្នើសុំ) នៅពេលដែលមានការស្នើសុំ" ដូចមាននៅក្នុងឧបសម្ព័ន្ធទី៦។

## ២.៤. លិខិតឆ្លើយតបទៅកាន់អាជ្ញាធរធ្វើសំណើ

បន្ទាប់ពីទទួលបានលិខិតឆ្លើយតបចំពោះសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលបានបញ្ជូនមកពីរដ្ឋទទួលសំណើវិញ មន្ត្រីជំនាញជាច់ខាតត្រូវពិនិត្យ និងសិក្សាលម្អិតទៅលើការឆ្លើយតបដែលបានផ្ដល់ឱ្យពីរដ្ឋទទួលសំណើនោះ ថាតើឯកសារ ឬចម្លើយដែលបានឆ្លើយតបនោះគ្រប់គ្រាន់ ឬត្រឹមត្រូវទៅនឹងខ្លឹមសារដែលអាជ្ញាធរធ្វើសំណើបានស្នើសុំហើយឬនៅ?

បើការឯកសារ ឬការឆ្លើយតបនោះមិនត្រឹមត្រូវ ឬមិនទាន់គ្រប់គ្រាន់ នោះអាជ្ញាធរកណ្ដាលត្រូវបញ្ជូនលិខិតទៅឱ្យរដ្ឋទទួលសំណើដើម្បីពិនិត្យ និងឆ្លើយតបម្ដងទៀត ប៉ុន្តែបើខ្លឹមសារនៃការឆ្លើយតបនោះគ្រប់គ្រាន់តាមការចង់បានពីអាជ្ញាធរធ្វើសំណើហើយ មន្ត្រីជំនាញត្រូវរៀបចំកំណត់បង្ហាញជម្រាបទៅរដ្ឋមន្ត្រី ដែលទម្រង់នៃការធ្វើកំណត់បង្ហាញត្រូវរៀបចំទៅតាមទម្រង់ដូចបានរៀបរាប់នៅក្នុងចំណុច ១.១ (កំណត់បង្ហាញ) ខាងលើនេះ លើកលែងតែខ្លឹមសារត្រូវប្ដូរមកដាក់ខ្លឹមសារនៃការឆ្លើយតបដែលបានមកពីរដ្ឋទទួលសំណើវិញ និងរំលេចឡើងនូវចំណុចមួយតាមបែបបទរដ្ឋបាល គឺស្នើសុំហត្ថលេខារបស់រដ្ឋមន្ត្រី ទៅលើលិខិតឆ្លើយតបនឹងសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ ដែលអាជ្ញាធរកណ្ដាលត្រូវផ្ញើឯកសារ ឬចម្លើយឆ្លើយតបនេះទៅកាន់អាជ្ញាធរធ្វើសំណើនៃព្រះរាជាណាចក្រកម្ពុជាផ្ទាល់តែម្ដង ដោយមិនចាំបាច់ផ្ញើតាមអង្គភាពសម្របសម្រួលណាមួយឡើយ ព្រោះថាអាជ្ញាធរកណ្ដាល និងអាជ្ញាធរធ្វើសំណើ គឺជាស្ថាប័នដែលនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដូចគ្នា មិនដូចការធ្វើសំណើចូលទេ ដែលលទ្ធផលនៃសំណើត្រូវផ្ញើចេញពីអាជ្ញាធរអនុវត្តសំណើទៅអាជ្ញាធរកណ្ដាល រួចអាជ្ញាធរកណ្ដាលត្រូវផ្ញើបន្តទៅស្ថានទូតនៃរដ្ឋធ្វើសំណើប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ឬផ្ញើទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យស្ថាប័នទាំងនេះផ្ញើលទ្ធផលនៃសំណើបន្តទៅអាជ្ញាធរកណ្ដាលនៃរដ្ឋធ្វើសំណើ។

ចំពោះទម្រង់នៃលិខិតឆ្លើយតបទៅនឹងសំណើសុំជំនួយផ្នែកច្បាប់របស់អាជ្ញាធរផ្ញើសំណើ អាចរៀបចំបានជា ២ បែប ដូចគ្នានឹងសំណើចូលដែរ គឺទី១ រៀបរាប់ខ្លឹមសារដែលរដ្ឋទទួលសំណើបានឆ្លើយតបមកនោះទាំងអស់ និងទី២ រៀបរាប់តែខ្លឹមសារបន្តិចបន្តួច (ប្រហែលជា ៣ ទី ៤បន្ទាត់តាមជាក់ស្តែង) រួចដាក់ពាក្យថា "ដូចបានជូនភ្ជាប់មកជាមួយ ឬដូចបានភ្ជាប់មកជាមួយ" រួចដាក់ឯកសារដែលជាការឆ្លើយតបពីអាជ្ញាធរអនុវត្តសំណើនោះភ្ជាប់ទៅជាមួយនឹងលិខិតនេះផ្ញើទៅកាន់អាជ្ញាធរផ្ញើសំណើ ដើម្បីពិនិត្យ និងចាត់ការបន្តតាមនីតិវិធីច្បាប់។ ហើយចំពោះទម្រង់នៃការផ្ញើលិខិតឆ្លើយតបដែលផ្ញើទៅអាជ្ញាធរផ្ញើសំណើនេះ គឺដូចគ្នានឹងទម្រង់ដែលបានរៀបរាប់ក្នុងចំណុច ១.២.២ (អាជ្ញាធរអនុវត្តសំណើ ជាសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី/ខេត្ត) ខាងលើនេះ ដោយគ្រាន់តែប្តូរឈ្មោះស្ថាប័ន និងឈ្មោះថ្នាក់ដឹកនាំ (ប្រធានសាលាដំបូង ឬព្រះរាជអាជ្ញា) របស់ស្ថាប័ននេះតែប៉ុណ្ណោះ។

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមរយៈការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្តីពី ជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌ នាពេលកន្លងមក ក្រុមខ្ញុំបាទទាំងពីរនាក់យល់ឃើញថា ប្រធានបទមួយនេះ ពិតជាមានសារៈសំខាន់ដែលអាចឱ្យយើងស្វែងយល់អំពីប្រវត្តិ តួនាទី និងការងាររបស់អង្គភាពដែលពាក់ព័ន្ធ និងអង្គភាពដែលទទួលបន្ទុកផ្ទាល់ទៅលើសំណុំរឿងជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌ ដែលមានដូចជា ប្រវត្តិនៃការកកើតសមាគមអាស៊ាន ប្រវត្តិរបស់ក្រសួងយុត្តិធម៌ដែលជាអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ប្រវត្តិរបស់អង្គភាពដែលទទួលបន្ទុកទៅលើកិច្ចការអាស៊ាននៃក្រសួងយុត្តិធម៌ ជាមួយគ្នានេះដែរ យើងក៏បានសិក្សាអំពី តួនាទី និងភារកិច្ចរបស់អាជ្ញាធរកណ្តាល និងអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធ ក៏ដូចជាស្វែងយល់អំពីទម្រង់ និងខ្លឹមសារ ក្នុងការធ្វើសំណើជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងរដ្ឋធ្វើសំណើ (ភាគីដាក់សំណើ) និងរដ្ឋទទួលសំណើ (ភាគីទទួលសំណើ) ហើយជាពិសេសទៅទៀតនោះ គឺបានយល់អំពីបែបបទរដ្ឋបាលនៃការអនុវត្តផ្ទាល់ទៅលើការធ្វើសំណើចេញ (Outgoing) និងសំណើចូល (Incoming) នៅក្នុងសំណុំរឿងជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នៅក្នុងដែនដីអាស៊ានមួយនេះផងដែរ។

នៅក្នុងវិស័យព្រហ្មទណ្ឌ ក្រៅអំពីការធ្វើបត្យាប័ន (Extradition) និងការផ្ទេរទណ្ឌិត (Transfer Sentenced Persons) យើងក៏នៅមានកិច្ចសហប្រតិបត្តិការមួយផ្សេងទៀត ដែលគេឱ្យឈ្មោះថាជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ (Mutual on legal Assistance in Criminal Matters-MLA) ដែលការធ្វើជំនួយផ្នែកច្បាប់នេះ បានផ្តោតសំខាន់ទៅលើរឿងក្នុងវិស័យព្រហ្មទណ្ឌមួយចំនួនដូចជា ការផ្តល់ព័ត៌មាន ឬឯកសារអំពីអត្តសញ្ញាណរបស់ជនល្មើស ការប្រមូលភស្តុតាង ការស្តាប់ចម្លើយរបស់សាក្សី ការឆែកឆេរ និងការចាប់យក ការផ្តល់ព័ត៌មាន ឬឯកសារដែលគ្រប់គ្រងដោយស្ថាប័នរដ្ឋ ការស្វែងរកមនុស្ស ការបង្កក ការចាប់យក និងការរឹបអូសទ្រព្យសម្បត្តិជាអាទិ៍។ បើយើងសិក្សាឱ្យស៊ីជម្រៅនៅក្នុងសំណុំរឿង MLA ខុសពីសំណុំរឿងបត្យាប័ន និងផ្ទេរទណ្ឌិត ត្រង់ថា នៅក្នុងសំណុំរឿងបត្យាប័ន និងផ្ទេរទណ្ឌិត គឺជាការផ្ទេរអ្នកទោស ឬជនជាប់ឃុំ ឱ្យទៅអនុវត្តទោសបន្តនៅរដ្ឋដែលស្នើសុំធ្វើបច្ចាប័ន និងផ្ទេរទណ្ឌិតនេះ ចំណែកនៅក្នុងសំណុំរឿង MLA វិញ មានការផ្ទេរជនជាប់ឃុំទៅឱ្យរដ្ឋធ្វើសំណើដូចគ្នា ប៉ុន្តែកម្មវត្ថុនៃការផ្ទេរនេះ គឺមិនមែនឱ្យជនជាប់ឃុំ ទៅអនុវត្តទោសបន្តនោះទេ គឺគ្រាន់តែទៅរដ្ឋធ្វើសំណើដើម្បីជួយផ្តល់សក្ខីភាព និងជួយដល់ការស៊ើបអង្កេតនៅក្នុងរដ្ឋធ្វើសំណើតែប៉ុណ្ណោះ ហើយបន្ទាប់ពីការអនុវត្តការងារបានចប់សព្វគ្រប់ហើយ ត្រូវនាំជនជាប់ឃុំនោះមកកាន់

រដ្ឋទទួលសំណើវិញ (រដ្ឋដែលមានសមត្ថកិច្ចឃុំឃាំងជនជាប់ឃុំនោះ) ដើម្បីឃុំឃាំង ឬអនុវត្តទោសទៅលើជននោះបន្តទៅទៀត។

បន្ថែមពីលើនេះទៅទៀត ការធ្វើ MLA នេះ គឺបានជួយបង្កើន និងពង្រឹងកិច្ចសហការរវាងអាជ្ញាធរកណ្តាលជាមួយនឹងអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធនៅក្នុងការផ្តល់ជំនួយផ្នែកច្បាប់នេះ តាមរយៈអាជ្ញាធរកណ្តាលបញ្ជូនសំណើទៅអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធទាំងនោះ ដើម្បីឱ្យអាជ្ញាធរអនុវត្តសំណើស្វែងរកព័ត៌មាន និងប្រមូលឯកសារពាក់ព័ន្ធផ្សេងៗ ដើម្បីផ្តល់ធាតុចូល ក៏ដូចជាឆ្លើយតបទៅនឹងសំណើរបស់រដ្ឋធ្វើសំណើដែលដែលបានដាក់មកនោះ។ ជាមួយគ្នានេះដែរ ការធ្វើ MLA នេះក៏បានជួយបង្កើន និងពង្រឹងទៅលើវិស័យការទូត តាមរយៈការធ្វើកិច្ចសហប្រតិបត្តិការក្នុងបញ្ជូនសំណើទៅវិញទៅមករវាងស្ថានទូតរបស់ព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងស្ថានទូត ឬស្ថានឯកអគ្គរាជទូត ឬស្ថានឯកអគ្គរដ្ឋទូត ឬស្ថានកុងស៊ុល របស់បណ្តាប្រទេសជាសមាជិកអាស៊ាន ហើយក៏ដើម្បីបង្កើននូវទំនាក់ទំនង ទៅលើការធ្វើសំណើដែលស្នើសុំទៅវិញទៅមកនោះឱ្យអនុវត្តទៅបានប្រកបដោយប្រសិទ្ធភាពខ្ពស់ និងអនុវត្តដោយរលូតជាពិសេសនោះគឺការធ្វើកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងអាជ្ញាធរកណ្តាលនៃបណ្តាប្រទេសជាសមាជិកអាស៊ានទាំងអស់ផងដែរ។ ក្រៅពីពង្រឹងវិស័យការទូត និងកិច្ចសហប្រតិបត្តិការអន្តរជាតិហើយ ការធ្វើ MLA នេះ ក៏បានជួយពង្រឹង និងជួយសម្រួលទៅដល់វិស័យព្រហ្មទណ្ឌនៅក្នុងព្រះរាជាណាចក្រកម្ពុជានិយាយដោយឡែក និងប្រទេសសមាជិកអាស៊ាននិយាយជារួមហើយមួយវិញទៀតនោះ អាជ្ញាធរកណ្តាលនៃប្រទេសជាសមាជិកអាស៊ានទាំងអស់ ចង់ឬមិនចង់អាចមានលទ្ធភាពក្នុងការក្តោបក្តាប់បាននូវរាល់សំណុំរឿងព្រហ្មទណ្ឌ ដែលបានប្រព្រឹត្ត ឬកើតមាននៅក្នុងដែនដីនៃតំបន់អាស៊ីភាគអាគ្នេយ៍ទាំងមូលផងដែរ។

ទោះបីជា ព្រះរាជាណាចក្រកម្ពុជាទើបតែអនុម័តច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៅអំឡុងឆ្នាំ២០២០ នាពេលកន្លងទៅនេះដ៏ដោយ ក៏សំណុំរឿងជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌមិនមែនជារឿងថ្មីស្រឡាងសម្រាប់ស្ថាប័នអាជ្ញាធរកណ្តាល (ក្រសួងយុត្តិធម៌) នោះដែរ ព្រោះថាស្ថាប័នអាជ្ញាធរកណ្តាលនេះ បានបង្កើតឡើងតាំងពីឆ្នាំ២០១១ មកម្លេះ គឺក្រោយពីពេលដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នទៅលើ សន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាននៅឆ្នាំ២០១០។ ដោយឡែងថា សំណុំរឿង MLA នេះគឺជារឿងថ្មីស្រលាងចំពោះ អង្គភាពជំនាញដែលចំណុះក្រសួងយុត្តិធម៌បច្ចុប្បន្ននេះ ដោយហេតុថា អង្គភាពជំនាញទទួលបន្ទុកកិច្ចការ MLA ជាមួយអាស៊ាននេះទើបតែបង្កើតឡើងតាមរយៈ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ នៅឆ្នាំ២០២២

ថ្មីៗនេះតែប៉ុណ្ណោះ។ អាស្រ័យហេតុនេះ ទើបនៅក្នុងឆ្នាំ២០២៣ នេះ អង្គភាពជំនាញដែលទទួលបន្ទុកកិច្ចការអាស៊ាននៅក្នុងក្រសួងយុត្តិធម៌បច្ចុប្បន្ន គឺជាអង្គភាពក្មេងខ្ចីក្នុងការទទួលបន្ទុកលើសំណុំរឿង MLA នេះ។

សរុបជារួមមក ជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌នេះ ពិតជាបានជួយទៅដល់ការសិក្សា និងយល់ដឹងអំពីផ្នែកមួយនៃវិស័យព្រហ្មទណ្ឌរបស់អាស៊ាន ក៏ដូចជាបានសិក្សាអំពីច្បាប់ដែលពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌនានា បែបបទរដ្ឋបាលក្នុងការធ្វើសំណើសុំជំនួយផ្នែកច្បាប់នេះ និងថែមទាំងបានសិក្សាឱ្យស៊ីជម្រៅទៅលើទំនាក់ទំនងកិច្ចសហការផ្ទៃក្នុងនៃព្រះរាជាណាចក្រកម្ពុជា នៅក្នុងការធ្វើសំណើជំនួយផ្នែកច្បាប់នេះ ហើយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិរវាងព្រះរាជាណាចក្រកម្ពុជាជាមួយនឹងបណ្តាប្រទេសដែលស្ថិតនៅក្រោមដំបូលនៃគ្រួសារអាស៊ាន ប្រចាំនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍មួយនេះផងដែរ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីក្រុមខ្ញុំបាទទាំងពីរនាក់ បានធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនេះរួចមក ក្រុមខ្ញុំបាទបានទទួលបាននូវបទពិសោធន៍ និងចំណេះដឹងថ្មីៗជាច្រើនពាក់ព័ន្ធនឹងសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ជាពិសេសការធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងបណ្ដារដ្ឋសមាជិកអាស៊ានទាំងអស់។ ទន្ទឹមនឹងនេះដែរ ការស្រាវជ្រាវរបស់ក្រុមខ្ញុំបាទ ក៏បានជួបប្រទះនឹងឧបសគ្គមួយចំនួន ដូចជាភាពលំបាកក្នុងការស្វែងរកឯកសារនៅក្នុងក្រសួងយុត្តិធម៌ដែលជាស្ថាប័នអាជ្ញាធរកណ្តាលនៅក្នុងរឿង MLA នេះ ហើយនិងប្រឈមនឹងភាពស្មុគស្មាញមួយចំនួនផងដែរ ប៉ុន្តែក្រុមខ្ញុំបាទនៅតែព្យាយាមខិតខំប្រមូលឯកសារពាក់ព័ន្ធទាំងឡាយអស់ពីសមត្ថភាពដែលអាចទៅរួច ដើម្បីចងក្រងជាសារណានេះឡើងដោយខានតែបាន។ មិនតែប៉ុណ្ណោះ ទោះបីជាសន្ធិសញ្ញាស្តីពីជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌអាស៊ានបានអនុម័តនៅឆ្នាំ២០០៤ និងព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ននៅឆ្នាំ២០១០ ហើយតែងតាំងក្រសួងយុត្តិធម៌ឱ្យធ្វើជាអាជ្ញាធរ កណ្តាលនៅក្នុងសំណុំរឿង MLA នេះក៏ដោយ ក៏ព្រះរាជាណាចក្រនៅតែពុំទាន់មានច្បាប់ណាមួយដែលបានចែងឱ្យលម្អិតអំពីសំណុំរឿង MLA នេះទេ។ គេត្រូវរង់ចាំរហូតទៅដល់ឆ្នាំ២០២០ ទើបរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះឡើង ហើយលើសពីនេះទៅទៀត គេត្រូវរង់ចាំរហូតដល់ឆ្នាំ២០២២ ទើបរាជរដ្ឋាភិបាលដាក់ចេញនូវ អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌ថ្មី ដែលផ្តល់សមត្ថកិច្ចឱ្យនាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន ជាអង្គភាពទទួលបន្ទុកផ្ទាល់ទៅលើកិច្ចការងារ MLA ជាមួយអាស៊ាននេះ អាស្រ័យហេតុនេះហើយទើបធ្វើឱ្យការអនុវត្តលើកិច្ចការងារ MLA របស់អង្គភាពទទួលបន្ទុកថ្មីមួយនេះ មានការលំបាកច្រើន។

កត្តាមួយចំនួនដែលអាចជួយបំពេញបន្ថែមទៅដល់ចំណុចខ្វះខាត និងធ្វើឱ្យមានភាពប្រសើរឡើងដល់ជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ក្នុងក្របខណ្ឌអាស៊ាន នៃក្រសួងយុត្តិធម៌ និងដើម្បីឱ្យមន្ត្រីក្រោមឱវាទអនុវត្តការងារប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមានភាពទទួលខុសត្រូវ ក្រុមខ្ញុំបាទសូមសំណូមពរ មួយចំនួនដូចខាងក្រោម ៖

- **ទី១៖** ស្នើសុំទៅដល់ក្រសួងយុត្តិធម៌ សូមជួយអភិវឌ្ឍន៍ និងបង្កើនផ្នែកធនធានមនុស្សសម្រាប់អង្គភាពទទួលបន្ទុកទៅលើកិច្ចការជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដើម្បីឱ្យការអនុវត្តការងារ និងការធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានានៅក្នុងអាស៊ាន ឱ្យមានភាពរលូន និងល្អប្រសើរ ហើយម្យ៉ាងវិញទៀត ដើម្បីឱ្យការអនុវត្តការងារប្រកបទៅដោយគុណភាព និងមានប្រសិទ្ធភាពខ្ពស់។

- **ទី២៖** ស្នើសុំទៅដល់ក្រសួងយុត្តិធម៌ សូមជួយបង្កើន និងពង្រឹងកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរកណ្តាល (ក្រសួងយុត្តិធម៌) និងអាជ្ញាធរអនុវត្តសំណើដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធ្វើឱ្យការអនុវត្តការងារមានប្រសិទ្ធភាពខ្ពស់ និងប្រព្រឹត្តទៅដោយរហូន។
- **ទី៣៖** ដោយបច្ចុប្បន្ននៅក្នុងអាស៊ានមានសន្ធិសញ្ញារួមមួយស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ហើយជាមួយគ្នានេះដែរ ព្រះរាជាណាចក្រកម្ពុជាក៏មានសន្ធិសញ្ញាទ្វេភាគីជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ។ អាស្រ័យហេតុនេះ សូមឱ្យប្រទេសជាសមាជិកអាស៊ានទាំងអស់គោរពតាមសន្ធិសញ្ញារួមរបស់អាស៊ានតែមួយបានហើយ។
- **ទី៤៖** ប្រទេសជាសមាជិកអាស៊ានទាំងអស់ គួរតែបង្កើតទម្រង់ផ្លូវការនៃការស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ ដើម្បីឱ្យប្រទេសជាសមាជិកទាំងអស់ងាយស្រួលក្នុងការអនុវត្តតាម ព្រោះបច្ចុប្បន្នអាស៊ានមិនទាន់មានទម្រង់នៃការស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ជាផ្លូវការនៅឡើយទេ ពោលគឺការធ្វើទម្រង់នៃការស្នើសុំនេះ ធ្វើឡើងតែទៅតាមទម្រង់នៃប្រទេសរៀងៗខ្លួនតែប៉ុណ្ណោះ។
- **ទី៥៖** ចំពោះទម្រង់នៃការស្នើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ គួរតែធ្វើជាភាសាជាតិរបស់ខ្លួនចំនួន១ និងភាសាអង់គ្លេសចំនួន១ បានហើយ មិនចាំបាច់ធ្វើដល់ទៅ ៣ ភាសា ដែលបូកបញ្ចូលនូវ ភាសារបស់ប្រទេសដែលយើងត្រូវស្នើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនោះទេ។ ឧទាហរណ៍៖ ប្រសិនបើព្រះរាជាណាចក្រកម្ពុជាស្នើសុំជំនួយផ្នែកច្បាប់ពីសាធារណរដ្ឋសង្គមនិយមវៀតណាម នោះព្រះរាជាណាចក្រកម្ពុជាធ្វើតែភាសាខ្មែរ ១ និងភាសាអង់គ្លេស ១ បានហើយ មិនចាំបាច់ធ្វើភាសាវៀតណាមនោះទេ។

មុននឹងបញ្ចប់ ក្រុមខ្ញុំបាទសូមកោតសរសើរទៅដល់រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្នក្រោមការដឹកនាំដ៏ឈ្លាសវៃ និងមានភាពប៉ិនប្រសព្វរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរកណ្តាល អាជ្ញាធរអនុវត្តសំណើ ជាពិសេសអង្គភាពក្រោមចំណុះក្រសួងយុត្តិធម៌ដែលទទួលបន្ទុកកិច្ចការអាស៊ាន ដែលបាននឹងកំពុងខិតខំប្រឹងបង្កើនគុណភាពនៃការធ្វើជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ពីមួយថ្ងៃទៅមួយថ្ងៃនិយាយដោយឡែក និងបានខិតខំអភិវឌ្ឍន៍លើគ្រប់វិស័យប្រកបដោយសុខសន្តិភាពនិយាយជារួម។ ក្រុមខ្ញុំបាទសង្ឃឹមថារាជរដ្ឋាភិបាល អាជ្ញាធរកណ្តាល អាជ្ញាធរអនុវត្តសំណើ ជាពិសេសអង្គភាពក្រោមចំណុះក្រសួងយុត្តិធម៌ដែលទទួលបន្ទុកកិច្ចការអាស៊ាន នឹងបន្តធ្វើឱ្យជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ កាន់តែប្រសើរជាងនេះទៅទៀត ដើម្បីលើកតម្កើងវិស័យ យុត្តិធម៌ ក៏ដូចជាវិស័យព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជាឱ្យមានភាពល្អប្រសើរ និងធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាមានការអភិវឌ្ឍលូតលាស់បន្ថែមប្រកបដោយវឌ្ឍនភាព ឧត្តមភាព និងភាពសុដុមជានិរន្តរ៍។

# ឯកសារយោង

# ឯកសារយោង

## ១. រដ្ឋធម្មនុញ្ញ

- ធម្មនុញ្ញអាស៊ាន ឆ្នាំ២០២០ ចេញផ្សាយដោយលេខាធិការដ្ឋានអាស៊ាន ប្រចាំនៅទីក្រុងហ្សាកាតា នៃសាធារណរដ្ឋឥណ្ឌូនេស៊ី
- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៩៣។

## ២. សន្ធិសញ្ញា

- សន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃអាស៊ាន ធ្វើនៅកូឡាឡាំពួរ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៤។

## ៣. ឯកសារច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត

### ៣.១. ច្បាប់ និងក្រឹត្យ

- ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃអាស៊ាន ឆ្នាំ២០០៤ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០។
- ច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌ តាមរយៈព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦។
- ច្បាប់ស្តីពីការយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ តាមរយៈព្រះរាជក្រមលេខ នស/រកម/០១១០/០០១ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១០។
- ច្បាប់ស្តីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ តាមរយៈព្រះរាជក្រមលេខ នស/រកម/០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០។
- ក្រឹត្យស្តីពីការតែងតាំងរដ្ឋាភិបាលបណ្តោះអាសន្ននៃកម្ពុជា ឆ្នាំ១៩៩៣ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៣។

### ៣.២. ព្រះរាជក្រឹត្យ

- ព្រះរាជក្រឹត្យ ស្តីពីតែងតាំងរាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី១ ឆ្នាំ១៩៩៣ ១៩៩៨ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។
- ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី២ ឆ្នាំ១៩៩៨ ២០០៣។

- ព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៨៧ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ ស្តីពីការតែងតាំង និងកែសម្រួលសមាជិករាជរដ្ឋាភិបាល ដោយតែងតាំង ឯកឧត្តម នាវ ស៊ីចុង ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួសឯកឧត្តម អ៊ុក វិធុន។
- ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី៣ ឆ្នាំ២០០៣ ២០០៨។
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី៤ ឆ្នាំ២០០៨ ២០១៣។
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី៥ ឆ្នាំ២០១៣ ២០១៨។
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាណត្តិទី៦ ឆ្នាំ២០១៨ ២០២៣។
- ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាជិករាជរដ្ឋាភិបាល ដោយតែងតាំង ឯកឧត្តម កើត រិទ្ធ ជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជំនួសឯកឧត្តម អង្គ វង្សវឌ្ឍានា ដែលត្រូវតែងតាំងជាទេសរដ្ឋមន្ត្រី (ទទួលបន្ទុកបេសកកម្មពិសេស)។

### ៣.៣. អនុក្រឹត្យ

- អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌។
- អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌។
- អនុក្រឹត្យលេខ ១៣០ អនក្រ.បក ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌។

### ៣.៤. ប្រកាស

- ប្រកាសលេខ ១២៧ កយ.ប្រក/២២ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃការិយាល័យចំណុះនាយកដ្ឋាននានា នៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌។
- ប្រកាសលេខ ១០០ កយ.ប្រក/១៧ ចុះថ្ងៃទី ១២ ខែមេសា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌។

## ៤. សេចក្តីសម្រេច និងសេចក្តីណែនាំ

- សេចក្តីសម្រេចលេខ ០១ កយ.សសរ/១៧ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១១ ស្តីពីការបង្កើតអាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌។
- សេចក្តីណែនាំលេខ ០៣ កយ.សណន/២០ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកំណត់អាទិភាពនៃការអនុវត្តសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។
- សេចក្តីណែនាំ ចុះថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីកំណត់ទម្រង់នៃការអនុវត្តសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

## ៥. សេចក្តីថ្លែងការណ៍ និងរបៀបវារៈ

- សេចក្តីថ្លែងការណ៍អាស៊ាន ធ្វើនៅទីក្រុងបាងកក ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ១៩៦៧
- សេចក្តីថ្លែងការណ៍របស់ប្រមុខដឹកនាំអាស៊ាន ស្តីពីសំណើសុំចូលជាសមាជិកអាស៊ានរបស់ទីម័រឡេស្តេ នាកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ចេញផ្សាយថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២២។
- របៀបវារៈនៃកិច្ចប្រជុំពេញអង្គរបស់បណ្តាញយុត្តិធម៌អាស៊ីអាគ្នេយ៍-SEAJust នៅថ្ងៃទី២៦-២៨ ខែមេសា ឆ្នាំ២០២៣ នៅទីក្រុងសេអ៊ូ នៃសាធារណរដ្ឋកូរ៉េ។
- របៀបវារៈទី៥ នៃកិច្ចប្រជុំ SOM-MLAT លើកទី៩ កាលពីថ្ងៃ២៣ ខែមេសា ឆ្នាំ២០១៩ នៅសណ្ឋាគារ Royal Ambarrukmo ក្នុងទីក្រុងយូយ៉ាកាតា នៃសាធារណរដ្ឋឥណ្ឌូនេស៊ី។

## ៦. សៀវភៅតែងនិពន្ធ

- សៀវភៅឯកសារស្រាវជ្រាវ និពន្ធដោយលោក ពុយគា ស្តីពី រដ្ឋាភិបាលកម្ពុជា ពីឆ្នាំ១៩៤៥ ដល់ឆ្នាំ២០១០។
- សៀវភៅសិក្សាអំពីអាស៊ាន រៀបរៀងដោយ ក្រុមអ្នកសរសេរហាតប៊ុក របស់គ្រឹស្ថានស្រាវជ្រាវ និងបោះពុម្ពផ្សាយហាតប៊ុក ឆ្នាំ២០២២។
- សៀវភៅអង្គការអន្តរជាតិ និពន្ធដោយលោក ពៅ សារឿន ឆ្នាំ២០១០។
- សៀវភៅអាស៊ាន និងសមាហរណកម្ម និពន្ធដោយលោក បណ្ឌិត ឈុន ណារ៉េត ឆ្នាំ២០១០។

# ឧបសម្ព័ន្ធ

# បញ្ជីឈ្មោះឧបសម្ព័ន្ធ

១. ច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ របស់អាស៊ាន ឆ្នាំ២០០៤។

២. ច្បាប់ស្តីពី ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២០។

៣. សេចក្តីណែនាំស្តីពីការកំណត់ទម្រង់នៃការអនុវត្តសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

៤. សំណុំរឿង MLA (សំណើចូល)។

៥. សំណុំរឿង MLA (សំណើចេញ)។

៦. គំរូលិខិតស្នើសុំ MLA របស់ព្រះរាជាណាចក្រកម្ពុជា។

៧. ឯកសារសំណើសុំចុះទៅកម្មសិក្សា និងស្រាវជ្រាវឯកសារ នៅក្រសួងយុត្តិធម៌។

# ឧបសម្ព័ន្ធទី១
# ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន ឆ្នាំ២០០៤

**មាត្រា៤០ .- សិទ្ធិរបស់បុគ្គលដែលផ្តល់សក្ខីកម្មឬជួយដល់ការស៊ើបអង្កេត**

ក្រៅពីលក្ខខណ្ឌដែលព្រមព្រៀងគ្នាជាមួយរដ្ឋទទួលសំណើ បុគ្គលណាមួយទោះបីជាបុគ្គលជាប់ឃុំឬបុគ្គលផ្សេងទៀតដែលមកព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងផ្តល់សក្ខីកម្មឬជួយដល់ការស៊ើបអង្កេតតាមច្បាប់នេះ៖

១- មិនអាចត្រូវបានចោទប្រកាន់ ឃុំខ្លួន ផ្តន្ទាទោស ឬកម្រិតសេរីភាពបុគ្គលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមូលហេតុនៃអំពើល្មើសណាមួយផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានចោទប្រកាន់ឬបានប្រព្រឹត្តមុនពេលចាកចេញពីរដ្ឋទទួលសំណើ។

២- មិនត្រូវបានតម្រូវឱ្យផ្តល់ភស្តុតាងដែលពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រៅពីបទល្មើសព្រហ្មទណ្ឌដែលបានកំណត់នៅក្នុងសំណើឡើយ លើកលែងតែមានការយល់ព្រមពីបុគ្គលនោះ។

៣- មិនត្រូវទទួលរងនូវបណ្តឹងរដ្ឋប្បវេណីឬបណ្តឹងផ្សេងទៀតទាក់ទងទៅនឹងអំពើនិងសកម្មភាពណាមួយដែលបុគ្គលនោះត្រូវបានចោទថាអំពើឬសកម្មភាពប្រព្រឹត្តបានកើតឡើងនៅមុនពេលបុគ្គលនោះចាកចេញពីរដ្ឋទទួលសំណើ។

សិទ្ធិដូចមានចែងក្នុងកថាខណ្ឌទី១ខាងលើនេះត្រូវរលត់ នៅពេលបុគ្គលនោះមានឱកាសចាកចេញពីព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល១៥ថ្ងៃ ក្រោយការជូនដំណឹងពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធថាវត្តមានរបស់បុគ្គលនោះលែងចាំបាច់ទៀតហើយ ប៉ុន្តែបុគ្គលនោះនៅតែបន្តស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាឬត្រឡប់មកវិញដោយខ្លួនឯង ក្រោយពីបានចាកចេញពីព្រះរាជាណាចក្រកម្ពុជារួចហើយ។

**មាត្រា៤១ .- របាយការណ៍ស្តីពីការបញ្ចប់ការផ្តល់សក្ខីកម្មឬការជួយដល់ការស៊ើបអង្កេត**

អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវធ្វើរបាយការណ៍ជូនទៅអាជ្ញាធរកណ្តាល នៅពេលដែលបុគ្គលជាប់ឃុំឬបុគ្គលផ្សេងទៀតបានបញ្ចប់ការផ្តល់សក្ខីកម្មឬការជួយដល់ការស៊ើបអង្កេត។

**មាត្រា៤២ .- ការផ្ទេរត្រឡប់ទៅវិញនូវបុគ្គលជាប់ឃុំ**

នៅពេលទទួលបានរបាយការណ៍ពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា៤១ (របាយការណ៍ស្តីពីការបញ្ចប់ការផ្តល់សក្ខីកម្មឬការជួយដល់ការស៊ើបអង្កេត)នៃច្បាប់នេះ អាជ្ញាធរកណ្តាលត្រូវធ្វើការសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដើម្បីបញ្ជូនបុគ្គលជាប់ឃុំត្រឡប់ទៅរដ្ឋទទួលសំណើវិញជាបន្ទាន់។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី៥
## ការចំណាយ

**មាត្រា៤៣ .-- ការចំណាយ**

រាល់ការចំណាយទាំងអស់របស់អាជ្ញាធរកណ្ដាលទាក់ទងនឹងការសម្របសម្រួលការជួយផ្នែកច្បាប់ដល់រដ្ឋផ្ញើសំណើនិងការស្នើសុំការជួយផ្នែកច្បាប់ពីរដ្ឋទទួលសំណើជាបន្ទុករបស់ក្រសួងយុត្តិធម៌។ ការចំណាយក្នុងការអនុវត្តសំណើ ត្រូវជាបន្ទុករបស់អាជ្ញាធរអនុវត្តសំណើ ហើយចំណាយពាក់ព័ន្ធនឹងការស្នើសុំជំនួយជាបន្ទុករបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។ ក្នុងករណីដែលការចំណាយលើការផ្ដល់ការជួយផ្នែកច្បាប់នេះជាបន្ទុកធ្ងន់ធ្ងរចំពោះព្រះរាជាណាចក្រកម្ពុជា ព្រះរាជាណាចក្រកម្ពុជាអាចស្នើសុំឱ្យរដ្ឋផ្ញើសំណើផ្ដល់ភាគទានលើការចំណាយនោះ។

## ជំពូកទី៦
## អវសានបញ្ញត្តិ

**មាត្រា៤៤ .-- ការប្រកាសឱ្យប្រើ**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ *សៅរ៍ ៧កើត* ខែ *អាសាឍ* ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២០

*ពារ.២០០៦.៦៩៧*

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កើត រិទ្ធ**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិសង្គហបណ្ឌិត ប៊ិន ឈិន**

# ឧបសម្ព័ន្ធទី៣
# សេចក្ដីណែនាំស្ដីពីការកំណត់ទម្រង់នៃការអនុវត្តសំណើសុំ ជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ : ០៣ កសយ. សកគន/២០

# សេចក្ដីណែនាំ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
## ជម្រាបមក
## ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាមន្ត្រីទទួលបន្ទុកការងារ ពាក់ព័ន្ធនឹងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌

**កម្មវត្ថុ៖** សេចក្ដីណែនាំស្ដីពីការកំណត់អាទិភាពនៃការអនុវត្តសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។

ក្រសួងយុត្តិធម៌បានកត់សម្គាល់ឃើញថា ក្នុងនាមជាអាជ្ញាធរកណ្ដាល ក្រសួងយុត្តិធម៌បានទទួលសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាច្រើនពីបណ្ដាប្រទេសនានា អនុលោមតាមច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។ ដើម្បីធានាការអនុវត្តសំណើទាំងនោះប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលា ការកំណត់អាទិភាពនៃការអនុវត្តសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌមានភាពចាំបាច់ និងមានសារៈសំខាន់។ ហេតុនេះ ក្រសួងយុត្តិធម៌សូមធ្វើការណែនាំដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាមន្ត្រីទទួលបន្ទុកការងារពាក់ព័ន្ធនឹងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌ ឱ្យធ្វើការកំណត់អាទិភាពនៃការអនុវត្តសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដោយពិចារណាលើចំណុចសំខាន់ៗដូចខាងក្រោម៖

**ក-ទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជានិងរដ្ឋផ្ញើសំណើ៖** គប្បីពិចារណាផ្ដល់អាទិភាពលើសំណើពីរដ្ឋដែលមានកិច្ចព្រមព្រៀងទ្វេភាគីពាក់ព័ន្ធនឹងការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាមួយព្រះរាជាណាចក្រកម្ពុជា រដ្ឋដែលធ្លាប់អនុវត្តសំណើរបស់ព្រះរាជាណាចក្រកម្ពុជាតាមគោលការណ៍បដិការ រដ្ឋដែលមានទំនាក់ទំនងកិច្ចសហប្រតិបត្តិការច្រើនជាមួយព្រះរាជាណាចក្រកម្ពុជា រដ្ឋដែលជាភាគីហត្ថលេខីនៃកិច្ចព្រមព្រៀងពាក់ព័ន្ធការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរួមគ្នាជាមួយព្រះរាជាណាចក្រកម្ពុជា ដូចជាសន្ធិសញ្ញាស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់អាស៊ាន រដ្ឋដែលមានព្រំប្រទល់ជាប់ព្រះរាជាណាចក្រកម្ពុជា រដ្ឋក្នុងតំបន់រួមគ្នាជាមួយព្រះរាជាណាចក្រកម្ពុជាជាអាទិ៍។

**ខ-ប្រភេទនៃបទល្មើស៖** គប្បីពិចារណាផ្ដល់អាទិភាពលើសំណើពាក់ព័ន្ធនឹងបទល្មើសដែលមានលក្ខណៈធ្ងន់ធ្ងរដែលធ្វើឱ្យប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ដូចជាបទល្មើសពាក់ព័ន្ធនឹងការរំលោភបំពានលើស្ត្រីឬកុមារ បទល្មើសជួញដូរមនុស្ស បទល្មើសឆ្លងដែន បទល្មើសសម្អាតប្រាក់ បទល្មើសគ្រឿងញៀនជាអាទិ៍។ ១០៤

**គ-កម្រិតនៃភាពស្មុគស្មាញនៃសំណើ៖** គប្បីពិចារណាផ្តល់អាទិភាពលើសំណើដែលមានភាពសាមញ្ញ មិនស្មុគស្មាញពេក ហើយមិនទាមទារការចំណាយពេលវេលាច្រើនក្នុងការសិក្សាលើសំណើនោះ។

**ឃ-កាលបរិច្ឆេទកំណត់នៃការអនុវត្តសំណើ៖** គប្បីពិចារណាផ្តល់អាទិភាពលើសំណើដែលកំណត់កាលបរិច្ឆេទអនុវត្តដែលមានភាពចាំបាច់ និងសមស្រប។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាមន្ត្រីទទួលបន្ទុកការងារពាក់ព័ន្ធនឹងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ត្រូវអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។ ០៥

ថ្ងៃ សុក្រ ៦កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**កើត រិទ្ធ**

ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

**ឯកឧត្តម ប៉ែន ពេជ្រសាលី**
**ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ**
**ជម្រាបមក**
**ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាមន្ត្រីទទួលបន្ទុកការងារ**
**ពាក់ព័ន្ធនឹងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌**

**កម្មវត្ថុ** ៖សេចក្តីណែនាំស្តីពីការកំណត់ទម្រង់នៃការអនុវត្តសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។
**យោង** ៖-ច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២០
-សេចក្តីណែនាំលេខ ០៣ កយ. សណន/២០ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការកំណត់អាទិភាពនៃការកំណត់សំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់ក្រសួងយុត្តិធម៌។

**អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌** បានកត់សម្គាល់ឃើញថា ក្នុងនាមជាសេនាធិការនៃអាជ្ញាធរកណ្តាល នៃក្រសួងយុត្តិធម៌ បានទទួលសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌជាច្រើន ដែលរួមមានសំណើដែលស្នើសុំដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា (សំណើចូល) និងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនោះទៅកាន់រដ្ឋទទួលសំណើ (សំណើចេញ) អនុលោមតាមច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ។ ដើម្បីជានាការអនុវត្តសំណើទាំងនោះប្រកបដោយប្រសិទ្ធិភាព និងទាន់ពេលវេលា ការកំណត់លើគោលការណ៍រួមនៃការពិនិត្យលើទម្រង់សំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌមានភាពចាំបាច់ និងមានសារៈសំខាន់។ ហេតុនេះ **អគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ នៃក្រសួងយុត្តិធម៌** សូមធ្វើការណែនាំដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលជាមន្ត្រីទទួលបន្ទុកការងារពាក់ព័ន្ធនឹងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ឱ្យធ្វើការពិនិត្យលើទម្រង់ និងខ្លឹមសារនៃសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដោយអនុវត្តនូវចំណុចសំខាន់ៗដូចខាងក្រោម៖

**១.ទម្រង់នៃសំណើ៖** សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរជាភាសាខ្មែរ និងភាសាអង់គ្លេស។

**២. ឈ្មោះស្ថាប័ន អង្គភាពដែលមានសមត្ថកិច្ចក្នុងសំណើ៖** នៅក្នុងសំណើនេះត្រូវបញ្ជាក់អំពីលេខនៃសំណុំរឿង និងឈ្មោះអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធដែលស្នើសុំជំនួយផ្នែកច្បាប់។

**៣. ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធនឹងសំណើ៖** នៅក្នុងសំណើនេះ ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធមានដូចជា នាមត្រកូល នាមខ្លួន ភេទ សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត លិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណ និងអាសយដ្ឋានបច្ចុប្បន្នរបស់បុគ្គលស្នើសុំ។

**៤. អង្គហេតុ៖** ការពណ៌នាអំពីសញ្ញាណនៃរឿងក្ដីព្រហ្មទណ្ឌ រួមបញ្ចូលទាំងសេចក្ដីសង្ខេបអង្គហេតុ ឈ្មោះនៃបទល្មើស និងទោសដែលត្រូវអនុវត្ត ដែលជាអំពើបង្កើតបានជាបទល្មើសព្រហ្មទណ្ឌហើយត្រូវបានផ្ដន្ទាទោសដោយច្បាប់ព្រហ្មទណ្ឌនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋទទួលសំណើ។

**៥. ព័ត៌មានអំពីកិច្ចនីតិវិធីរបស់តុលាការ ឬមន្ត្រីនគរបាលយុត្តិធម៌៖** ចំណាត់ការនៃនីតិវិធីពាក់ព័ន្ធនឹងបុគ្គលស្នើសុំ។

**៦. បទប្បញ្ញត្តិនៃច្បាប់៖** អត្ថបទច្បាប់ដែលចែងអំពីបទល្មើស ព្រមទាំងសេចក្ដីបង្គាប់របស់តុលាការ

**៧. កម្មវត្ថុនៃការស្នើសុំ៖** ការពិពណ៌នាអំពីគោលបំណងនៃការស្នើសុំជំនួយ និងប្រភេទនៃជំនួយដែលត្រូវស្វែងរកស្របតាមបទប្បញ្ញត្តិនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋទទួលសំណើ។

**៨. ការបញ្ជាក់ពីមូលហេតុ និងតម្រូវការជាក់លាក់ក្នុងសំណើ៖** ជាការរៀបរាប់របស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធរបស់ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋធ្វើសំណើអំពីសារៈសំខាន់នៃការអនុវត្តសំណើសុំការជួយផ្នែកច្បាប់ និងការប្រើប្រាស់សំណើបំរើដល់ដំណើការនីតិវិធីនានាពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌ។

**៩. ការកំណត់កាលបរិច្ឆេទនៃការផ្ដល់ព័ត៌មាន៖** យោងតាម **សេចក្ដីណែនាំលេខ ០៣ កយ. សណន/២០ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្ដីពីការកំណត់អាទិភាពនៃការកំណត់សំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ** ក្នុងករណីចំបាច់ សំណើសុំការជួយផ្នែកច្បាប់ អាចបញ្ជាក់ពេលវេលាជាក់លាក់របស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ឬរដ្ឋបរទេស ក្នុងការផ្ដល់ព័ត៌មានពាក់ព័ន្ធនឹងនឹងការអនុវត្តសំណើ។

**១០. ការរក្សាការសម្ងាត់៖ ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលជាមន្ត្រីទទួលបន្ទុកការងារពាក់ព័ន្ធនឹងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ព្រមទាំងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា (សំណើចូល) និងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនោះទៅកាន់រដ្ឋទទួលសំណើ (សំណើចេញ) ត្រូវចាត់រាល់វិធានការសមស្របដើម្បីរក្សាការសម្ងាត់នៃសំណើសុំជំនួយ ខ្លឹមសារ និងឯកសារយោងនៃសំណើ ការសម្រេចផ្ដល់ជំនួយ និងចំណាត់ការណាមួយនៃការអនុវត្តសំណើ ប្រសិនបើមានការស្នើសុំដូច្នេះពីរដ្ឋធ្វើសំណើ។ ប្រសិនបើសំណើមិនអាចអនុវត្តបានដោយមិនបំពានលើតម្រូវការរក្សាការសម្ងាត់នោះ មន្ត្រីនៃអាជ្ញាធរកណ្ដាលត្រូវជូនដំណឹងអំពីបញ្ហានេះឱ្យអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ និងរដ្ឋធ្វើសំណើដើម្បីកំណត់ថាតើសំណើត្រូវអនុវត្តដែរឬទេ។

សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលជាមន្ត្រីទទួលបន្ទុកការងារពាក់ព័ន្ធនឹងសំណើសុំការជួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ ត្រូវអនុវត្តសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃសុក្រ ១២កើត ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០

**ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក**

**ប៉ែន ពេជ្រសាលី**

# ឧបសម្ព័ន្ធទី៤

# សំណុំរឿង MLA ( សំណើចូល )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខុទ្ទកាល័យ
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ចូល អានល់ថ្ងៃទី......ខែ......ឆ្នាំ......
ម៉ោង......

អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ
និងអភិវឌ្ឍន៍វិស័យយុត្តិធម៌
ចូល ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០២៣
លេខ: ...១៩....... ម៉ោង ៩:០០

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

លេខ

ក្រសួងយុត្តិធម៌
មកដល់ថ្ងៃទី ១១-០១-២០២៣
លេខ.......... ម៉ោង..........

សូមគោរពជូន
ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

កម្មវត្ថុ ៖ សំណើសុំជំនួយផ្នែកច្បាប់ពាក់ព័ន្ធនឹងពលរដ្ឋខ្មែរ ឈ្មោះ ។
យោង ៖ លិខិតលេខ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២២ របស់តុលាការកំពូលវៀតណាម។

ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា អយ្យការអមតុលាការកំពូលវៀតណាម ស្នើសុំបញ្ជូនលិខិតរបស់ខ្លួនជូនទៅក្រសួងយុត្តិធម៌កម្ពុជា ដើម្បីស្នើសុំជំនួយផ្នែកច្បាប់ពាក់ព័ន្ធនឹងករណី ពលរដ្ឋខ្មែរឈ្មោះ ភេទប្រុស កើតថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៨៦ ដែលត្រូវបានអាជ្ញាធរវៀតណាមចោទប្រកាន់ពីបទដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់នៅព្រំដែនកម្ពុជា-វៀតណាម។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច និងទទួលនូវការគោរពពីខ្ញុំ ៕

ថ្ងៃ..... ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី..... ខែមករា ឆ្នាំ២០២៣

នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន
ចូល លេខ ......
ថ្ងៃទី ...... ខែ ...... ឆ្នាំ២០២៣
ម៉ោង ......

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ឧបសម្ព័ន្ធទី៤ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសវៀតណាមមកស្ថាប័នរដ្ឋនៃប្រទេសកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**
**អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ**
**និងអភិវឌ្ឍន៍វិស័យយុត្តិធម៌**
**នាយកដ្ឋានកិច្ចការច្បាប់**
**និងកិច្ចសហប្រតិបត្តិការអាស៊ាន**
លេខ៖.....

**កំណត់បង្ហាញ**
**សូមគោរពជូន**
**ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**តាមរយៈ** ៖ - ឯកឧត្តម រដ្ឋលេខាធិការក្រសួងយុត្តិធម៌
- ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌។

**កម្មវត្ថុ** ៖ អំពីសំណើសុំជំនួយផ្នែកច្បាប់ពាក់ព័ន្ធនឹងពលរដ្ឋខ្មែរឈ្មោះ ។

**យោង** ៖ លិខិតលេខ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធនឹងសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ពាក់ព័ន្ធនឹងឈ្មោះ ដែលត្រូវបានប៉ុស្តិ៍យោធាការពារព្រំដែនច្រកទ្វារអន្តរជាតិទិញបៀន ឃាត់ខ្លួននិងបញ្ជូនជនល្មើស ព្រមទាំងឯកសារភស្តុតាងទៅកាន់ស្ថាប័ននគរបាលស៊ើបអង្កេតនៃស្នងការដ្ឋាននគរបាលខេត្តអានយ៉ាងដើម្បីស៊ើបអង្កេតតាមសមត្ថកិច្ច។ អាស្រ័យហេតុនេះ ស្នងការដ្ឋាននគរបាលខេត្តអានយ៉ាងនៃសាធារណរដ្ឋសង្គមនិយមវៀតណាមបានស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌមកក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយបញ្ជាក់បភ្លឺអំពីសញ្ជាតិ អត្តសញ្ញាណ ប្រវត្តិរូប ទោសល្មើសពីមុន និងស្ថានភាពគ្រួសាររបស់ឈ្មោះ ។

ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ពាក់ព័ន្ធនឹងសំណើសុំខាងលើ គឺពឹងផ្អែកលើសន្ធិសញ្ញាស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ហេតុនេះនាយកដ្ឋានយល់ឃើញថា ការស្នើសុំពាក់ព័ន្ធនឹងការបញ្ជាក់សអត្តសញ្ញាណ ប្រវត្តិរូប និងស្ថានភាពគ្រួសាររបស់ឈ្មោះ ក្រសួងគម្បីធ្វើលិខិតទៅក្រសួងមហាផ្ទៃ ហើយពាក់ព័ន្ធនឹងការបញ្ជាក់ប្រវត្តិនៃការផ្តន្ទាទោសពីមុនរបស់ឈ្មោះ នាយកដ្ឋានបានបញ្ជូនលិខិតទៅអគ្គនាយកដ្ឋានកិច្ចការទោស ដើម្បីពិនិត្យលើនីតិវិធីនៃការស្នើសុំនេះ។

ក្នុងករណី **ឯកឧត្តមរដ្ឋមន្ត្រី** ផ្តល់ការឯកភាព ខ្ញុំបាទសូមគោរពស្នើសុំហត្ថលេខាដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមរដ្ឋមន្ត្រី** លើលិខិតដែលបានគោរពភ្ជាប់ជូនមកជាមួយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច ព្រមទាំងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃ អង្គារ ១៥កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៧ ខែ មីនា ឆ្នាំ២០២៣

**ប្រធាននាយកដ្ឋាន**

## មតិយោបល់ និងការសម្រេចរបស់ថ្នាក់ដឹកនាំ

**កម្មវត្ថុ** ៖ អំពីសំណើសុំជំនួយផ្នែកច្បាប់ពាក់ព័ន្ធនឹងពលរដ្ឋខ្មែរឈ្មោះ ។

**បានពិនិត្យ៖** លិខិតលេខ ចុះថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ របស់នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន។

| អនុរដ្ឋលេខាធិការ | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក |
|---|---|
| បានពិនិត្យ និងឯកភាពតាមសំណើ ។ ស្នើលោក [illegible] មេត្តាពិនិត្យ និងសម្រេចផ្ទាល់ [illegible] ៥/[illegible]/២៣ | បានពិនិត្យ និងឯកភាព ។ ស្នើលោក [illegible] មេត្តាពិនិត្យ និងសម្រេច ។ |

**រដ្ឋលេខាធិការ**

បានពិនិត្យ និងឯកភាព ។
ស្នើសូម [illegible] មេត្តាពិនិត្យ និងសម្រេច ។

([illegible] 07/04/23)

**ការសម្រេចរបស់ ឯកឧត្តមរដ្ឋមន្ត្រី** ៖ ឯកភាព ។

12/04/2023

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

ថ្ងៃព្រហស្បតិ៍ ៨រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣

លេខ :

**សូមគោរពជូន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ** ៖ សំណើសុំជំនួយផ្នែកច្បាប់ពាក់ព័ន្ធនឹងពលរដ្ឋខ្មែរឈ្មោះ ។

**យោង** ៖ លិខិតលេខ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលមានខ្លឹមសារស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីសាធារណរដ្ឋសង្គមនិយមវៀតណាម ដើម្បីជួយបញ្ជាក់បំភ្លឺអំពីសញ្ជាតិ អត្តសញ្ញាណ ប្រវត្តិរូប និងស្ថានភាពគ្រួសារ របស់ឈ្មោះ

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងចាត់នីតិវិធីបន្តដោយក្ដីអនុគ្រោះបំផុត។

សូម **សម្ដេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

ឧបសម្ព័ន្ធទី៤ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសវៀតណាមមកស្ថាប័នតុលាការនៃប្រទេសកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខុទ្ទកាល័យ
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ចូល មកដល់ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០២៣
ម៉ោង ១១:៣០ នាទី

អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌
ចូល ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០២៣
លេខ: ១៣៦ ម៉ោង ១០:០០

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
លេខ

ក្រសួងយុត្តិធម៌
មកដល់ថ្ងៃទី ០៥-០៤-២០២៣
លេខ ១៧៦៦ ម៉ោង ០៩:២៥

**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**កម្មវត្ថុ** ៖ សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌពាក់ព័ន្ធនឹងពលរដ្ឋខ្មែរឈ្មោះ

**យោង** ៖ ដីកាបញ្ជូនលេខ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ របស់ស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋសង្គមនិយមវៀតណាម។

ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា មហាអយ្យការអមតុលាការកំពូលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្នើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌពាក់ព័ន្ធនឹងពលរដ្ឋខ្មែរឈ្មោះ ៖ ភេទប្រុស កើតឆ្នាំ១៩៨៧ ដែលត្រូវបានអាជ្ញាធរវៀតណាមចោទប្រកាន់ពីបទដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ ។

សូមគោរពជូននូវឯកសារពាក់ព័ន្ធ ដូចមានគោរពជូនភ្ជាប់។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច និងទទួលនូវការគោរពពីខ្ញុំ។

ថ្ងៃ ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣

នាយកដ្ឋាន...ច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន
ចូល លេខ ១៥៤
ថ្ងៃទី ០១ ខែ ០៤ ឆ្នាំ២០២៣
ម៉ោង ១០:០០

**ជ. រដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**
**អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ**
**និងអភិវឌ្ឍន៍វិស័យយុត្តិធម៌**
**នាយកដ្ឋានកិច្ចការច្បាប់**
**និងកិច្ចសហប្រតិបត្តិការអាស៊ាន**
លេខ៖...

**<u>កំណត់បង្ហាញ</u>**

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**តាមរយៈ** ៖- ឯកឧត្តម រដ្ឋលេខាធិការក្រសួងយុត្តិធម៌
- ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌។

**កម្មវត្ថុ** ៖ អំពីសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌពាក់ព័ន្ធនឹងពលរដ្ឋខ្មែរឈ្មោះ ។

**យោង** ៖ លិខិតលេខ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធនឹងសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ពាក់ព័ន្ធនឹងឈ្មោះ ភេទប្រុស ជនជាតិខ្មែរ កើតឆ្នាំ១៩៨៧ ដែលត្រូវបានអាជ្ញាធរនៃសាធារណរដ្ឋសង្គមនិយមវៀតណាមចោទប្រកាន់ពីបទ "**ដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់**" ប្រព្រឹត្តទៅនៅទីរួមខេត្តប៊ិញឡុង ខេត្តប៊ិញភឿក កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២។ អាស្រ័យហេតុនេះ អាជ្ញាធរកណ្ដាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមបានស្នើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌមកអាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយផ្ទៀងផ្ទាត់ចម្លើយដូចបានគោរពជូនភ្ជាប់មកជាមួយ។

ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ពាក់ព័ន្ធនឹងសំណើសុំខាងលើ នាយកដ្ឋានយល់ឃើញថា ការស្នើសុំពាក់ព័ន្ធការផ្ទៀងផ្ទាត់ចម្លើយដូចបានគោរពជម្រាបជូនខាងលើនេះ ក្រសួងគប្បីបញ្ជូនលិខិតទៅអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ដើម្បីពិនិត្យលើនីតិវិធីនៃការស្នើសុំនេះ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច ព្រមទាំងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។ ក្នុងករណី **ឯកឧត្តមរដ្ឋមន្ត្រី** ផ្តល់ការឯកភាព ខ្ញុំបាទសូមគោរពស្នើសុំហត្ថលេខាដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមរដ្ឋមន្ត្រី** លើលិខិតដែលបានគោរពភ្ជាប់ជូនមកជាមួយ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ១៣ កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២៣

**ប្រធាននាយកដ្ឋាន**

## មតិយោបល់ និងការសម្រេចរបស់ថ្នាក់ដឹកនាំ

**កម្មវត្ថុ** ៖ អំពីអំពីសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌពាក់ព័ន្ធនឹងពលរដ្ឋខ្មែរ ឈ្មោះ

**បានពិនិត្យ៖** លិខិតលេខ ចុះថ្ងៃទី០៦ ខែ[illegible]ឆ្នាំ២០២៣ របស់នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន។

| អនុរដ្ឋលេខាធិការ | ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក |
|---|---|
| [illegible] | [illegible] |

**រដ្ឋលេខាធិការ**

[illegible]

**ការសម្រេចរបស់ ឯកឧត្តមរដ្ឋមន្ត្រី** ៖ ឯកភាព.

ឧបសម្ព័ន្ធទី៤ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសវៀតណាមមកស្ថាប័នតុលាការនៃប្រទេសកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

ថ្ងៃអង្គារ ៤កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែឧសភា ឆ្នាំ២០២៣

លេខ :

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ជម្រាបមក**

**ឯកឧត្តម ព្រះរាជអាជ្ញា នៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ**

**កម្មវត្ថុ** ៖ អំពីសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌពាក់ព័ន្ធនឹងពលរដ្ឋខ្មែរឈ្មោះ ។

**យោង** ៖ លិខិតលេខ ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០២៣ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូម **ឯកឧត្តមព្រះរាជអាជ្ញា** ជ្រាបថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ពាក់ព័ន្ធនឹងសំណើសុំជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ពាក់ព័ន្ធនឹងឈ្មោះ ភេទប្រុស ជនជាតិខ្មែរ កើតឆ្នាំ១៩៨៧ ដែលត្រូវបានអាជ្ញាធរនៃសាធារណរដ្ឋសង្គមនិយមវៀតណាមចោទប្រកាន់ពីបទ "**ដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់**" ប្រព្រឹត្តទៅនៅទីរួមខេត្តប៊ិញឡុង ខេត្តប៊ិញភឿក កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២២។ ហេតុនេះ អាជ្ញាធរកណ្តាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយស្រាយបំភ្លឺនូវសំណួរដូចបានភ្ជាប់មកជាមួយ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមព្រះរាជអាជ្ញា** ពិនិត្យ និងចាត់នីតិវិធីបន្ត។

សូម **ឯកឧត្តម ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ** ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

## កម្រងសំណួរនៃសំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ

(១) កត់សរសេរចម្លើយរបស់មនុស្សដែលមានសិទ្ធិ និងកាតព្វកិច្ចពាក់ព័ន្ធ បន្ទាប់ពីការកាត់ទោសសំណុំរឿងរបស់ឈ្មោះ និងឈ្មោះ (ឥឡូវនេះបានជូនត្រឡប់ទៅកម្ពុជាវិញ) ជាក់ស្តែង៖

- តើស្ថានភាពសុខភាព និងស្ថានភាពផ្លូវចិត្ត របស់បុគ្គលទាំងពីរខាងលើនេះយ៉ាងណានៅពេលជួបជាមួយកម្លាំងនគរបាលថ្ងៃនេះ?
- តើបុគ្គលទាំងពីរខាងលើនេះមានទំនាក់ទំនងជាមួយនឹង យ៉ាងដូចម្តេច?
- តើបុគ្គលទាំងពីរខាងលើនេះនៅថ្ងៃទី០៥/៧/២០២៣ ទៅណា? ធ្វើអ្វី? ជាមួយអ្នកណា?
- តើបុគ្គលទាំងពីរខាងលើនេះ កាលទៅប្រទេសវៀតណាមមានគោលបំណងអ្វី? ហើយអ្នកណាជាអ្នកបង់លុយពេលឆ្លងកាត់ទៅប្រទេសវៀតណាម?
- តើបុគ្គលទាំងពីរខាងលើនេះដឹងថាឈ្មោះ ប្រព្រឹត្តបទល្មើសឬទេ? បើដឹង តើនៅពេលណា? កើតឡើងយ៉ាងណា? តើបុគ្គលទាំងពីរខាងលើនេះពាក់ព័ន្ធយ៉ាងដូចម្តេច? មានអ្នកណាក្រៅពីបុគ្គលទាំងពីរខាងលើនេះដឹងឬទេ?
- តើបុគ្គលទាំងពីរខាងលើនេះមានប្រវត្តិបទឧក្រិដ្ឋទេ?
- តើបុគ្គលទាំងពីរខាងលើនេះមានអ្វីចង់និយាយបន្ថែមទេ? តើអ្វីជាការធានាអំពីចម្លើយខាងលើ?

(២) ស្វែងរកព័ត៌មានអំពីម្ចាស់អតិថិជនលេខ ប្រមូលយកឯកសារដែលផ្តល់ដោយម្ចាស់បណ្តាញទូរស័ព្ទចល័ត ផ្ទៀងផ្ទាត់ព័ត៌មានម្ចាស់អតិថិជន។ នៅពេលព័ត៌មានអាចរកបាន សូមផ្ទៀងផ្ទាត់ម្ចាស់អតិថិជន និងធ្វើកំណត់ហេតុក្នុងពេលដំណើរការផ្ទៀងផ្ទាត់។ ប្រសិនបើអាចធ្វើការជាមួយអតិថិជនខាងលើ ត្រូវធ្វើខ្លឹមសារជាក់លាក់៖

- តើស្ថានភាពសុខភាព និងស្ថានភាពផ្លូវចិត្ត របស់ម្ចាស់លេខទូរស័ព្ទខាងលើនេះយ៉ាងណាក្នុងពេលជួបជាមួយកម្លាំងនគរបាលថ្ងៃនេះ?
- តើម្ចាស់លេខទូរស័ព្ទខាងលើនេះរស់នៅទីណា ហើយប្រកបមុខរបរអ្វី?
- តើម្ចាស់លេខទូរស័ព្ទខាងលើនេះមានទំនាក់ទំនងជាមួយឈ្មោះ យ៉ាងដូចម្តេច? បើស្គាល់ តើស្គាល់នៅពេលណា? បានជួបឈ្មោះ ហើយឬនៅ? បើសិនជាជួបគាត់ជួបនៅកន្លែងណា? ហើយជួបធ្វើអ្វី?
- បើតាមចម្លើយរបស់ឈ្មោះ ចន្លោះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២២ ដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ បានឱ្យម្ចាស់លេខទូរស័ព្ទខាងលើនេះ ដឹកជញ្ជូនគ្រឿងញៀន ៣ដង ពីប្រទេសកម្ពុជា ទៅកាន់ទីក្រុងហូជីមិញ ប្រទេសវៀតណាម ដូច្នេះថា តើម្ចាស់លេខទូរស័ព្ទខាងលើនេះ មានយោបល់យ៉ាងណាដែរ?
- តើម្ចាស់លេខទូរស័ព្ទខាងលើនេះដឹងទេថា មានអ្វីខ្លះនៅក្នុងធុងជ័ររបស់ឈ្មោះ ដែលចាត់ឱ្យម្ចាស់លេខទូរស័ព្ទខាងលើនេះដឹកជញ្ជូន? តើឈ្មោះ មានប្រាប់អ្នកថាមានអ្វីនៅក្នុងធុងជ័រទេ?

- តើម្ចាស់លេខទូរស័ព្ទខាងលើនេះ ប្រើលេខទូរស័ព្ទប៉ុន្មានប្រព័ន្ធ? តើអ្នកហៅទូរស័ព្ទទៅឈ្មោះ លេខទូរស័ព្ទមួយណា?
- តើម្ចាស់លេខទូរស័ព្ទខាងលើនេះ ផ្ទេរប្រាក់ទៅឈ្មោះ ដោយរបៀបណា?
- តើម្ចាស់លេខទូរស័ព្ទខាងលើនេះមានអ្វីចង់និយាយបន្ថែមទេ? តើអ្វីជាការធានាអំពីចម្លើយខាងលើ?

(៣) តាមរយៈរូបភាពដែលផ្ដល់ដោយភាគីអ្នកស៊ើបអង្កេតបានធ្វើការជាមួយជនជាប់ចោទឈ្មោះ និងឈ្មោះ និងផ្ដល់អត្តសញ្ញាណរូបថតចុងចោទទាំងពីរបានកំណត់បានអត្តសញ្ញាណឈ្មោះ និងឈ្មោះ ។ ស្នើសុំស្នងការនគរបាលខេត្តត្បូងឃ្មុំ ជាអង្គភាពដែលមានសមត្ថកិច្ចដើម្បីដឹកនាំការកត់ត្រាសរសេរចម្លើយឈ្មោះ និងឈ្មោះ ជាក់ស្ដែង៖

- តើ ស្ថានភាពសុខភាព និងស្ថានភាពផ្លូវចិត្ត របស់ឈ្មោះ និងឈ្មោះ យ៉ាងណានៅពេលជួបជាមួយកម្លាំងនគរបាលថ្ងៃនេះ?
- តើឈ្មោះ និងឈ្មោះ មានទំនាក់ទំនងអ្វីជាមួយឈ្មោះ , ឈ្មោះ និង យ៉ាងដូចម្ដេច?
- បើតាមចម្លើយរបស់ឈ្មោះ ចន្លោះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០២២ ដល់ថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ បានប្រគល់ជូនធុងជ័រឱ្យឈ្មោះ និងឈ្មោះ ចំនួន ០៣ ដើម្បីដឹកជញ្ជូនពីប្រទេសកម្ពុជា ទៅកាន់ប្រទេសវៀតណាម ប្រគល់ជូនឈ្មោះ និង ដូច្នេះ តើឈ្មោះ និងឈ្មោះ **មាន**យោបល់យ៉ាងណាដែរ?
- តើឈ្មោះ និងឈ្មោះ ដឹងទេថាមានអ្វីខ្លះនៅក្នុងធុងជ័ររបស់ឈ្មោះ ដែលចាត់ឱ្យអ្នកដឹកជញ្ជូន? តើឈ្មោះ មានប្រាប់អ្នកថាមានអ្វីនៅក្នុងធុងជ័រនោះឬទេ?
- តើពេលឈ្មោះ ស្នើសុំឱ្យឈ្មោះ និងឈ្មោះ ជួយដឹកធុងជ័រ តើអ្នកមានទទួលបានលុយ ឬទទួលបានអត្ថប្រយោជន៍អ្វីទេ? ហេតុអ្វីអ្នកទាំងពីរជួយឈ្មោះ ?
- តើឈ្មោះ និងឈ្មោះ មានប្រវត្តិប្រព្រឹត្តបទឧក្រិដ្ឋទេ?
- តើឈ្មោះ និងឈ្មោះ មានអ្វីចង់និយាយបន្ថែមទេ? តើអ្វីជាការធានាអំពីចម្លើយខាងលើ?

(៤) ដំណើរការស៊ើបអង្កេតក៏បានកំណត់បានផងដែរ៖ ប្រហែលខែកុម្ភៈ ឆ្នាំ២០២២ ឈ្មោះ បានទិញគ្រឿងញៀនចំនួន ៩៩៦,៥ ក្រាមពីបុរសជនជាតិ ខ្មែរម្នាក់ឈ្មោះ ក្នុងតម្លៃ ១១,០០០ ដុល្លារ មកប្រទេសវៀតណាម ដើម្បីប្រើប្រាស់។ បច្ចុប្បន្ននេះមិនទាន់កំណត់បានអត្តសញ្ញាណ ប្រវត្តិរូប អាស័យដ្ឋាន និងលេខទូរស័ព្ទរបស់បុរសឈ្មោះ នោះឡើយ។ តាមរយៈរូបភាពរបស់ឈ្មោះ ផ្ដល់ដោយភាគីកម្ពុជា អ្នកស៊ើបអង្កេតបានធ្វើការជាមួយជនជាប់ចោទឈ្មោះ និងឈ្មោះ ហើយបានផ្ដល់អត្តសញ្ញាណរូបថត ដោយអ្នកទាំងពីរបានកំណត់ថា មិនមែនជាអ្នកលក់ឱ្យជនជាប់ចោទឈ្មោះ មេតំហេតាមីនទម្ងន់ ៩៩៦,៥ ក្រាម ស្មើនិងចំនួនលុយ ១១,០០០ ដុល្លារ។ សូមស្នើសុំបន្តផ្ទៀងផ្ទាត់ ប្រសិនបើរកឃើញ និងធ្វើការជាមួយមនុស្សនោះ ត្រូវបញ្ជាក់អោយច្បាស់ខ្លឹមសារដូចខាងក្រោម៖

- តើស្ថានភាពសុខភាព និងស្ថានភាពផ្លូវចិត្ត របស់ឈ្មោះ យ៉ាងណាក្នុងពេលជួបជាមួយកម្លាំងនគរបាលថ្ងៃនេះ?

- តើឈ្មោះ រស់នៅទីណា ហើយប្រកបមុខរបរអ្វី?

- តើឈ្មោះ មានទំនាក់ទំនងជាមួយឈ្មោះ យ៉ាងដូចម្តេច? បើស្គាល់ តើអ្នកស្គាល់នៅពេលណា? បានជួបឈ្មោះ ហើយឬនៅ? បើសិនជាជួបគាត់ជួបនៅកន្លែងណា? ជួបធ្វើអ្វី?

- បើយោងតាមចម្លើយសារភាពរបស់ឈ្មោះ អំឡុងខែកុម្ភៈ ឆ្នាំ២០២២ ហើយបានលក់ជូនអោយឈ្មោះ ០១គីឡូក្រាម គ្រឿងញៀន ក្នុងតម្លៃ ១១,០០០ ដុល្លារ ដូច្នេះ តើឈ្មោះ យោបល់យ៉ាងណាដែរ?

- តើឈ្មោះ មានអ្វីចង់និយាយបន្ថែមទេ? តើអ្វីជាការជោនាអំពីចម្លើយខាងលើ?

(៥) ដែលផ្ទៀងផ្ទាត់បានអត្តសញ្ញាណប្រវត្តិរូប និងស្នើអ្នកផ្តល់សេវាផ្ទេរប្រាក់តាមរយៈប្រព័ន្ធ "វីង" រាយការណ៍ពីប្រវត្តិផ្ទេរប្រាក់របស់ឈ្មោះ ផ្ទេរប្រាក់ទៅប្រទេសវៀតណាម ដើម្បីបង់ថ្លៃដឹកជញ្ជូនគ្រឿងញៀនដល់ជនជាប់ចោទឈ្មោះ ។ ស្នើសុំអាជ្ញាធរមានសមត្ថកិច្ច ដើម្បីដឹកនាំការកត់ត្រាចម្លើយសារភាពរបស់បុគ្គលដែលផ្តល់សេវាផ្ទេរប្រាក់ "វីង" ដល់ឈ្មោះ ជាក់ស្តែង៖

- តើស្ថានភាពសុខភាព និងស្ថានភាពផ្លូវចិត្តរបស់អ្នកផ្តល់សេវាផ្ទេរប្រាក់យ៉ាងណាក្នុងពេលជួបជាមួយកម្លាំងនគរបាលថ្ងៃនេះ?

- តើអ្នកផ្តល់សេវាផ្ទេរប្រាក់រស់នៅទីណា? ហើយប្រកបមុខរបរអ្វី?

- តើអ្នកផ្តល់សេវាផ្ទេរប្រាក់មានទំនាក់ទំនងអ្វីជាមួយឈ្មោះ យ៉ាងដូចម្តេច? បើស្គាល់ តើស្គាល់នៅពេលណា? បានជួបឈ្មោះ ហើយឬនៅ? បើសិនជាជួបគាត់ ជួបនៅកន្លែងណា? ជួបធ្វើអ្វី?

- បើយោងតាមចម្លើយសារភាពរបស់ឈ្មោះ បានឲ្យដឹងថា ចាប់ពីខែមិថុនា ឆ្នាំ២០២២ ដល់ខែកក្កដា ឆ្នាំ២០២២ ឈ្មោះ បានទៅដល់កន្លែងវីង ដើម្បីជួប និងសុំផ្ទេរប្រាក់ទៅប្រទេសវៀតណាមឲ្យឈ្មោះ ចំនួន០៣លើក។ បន្ទាប់មកអ្នកផ្តល់សេវាផ្ទេរប្រាក់បានផ្ទេរប្រាក់ដោយប្រើប្រព័ន្ធ"វីង" ទៅកាន់អ្នកស្គាល់គ្នានៅប្រទេសវៀតណាមឈ្មោះ ហើយបានប្រាប់ឈ្មោះ ថាបានផ្ទេរប្រាក់ទៅឱ្យឈ្មោះ ដូច្នេះ តើត្រឹមត្រូវឬអត់?

- ប្រសិនបើខ្លឹមសារខាងលើត្រឹមត្រូវ តើត្រូវផ្ទេរប្រាក់ប៉ុន្មានដង? លុយប៉ុន្មាន? ផ្ទេរដោយរបៀបណា? ដឹងទេថាឈ្មោះ សុំផ្ទេរលុយទៅវៀតណាមឲ្យឈ្មោះ ដើម្បីធ្វើអ្វីទេ?

- តើអ្នកផ្តល់សេវាផ្ទេរប្រាក់មានអ្វីចង់និយាយបន្ថែមទេ? តើអ្វីជាការជោនាអំពីចម្លើយខាងលើ?

(៦) ផ្ទៀងផ្ទាត់ និងប្រមូលព័ត៌មានប្រតិបត្តិការនៃលេខគណនី របស់ នៅធនាគារ ABA នៃព្រះរាជាណាចក្រកម្ពុជា។

# ឧបសម្ព័ន្ធទី៥

# សំណុំរឿង MLA (សំណើចេញ)

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាកល ករុណា

ខុទ្ទកាល័យ
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ចូល មកដល់ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២២
ម៉ោង ១៧:០០នាទី

សាលាដំបូងរាជធានីភ្នំពេញ

លេខ ៖

ក្រសួងយុត្តិធម៌
មកដល់ថ្ងៃទី ២៨ - ធ្នូ - ២០២២
លេខ ៦១៣៣ ម៉ោង ១៥:០០

# ដីកាបញ្ជូន

## សូមគោរពជូន

## ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្តីផ្សេងៗ |
|---|---|---|---|
| ០១ | - លិខិតលេខ .. .......... ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ ។ (នៅក្នុងសំណុំព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ)។ | ០២ច្បាប់ | |
| | សរុប | ០២ ច្បាប់ | |

អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ
និងអភិវឌ្ឍន៍វិស័យយុត្តិធម៌
ចូល ថ្ងៃទី ៩ ខែមករា ឆ្នាំ២០២៣
លេខ: ៦ ម៉ោង ៩:០០

ថ្ងៃ ពុធ ៦កើត ខែ បុស្ស ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
រាជធានីភ្នំពេញ , ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០២២
ចៅក្រមស៊ើបសួរ

នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន
ចូល លេខ ០១
ថ្ងៃទី ១០ ខែ ០១ ឆ្នាំ២០២៣
ម៉ោង ១៤:០០

ឧបសម្ព័ន្ធទី៥ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសកម្ពុជាទៅប្រទេសឡាវ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**
**អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ**
**និងអភិវឌ្ឍន៍វិស័យយុត្តិធម៌**
**នាយកដ្ឋានកិច្ចការច្បាប់**
**និងកិច្ចសហប្រតិបត្តិការអាស៊ាន**
លេខ៖..

**កំណត់បង្ហាញ**
**សូមគោរពជូន**
**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**តាមរយៈ** ៖ - ឯកឧត្តម រដ្ឋលេខាធិការក្រសួងយុត្តិធម៌
- ឯកឧត្តម អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌
- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌។

**កម្មវត្ថុ** ៖ អំពីសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងការស្រាវជ្រាវប្រវត្តិនៃការផ្តន្ទាទោសលើជនត្រូវចោទឈ្មោះ និង

**យោង** ៖ ដីកាបញ្ជូនលេខ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ ដែលមានជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឡាវ និងឈ្មោះ ភេទប្រុស កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៩៥ ជនជាតិឡាវ ដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទ **"ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"** និងបទ **"សម្អាតប្រាក់"** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ម្លប់លាក ផ្លូវលេខ១ និងនៅចំណុចផ្ទះជួលលេខ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីអំឡុងដើមឆ្នាំ២០២០ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។ ដោយពិនិត្យឃើញថា នៅក្នុងអង្គហេតុមានជនត្រូវចោទជាជនជាតិឡាវ ហើយការស្រាវជ្រាវទាមទារនូវកិច្ចសហការពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រៃវែងយល់ឃើញថា ការធ្វើសហប្រតិបត្តិការជាមួយសាធារដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវជាការចាំបាច់។ អាស្រ័យហេតុនេះ ចៅក្រមស៊ើបសួរបានស្នើសុំក្រសួងយុត្តិធម៌ ដើម្បីស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ក្នុងការស្រាវជ្រាវប្រវត្តិនៃការផ្តន្ទាទោសលើជនត្រូវចោទឈ្មោះ និង

ហេតុដូចនេះ ក្រសួងគប្បីរៀបចំសំណើសុំការជួយគ្នាផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងបញ្ជូនសំណើនេះតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិទៅអាជ្ញាធរកណ្តាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ក្នុងករណី **ឯកឧត្តមរដ្ឋមន្ត្រី** ផ្តល់ការឯកភាព ខ្ញុំបាទសូមគោរពស្នើសុំហត្ថលេខាដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមរដ្ឋមន្ត្រី** លើលិខិតដែលបានគោរពភ្ជាប់ជូនមកជាមួយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច ព្រមទាំងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃអង្គារ ១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣

**ប្រធាននាយកដ្ឋាន**

## មតិយោបល់ និងការសម្រេចរបស់ថ្នាក់ដឹកនាំ

**កម្មវត្ថុ** ៖ អំពីសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងស្រាវជ្រាវប្រវត្តិនៃការផ្តន្ទាទោសលើជនត្រូវចោទឈ្មោះ និង

**បានពិនិត្យ** ៖ លិខិតលេខ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២៣ របស់នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន។

| **អនុរដ្ឋលេខាធិការ** | **ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក** |
|---|---|
| របសគម្ម | បានពិនិត្យ និងឯកភាព<br>សូមគោរពជូន ឯ.ឧ. [illegible]<br>មេត្តាពិនិត្យ និង សម្រេច។ |

**រដ្ឋលេខាធិការ**

បានពិនិត្យ និង ឯកភាព។
សូមគោរពជូន ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់។

(ហត្ថលេខា 14/03/23)

**ការសម្រេចរបស់ឯកឧត្តមរដ្ឋមន្ត្រី** ៖

ឯកភាព.

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF JUSTICE

N°..

Phnom Penh March 30 2023

The Office of The Supreme People's Prosecutor
Lao People's Democratic Republic

**Subject** : The request for legal assistance in criminal matters to research the history of convictions of and

**Reference**: The Law on Mutual Legal Assistance in Criminal Matters of the Kingdom of Cambodia.

Your Excellency,

With reference to the above subject, the Ministry of Justice of the Kingdom of Cambodia presents its compliments to the office of the Supreme People's Prosecutor of the Lao People's Democratic Republic and has the honor to inform that the Ministry of Justice of the Kingdom of Cambodia would like to request the office of the Supreme People's Prosecutor of the Lao People's Democratic Republic to assist in executing the request for legal assistance to research the history of convictions of and

The detailed contents of the request are specified in the attachment herewith. The Ministry of Justice of the Kingdom of Cambodia highly appreciates the assistance of the office of the Supreme People's Prosecutor of the Lao People's Democratic Republic in executing the aforesaid request as soon as possible.

The Ministry of Justice of the Kingdom of Cambodia avails itself of this opportunity to renew to the office of the Supreme People's Prosecutor of the Lao People's Democratic Republic the assurances of its high consideration.

**Yours Sincerely,**

**CONTACT:**
Central Authority of the Kingdom of Cambodia
Email: ca_cambodia@moj.gov.kh

ឧបសម្ព័ន្ធទី៥ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសកម្ពុជាទៅប្រទេសឡាវ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ :.

ថ្ងៃព្រហស្បតិ៍ ៩កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣

**សូមគោរពជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ** ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្នុងការស្រាវជ្រាវ ប្រវត្តិនៃការផ្តន្ទាទោសលើជនត្រូវចោទឈ្មោះ និង

**យោង** ៖ ដីកាបញ្ជូនលេខ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីស្រាវជ្រាវប្រវត្តិនៃការផ្តន្ទាទោសលើឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឡាវ និងឈ្មោះ ភេទប្រុស កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៩៥ ជនជាតិឡាវ។ ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំសំណើ និងលិខិតផ្ញើជូនក្រសួងយុត្តិធម៌នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌក្នុងករណីខាងលើ ដូចបានគោរពភ្ជាប់មកជាមួយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងចាត់នីតិវិធីបន្តដោយក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322, 023 217 841, 023 212 693

ឧបសម្ព័ន្ធទី៥ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសកម្ពុជាទៅប្រទេសឡាវ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

## សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ

អាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ពីអាជ្ញាធរកណ្ដាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវលើករណីដែលបានបញ្ជាក់ក្នុងសំណើនេះ ផ្អែកតាមច្បាប់ស្ដីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

**១.ព័ត៌មានរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ**

- **លិខិត/សំណុំរឿង ៖** សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។
- **អាជ្ញាធរធ្វើសំណើ ៖** សាលាដំបូងរាជធានីភ្នំពេញ។

**២.ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធនឹងសំណើ**

- ជនត្រូវចោទឈ្មោះ កេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឡាវ។
- ជនត្រូវចោទឈ្មោះ កេទប្រុស កើតថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៩៥។

**៣.អង្គហេតុ**

នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ កម្លាំងជំនាញ នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្ទះសំណាក់ម្លប់លាក ផ្លូវលេខ១ និងនៅចំណុចផ្ទះជួលលេខ៧៧៦ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយឃាត់ខ្លួនបានបុរសម្នាក់ឈ្មោះ កេទប្រុស អាយុ៤២ឆ្នាំ រួមទាំងវត្ថុតាងជាសារធាតុញៀនចំនួន០៧កញ្ចប់ នៅពេលឈ្មោះ កំពុងធ្វើការដោះដូរគ្រឿងញៀនជាមួយម៉ូយ ហើយសមត្ថកិច្ចក៏បន្តទៅឆែកឆេរនៅចំណុចដែលឈ្មោះ ស្នាក់នៅផ្ទះលេខ៧៧៦ ផ្លូវលេខ១ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ រកឃើញប៉ាន់គ្រឿងញៀនមួយកញ្ចប់តូច និងរថយន្តមួយគ្រឿងម៉ាក TOYOTA PRIUS ពណ៌ទឹកប្រាក់ ពាក់ផ្លាកលេខ ភ្នំពេញ ដែលជារបស់ឈ្មោះ ; ជាបក្ខពួករបស់ឈ្មោះ ក្រោយពេលឃាត់ខ្លួនសមត្ថកិច្ចបាននាំខ្លួនឈ្មោះ

រួមទាំងក្រាមពណ៌សថ្លាសរុបទម្ងន់ ៦,៩៣០ក្រាម យកមកសាកសួរនៅមន្ទីរប្រឆាំងគ្រឿងញៀនតែម្ដង។ បន្ទាប់ពីសាកសួររួច ឈ្មោះ បានសារភាពថា បក្ខពួករបស់ខ្លួនឈ្មោះ បានចូលមកប្រទេសកម្ពុជាតាំងពីដើមឆ្នាំ២០២០ ចំណែកខ្លួនបានចូលមកប្រទេសកម្ពុជាក្នុងអំឡុងខែសីហា ឆ្នាំ២០២២ តាមច្រកទ្វារអន្តរជាតិត្រពាំងក្រៀល ខេត្តស្ទឹងត្រែង ចំណែកគ្រឿងញៀនដែលសមត្ថកិច្ចដកហូតបានខាងលើ គឺជារបស់ ជនមិនស្គាល់ឈ្មោះ (ហៅបងធំ) ភេទប្រុស អាយុប្រហែល៥០ឆ្នាំ ជនជាតិឡាវ បានឱ្យ

ខ្លួនយកគ្រឿងញៀនទម្ងន់ ៨គីឡូក្រាមទៅលក់ឱ្យម៉ូយបានចំនួន០២លើក លើកទី១ នៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២២ ខ្លួនបានយកគ្រឿងញៀនទម្ងន់១គីឡូក្រាម ទៅឱ្យបុរសម្នាក់មិនស្គាល់ឈ្មោះ នៅរង់ចាំមុខផ្ទះសំណាក់ដែលខ្លួនស្នាក់នៅ និងលើកទី២ នៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ ខ្លួនបានយកគ្រឿងញៀនចំនួន៧កញ្ចប់ ទៅឱ្យម៉ូយថ្មី នៅមុខផ្ទះសំណាក់ដដែល ពេលកំពុងតែដោះដូរគ្រឿងញៀន តែត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

**៤.ដំណើរការនៃសំណុំរឿង**

៤.១.ការស្រាវជ្រាវរបស់សមត្ថកិច្ច

កាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ មានប្រជាពលរដ្ឋបានរាយការណ៍ជូនមន្ត្រីនគរបាល នៃការិយាល័យប្រឆាំងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន ថានៅចំណុចផ្ទះសំណាក់ម្លប់លាភ ផ្លូវលេខ១ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ មានករណីជួញដូរ ដោយខុសច្បាប់នូវសារធាតុញៀនកើតឡើង។ បន្ទាប់ពីទទួលបានព័ត៌មាននេះ មន្ទីរប្រឆាំងបទល្មើសគ្រឿងញៀនបានចាត់តាំងកម្លាំងមន្ត្រីជំនាញ ចុះទៅស៊ើបអង្កេតករណីនេះ ដោយមានការដឹកនាំសម្របសម្រួលពីព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញផងដែរ។ លុះដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង១៦និង២៥នាទី កម្លាំងជំនាញការិយាល័យប្រឆាំងការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ម្លប់លាភ ផ្លូវលេខ១ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយបានឃាត់ខ្លួនជនសង្ស័យចំនួន០១នាក់ រួមទាំងវត្ថុតាងជាសារធាតុញៀន ពេលសួរចម្លើយរួចនៅវេលាម៉ោង១៩និង០០នាទី ថ្ងៃខែឆ្នាំដដែល កម្លាំងជំនាញបានបន្តទៅឆែកឆេរលំនៅដ្ឋានផ្ទះលេខ          ភូមិព្រៃជីសាក់ សង្កាត់ចោមចៅ៣ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ រកឃើញវត្ថុតាងបន្ថែមទៀត។

៤.២.ការស្រាវជ្រាវរបស់តំណាងអយ្យការ

បន្ទាប់ពីទទួលបានសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានធ្វើការសួរចម្លើយ និងបានសម្រេចបើកការស៊ើបសួរលើឈ្មោះ          ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឡាវ, ឈ្មោះ          ភេទប្រុស អាយុប្រហែល២៦ឆ្នាំ ជនជាតិឡាវ, ឈ្មោះ

ភេទប្រុស កើតថ្ងៃ០៨ ខែមិថុនា ឆ្នាំ១៩៩៥ ជនជាតិឡាវ និងឈ្មោះ ជនមិនស្គាល់ឈ្មោះ ហៅបងធំ ភេទប្រុស អាយុប្រហែល៥០ឆ្នាំ ជនជាតិឡាវ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងបទ សម្អាតប្រាក់ ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ម្លប់លាភ ផ្លូវលេខ១ និងនៅចំណុចផ្ទះលេខ៧៧៦ ភូមិព្រៃជីសាក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កាលពីអំឡុងដើមឆ្នាំ២០២០ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា ៣៨ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម តាមដីកាសម្រេចបញ្ជូនរឿងឱ្យស៊ើបសួរលេខ          ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២២។

៤.៣.ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

បន្ទាប់ពីទទួលបានសំណុំរឿងចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ បានសម្រេចឃុំខ្លួនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ជនជាតិឡាវ ជាបណ្ដោះអាសន្ន នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២២ និងបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនជនត្រូវចោទឈ្មោះ នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។ នៅពេលបច្ចុប្បន្នចៅក្រមស៊ើបសួរបានបំពេញកិច្ចស្រាវជ្រាវជាច្រើនដែលទាក់ទងនឹងអត្តសញ្ញាណរបស់ជនត្រូវចោទ និងទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងបទល្មើសខាងលើ ព្រមទាំងកំពុងបន្តកិច្ចស៊ើបសួរតាមនីតិវិធីច្បាប់។

**៥. បទប្បញ្ញត្តិនៃច្បាប់**

**ច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន (ឆ្នាំ២០១២)**

**-មាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន**

ការកាន់កាប់ ការលាក់ទុក សន្និធិ និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។

ការបញ្ជូនតាមគ្រប់រូបភាពដែលនាំឱ្យមានការផ្លាស់ទី ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវសារធាតុញៀន ជាអាទិ៍ តាមរយៈការផ្ញើ ការធ្វើចរាចរ ការនាំចូល ឬការនាំចេញ គឺជាអំពើដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន។

ការផ្ដល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬការដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន។

បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ។ ក្រៅពីទោសដាក់ពន្ធនាគា ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ ៖

១-បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង។

២-បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ។

៣-ជ័រអាភៀន ជ័រកញ្ឆា ឬកាកូកា មានបរិមាណសុទ្ធចាប់ពី ៤០០ (បួនរយ) ក្រាម រហូតដល់ក្រោម ៨០០ (ប្រាំបីរយ) ក្រាម ។

៤-ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ២០០ (ពីរយ) ក្រាម រហូតដល់ក្រោម ៤០០ (បួនរយ) ក្រាម។

៥-ម៉ូហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ៤ (បួន) ក្រាម រហូតដល់ក្រោម ២៥ (ម្ភៃប្រាំ) ក្រាម។

៦-អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ១៥ (ដប់ប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម។

៧-កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៨ (ប្រាំបី) គីឡូក្រាម រហូតដល់ក្រោម ២០ (ម្ភៃ) គីឡូក្រាម។

៨-ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ៨ (ប្រាំបី) គីឡូក្រាម រហូតដល់ក្រោម ៤០ (សែសិប) គីឡូក្រាម។

៩-ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ៤០ (សែសិប) គីឡូក្រាម រហូតដល់ក្រោម ១៦០ (មួយរយហុកសិប) គីឡូក្រាម។

១០-បណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ១៥ (ដប់ប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម។

១១-សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុស្មើនឹងបរិមាណសុទ្ធសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយចាប់ពីចំណុចទី ៣ ដល់ចំណុចទី ១០ នៃកថាខណ្ឌនេះ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ ៖

១-ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ៨០០ (ប្រាំបីរយ) ក្រាម រហូតដល់ក្រោម ១.៦០០ (មួយពាន់ប្រាំមួយរយ) ក្រាម ។

២-ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៤០០ (បួនរយ)ក្រាម រហូតដល់ក្រោម ៨០០ (ប្រាំបីរយ) ក្រាម។

៣-ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ២៥ (ម្ភៃប្រាំ)ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម។

៤-អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ក្រោម ២៤០ (ពីរយសែសិប) ក្រាម។

៥-កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ២០ (ម្ភៃ) គីឡូក្រាម រហូតដល់ក្រោម ៦០ (ហុកសិប) គីឡូក្រាម។

៦-ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ៤០ (សែសិប) គីឡូក្រាម រហូតដល់ក្រោម ១២០ (មួយរយម្ភៃ) គីឡូក្រាម។

៧-ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ១៦០ (មួយរយហុកសិប) គីឡូក្រាម រហូតដល់ក្រោម ៤៨០ (បួនរយប៉ែតសិប) គីឡូក្រាម។

៨-បណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ក្រោម ២៤០ (ពីររយសែសិប) ក្រាម។

៩-សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយចាប់ពីចំណុចទី ១ ដល់ចំណុចទី ៨ នៃកថាខណ្ឌនេះ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ ៖

១-ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធ ចាប់ពី ១.៦០០ (មួយពាន់ប្រាំមួយរយ) ក្រាម ឡើងទៅ។

២-ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៨០០ (ប្រាំបីរយ) ក្រាម ឡើងទៅ។

៣-ម៉ាហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម ឡើងទៅ។

៤-អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ២៤០ (ពីរយសែសិប) ក្រាម ឡើងទៅ។

៥-កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៦០ (ហុកសិប) គីឡូក្រាម ឡើងទៅ។

៦-ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ១២០ (មួយរយម្ភៃ) គីឡូក្រាម ឡើងទៅ។

៧-ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ៤៨០ (បួនរយប៉ែតសិប) គីឡូក្រាម ឡើងទៅ។

៨-បណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ២៤០ (ពីរយសែសិប) ក្រាម ឡើងទៅ។

៩-សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី១ និងតារាងទី២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយចាប់ពីចំណុចទី១ ដល់ចំណុចទី៨ នៃកថាខណ្ឌនេះ។

**ច្បាប់ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ឆ្នាំ២០២០)**

-មាត្រា ៣៨-បទសម្អាតប្រាក់

១- ការសម្អាតប្រាក់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំ ទៅ ៥ឆ្នាំ និងពិន័យជាប្រាក់ពី ១០០.០០០.០០០ រៀល ទៅ ៥០០.០០០.០០០ រៀល ឬហួតដល់ស្មើនឹងតម្លៃមូលនិធិ ឬទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសម្អាតប្រាក់។

២- បទប្បញ្ញត្តិពីមាត្រា ៤០៦ (ស្ថានទម្ងន់ទោស) ដល់មាត្រា ៤០៨ (ទោសបន្ថែមៈប្រភេទនិងរយៈពេល) នៃក្រមព្រហ្មទណ្ឌត្រូវយកមកអនុវត្ត។

៣- នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌសម្រាប់បទល្មើសសម្អាតប្រាក់។

៤- នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០.០០០ រៀល ទៅ ១.០០០.០០០.០០០ រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើន ដូចមានចែងនៅក្នុងមាត្រា ៤៣ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃច្បាប់នេះ។

## ៦. សំណើសុំជំនួយ

អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាស្នើសុំជំនួយផ្នែកច្បាប់ ពីអាជ្ញាធរកណ្តាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីធ្វើការស្រាវជ្រាវប្រវត្តិនៃការផ្តន្ទាទោសលើជនត្រូវចោទឈ្មោះ

និង ។

## ៧. កាលបរិច្ឆេទកំណត់នៃការផ្តល់ព័ត៌មាន

អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យអាជ្ញាធរកណ្តាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជួយផ្តល់នូវព័ត៌មានដែលបានស្នើសុំខាងលើឱ្យបានឆាប់ ដើម្បីជួយដល់ការស៊ើបសួរក្នុងព្រះរាជាណាចក្រកម្ពុជា។

**៨. ការរក្សាការសម្ងាត់**

អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យអាជ្ញាធរកណ្តាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ជួយរក្សាការសម្ងាត់នៃសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ រួមទាំងឯកសារទាំងឡាយដែលបានភ្ជាប់ជូននៅក្នុងសំណើនេះ។

**៩. ការអះអាង**

អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាអះអាងថា ជំនួយផ្នែកច្បាប់ដែលបានផ្តល់ឱ្យសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចំពោះសំណើនេះនឹងត្រូវបានរក្សាការសម្ងាត់ និងត្រូវប្រើប្រាស់សម្រាប់តែគោលបំណងដែលមានចែងក្នុងសំណើនេះតែប៉ុណ្ណោះ។ អាជ្ញាធរកម្ពុជានឹងផ្តល់ជំនួយផ្នែកច្បាប់ឱ្យសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវនៅពេលដែលមានការស្នើសុំ។

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF JUSTICE

# REQUEST FOR LEGAL ASSISTANCE IN CRIMINAL MATTERS

The Central Authority of the Kingdom of Cambodia requests legal assistance from the Central Authority of the Lao People's Democratic Republic on the case referred to in this request pursuant to the Law on Mutual Legal Assistance in Criminal Matters of the Kingdom of Cambodia.

## 1. INFORMATION OF RELEVANT COMPETENT AUTHORITIES

- **File/Case:** Criminal Case dated October 19, 2022 by the Prosecution attached to the Phnom Penh Municipal Court of the First instance.

- **Requesting authority:** The Phnom Penh Municipal Court of the First Instance.

## 2. INFORMATION OF RELEVANT PERSONS SUBJECT TO THE REQUEST

- Defendant's name: , male, 42 years old, Laotian.
- Defendant's name: male, born on June 8,1995, Laotian.

## 3. FACT

On October 16, 2022, the Department of Anti-Drug Crimes cracked down on drug trafficking cases at the Mlup Leap Guesthouse, Street 1 and at the rental house No.776, Prey Chisak Village, Sangkat Choam Chao, Khan Por Senchey, Phnom Penh, arrested a 42-year-old man named with 7 packs of drug paraphernalia while was exchanging drugs with customer, and the police continued to search the place where was staying, Street 1, Prey Chisak Village, Sangkat Choam Chao, Khan Por Senchey, Phnom Penh and found a pack of drug and a silver car (TOYOTA PRIUS), plate number (Phnom Penh: 2W-7766) which belongs to who is an ally of After arrested, the police brought CHOUA MOUA including the drug, weighing a total of 6,930 grams for questioning at the Anti-Drug Department. After interrogated, said that had been coming to the Kingdom of Cambodia since the beginning of 2020 and he came to the kingdom of Cambodia during August 2022, through the international gate of Trapeang Kriel, Stung Treng province. The drugs confiscated by the police belonged to the unidentified Laotian man known as "Big Brother", about 50 years old who offered him to bring 8 kilograms of drugs from Laos by bus to Cambodia with a 26 years old Laotian man name's JE, to sold the drugs to the customer in Phnom Penh and he has sold the drugs for 2 times. First time, On October 14, 2022, he sold 1 kilogram of drugs to an

unknown man in front of the guesthouse where he lived. Second time, on October 16, 2022, he sold seven packages of drugs to the new customer in front of the same guesthouse while exchanging drugs, he was arrested by the authorities.

**4. PROCEEDING OF THE CASE**

**(1). Investigation of Competent Authority**

On October 13, 2022, people reported to the police officer of the Office of Anti-Illegal Drug Use, Department of Anti-Drug Crimes that at the Mlup Leap Guesthouse, Street 1, Prey Chisak Village, Sangkat Choam Chao, Khan Por Senchey, Phnom Penh, there have been cases of illegal drug trafficking. After receiving this information, the Anti-Drug Department assigned a team of specialized officers to investigate this case, with the coordination of the Deputy Prosecutor of Prosecution attached to the Phnom Penh Municipal Court of the First Instance. On October 16, 2022, at 16:25, the Anti-Drug Bureau of the Anti-Drug Department cracked down on drug trafficking at Mlup Leap Guesthouse, Road No.1, Prey Chisak Village, Sangkat Choam Chao, Khan Por Senchey, Phnom Penh, arrested 1 suspect, including drug exhibits, during interrogation at 19:00 on the same day, the specialized force continued to search the house Prey Chisak Village, Sangkat Choam Chao 3, Khan Por Senchey, Phnom Penh, more exhibits were found.

**(2). Investigation of Prosecutor**

After receiving the case file from the Judicial Police Officer, the representative Prosecutor of Prosecution attached to the Phnom Penh Municipal Court of the First Instance interrogated and decided to open an investigation on , male, 42 years old, Lao national, and male, about 26 years old, Laotian, male, born on June 08, 1995, Laotian, and an unidentified man known as Big Boss, male, about 50 years old, Laotian, on charges of drug trafficking and money laundering at Mlup Leap Guesthouse, Street 1 and at house No.776, Prey Chisak Village, Sangkat Choam Chao, Khan Por Senchey, Phnom Penh, during the early 2020 to October 16, 2022, criminal offenses punishable under Article 40 of Law on Drug Control and Article 38 of the Law on Anti-Money Laundering and Combating the Financing of Terrorism by Order dated October 21, 2022.

**(3). The investigation of Investigating Judge**

After receiving the case, the Investigating Judge of the Phnom Penh Municipal Court of the First Instance decided to detain a 42-year-old Lao national, on October 22, 2022 and issued an arrest the defendant name's on December 23, 2022. At present, the investigating judge has carried out a lot of research related to the identity of the accused and the property related to the above crimes, and continuing the investigation in accordance with legal procedures.

## 5. APPLICABLE LAW TO THE OFFENSE

**Law on Drug Control (2012)**

**Article 40.- Unlawful Keeping, Transporting, or Trafficking of Narcotics Substances**

Possession, concealment, storage, and any other similar unlawful activities relating to narcotic drugs is the unlawful keeping of the narcotic substances.

The unlawful transfer by all means from one place to another, from one person to another, or from one country to another of narcotic drugs be it through sending, trafficking, exporting or importing, is the unlawful transportation of narcotic substances.

Providing for selling, buying, buying for selling or exchanging, unlawful trading in of narcotic substances is the unlawful trafficking of narcotic substances.

Unlawful keeping, transporting, or trafficking of narcotic substances as listed in Table I and Table II shall be punishable by imprisonment from 2 (two) years to 5 (five) years. In addition, the offender may be held liable by a fine from 4,000,000 million (four million) Riels to 10,000,000 (ten million) Riels.

Shall be punishable by imprisonment from 5 (five) years to 10 (ten) years and with by a fine from 10,000,000 (ten million) Riels to 20,000,000 (twenty million) Riels, the offence which is carried out in one of the following circumstances:

1- Repeat offences;
2- The offence committed in the framework of one's function or in the performance of one's function;
3- Opium resin, cannabis resin, or coca paste with a pure quantity from 400 (four hundred) grams to less than 800 (eight hundred) grams;
4- Cannabis oil with a pure quantity from 200 (two hundred) grams to less than 400 (four hundred) grams;
5- Morphine, heroin, or cocaine with a pure quantity from 4 (four) grams to less than 25 (twenty five) grams;
6- Methamphetamine, amphetamine or ecstasy with a pure quantity from 15 (fifteen) grams to less than 80 (eighty) grams;
7- Dry cannabis or coca leaves with a quantity from 8 (eight) kilograms to less than 20 (twenty) kilograms;
8- Fresh opium fruit with a quantity from 8 (eight) kilograms to less than 40 (forty) kilograms;
9- Dry opium fruit with a quantity from 40 (forty) kilograms to less than 160 (one hundred and sixty) kilograms;
10- Other narcotic substances as provided for in Table I and Table II with a pure quantity from 15 (fifteen) grams to less than 80 (eighty) grams;
11- Narcotic substances in Table I and Table II from two types and with a total pure quantity of those substances equal to the pure quantity of narcotic substances as indicated from sub-paragraphs 3 to 10.

Shall be punishable by imprisonment from 10 (ten) years to 20 (twenty) years and by a fine from 20,000,000 (twenty million) Riels to 40,000,000 (forty million) Riels, the offence which is carried out in one of the following circumstances:

1- Opium resin, cannabis resin or coca paste with a pure quantity from 800 (eight hundred) grams to less than 1,600 (one thousand and six hundred) grams;
2- Cannabis oil with a pure quantity from 400 (four hundred) grams to less than 800 (eight hundred) grams;
3- Morphine, heroin, or cocaine with a pure quantity from 25 (twenty-five) grams to less than 80 (eighty) grams;
4- Amphetamine, methamphetamine or ecstasy with a pure quantity from 80 (eighty) grams to less than 240 (two hundred and forty) grams;
5- Dry cannabis or coca leaves with a quantity from 20 (twenty) kilograms to less than 60 (sixty) kilograms;
6- Fresh opium fruit with a quantity from 40 (forty) kilograms to less than 120 (one hundred and twenty) kilograms;
7- Dry opium fruit with a quantity from 160 (one hundred and sixty) kilograms to less than 480 (four hundred and eighty) kilograms;
8- Other narcotic substances as provided for in Table I and Table II with a pure quantity from 80 (eighty) grams to less than 240 (two hundred and forty) grams;
9- Narcotic substances in Table I and Table II from two types and with a total pure quantity of those substances equal to the pure quantity of narcotic substances as indicated from sub-paragraphs 1 to 8.

Shall be punishable by imprisonment from 20 (twenty) years to 30 (thirty) years or by life imprisonment and by a fine from 40,000,000 (forty million) Riels to 100,000,000 (one hundred million) Riels, the offence which is carried out in one of the following circumstances:

1- Opium resin, cannabis resin or coca paste with a pure quantity from 1,600 (one thousand and six hundred) grams;
2- Cannabis oil with a pure quantity from 800 (eight hundred) grams;
3- Morphine, heroin, or cocaine with a pure quantity from 80 (eighty) grams;
4- Amphetamine, methamphetamine or ecstasy with a pure quantity from 240 (two hundred and forty) grams;
5- Dry cannabis or coca leaves with a quantity from 20 (twenty) kilograms to less than 60 (sixty) kilograms;
6- Fresh opium fruit with a quantity from 120 (one hundred and twenty) kilograms;
7- Dry opium fruit with a quantity from 480 (four hundred and eighty) kilograms;
8- Other narcotic substances as provided for in Table I and Table II with a pure quantity from 240 (two hundred and forty) grams;
9- Narcotic substances in Table I and Table II from two types and with a total pure quantity of those substances equal to the pure quantity of narcotic substances as indicated from sub-paragraphs 1 to 8

**Law on Anti-Money Laundering and Combating the Financing of Terrorism (2020)**

**-Article 38.- Money Laundering Offence**

1. Money laundering is punishable by an imprisonment from 2 years to 5 years and a fine from 100,000,000 riels up to 500,000,000 riels, or up the value of fund or property which was the subject of money laundering.
2. The provisions of Articles 406 (Aggravating Circumstances) to 408 (additional Penalties: Categories and Duration) of the Criminal Code shall apply.
3. The legal entity may be declared as being criminally responsible under conditions as stipulated in Article 42 (Criminal Responsibility of a Legal Entity) of the Criminal code for money laundering offences.
4. The legal entity shall be subject to a fine from 200,000,000 riels up to 1,000,000,000 riels and any one or more additional sanctions as stipulated in Article 43 (Additional Penalties Applicable to Legal Entity) of the present Law.

**6. ASSISTANCE REQUESTED**

The Central Authority of the Kingdom of Cambodia requesting legal assistance from the Central Authority of the Lao People's Democratic Republic to research the history of convictions of and

**7. DEADLINE OF THE LEGAL ASSISTANCE**

The Central Authority of the Kingdom of Cambodia kindly requests legal assistance from the Central Authority of the Lao People's Democratic Republic at the earliest date for the investigation of the case in the Kingdom of Cambodia.

**8. CONFIDENTIALITY**

The Central Authority of the Kingdom of Cambodia urges the Central Authority of the Lao People's Democratic Republic to keep this request for mutual legal assistance including any documents attached herewith confidential.

**9. ASSURANCE**

The Central Authority of the Kingdom of Cambodia asserts that this request for legal assistance provided by the Lao People's Democratic Republic to this request will be kept confidential and used for the purposes set forth in the request only. The Central Authority of the Kingdom of Cambodia will provide legal assistance to the Lao People's Democratic Republic when requested.

ឧបសម្ព័ន្ធទី៥ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសកម្ពុជាទៅប្រទេសម៉ាឡេស៊ី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌
ចូល ថ្ងៃទី ២-វិច្ឆិកា-២០២២ លេខៈ ២៥៧ ម៉ោង ១១:០០

ខុទ្ទកាល័យ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌
ចូល មកដល់ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០២២ ម៉ោង ១៧:០០នាទី

សាលាដំបូងខេត្តព្រះសីហនុ

លេខ

ក្រសួងយុត្តិធម៌
មកដល់ថ្ងៃទី ២៦-១០-២០២២
លេខ ៤៨៤២ ម៉ោង ០៨:១០

## ដីកាបញ្ជូន

គោរពជូន ៖ ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២

| ល.រ | រាយឈ្មោះលិខិត | ចំនួន | សេចក្ដីផ្សេងៗ |
|---|---|---|---|
| ១ | សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកពី ប្រទេសម៉ាឡេស៊ី ដើម្បីផ្ដល់អត្តសញ្ញាណ និងព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងជនត្រូវចោទ ដែលជាជនជាតិចិនឈ្មោះ ; លេខ ....... រ.ប/ច/២២ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០២២ ។ | ២ច្បាប់ | |
| | សរុប | ២ច្បាប់ | |

ថ្ងៃព្រហស្បតិ៍ ៣រោច ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ខេត្តព្រះសីហនុ ថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២២
ប្រធានសាលាដំបូង

ឧបសម្ព័ន្ធទី៥ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសកម្ពុជាទៅប្រទេសម៉ាឡេស៊ី

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**
**អគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ**
**និងអភិវឌ្ឍន៍វិស័យយុត្តិធម៌**
**នាយកដ្ឋានកិច្ចការច្បាប់**
**និងកិច្ចសហប្រតិបត្តិការអាស៊ាន**

**កំណត់បង្ហាញ**

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**តាមរយៈ** ៖ ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការអន្តរជាតិ និងអភិវឌ្ឍន៍វិស័យយុត្តិធម៌។

**កម្មវត្ថុ** ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសម៉ាឡេស៊ី ដើម្បីផ្តល់អត្តសញ្ញាណ និងព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងជនត្រូវចោទ ដែលជាជនជាតិចិនឈ្មោះ ។

**យោង** ៖ ដីកាបញ្ជូនលេខ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់សាលាដំបូងខេត្តព្រះសីហនុ ដែលបានស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសម៉ាឡេស៊ី ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២។ អង្គហេតុនៃសំណុំរឿងព្រហ្មទណ្ឌខាងលើមានដូចតទៅ៖ ឈ្មោះ ហៅ ភេទប្រុស កើតនៅឆ្នាំ១៩៩០ ត្រូវបានសមត្ថកិច្ចបានឃាត់ខ្លួនពាក់ព័ន្ធនឹងករណីជួញដូរមនុស្ស រហូតដល់មានការស្រាវជ្រាវឈានដល់ការកំណត់បាននូវអត្តសញ្ញាណ និងបានធ្វើការចោទប្រកាន់តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ លើឈ្មោះ ហៅ ភេទប្រុស អាយុ៣២ឆ្នាំ កើតឆ្នាំ១៩៩០ ជនជាតិម៉ាឡេស៊ី ពីបទ " **អំពើលក់ដូរមនុស្ស, បទចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស, ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស**" ប្រព្រឹត្តនៅក្រុងបាវិត ខេត្តស្វាយរៀង និងខេត្តព្រះសីហនុ (អគារ ) កាលពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៣, មាត្រា ១៤ និងមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ។ ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តព្រះសីហនុបានបញ្ជាក់ថា ដើម្បីធានាឱ្យមានការស៊ើបសួរមួយពេញលេញ និងមានប្រសិទ្ធភាព ការផ្ទៀងផ្ទាត់ និងស្រាវជ្រាវអំពីអត្តសញ្ញាណរបស់ជនត្រូវចោទ គឺជាកិច្ចការមួយចាំបាច់ដែលទាមទារកិច្ចសហប្រតិបត្តិការពីប្រទេសម៉ាឡេស៊ី ហេតុដូច្នេះបានស្នើសុំក្រសួងយុត្តិធម៌ ធ្វើការស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសម៉ាឡេស៊ី ដើម្បីបញ្ជាក់ និងផ្តល់អត្តសញ្ញាណ ជាមួយនឹងព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងជនត្រូវចោទឈ្មោះ ។

ហេតុដូចនេះ ក្រសួងគប្បីរៀបចំសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសម៉ាឡេស៊ី និងបញ្ជូនសំណើនេះតាមរយៈក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិទៅអាជ្ញាធរកណ្តាលនៃប្រទេសម៉ាឡេស៊ី។

ក្នុងករណី **ឯកឧត្តមរដ្ឋមន្ត្រី** ផ្តល់ការឯកភាព ខ្ញុំបាទសូមគោរពស្នើសុំហត្ថលេខាដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមរដ្ឋមន្ត្រី លើលិខិតដែលបានគោរពភ្ជាប់ជូនមកជាមួយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាប ព្រមទាំងផ្តល់អនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ៧ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២

**ប្រធាននាយកដ្ឋាន**

## មតិយោបល់ និងការសម្រេចរបស់ថ្នាក់ដឹកនាំ

**កម្មវត្ថុ** ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសម៉ាឡេស៊ី ដើម្បីផ្តល់អត្តសញ្ញាណ និងព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងជនត្រូវចោទ ដែលជាជនជាតិចិនឈ្មោះ

**បានពិនិត្យ** ៖ លិខិតចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២២ របស់នាយកដ្ឋានកិច្ចការច្បាប់ និងកិច្ចសហប្រតិបត្តិការអាស៊ាន។

| **ប្រតិភូរាជរដ្ឋាភិបាល និងជាអគ្គនាយក** | |
|---|---|
| បានពិនិត្យ និង ឯកភាព ។<br>សូមគោរពជូន ឧ.រដ្ឋមន្ត្រី មេត្តាពិនិត្យ និង សម្រេច<br>ព្រមទាំងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ ដោយក្តីគោរព ។ | |
| **ការសម្រេចរបស់<br>ឯកឧត្តមរដ្ឋមន្ត្រី** ៖ | ឯកភាព.<br>02/01/2023 |

ឧបសម្ព័ន្ធទី៥ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសកម្ពុជាទៅប្រទេសម៉ាឡេស៊ី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

ថ្ងៃអង្គារ ១២កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

លេខ :.

រាជធានីភ្នំពេញ ថ្ងៃទី ៣ ខែ មករា ឆ្នាំ២០២៣

**សូមគោរពជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ៖** សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសម៉ាឡេស៊ី ដើម្បីផ្តល់អត្តសញ្ញាណ និងព័ត៌មានមួយចំនួនពាក់ព័ន្ធនឹងជនត្រូវចោទ ដែលជាជនជាតិចិនឈ្មោះ ។

**យោង ៖** ដីកាបញ្ជូនលេខ ចុះថ្ងៃទី១៣ តុលា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តព្រះសីហនុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ក្រសួងយុត្តិធម៌បានទទួលលិខិតរបស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសម៉ាឡេស៊ីពាក់ព័ន្ធនឹងឈ្មោះ ភេទប្រុស កើតនៅឆ្នាំ១៩៩០ ដែលត្រូវបានចោទប្រកាន់ពី **បទអំពើលក់ដូរមនុស្ស, បទចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស, ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស** ប្រព្រឹត្តនៅក្រុងបាវិត ខេត្តស្វាយរៀង និងខេត្តព្រះសីហនុ កាលពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៣ មាត្រា ១៤ និងមាត្រា ២០ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ។ ដើម្បីធានាឱ្យមានការស៊ើបសួរមួយពេញលេញ និងមានប្រសិទ្ធភាព ការផ្ទៀងផ្ទាត់ និងស្រាវជ្រាវអំពីអត្តសញ្ញាណរបស់ជនត្រូវចោទ គឺជាកិច្ចការមួយចាំបាច់ដែលទាមទារកិច្ចសហប្រតិបត្តិការពីប្រទេសម៉ាឡេស៊ី។ ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំសំណើ និងលិខិតផ្ញើជូនក្រសួងយុត្តិធម៌នៃប្រទេសម៉ាឡេស៊ី ដើម្បីស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌក្នុងករណីខាងលើ ដូចបានគោរពភ្ជាប់មកជាមួយ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងចាត់ចែងបន្តដ៏ខ្ពង់ខ្ពស់។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

ឧបសម្ព័ន្ធទី៥ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសកម្ពុជាទៅប្រទេសម៉ាឡេស៊ី

**KINGDOM OF CAMBODIA**

**NATION RELIGION KING**

MINISTRY OF JUSTICE

Nº.

Phnom Penh, January 3, 2023

The Attorney General of Malaysia
Level 8 Attorney General's Chambers Malaysia
No. 45 Persiaran Perdana
62100 PUTRAJAYA
MALAYSIA

**Subject** : The request for legal assistance in criminal matters in the case of related to the human trafficking and detention and unlawful confinement committed in the Kingdom of Cambodia.

**Reference**: - The Law on Mutual Legal Assistance in Criminal Matters of the Kingdom of Cambodia

Your Excellency,

With reference to the above subject, the Ministry of Justice of the Kingdom of Cambodia presents its compliments to the Attorney General of Malaysia and has the honor to inform that the Ministry of Justice of the Kingdom of Cambodia would like to request the Attorney General of Malaysia to assist in executing the request for mutual legal assistance in a case of related to the human trafficking and detention and unlawful confinement committed in the Kingdom of Cambodia.

The detailed contents of the request are specified in the attachment herewith. The Ministry of Justice of the Kingdom of Cambodia highly appreciates the assistance of the Attorney General of Malaysia in executing the aforesaid request as soon as possible.

The Ministry of Justice of the Kingdom of Cambodia avails itself of this opportunity to renew to the Attorney General of Malaysia the assurances of its high consideration.

Yours Sincerely,

CONTACT:
Central Authority of the Kingdom of Cambodia
Email: ca_cambodia@moj.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

## សំណើសុំជំនួយផ្នែកច្បាប់ទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ

ផ្អែកតាមច្បាប់ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ពីអាជ្ញាធរកណ្តាលនៃប្រទេសម៉ាឡេស៊ីលើករណីដែលបានបញ្ជាក់ក្នុងសំណើនេះ។

### ១.ព័ត៌មានរបស់អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ

- សំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២២ របស់អយ្យការអមសាលាដំបូងខេត្តព្រះសីហនុ។
- ស្នើសុំដោយសាលាដំបូងខេត្តព្រះសីហនុ។

### ២.ព័ត៌មានរបស់បុគ្គលពាក់ព័ន្ធនឹងសំណើ

ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ៣២ឆ្នាំ កើតឆ្នាំ១៩៩០ ជនជាតិម៉ាឡេស៊ី មុខរបរបុគ្គលិកអនឡាញ ទីកន្លែងកំណើតនៅប្រទេសម៉ាឡេស៊ី អាសយដ្ឋានមិនពិតប្រាកដ ប្រពន្ធឈ្មោះ គ្មានកូន ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (មិនស្គាល់)។

### ៣.អង្គហេតុ

កាលពីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ៩ និង ៣០នាទី ថៅកែរបស់ឈ្មោះ (ថៅកែនៃក្រុមហ៊ុនមួយក្នុងអគារ ) បានឱ្យឈ្មោះ និងបុរសជនជាតិចិនម្នាក់ទៀតឈ្មោះ បានជិះឡាន Vellfire ពណ៌ស ពាក់ស្លាកលេខ ធ្វើដំណើរពីរាជធានីភ្នំពេញទៅកាន់ទីតាំងអគារអនឡាញមួយមិនស្គាល់ឈ្មោះ ស្ថិតនៅក្រុងបាវិត ខេត្តស្វាយរៀង ដើម្បីយកមនុស្សចំនួន ២នាក់ មកកាន់ខេត្តព្រះសីហនុវិញ។ ពេលទៅដល់អគារនោះ ឈ្មោះ ទៅដល់គោះទ្វារបន្ទប់មួយមិនចាំលេខ និងបើកទ្វារឃើញមានមនុស្សចំនួន ៣នាក់ ដែលមានជនជាតិវៀតណាម ២នាក់ (ជាជនរងគ្រោះ) និងជនជាតិចិនម្នាក់ (ឈ្មោះ ហៅ )។

បន្ទាប់មកឈ្មោះ និងឈ្មោះ បានជិះរថយន្តនោះដឹកជនជាតិវៀតណាម និងជនជាតិចិនឈ្មោះ មកកាន់ខេត្តព្រះសីហនុ។ លុះពេលមកដល់ចំណុចភូមិអូរតាប៉ាំ ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនុប ខេត្តព្រះសីហនុ ស្រាប់តែរថយន្តនោះមានគ្រោះថ្នាក់ចរាចរណ៍ ដោយអ្នកបើកបរបានបើកបុកដើមត្នោតមួយ រួចរថយន្តក៏ធ្លាក់ចូលប្រឡាយទឹក។ ក្នុងគ្រោះថ្នាក់នោះ ឈ្មោះ និងឈ្មោះ ជនជាតិវៀតណាម ក៏បានស្រែកឱ្យគេជួយ។

ក្រោយពីមានហេតុការណ៍នេះ សមត្ថកិច្ចក៏ចុះទៅដល់កន្លែងកើតហេតុ និងធ្វើការសួរនាំជនជាតិវៀតណាមទាំងពីរនាក់នោះ។ ជនជាតិវៀតណាមទាំងពីរនោះបានឆ្លើយប្រាប់សមត្ថកិច្ចថា ពួកគាត់បានចូល

មកប្រទេសកម្ពុជា ធ្វើការនៅក្រុមហ៊ុនអនឡាញ ចាប់ពីខែកុម្ភៈ ឆ្នាំ២០២២ ហើយត្រូវបានក្រុមហ៊ុនមួយលក់ទៅឱ្យក្រុមហ៊ុនមួយទៀតជាបន្តបន្ទាប់។ អំឡុងពេលធ្វើការនៅកន្លែងអនឡាញ ពួកគេក៏ត្រូវបានរងការធ្វើទារុណកម្ម ដោយមានការដាក់ឃុំក្នុងបន្ទប់, បង្អត់អាហារ, វាយធ្វើបាប និងឆក់ខ្សែភ្លើងជាដើម។

បន្ទាប់មកទៀត សមត្ថកិច្ចបានឃាត់ខ្លួនឈ្មោះ និងឈ្មោះ រួមទាំងឈ្មោះ ផងដែរ។

អំពើខាងលើគឺជាបទល្មើស៖ **អំពើលក់ដូរមនុស្ស, បទចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់មានស្ថានទម្ងន់ទោស, ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស** ប្រព្រឹត្តនៅក្រុងបាវិត ខេត្តស្វាយរៀង និងខេត្តព្រះសីហនុ កាលពីខែកុម្ភៈ ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ១៣, មាត្រា ១៤ និងមាត្រា ២០ នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រា ២៥៤ នៃក្រមព្រហ្មទណ្ឌ។

## ៤.ដំណើរការនៃសំណុំរឿង

### ៤.១.ការស្រាវជ្រាវរបស់សមត្ថកិច្ច

នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ៨ និង ៣០នាទី ក្រោយពីទទួលបានព័ត៌មានពីរឿងគ្រោះថ្នាក់ចរាចរណ៍ កម្លាំងជំនាញអធិការដ្ឋាននគរបាលស្រុកព្រៃនប់ និងបានសហការជាមួយប៉ុស្តិ៍នគរបាលឃុំអូរឧកញ៉ាហេង ធ្វើការចុះពិនិត្យទីកន្លែងកើតហេតុ និងរកឃើញរថយន្ត១គ្រឿងម៉ាក VELLFIRE ពណ៌សពាក់ផ្លាកលេខ ដែលអ្នកបើកបរបានបើកបុកដើមត្នោត រួមធ្លាក់ចូលប្រឡាយនៅក្បែរចិញ្ចើមផ្លូវជាតិលេខ៤ ស្ថិតក្នុងភូមិអូរតាប៉ាង ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។ សមត្ថកិច្ចបានជួយសហការនាំអ្នកដែលជិះក្នុងរថយន្តនោះទៅព្យាបាលនៅមន្ទីរពេទ្យ។

លុះដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២ វេលាម៉ោង ១៦ និង ៣០នាទី កម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួលសំណុំរឿង ១ករណី ពីការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ ដែលពាក់ព័ន្ធនឹងជនជាតិចិន ៣នាក់ និងជនរងគ្រោះជនជាតិវៀតណាម ២នាក់ ក្នុងគ្រោះថ្នាក់ចរាចរណ៍នោះ។ ក្រោយពីបានទទួលសំណុំរឿង កម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានធ្វើការសាកសួរបុរសពីរនាក់ជាជនជាតិវៀតណាម និងបានឃាត់ខ្លួនឈ្មោះ
ឈ្មោះ និងឈ្មោះ ព្រមបានដកហូតវត្ថុតាងមួយចំនួន។

វត្ថុតាងដែលសមត្ថកិច្ចបានដកហូតនោះ មានដូចខាងក្រោម៖

១). រថយន្ត ១គ្រឿង ម៉ាក VELLFIRE ពណ៌ស ពាក់ស្លាកលេខ (រថយន្តនេះគឺកំពុងរក្សាទុកនៅប៉ុស្តិ៍នគរបាលឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

២). វ៉ាលីធំពណ៌ប្រផេះ ១ (ក្នុងវ៉ាលីមានសំលៀកបំពាក់មួយចំនួន)

៣). កូនកាបូបពណ៌ខ្មៅ ចំនួន ១

៤). ទូរស័ព្ទដៃចំនួន ៤គ្រឿង (ម៉ាក OPPO ពណ៌លឿង ១គ្រឿង, ម៉ាក OPPO ពណ៌សលាយទឹកសណ្ដែក ១គ្រឿង, ម៉ាក OPPO ពណ៌ទឹកប៊ិច ១គ្រឿង និងម៉ាក IPHONE X ពណ៌ខ្មៅ ១គ្រឿង។

៥). ដុំសាកភ្លើង (POWER BANK)ចំនួន ១

៦). កូនកាំបិតតូច ចំនួន ១

៧). សោរឡាន ចំនួន ១

ជាចុងក្រោយ សមត្ថកិច្ចបានកសាងសំណុំរឿង និងបញ្ជូនបុគ្គលទាំងបីនាក់ខាងលើ រួមទាំងវត្ថុតាងមកអយ្យការអមសាលាដំបូងខេត្តព្រះសីហនុដើម្បីចាត់ការតាមនីតិវិធី។

### ៤.២.ការស្រាវជ្រាវរបស់តំណាងអយ្យការ

បន្ទាប់ពីទទួលបានសំណុំរឿងពីសមត្ថកិច្ច តំណាងអយ្យការអមសាលាដំបូងខេត្តព្រះសីហនុបានធ្វើការពិនិត្យអង្គហេតុដែលកើតឡើង និងកស្តុតាង ហើយបានសម្រេចបើកការស៊ើបសួរលើជនត្រូវចោទចំនួន ៣នាក់ខាងលើ អំពីបទល្មើសដូចបានសរសេរបង្ហាញនៅក្នុងចំណុច "**ជនត្រូវចោទ និងបទល្មើសនៃការចោទប្រកាន់**" ខាងលើ ឬដូចមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ ដែលនឹងត្រូវបានផ្ញើជូនភ្ជាប់ជាមួយនឹងលិខិតនេះ។

### ៤.៣.ការស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

បន្ទាប់ពីទទួលបានសំណុំរឿងពីអយ្យការអមសាលាដំបូងខេត្តព្រះសីហនុ ចៅក្រមស៊ើបសួរបានសម្រេចឃុំខ្លួនជនត្រូវចោទ ឈ្មោះ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិម៉ាឡេស៊ី ឈ្មោះ ភេទប្រុស អាយុ៣៧ឆ្នាំ ជនជាតិចិន និងឈ្មោះ ភេទប្រុស អាយុ២៦ឆ្នាំ ជនជាតិចិន ជាបណ្ដោះអាសន្ន នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២២ ហើយក៏បានបន្តបំពេញកិច្ចស្រាវជ្រាវបន្ថែមជាច្រើនទៀតពាក់ព័ន្ធទៅនឹងបទល្មើស និងជនត្រូវចោទផ្សេងទៀតដែរ។

## ៥. បទប្បញ្ញត្តិនៃច្បាប់

ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨

-មាត្រា ១៣ និយមន័យនៃអំពើលក់-ដូរមនុស្ស

អំពើលក់ដូរ-មនុស្សមានន័យថា ប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬទទួលយកដោយខុសច្បាប់នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយផ្លោះប្ដូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង។

អំពើធ្វើជាភ្នាក់ងារកណ្ដាលនៃការលក់-ដូរមនុស្ស ត្រូវផ្ដន្ទាទោសដូចគ្នានឹងអំពើលក់-ដូរមនុស្សដោយផ្ទាល់។

-មាត្រា ១៤ អំពើលក់-ដូរមនុស្ស

ជនណាដែលលក់-ដូរជនដទៃ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ដល់ ៥ (ប្រាំ) ឆ្នាំ។

-មាត្រា ២០ ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស

ជនណាដែលទទួល ផ្ដល់ជម្រក ឬលាក់បំពួន ជនរងគ្រោះក្នុងអំពើនាំយកចេញដោយមិនស្របច្បាប់ ជ្រើសរើស លក់-ដូរ ឬដឹកជញ្ជូន ក្នុងគោលដៅដើម្បីជួយដល់ជនល្មើសដែលបាននាំចេញដោយមិនស្របច្បាប់

ជ្រើសរើស លក់-ដូរ ឬដឹកជញ្ជូន ជនរងគ្រោះនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ដល់ ១០.០០០.០០០ (ដប់លាន) រៀល។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ក្នុងករណីជនរងគ្រោះជាអនីតិជន។

**ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩**

**-មាត្រា ២៥៤ បទចាប់ឃុំឃាំង និងបង្ខាំងដោយខុសច្បាប់ មានស្ថានទម្ងន់ទោស**

បុគ្គលដែលចាប់ ដែលឃុំឃាំង ឬដែលបង្ខាំងបុគ្គលផ្សេងទៀត ដោយគ្មានបញ្ជាពីអាជ្ញាធរស្របច្បាប់ ឬក្រៅពីករណីដែលច្បាប់អនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ក្នុងករណីដូចខាងក្រោម ៖

១- ដោយមានទារុណកម្ម ឬ អំពើឃោរឃៅ។

២- បណ្តាលឱ្យមានមនុស្សស្លាប់ដោយគ្មានបំណងនឹងធ្វើឱ្យស្លាប់។

៣- ប្រព្រឹត្តក្នុងគោលដៅជំរិតយកទ្រព្យសម្បត្តិ ឬទាមទារឱ្យបំពេញលក្ខខណ្ឌអ្វីមួយ។

## ៦. សំណើសុំជំនួយ

អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាស្នើសុំជំនួយផ្នែកច្បាប់ ពីអាជ្ញាធរកណ្តាលនៃប្រទេសម៉ាឡេស៊ីឱ្យជួយបញ្ជាក់ និងផ្តល់ព័ត៌មានពាក់ព័ន្ធនឹងជនត្រូវចោទឈ្មោះ ដូចខាងក្រោម៖

១. តើឈ្មោះ គឺជាជនជាតិម៉ាឡេស៊ីមែន ឬទេ?

២. តើអាសយដ្ឋានក្នុងប្រទេសម៉ាឡេស៊ីរបស់ឈ្មោះ នៅកន្លែងណាដែរ?

៣. តើឈ្មោះ កើតនៅឆ្នាំ១៩៩០ មែន ឬទេ?

៤. តើឈ្មោះ មានមុខរបរ ឬការងារអ្វីនៅប្រទេសម៉ាឡេស៊ី?

៥. តើឈ្មោះ ធ្លាប់ត្រូវតុលាការប្រទេសម៉ាឡេស៊ីផ្តន្ទាទោសដែរ ឬទេ?

## ៧. កាលបរិច្ឆេទកំណត់នៃការផ្តល់ជំនួយ

ដោយសារតែជនត្រូវចោទឈ្មោះ ត្រូវបានឃុំខ្លួនជាបណ្តោះអាសន្ន ហើយថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នលើជនត្រូវចោទនេះមានរយៈពេល ៤ (បួន) ខែ ជាហេតុនាំឱ្យមានការឃុំខ្លួនបណ្តោះអាសន្ននឹងត្រូវបានបញ្ចប់ នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២ ហេតុនេះចៅក្រមស៊ើបសួរសូមស្នើឱ្យកិច្ចសហប្រតិបត្តិការណ៍នេះធ្វើឡើងជាកិច្ចការប្រញាប់ក្នុងអំឡុងពេលនេះផងដែរ។

## ៨. ការរក្សាការសម្ងាត់

អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឱ្យអាជ្ញាធរកណ្តាលនៃប្រទេសម៉ាឡេស៊ី ជួយរក្សាការសម្ងាត់នៃសំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌនេះ រួមទាំងឯកសារទាំងឡាយដែលបានភ្ជាប់ជូននៅក្នុងសំណើនេះ។

## ៩. ការអះអាង

អាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជាអះអាងថា ជំនួយផ្នែកច្បាប់ដែលបានផ្តល់ឱ្យដោយប្រទេសម៉ាឡេស៊ី ចំពោះសំណើនេះនឹងត្រូវបានរក្សាការសម្ងាត់ និងត្រូវប្រើប្រាស់សម្រាប់តែគោលបំណងដែលមានចែងក្នុងសំណើនេះតែប៉ុណ្ណោះ។ អាជ្ញាធរកម្ពុជានឹងផ្តល់ជំនួយផ្នែកច្បាប់ប្រទេសម៉ាឡេស៊ី នៅពេលមានការស្នើសុំ។

ឧបសម្ព័ន្ធទី៥ ៖ សំណើសុំជំនួយផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌពីប្រទេសកម្ពុជាទៅប្រទេសម៉ាឡេស៊ី

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF JUSTICE

# REQUEST FOR LEGAL ASSISTANCE IN CRIMINAL MATTERS

Pursuant to the Law on Mutual Legal Assistance in Criminal Matters of the Kingdom of Cambodia, the Central Authority of the Kingdom of Cambodia hereby requests legal assistance from the Central Authority of Malaysia on the case referred to in this request.

## 1. INFORMATION OF RELEVANT COMPETENT AUTHORITIES

- **File/Case:** Criminal dated August 27, 2022 by the Prosecution attached to the Preah Sihanouk Provincial Court of First Instance.
- **Requesting authority:** Preah Sihanouk Provincial Court of First Instance.

## 2. INFORMATION OF RELAVANT PERSONS SUBJECT TO THE REQUEST

Defendant , male, 32-years-old, born in 1990, Malaysian national; Occupations: online staff; Place of Birth: Malaysia; Address (unknown), wife's name , no child, father's name (alive) and mother's name (unknown).

## 3. FACTS

On August 23, 2022, at 9:30am, 's boss (the owner of a company in building) ordered and another Chinese man name drove a white Vellfire's car with license plate , travels from Phnom Penh to an anonymous online building in Bavet City, Svay Rieng province, to bring two people back to Preah Sihanouk province. Upon arrival at the building, knocked on the door of a room with unremembered number and opened the door to find three people, two Vietnamese (victims) and a Chinese called .

Later, and drove the car carrying Vietnamese and Chinese to Preah Sihanouk province. When they arrived at O'Tapa village, O'Oknha Heng commune, Prey Nob district, Preah Sihanouk province, the car had a traffic accident. The driver hit a palm tree and the car fell into a canal. In the accident, and a Vietnamese national, shouted for help.

After the incident, the police arrived at the scene and interrogated the two Vietnamese nationals. The two Vietnamese told authorities that they had been in Cambodia working for an online company since February 2022 and had been sold by one company to another. While working online, they were also subjected to incarceration, starvation, beatings and electric shocks. Authorities later arrested and , as well as

The above acts are crimes: **human trafficking; Arrest, Detention and Unlawful Confinement with Aggravating circumstances; Receipt of a Person for Purpose of Assisting the Offender**, committed in Bavet, Svay Rieng and Preah Sihanouk provinces in February 2022 to 23 August 2022. Criminal offenses are punishable under the provisions of **Article 13, Article 14 and Article 20 of the Law on Suppression of Human Trafficking and Sexual Exploitation and Article 254 of the Criminal Code of the Kingdom of Cambodia.**

**4. PROCEEDING OF THE CASE**

**(1). Investigation of Competent Authority**

On August 24, 2022, at 8:30am, after receiving information about the traffic accident, the Prey Nup District Police Inspectorate and in cooperation with O'Oknha Heng Commune Police Station inspected the scene and found a white VELLFIRE's car with license plate , which the driver hit a palm tree and fell into a canal near the side of National Road 4 in O'Tapang village, O'Oknha Heng commune, Prey Nob district, Preah Sihanouk province. Authorities have helped the passengers in the car to the hospital.

On August 25, 2022, at 16:30pm, the Anti-Human Trafficking and Juvenile Protection Bureau received a case from the Bureau of Serious Crimes involving three Chinese nationals and two Vietnamese victims in that traffic accident. After receiving the case, the Anti-Human Trafficking and Juvenile Protection Bureau interrogated two Vietnamese men and arrested and and confiscated some exhibits.

The exhibits confiscated by the authorities are as follows:

1). A white VELLFIRE car with license plate (this car is being kept at the police station of O'Oknha Heng commune, Prey Nob district, Preah Sihanouk province).

2). 1 large gray suitcase (there are some clothes in the suitcase)

3). 1 black bag

4). 4 mobile phones (1 yellow OPPO, 1 white OPPO, 1 blue OPPO and 1 black IPHONE X).

5). 1 power bank

6). 1 small knife

7). 1 car key

Finally, the police prepared a case file and sent the three individuals, including exhibits, to the Preah Sihanouk Provincial Prosecutor's Office for processing.

(2). Investigation of Prosecutor

After receiving the case file from the competent authorities, the representative of the Prosecutor's Office of Preah Sihanouk Provincial Court examined the facts and evidence and decided to investigate the above three accused about the offenses as stated in "Defendants and the Offenses of the Accused" above or as stated in the Submission of Investigating Order dated 28 August 2022, which will be sent with this letter.

**(3). The investigation of Investigating Judge**

After receiving the case from the Preah Sihanouk Provincial Prosecutor's Office, the investigating judge decided to temporarily detain the accused 32-years-old, Malaysian, 37-years-old, Chinese and , a 26-year-old, Chinese, on August 28, 2022 and has been further investigated in connection with the crime and other defendants.

## 5. APPLICABLE LAW TO THE OFFENSE

### Law on Suppression of Human Trafficking and Sexual Exploitation (2008)

**Article 13. Definition of the Act of Selling, Buying or Exchanging a Person**

The act of selling, buying or exchanging a person shall mean to unlawfully deliver the control over a person to another, or to unlawfully receive the control over a person from another, in exchange for anything of value including any services and human beings.

The act of procuring the act of selling, buying or exchanging a human being as intermediary shall be punished the same as the act of selling, buying or exchanging a human being.

**Article 14. The Act of Selling, Buying or Exchanging a Person**

A person who sells, buys or exchanges another person shall be punished with imprisonment from 2 to 5 years.

**Article 20. Receipt of a Person for the Purpose of Assisting the Offender**

A person who receives, harbors, or conceals a victim who has been unlawfully removed, recruited, sold, bought, exchanged, or transported for the purpose of assisting the offender who has unlawfully removed, recruited, sold, bought, exchanged or transported that victim shall be punished with imprisonment from 2 to 5 years and a fine from 4,000,000 to 10,000,000 riels.

The offence stipulated in this article shall be punished with imprisonment from 5 to 10 years when the victim is a minor.

### Criminal Code of the Kingdom of Cambodia (2009)

**Article 254. Arrest, Detention and unlawful confinement with Aggravating circumstances**

Anyone who, without judicial authorization, or who unlawfully arrests, detains or unlawfully confines another person shall be punishable by imprisonment from 15 to 30 years in the following cases:

1) The arrest, detention or unlawful confinement is accompanied by torture or acts if cruelty;
2) The arrest, detention or unlawful confinement is followed by the unintentional death of the person;
3) If the arrest, detention or unlawful confinement is committed to secure the payment of a ransom or to demand fulfilment of condition.

## 6. ASSISTANCE REQUESTED

The Central Authority of the Kingdom of Cambodia requests legal assistance from the Central Authority of the Malaysia to clarify and provide information related to the accused as follows:

1. Is a Malaysian?
2. Where is 's Malaysia address?
3. Was born in 1990?
4. What kind of business or job does have in Malaysia?
5. Has ever been convicted by a Malaysian court?

**7. DEADLINE OF THE LEGAL ASSISTANCE**

Due to the fact that the accused has been remanded in custody and the duration of the pre-trial detention of the accused is 4 months, hence the provisional detention maybe completed on December 28, 2022, therefore, the investigation judge would like to request that this cooperation be made urgent as well during this period.

**8. CONFIDENTIALITY**

The Central Authority of the Kingdom of Cambodia urges the Central Authority of Malaysia to keep this request for legal assistance including any documents attached herewith confidential.

**9. ASSURANCE**

The Central Authority of the Kingdom of Cambodia assures that the legal assistance provided by Malaysia to this request will be kept confidential and will be used only for the purposes set forth in this request. The Central Authority of the Kingdom of Cambodia will provide legal assistance to Malaysia when requested.

**ឧបសម្ព័ន្ធទី៦**

**គំរូលិខិតស្នើសុំ MLA របស់ព្រះរាជាណាចក្រកម្ពុជា**